# ដើមកំណើតអក្សរ

ប្រជុំពិធីបណ្ណាល័យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

៥២០.
១

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥០០០ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្មៅ យុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥០០០ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh** **www.elibraryofcambodia.org**

www.budinst.gov.kh www.elibraryofcambodia.org

# ដើមកំណើតអង្គរ



www.budinst.gov.kh www.elibraryofcambodia.org



www.budinst.gov.kh www.elibraryofcambodia.org

៩២០.១

# កំណើតប្រាសាទអង្គរ

រៀបរៀងដោយ

**ម៉ាវ - មូ**

ធ្វើការនៅក្រសួងអភិរក្សអង្គរសៀមរាប

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
១៩១១/៨៦
16-1

ការផ្សាយរបស់

ព.ស. ២៥១៣ គ.ស. ១៩៦៩

រក្សាសិទ្ធិ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# បញ្ជីរាយឈ្មោះប្រាសាទ


| លេខរៀង | រាយឈ្មោះប្រាសាទ | ទំព័រ |
|---|---|---|
| ១– | ប្រាសាទអង្គរវត្ត | ១ |
| ២– | ប្រាសាទតាព្រហ្មកិល | ៦២ |
| ៣– | ប្រាសាទបក្សីចាំក្រុង | ៦៤ |
| ៤– | ប្រាសាទភ្នំបាខែង | ៦៩ |
| ៥– | អង្គរធំ, បាយ័ន | ៨៣ |
| ៦– | បាពួន | ១៤៦ |
| ៧– | បរិវេណវាំងស្ដេច (វិមានអាកាស) | ១៦៥ |
| ៨– | ព្រះទេពប្រណម្យ | ១៨៤ |
| ៩– | ព្រះបាលិល័យ | ១៨៧ |
| ១០– | ប្រាសាទព្រះពិថ្នូ | ១៨៧ |
| ១១– | ព្រះរាជលានអង្គរធំ | ១៩០ |


www.budinst.gov.kh www.elibraryofcambodia.org

# វង់តូច


| លេខរៀង | តាមឈ្មោះប្រាសាទ | ទំព័រ |
|---|---|---|
| ១២– | ប្រាសាទធម្មនន្ទ | ១៩៣ |
| ១៣– | ប្រាសាទចៅសាយទេវតា | ១៩៦ |
| ១៤– | ប្រាសាទតាកែវ | [illegible] |
| ១៥– | ប្រាសាទតាព្រហ្ម | ២០៣ |
| ១៦– | ប្រាសាទបន្ទាយក្ដី | ២១២ |
| ១៧– | ស្រះស្រង់ | ២១៦ |
| ១៨– | ប្រាសាទក្រវាន់ | ២១៨ |
| ១៩ | ប្រាសាទប្រែរូប | ២១៩ |
| ២០– | ប្រាសាទមេបុណ្យទិសបូព៌ | ២២៦ |
| ២១– | ប្រាសាទនាគព័ន្ធ | ២៣១ |
| ២២– | ប្រាសាទព្រះខ័ន | ២៣៥ |


www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទក្រៅបរិវេណប័ក្សអង្គរ


| លេខរៀង | ភាយឈ្មោះប្រាសាទ | ទំព័រ |
|---|---|---|
| ២៣– | ប្រាសាទលលៃ | ២៤២ |
| ២៤– | ប្រាសាទព្រះគោ | ២៤៧ |
| ២៥– | ប្រាសាទបាគង | ២៥០ |
| ២៦– | ប្រាសាទបន្ទាយសំរែ | ២៥៤ |
| ២៧– | ប្រាសាទបន្ទាយស្រី | ២៥៨ |


www.budinst.gov.kh www.elibraryofcambodia.org

# ផែនទីអង្គរ

( វង់ធំ និង វង់តូច )



www.budinst.gov.kh www.elibraryofcambodia.org

# បុព្វកថា

ហេតុដែលនាំឲ្យកើតជាសៀវភៅនេះឡើង គឺដោយខ្ញុំធ្លាប់បានស្តាប់ជាញឹកញាប់ នូវការកោតសរសើរពីអ្នកទេសចរណ៍បរទេសជាច្រើន ដែលគេមកទស្សនាប្រទេសយើង គេតែងនិយាយថា ប្រទេសកម្ពុជា ជាប្រទេសរុងរឿងបំផុត សម្បូណ៌ដោយអារ្យធម៌ វប្បធម៌ សិល្បៈយ៉ាងល្អឯក តាំងពីអតីត-កាល នៅក្នុងចំណោមប្រទេសទាំងឡាយ ដែលស្ថិតនៅទិសនិរតីនៃទ្វីបអាស៊ី ។ បើយើងមិនបានត្រិះរិះឲ្យបានហ្មត់ចត់ទេ យើងមុខជាយល់ច្រឡំថា ប្រាសាទទាំងឡាយ ជាស្នាដៃនៃទេពនិម្មិតថ្វាយចំពោះព្រះរាជាខេមរជាតិយ៉ាងពិតប្រាកដ ដូចមានពាក្យខ្មែរភាគខ្លះថា ប្រាសាទអង្គរព្រះឥន្ទ្រប្រើ ពិស្ណុការមកសាងថ្វាយព្រះកេតុមាលា ។

បើតាមពិត ប្រាសាទទាំងឡាយដែលស្ថិតនៅក្នុងអតីតរាជធានីអង្គរ ជាប្រាសាទសាងដោយស្នាដៃមនុស្សពិតៗ ដែលមានព្រះរាជាជាប្រមុខនៃអារ្យធម៌ វប្បធម៌ និងសិល្បៈយ៉ាងស្កាត់ជំនាញ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ យុវជនទាំងឡាយ អ្នកត្រូវតែទៅទស្សនា ប្រាសាទទាំងនោះកុំឲ្យខាន ពេលអ្នកទៅទស្សនានោះមិនខាត ប្រយោជន៍ឡើយ ៖

១ — អ្នកនឹងបានឃើញប្រាសាទប្រកបដោយក្បាច់ចនា យ៉ាងប្លែក ៗ ពីដីរហូតដល់កំពូល ។

២ — អ្នកនឹងបានដឹងនូវរឿងប្លែកខ្លះក្នុងប្រាសាទ ។

៣ — អ្នកនឹងបានចេះនូវប្រវត្តិសាស្ត្រ ក្នុងជំនាន់នោះ ។

៤ — អ្នកនឹងមានចិត្តកោតសរសើរ ចំពោះបុព្វបុរសរបស់ យើង ដែលចេះដឹកជញ្ជូនថ្មសិលាធំ ៗ មកដាប់ ថ្នាក់ដាក់បន្តុបលើគ្នា កសាងប្រាង្គប្រាសាទទុកជា កេរ្តិ៍ដំណែលឲ្យកូនចៅជាន់ក្រោយ ។ 4

៥ — អ្នកនឹងបានឃើញនូវរបៀប នៃសាសនាក្នុងជំនាន់ នោះ ។

៦ — អ្នកនឹងបានគោរពចំពោះវិញ្ញាណក្ខន្ធបុព្វបុរសយើង ដែលទុកជាបូជនីយស្ថានដ៏ប្រសើរ ។

www.budinst.gov.kh www.elibraryofcambodia.org

៧ – អ្នកនឹងបានគោរពបូជាចំពោះព្រះបដិមាករ "ព្រះ-ពុទ្ធរូប" ។

ហេតុដូច្នេះហើយ បានជាខ្ញុំប្រមូលឯកសារផ្សេង ៗ មករៀបរៀងជាសៀវភៅនេះឡើង ឲ្យឈ្មោះថា "កំណើតប្រាសាទអង្គរ" ដើម្បីទុកជាសតិបញ្ញាស្មារតី ដល់យុវជនគ្រប់រូបដែលប្រាថ្នាទៅទស្សនាបុរាណវត្ថុរបស់យើង គ្រាន់បានជាមិត្តជាប់នៅដៃជួយព្រោលបំភ្លឺផ្លូវ ។

ទីបំផុត សូមអ្នកចាំឲ្យជាក់ថា ប្រាសាទនិមួយ ៗ សុទ្ធតែមានក្បាច់របនាល្អថ្លៃ ៗ ថ្មនេះចាក់ក្បាច់កំ នេះនិយាយស្ដី នេះសើចញញឹមពព្រាយ នេះប្រៀនបំពេញអារម្មណ៍អស់លោកអ្នក ដែលបានអញ្ជើញទៅទស្សនាបុរាណប្រាសាទរបស់យើង ៗ អ្នកដែលបានទៅទស្សនាបុរាណប្រាសាទ ទុកជាមានកិត្តិសនាយ៉ាងប្រសើរខ្ពង់ខ្ពស់ អ្នកដែលមិនបានទស្សនាបុរាណប្រាសាទ ទុកដូចជាមនុស្សគ្មានកិត្តិសនាសោះឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ការទស្សនាបុរាណប្រាសាទនោះទៀតសោត សូមកុំតែមើលទទេ ៗ ត្រូវមើលពិនិត្យពិច័យឲ្យបានហ្មត់ចត់ថា បុរាណប្រាសាទដ៏ធំសម្បើមអស្ចារ្យនេះ ពិតជាស្នាដៃនៃបុព្វបុរសរបស់យើងជាអ្នកកសាងដោយពិតប្រាកដ ព្រោះគេឃើញមានស្នាមពន្លាកដែកជាប់ជាប់នៅរហូតសព្វថ្ងៃនេះ មិនមែនព្រះឥន្ទ្រទេវតា ព្រះពិស្ណុការកូនជំនាន់នោះ ប៉ុនគ្នានឹងពាក្យថា វិស្វករកូនជំនាន់សព្វថ្ងៃនេះដែរ គេគ្រាន់តែលើកតំកើងវិស្វករដែលមានស្នាដៃយ៉ាងចំណាន ៗ ក្នុងកាលនោះ ឲ្យមានឋានៈជាព្រះពិស្ណុការ ថាជាអ្នកបេះរចនាកសាងប្រាសាទយ៉ាងល្អចិញ្ចាច ហាក់ដូចជាទើបផុះលេចឡើងពីគតដែនដីមក នៅក្នុងអាស៊ីភាគអាគ្នេយ៍នេះ ។

ម៉ារ - ប៊ូ

# ប្រាសាទអង្គរវត្ត

ប្រាសាទអង្គរវត្តជាបុរីឬជាទីក្រុង ហើយថែមទាំងជាវិហារឬក៏ជាចេតិយទៀតផង ។ ប្រាសាទនេះ សាងឡើងនៅពាក់កណ្តាលសតវត្សទី ១១ ដោយស្តេចព្រះហស្តព្រះបាទ " សុរិយាវរ្ម័នទី ២ " ដែលទ្រង់មានព្រះបរមនាមក្រោយទិវង្គតថា " ព្រះបរមវិស្ណុលោក " ។ សាសនានៅសម័យនោះ គឺព្រហ្មញ្ញសាសនា មានការគោរពបូជាព្រះនារាយណ៍ជាដើម ។ ក្រោយមកក្នុងគ្រិស្តសករាជ ១៩០៨ ក្រសួងអភិរក្សអង្គរ បានកាប់ឆ្ការព្រៃសំអាតក្នុងប្រាសាទ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទអង្គរវត្តមានសណ្ឋានទ្រង់ទ្រាយរាង ៤ ជ្រុងទ្រវែង ដែលមានបណ្តោយប្រវែងប្រមាណ ១៥០០ ម៉ែត្រ ទទឹងប្រមាណ ១៣០០ ម៉ែត្រ ។ ផ្ទៃដីទាំងមូលនៃប្រាសាទ រួមបញ្ចូលសារុបទាំងស្រះពោក្ខរណី ទទឹង៨០០ម៉ែត្រផង មានទំហំផ្ទៃទាំងអស់២០០ហិកតារ ។ ខាងក្នុងស្រះ ដីដែលមានជញ្ជាំងជាកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញនោះ

www.budinst.gov.kh www.elibraryofcambodia.org

មានបណ្ដោយប្រវែង ១០២៥ ម៉ែត្រ ទទឹង ៨០០ ម៉ែត្រ ។ បើគិតជាទំហំផ្ទៃដីវិញមាន ៨២ ហិកតារ ។ ដូច្នេះប្រាសាទនេះមានទំហំធំជាងគេបង្អស់ ក្នុងចំណោមប្រាសាទនានានៅក្រុងអង្គរធំ ។

ប្រាសាទអង្គរវត្តតាំងនៅខាងត្បូងកំផែងទីអង្គរធំ ហើយស្ថិតនៅក្នុងលង្វែកប៉ែកខាងត្បូង ឆៀងខាងកើតនៃអតីតបុរីអង្គរ „យសោធរបុរៈ„ ។ ក្រុងយសោធរបុរៈនេះសាងឡើងដោយស្នាព្រះហស្តព្រះបាទ " យសោវរ្ម្ម ទី ១ " ហើយមជ្ឈមណ្ឌលសម័យនោះតាំងនៅលើភ្នំបាខែង ។ ព្រំប្រទល់នៃបុរីអង្គរក្នុងគ្រានោះ ខាងកើតទល់នឹងស្ទឹងសៀមរាប ខាងលិចទល់នឹងទំនប់ខ្នងបារាយណ៍ ។ អាស្រ័យហេតុដូច្នេះ ព្រះវិហារអង្គរវត្តស្ថិតនៅតាំងសងខាងមាត់ប្រែកផ្លូវធំចូលទៅអង្គរធំ ជាការប្រសើរបំផុត ។ បើគេយកសំគាល់នៃស្ថានលេខាមកពិចារណាដោះស្រាយវិញ បុព្វហេតុដែលនាំឲ្យប្រាសាទនេះបែរក្រោយទៅរកទិសបស្ចិមនោះ គឺមកពីការងាយស្រួលក្នុងការដឹកនាំផ្ទាំងសិលា តាមផ្លូវទឹក ពីភ្នំគូលែន ហើយ

www.budinst.gov.kh www.elibraryofcambodia.org

និងការធ្វើដំណើរបានរហ័សដោយនៅជិតស្ទឹងសៀមរាបផង ។

ដោយការសង្កេតពិនិត្យ អ្នកទស្សនាទាំងឡាយក៏គាប់យល់ច្បាស់ថា ប្រាសាទអង្គរវត្តបានចាប់ផ្ដើមសាងឡើងពីទិសបស្ចិមមកមុនគេបង្អស់ ព្រោះយើងបានឃើញយ៉ាងច្បាស់លាស់ នៅផ្នែកខាងកើតមានភាគច្រើនមិនទាន់ឆ្លាក់រចនារូបនៅឡើយ ។ តាមធម្មតាគេតែងធ្វើអ្វីពីចម្ងាយមកមុន ហើយគ្រាក្រោយបំផុតទើបទីជិតក្រោយគេបង្អស់ ។ ក្បាច់ក្បូរចម្លាក់ភាគច្រើន នៅខាងលិចសិនរូបស្រេចទាំងអស់ តែជាអកុសលឯផ្នែកខាងកើតវិញ ឃើញហាក់ដូចជាមិនទាន់ហើយ ម្យ៉ាងទៀតភាពក្បាច់ហាក់ដូចជាធ្វើឡើងដោយប្រញាប់ប្រញាល់ផង ។ នៅផ្នែកដដែលនេះ បើយើងចូលតាមក្លោងទ្វារខាងកើតមកវិញ យើងនឹងជួបប្រទះនូវគំនរដីខ្ពស់ ៗ មិនទាន់បានស្លាចនាអ្វីពីលើនៅឡើយ ៗ ការមិនហើយស្រេច ការធ្វើដោយបន្ទាន់ និងគំនរដីមិនទាន់បានប្រើការអ្វីសោះនោះ ទាំងនេះជាហេតុបណ្ដាលមកពីសង្គ្រាមដ៏កាចសាហាវយង់ឃ្នង់នៃប្រទេសជិតខាងដែលចូលមកលុកលុយ ។

www.budinst.gov.kh www.elibraryofcambodia.org

...អធិប្បាយដោះស្រាយបែបនេះ ពិតជាមិនអាចទទឹងសន្មតថាគ្រប់គ្រាន់បានការនៅឡើយ ហើយគេមិនអាចលះបង់ឡើយច្បាប់ក្បួនប្រពៃណី ដោយឥតយកមកដោះស្រាយបានដែរ ។ ដូច្នេះតាមប្រពៃណីវិញ មូលហេតុដែលបណ្ដាលឲ្យមានការបំបែរមុខប្រាសាទទៅបស្ចិមទិស ប្លែកខុសពីប្រក្រតីយ៉ាងដូច្នេះនោះ គឺដើម្បីសម្រួបឲ្យស្របតាមទ្រឹស្ដីនៃលទ្ធិព្រហ្មញ្ញសាសនា “ សាសនាព្រាហ្មណ៍ ” តែប៉ុណ្ណោះ ដោយអាស្រ័យទៅលើ ការស្រាវជ្រាវរបស់លោក ហ្វីណូត៍ , លោក សេដែស និង លោក ព្រសស៊ុស្គី ហើយនិងលោកវេជ្ជបណ្ឌិត ប៉ូសហ៍ ដែលជានាយកត្រួតនៃក្រសួងបុរាណវត្ថុនៃប្រទេសឥណ្ឌា លោក ភិក ឡង់ដែស បានពន្យល់ថា ប្រាសាទអង្គរវត្តជាព្រះវិហារឬជាចេតិយសម្រាប់ដំកល់ព្រះអដ្ឋិ សម្រាប់ជានិម្មិតរូបនៃព្រះវិញ្ញាណក្ខន្ធរបស់ព្រះរាជាដែលយាងចូលទិវង្គត ទៅកាន់បរលោកនាយតែប៉ុណ្ណោះ ។ សេចក្ដីបន្ថែមទៀតថា ព្រះវិហារអង្គរវត្តជាគំរូផល់ប្រាសាទទាំងឡាយ ដែលសម្រាប់ដំកល់ព្រះអដ្ឋិនៃព្រះរាជា ។ ព្រះបាទ “ សុរិយាវរ្ម័នទី២ ”



ប្រាសាទអង្គរវត្ត

មើលពីជ្រុងខាងលិចខាងជើង

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់បានសាងប្រាសាទនេះឡើង កាលព្រះអង្គទ្រង់គង់ព្រះជន្មនៅឡើយ ដើម្បីទុកឲ្យគេគោរពបូជាព្រះអង្គដែលជានិមិត្តរូបនៃព្រះអាទិទេព ហើយជាពិសេស ដើម្បីទុកដំកល់ព្រះអដ្ឋិនៃព្រះអង្គផង ។ លោកវេជ្ជបណ្ឌិត បូសហ៍ បានពោលបញ្ជាក់ទៀតថា ប្រាសាទអង្គរវត្តបែរភក្ត្រទៅរកទិសបស្ចិម មិនខុសពីប្រាសាទនានានៅប្រទេសជ្វា ដែលជាប្រាសាទមានមុខបែរផ្សេងគ្នាស្រឡះពីប្រាសាទសម្រាប់ទុកទុំសបូជាថ្វាយព្រះអាទិទេព ។ ម្យ៉ាងទៀត បើតាមបទបញ្ញត្តិគន្ថទ្រឹស្តីព្រហ្មញ្ញសាសនា ក្បួនហែព័ទ្ធជុំវិញបាធាដើម្បីធ្វើឈាបនកិច្ច ត្រូវធ្វើឡើងមិនដូចប្រក្រតីឡើយ ។ ២
ដូច្នេះរូបភាពម្ចាក់តាំងឡាយ ក្នុងកេនថែវនៃប្រាសាទអង្គរវត្តបង្ហាញឲ្យយើងឃើញច្បាស់នូវក្បួនហែតាំងឡាយដែរ ដូចជាក្បួនហែនៃពិធីបុណ្យខ្មោចជាអាទិ៍ ; ក្បួនហែនៃពិធីបុណ្យឈាបនកិច្ចនេះធ្វើឡើងមិនដូចក្បួនច្បាប់ប្រពៃណីបុរាណធម្មតា គឺតាមវិថីគោចរព្រះ-អាទិត្យ ពីខាងស្តាំវត្ថុឡើយ ( ប្រទក្សិណ ) គេប្រតិបត្តិបញ្ច្រាស

www.budinst.gov.kh www.elibraryofcambodia.org

វិធីគោចរព្រះអាទិត្យទៅវិញ ។ ចុងក្រោយបង្អស់លោក សេដែស បានថ្លែងបញ្ជាក់ថា គ្មានព្រះអាទិទេពអង្គណាឡើយ ក្រៅពីព្រះបាទ « សុរិយាវរ័ន្ទ ទី ២ ទេ » ដែលបានសាងប្រាសាទអង្គរវត្តសម្រាប់ជាវិមានស្តេចទេវតា ឬ ទេវរាជ « គឺព្រះបាទ សុរិយាវរ័ន្ទ ទី ២ នេះឯង » ដោយបង្កើតឲ្យមានទូវមូលស្ថាបនាជាព្រះនារាយណ៍ ហើយ តាំងព្រះអង្គឯងជាព្រះឥស្សូរ ដោយពុំបង្កើតឲ្យមានលិង្គដូចបុព្វការីមុនៗទេ ជាពិសេសទ្រង់តាំងព្រះអង្គជាព្រះនារាយណ៍ផង ដែលមានសមាគមសិង្ហាប់ខ្លួនពាក់ចង់ទៅនឹងបស្ចិមប្រទេស « ប្រទេសឥណ្ឌា » យ៉ាងសុខសាទ ។ អាស្រ័យហេតុដូច្នេះបានជាព្រះអង្គបង្កើតឲ្យមានទូវការ
17 បែរមុខប្រាសាទបែបដូច្នេះ ។

នៅចុងសតវត្សទី ១៣ អ្នកដំណើរជាតិចិនម្នាក់ឈ្មោះលោក ជីវ-តាក្វាន់ បានបញ្ជាក់ថា ផ្នូរខ្មោច « លូបាន់ » ដែលស្ថិតនៅខាងត្បូងរាជធានី ហើយមានជីនៃប្រាង្គ ១០ នោះ មានលក្ខណៈដូចគ្នានឹងប្រាសាទអង្គរវត្តដែរ ។ ហេតុដូច្នេះចាប់តាំងពីសម័យនោះមក

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទអង្គរវត្តមានលក្ខណៈកាន់តែច្បាស់ណាស់ ជាទីសម្រាប់ដំកល់ព្រះអដ្ឋិ ។ ម្យ៉ាងទៀតរឿងព្រេងខ្មែរបុរាណមួយនិទានពីព្រះកេតុមាលា ដែលព្រះឥន្ទ្រាធិរាជទ្រង់ត្រាស់បញ្ជា សូមឲ្យយានចុះមកយាងយកកំណើតជាមនុស្សលោក ។ លុះដល់ព្រះរាជកុមារមានវ័យចំរើនឡើង ទើបព្រះឥន្ទ្រាធិរាជត្រាស់ប្រើឲ្យទេពស្ថាបត្យករ "វិស្សុកម្ម ពិស្ណុការ" មកនិម្មិតជាប្រាសាទអង្គរវត្តទុកជាពន្លះស្តូបដែលប្រកបដោយលក្ខណៈ សណ្ឋានទ្រង់ទ្រាយដូចគ្នាសុទ្ធសាធនឹងស្ថានសួគ៌ "តាវតឹង្សទាំង ៣៣ ជាន់" ដើម្បីជាវិមានថ្វាយដល់ព្រះកេតុមាលា ហើយនឹងសម្រាប់ដំកល់ព្រះរូបនៃព្រះអង្គ ដែលគេសន្មត់ជាព្រះពេទ្យទេព ឬទេវរាជ ក្រោយពេលព្រះអង្គចូលទិវង្គត ។ 8

## ពិពណ៌នា

ប្រាសាទអង្គរវត្ត ស្ថិតនៅលើទីតាំងដ៏ប្រសើរជាងពួកប្រាសាទឯទៀត ហើយដាច់ឆ្ងាយពីព្រៃព្រឹក្សលតាវល្លិ ដោយមានស្រះបារាយណ៍ពីក្រៅ ដែលជាហេតុនាំឲ្យប្រាសាទនេះប្រាសផុតពីគ្រោះកាច

www.budinst.gov.kh www.elibraryofcambodia.org

អន្តរាយ ដែលកើតឡើងពីការរុករានទន្ទ្រានដៃរុក្ខជាតិធំនានា ។ ប្រាសាទនេះ ស្ថិតនៅជាបូជនីយដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរគ្រប់កាលវេលា ៖ នៅក្នុងបរិវេណប្រាសាទមានវត្តជាច្រើនដែលស្ថាបនាឡើងតាំងពីយុគនៃព្រះពុទ្ធសាសនា ថែបហីនយានចាប់កើតមានឡើងម្ល៉េះ ។ អាគមតាំងនេះកាលជំនាន់ដើមសង់នៅលើដីលានធំមួយផ្នែកមុខប្រាសាទ ហើយក្រោយមក គេបានរំកិលបន្តិចទៅនៅបំហៀងបន្តិច ដើម្បីកុំឲ្យខូចខូវនេត្រាទស្សនៈរបស់ប្រាសាទ ។

ក្នុងការរៀបចំប្រាសាទនេះ គេបានបំពេញបេសកកម្មក្នុងកិច្ចប្រតិបត្តិការបាចគាស់ផ្កាព្រលគាវល្ងរុញច្រាន ពង្រាបដីតាំងគំនរៗជាច្រើនម៉ែត្រគ្រីគុណ ដើម្បីរកវិធីដោះស្រាយធ្វើយ៉ាងដូចម្តេចឲ្យប្រាសាទបានជាប់មាំទាំជាយូរអង្វែង ហើយនិងការរៀបចំដាក់ឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ នូវទ្រូនថ្នល់ស័ក្យដែលចូលទៅកាន់ប្រាសាទ ។

ប្រាសាទអង្គរវត្តជាវិមានមួយ ដែលអាចយកទៅប្រៀបធៀប

www.budinst.gov.kh www.elibraryofcambodia.org

នឹងអច្ឆរិយវត្ថុដែលមនុស្សប្រឌិតដ៏ធំ ៗ ល្អ ៗ ជាងគេក្នុងសាកលលោក ដោយប្រាសាទនេះមានលក្ខណៈធំទូលាយ នៅគង់វង់ល្អជាងវិមានទាំងឡាយ ជាពិសេស ដោយមានលក្ខណៈនៃថាវរភាពស្ថាបត្យកម្មល្អផើតផ្តាច់គេទាំងអស់ ។ ម្យ៉ាងទៀត ប្រាសាទអង្គរវត្តអាចចាត់ទុកជាសិល្បត្ថាគិវុឌ្ឍិ ដោយសំអាងទៅលើខ្នាតផែនទីសំអិតសំអាងត្រឹមត្រូវសមសួនក្រៃលែង ទៅលើសហមាត្រដែលមានសុខដុមរមនានិងការបរិសុទ្ធនៃរេខាស្ថាបត្យកម្មយ៉ាងកម្រ ដែលខ្មែរយើងពុំសូវបានជួបប្រទះផងឡើយ ។ ភាពពិបាកសាំញ៉ាំស្មុគ្រស្មាញនៃសិល្បៈវិស័យនៃការផ្ចាក់ប្រកបនូវភាពរហ័សយ៉ាងបំណាន ដែលមានវិស័យហាក់ដូចជាមិនបានផ្ចិតផ្ចង់ទេ ទាំងអស់នេះអាចចាត់ទុកជាទីស្ញើចសរសើរក្រៃពេកណាស់ ។

ព្រះវិហារអង្គរវត្ត អាស្រ័យនៅលើអ័ក្សទាំងឡាយដែលកើតមានឡើង អាចទុកជាវិមានមួយប្រកបដោយការពាក់ទងយ៉ាងជិតស្និទ្ធនៅនឹងទស្សនទាន « ឡូកតាំង » ដែលសំអាងទៅលើឯកភាពនិង

www.budinst.gov.kh www.elibraryofcambodia.org

សណ្ដាប់ធ្នាប់បុរាណ ដែលកើតមកពីសមប្បមាណ ។ អាស្រ័យហេតុដូច្នេះ ប្រាសាទអង្គរវត្តសឲ្យឃើញនូវថ្វីដៃនៃពលានុភាពនិងវិចារណញ្ញាណរបស់ខ្មែរយើងសម័យបុរាណ ។

ចាប់តាំងពី គ.ស. ១៨៦៦ មក លោក ជំសុន ជាតិអង់គ្លេស បានសង្កេតឃើញថា ប្រាសាទអង្គរវត្តជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាមជ្ឈមណ្ឌលនៃសកលទ្វីប ។ អ្នកស្រី កូរាល រេមុសា បានបញ្ជាក់ស្របនឹងលោក ជំសុន ថាមណ្ឌលតាំង ៧ នៃប្រាសាទកណ្ដាលមានលក្ខណៈដូចគ្នានឹងមណ្ឌលតាំង ៧ នៃថ្នាំងសិលាខ្ពស់ ១ នៃភ្នំព្រះសុមេរុ ពនហានតាំងបីនៃប្រាសាទដូចគ្នានឹងហានតាំង ៣ ជាន់នៃដី ទឹក ភ្លើង ខ្យល់ ហើយនៅហានតាំង ៣ នេះមានភ្នំព្រះ-សុមេរុ ហើយទីបំផុតស្រះដែលពេញទៅដោយទឹក មានលក្ខណៈដូចគ្នានឹងមហាសមុទ្រ ។

ចំពោះផែនទីអង្គរវត្ត សឹងមានការដោះស្រាយជាមជ្ឈត្តិកភាព បញ្ចូលនូវរូបមន្តនៃសាជីជ្រុងប្រកបទៅដោយថ្នាក់ ហើយទិនព្រះ-

www.budinst.gov.kh www.elibraryofcambodia.org

នឹងអច្ឆរិយវត្ថុដែលមនុស្សប្រឌិតដ៏ធំ ៗ ល្អ ៗ ជាងគេក្នុងសាកលលោក ដោយប្រាសាទនេះមានលក្ខណៈធំទូលាយ នៅគង់វង្សល្អជាងវិមានទាំងឡាយ ជាពិសេស ដោយមានលក្ខណៈនៃថាវរភាពស្ថាបត្យកម្មល្អលើតផ្ដាច់គេទាំងអស់ ៗ ម្យ៉ាងទៀត ប្រាសាទអង្គរវត្តអាចចាត់ទុកជាសិល្បត្តាតិវុឌ្ឍិ ដោយសំអាងទៅលើខ្នាតផែនទីសំអិតសំអាងត្រឹមត្រូវសមស្រួលក្រៃលែង ទៅលើសហមាត្រដែលមានសុខដុមរមនានិងការបរិសុទ្ធនៃរេខាស្ថាបត្យកម្មយ៉ាងកម្រ ដែលខ្មែរយើងពុំសូវបានជួបប្រទះផងឡើយ ៗ ភាពពិបាកសាំញ៉ាំស្មុគស្មាញនៃសិល្បៈវិស័យនៃការឆ្លាក់ប្រកបទូវភាពរហ័សយ៉ាងចំណាន ដែលមានវិស័យហាក់ដូចជាមិនបានផ្ចិតផ្ចង់ទេ ទាំងអស់នេះអាចចាត់ទុកជាទីស្ញើចសរសើរក្រៃពេកណាស់ ៗ

ព្រះវិហារអង្គរវត្ត អាស្រ័យនៅលើអក្សរតាំងឡាយដែលកើតមានឡើង អាចទុកជាវិមានមួយប្រកបដោយការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ[៥៨] ទៅនឹងទស្សនទាន « ឡូតាំង », ដែលសំអាងទៅលើឯកភាពនិង

www.budinst.gov.kh www.elibraryofcambodia.org

សណ្តាប់ធ្នាប់បុរាណ ដែលកើតមកពីសមប្បមាណ ។ អាស្រ័យហេតុដូច្នេះ ប្រាសាទអង្គរវត្តសឲ្យឃើញនូវថ្វីដៃនៃពលានុភាពនិងវិចារណញ្ញាណរបស់ខ្មែរយើងសម័យបុរាណ ។

តាប់តាំងពី គ.ស. ១៨៦៦ មក លោក ធំសុន ជាតិអង់គ្លេស បានសង្កេតឃើញថា ប្រាសាទអង្គរវត្តជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាមជ្ឈមណ្ឌលនៃសកលទ្វីប ។ អ្នកស្រី កូពល រេមុសត៍ បានបញ្ជាក់ស្របនឹងលោក ធំសុន ថាមណ្ឌលតាំង ៧ នៃប្រាសាទកណ្តាលមានលក្ខណៈដូចគ្នានឹងមណ្ឌលតាំង ៧ នៃថ្នាំងសិលាខ្ពស់ ១ នៃភ្នំព្រះសុមេរុ ឯឋានតាំងបីនៃប្រាសាទដូចគ្នានឹងឋានតាំង ៣ ជាន់នៃដី ទឹក ភ្លើង ខ្យល់ . ហើយនៅឋានតាំង ៣ នេះមានភ្នំព្រះសុមេរុ ហើយទីបំផុតស្រះដែលពេញទៅដោយទឹក មានលក្ខណៈដូចគ្នានឹងមហាសមុទ្រ ។

ចំពោះផែនទីអង្គរវត្ត សឹងមានការដោះស្រាយជាមជ្ឈត្តិកភាព បញ្ចូលនូវរូបមន្តនៃសាជីជ្រុងប្រកបទៅដោយថ្នាក់ ហើយនិងព្រះ-

www.budinst.gov.kh www.elibraryofcambodia.org

វិហារនៅទីស្មើគ្នា ដែលផ្សំគ្នាជាអាគារសន្ធឹងបណ្ដោយទៅតាមទ្វារ។ រៀងខាងកើតនិងខាងលិច ។ ជួរខ្លះប្រាសាទអង្គរវត្តជាសាជី ៣ ជាន់ ដែលនៅជាន់និមួយៗ មានកំណត់ព្រំដែនដោយរោងវែងតាំងឡាយ ដែលមានទ្វារធំៗបួន ហើយនិងបណ្ខូលមុខ ។ លានខាងលើ មានភាគ ៤ ជ្រុងស្មើផ្សំបង្កើតជាប្រាសាទបញ្ចសូល៍ "គឺមានបណ្ដាប មួយខ្ពស់នៅកណ្ដាល, ៤ ទៀតនៅខាងមុមទាំង ៤" ។ មានទីរ ទៀត សហាគារ ពីខាងមុខទាំង ៣ នៃលាន មានសណ្ឋានទ្រង់ទ្រាយភាគ ៤ ជ្រុងទ្រវែង បណ្ដោយទៅខាងលិច ។ លានទាំងពីរ ដែលមានសណ្ឋានខ្លះ បើតាមការយល់ គឺដើម្បីទុកសម្រាប់ស្ពានទៅជាន់ទី ២ នូវប្រាសាទបណ្ណាល័យ នៅជាន់ទីមួយមានអគារពីរទៀតករជាប្រាសាទ នៅអមអាគារដែលខ្វែងគ្នាជាកាកបាទ ដោយរោងវែងតាំងឡាយ ។

## ស្រះបោក្ខរណី[៨]

ពីខាងក្រៅបរិវេណនៃកំពែងប្រាសាទអង្គរវត្ត " កំពែង ទី ៤

www.budinst.gov.kh www.elibraryofcambodia.org

ដោយរាប់ពីកណ្ដាលមក ,, មានស្រះបោក្ខរណីព័ទ្ធជុំវិញ ។ ស្រះនេះមានទឿនថ្មជាថ្នាក់ ៗ ដូចកាំជណ្ដើរ ហើយរចនាជាក្បាច់ជើងទៀនព័ទ្ធជុំវិញបរិវេណស្រះទាំងអស់ មានប្រមាន ៥ គីឡូម៉ែត្រ៥០០ ។ ស្រះនេះនៅជាប់គ្នាពីមួយទៅមួយ ដែលកាលសម័យបុរាណគេទុកសម្រាប់ដឹកជញ្ជូនសិលាសម្ភារៈដែលយកមកតាមស្ទឹង ។ ឯខាងលិចវិញ ជាប់គ្នាដោយទ្រូងថ្នល់ក្រាលថ្មដែលមានបណ្ដោយ២០០ម៉ែត្រ ទទឹង ១២ ម៉ែត្រ ទ្រូងថ្នល់ចូលកាន់ប្រាសាទនេះ ត្រូវគុបតែងលំអដោយសសរធំ ៗ ខ្ពស់ស្រឡះ ដែលនៅខាងចុងមានក្បាច់រចនាដ៏ល្អវិចិត្រ ។ ក្នុងពួកសសរទាំងនេះ មានសសរខ្លះមាននៅសល់នៅឡើយ ជាពិសេសសសរបញ្ឈរនៅតាមទឿនទាំងសងខាងជណ្ដើរដែលចុះទៅក្នុងផ្ទៃទឹកស្រះ ។ ភ្ជាប់ច្ដីខាងមុខទ្រូងថ្នល់ធំចូលទៅកាន់ប្រាសាទ , បែកខាងផ្លូវគម្ពា គេឃើញមានលាន ១ រាងជាកាកបាទ ។ នៅអមសងខាងផ្លូវថ្នល់ចូលទាំងពីរមានបង្កាន់ដៃនាគដែលមានជើងទៀនរចនាជាក្បាច់យ៉ាងល្អស្កុសាល ។

www.budinst.gov.kh www.elibraryofcambodia.org

# កំពែងក្រៅ

កំពែងក្រៅប្រាសាទអង្គរវត្ត ធ្វើពីថ្មបាយក្រៀម ហើយឋិតនៅដាច់ឆ្ងាយពីមាត់ស្រះដោយទីធ្លាមួយ ប្រវែងទទឹងប្រមាណជា ៣០ ម៉ែត្រ នៅចំអ័ក្សប្រាសាទ ជាប់នឹងកំពែងនេះ មានរោងថែវទទឹងក្លោងទ្វារមួយប្រវែងប្រមាណជា ២៣៥ ម៉ែត្រ ។ នៅក្នុងរោងថែវទទឹងក្លោងទ្វារនេះ មានៈក្លោងទ្វារមួយយ៉ាងធំហៅ "គោបុរៈ" ប្រកបដោយកំពូលប្រាង្គ ៣ និងទ្វារចូល៣ផង ធ្វើរត្ដធាតុពងជាកាកបាទ, ព្រះពន្លាខាងចុងពីរ សម្រាប់ឡើងជិះលើខ្នងដំរី និងរោងថែវបន្តភ្ជាប់គ្នាជាច្រើន ។

ចំណែកឯផ្លូវខាងចុងរោងថែវទទឹងក្លោងទ្វារវិញនោះ សឹងបិទនៅត្រង់ត្រឡែងកែងល្វែងមុខទឹងហោជាង ។ ប៉ែកដែលបែរផ្ទោះទៅរករោងថែវ ត្រូវបិទជិតដោយទ្វារបញ្ឆោតជាច្រើនដែលតុបតែងយ៉ាងល្អវិសេស ។ ទ្វារទាំង ៣ នៃក្លោងទ្វារធំចូលទៅកាន់ប្រាសាទអង្គរវត្តនេះ អាចផ្តល់ឲ្យមានផ្លូវចរាចរណ៍ចេញចូលបានដោយងាយ

www.budinst.gov.kh www.elibraryofcambodia.org

ហើយសុទ្ធសឹងតែមានកំពូលប្រាង្គមួយពីលើតាំងអស់ តែកំពូលប្រាង្គ តាំងនោះត្រូវបាក់កំបុតតាំងអស់ ៗ ជាន់លើខ្លះដែលមានស្នាម សណ្ដកឬជាបន្ទប់ភ្ជាប់គ្នានោះ ឥឡូវនេះរលំវិនាសបាត់បង់គ្មានសល់ៗ ពេនថែវតាំងឡាយ ផ្នែកដែលបែរក្ដោះទៅរកប្រាសាទ មានជញ្ជាំង ជិតឥតបង្អួច បិទយ៉ាងជិតស្និទ ថែមតាំងតុបតែងរចនាជាក្បាច់ក្បាំង ក្បាលជញ្ជាំងទិសចំរៃរូបទេពអប្សរតាម ៗ ជារបៀបក្បាច់វិចិត្រសិល្បៈ គ្រឿងព្រំ ៗ ពេនថែវតាំងនេះបង្អៀតណាស់ មានទទឹងតែ ២ ម៉ែត្រ ២០ ហើយមានព្រំដែនខាងក្រៅកំណត់តែត្រឹមជួរសសរ ៤ ជ្រុងស្មើមួយជួរ ដែលមានល្វែងចំហៀងទ្រង់ទ្រាយជារានក្ដានតែ ពាក់កណ្ដាល ពីលើសសរតាំងនេះ នៅអមសនខាងពេនថែវ ៗ ឯស្នាមដំណែលនៃល្វែងចំហៀងនេះ នៅសល់តែបន្តិចបន្តួចប៉ុណ្ណោះៗ ការបាក់បង់នូវល្វែងចំហៀងនេះ អាចបំបាត់ពេលស្រឡះនូវភាគជ្រុំ ផ្ដុកណាមួយនៃសសរតាំងនោះ ហើយថែមតាំងធ្វើឲ្យខូចខាតនូវ សហមាត្រតាំងស្រុងនៃក្លោងទ្វារធំនេះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

បើទស្សនាកំពែងទាំងមូលចំពីមុខ ហាក់ដូចជារបាំងអ្វីមួយគ្របដណ្ដប់បាំងបិទប្រាសាទទាំងមូល ឲ្យឃ្លាតចាកការពិនិត្យនៃអ្នកដំណើរ ដែលចូលចិត្តមើលនូវរូបភាពខ្លះទៅនៃប្រាសាទដោយមាត្រាសាស្ត្រ ។

នៅចំអ័ក្សនៃផ្លូវខាងលិចដែលនាំទៅជ្រុងខាងជើង មាននាគ ១ ដំសំបើមអស្ចារ្យ បញ្ជាក់ឲ្យយើងយល់ច្បាស់នូវគុណសម្បត្តិដ៏វិសេសវិសាលក្រៃលែងនៃក្បាច់រចនាអង្គរវត្ត ។

ក្បាច់ក្បាលសសរនិងក្បាច់លើធ្នឹម សឹងប្រកបដោយភាពចំហៀងដ៏បរិសុទ្ធ ដូចគ្នានឹងក្បាច់សិល្បៈនៃប្រទេសក្រិកដែរ ។ ឯចំណែកសសរ ៤ ជ្រុង ដែលផ្សាបជាប់ទៅនឹងជញ្ជាំងដូចជាមេទ្វារខាងលើដែលនៅគង់នៅល្អគ្រាន់បើ ដូចជាក្លោងទ្វារខាងកើតជាដើម សឹងតែមានសុខុមាលភាពយ៉ាងចំណាន ។

មុខខាងកើតនៃពេនថ្មទាំងឡាយ បញ្ជាក់ឲ្យគាត់តែច្បាស់លាស់ទៅទៀត នូវភាពនៃការចាប់ការណ៍ទំពោះសម្រស់ដ៏ល្អឥត

www.budinst.gov.kh www.elibraryofcambodia.org

ដែរ , បន្ទប់ទាំងឡាយសឹងប្រកបដោយកូនសសរ ជើងទៀនក្រឡឹង យ៉ាងស្អាត ហើយមានចម្រឹងឆ្លាក់ជារូបសត្វគ្រប់យ៉ាងដាក់បទ្តើត ពីលើ នៅអមសងខាងរូបទេពធីតាទាំងឡាយ ៗ រូបទេពធីតា ទាំងនោះ នៅគង់វង់ល្អនៅឡើយ ហើយជួនកាលនៅផ្តុំគ្នាជាក្រុម ពីរ ឬបី ៗ ម្យ៉ាងទៀតរូបទេពកញ្ញានេះក៏ចាត់ទុកជារូបដ៏ល្អមួយ ផ្នែកក្នុងពពួករូបទេពធីតាទាំងឡាយនៃប្រាសាទអង្គរវត្តដែរ ៗ

តពីនេះទៅយើងនឹងនាំជូនអស់លោកអ្នក ទៅទស្សនា ត្រួស ៗ នូវក្លោងទ្វារធំ ៗ ទាំងឡាយ នៅកំពែងទី ៤ នៃទិសបន្ទាប់ បន្ទាំងបី ព្រោះថាមិនសូវមាននរណាទៅទស្សនាឡើយ ៗ នៅ កន្លែងខ្លះមានសហមាត្រដឹកត្តមតែមិនទាន់ហើយនៅឡើយ ជាពិសេស ប៉ែកខាងក្នុងនៃក្លោងទ្វារ , ក្លោងទ្វារទាំងនោះមានរាងបួនជ្រុង ទ្រវែង គ្រប់គ្រឿងតែងល្អស៊ុខទិនល្អឥតបំហៀង ហើយថែមទាំង តូចជាងក្លោងទ្វារខាងលិចជាច្រើនផង ៗ គេដើរឆ្ពោះទៅកាន់ព្រះ វិហារកណ្តាលបានដែរ ដោយផ្លូវដើរដែលក្រោយក្នុងគុម្ពោតព្រៃជា

www.budinst.gov.kh www.elibraryofcambodia.org

ព្រេន ហើយទិដ្ឋភាពពីក្លោងទ្វារខាងជើងទៅលើស្រះទឹកក្នុងបាខែង -
ជាទីមេតនាក្រៃលែង ។

## គ ប្រាសាទអង្គរវត្ត

ក្នុងខណៈដែលដើរក្រោមម្លប់ដំបូលផ្ទាក់នៃក្លោងទ្វារទិសបស្ចិម អ្នកទស្សនាទាំងឡាយអាចក្រឡេកមើលតាមរន្ធនៃក្លោងទ្វារធំ ទូរ-ស្សប្រសេងនៃព្រះអាទិត្យ ដែលជះចាំងមកលើទ្រូងថ្មល់នឹងតួប្រាសាទអង្គរវត្តដ៏ល្បីល្បាញ លើសលប់ពេញសាកលលោក ។ ទ្រូងថ្មល់នេះសង់លើដីលើកមួយផ្នែកមានបណ្ដោយ ៣៥០ ម៉ែត្រ ទទឹង៩ម៉ែត្រ ៤០ ចន្លោះសម្រាប់ដើរ ៨ ម៉ែត្រ ហើយនៅខ្ពស់ផុតពីដីរាបធម្មតា ចំនួន ១ ម៉ែត្រផង ។ នៅអមសងខាងទ្រូងថ្មល់ មានសសរតសំអាង ចេញនាគដោយប្រកាន់នៃរូបនាគ ដែលមានជាជើងទៀនទ្រពីក្រោមយ៉ាងល្អលើសលប់ ។ នៅពេលដែលព្រះអាទិត្យជះកាំរស្មីមកលើពិទីដែលលោកបានបន្តតាមរបៀបពុះជើងទៀនរូបកាច់ដែលនាគនោះ មានកំរើបហាក់ដូចជាក្បាច់រំលោភ ។ នៅសងខាងទ្រូងថ្មល់ដដែលនេះ

www.budinst.gov.kh www.elibraryofcambodia.org

មានជណ្ដើរប្រាំមួយប្រកបដោយក្បាលនាគបើកពារផ្លូវជាជិត ។ តាមការពិនិត្យសង្កេត ជណ្ដើរទាំងប្រាំមួយនេះ មានលក្ខណៈហាក់ដូចជាជួយជ្រែងកុំឲ្យថ្ពល់ទាំងមូលទ្រេតរលំ ជាពិសេសធ្វើឲ្យទ្រូងថ្ពល់នេះកុំឲ្យមានសភាពជដែល ៗ ផង ។

នៅចំពាក់កណ្ដាលថ្ពល់ ខាងត្បូងនិងខាងស្ដាំ គេឃើញមានប្រាសាទតូច ៗ ពីរបែរមុខឈមរកគ្នាតាមបណ្ដោយទ្រូងថ្ពល់ ប្រាសាទតូចនេះ គេហៅថា ប្រាសាទបណ្ណាល័យ បើតាមពាក្យចាស់ទុំធ្លាប់ហៅថា "ក្រយាចំអិន" តែតាមការសង្កេតទូទៅ ប្រៀបបាននឹងវត្តដ៏តូចក្នុងសម័យបុរាណ ។ ប្រាសាទតូច ៗ នេះ មានលក្ខណៈដូចជាសាលាសំណាក់ សម្រាប់ឲ្យអ្នកចូលទៅកាន់វត្តផ្លាស់សំលៀកបំពាក់ចាស់ចោលហើយស្លៀកពាក់ជាថ្មី មុននឹងចូលទៅកាន់វត្ត អាស្រ័យហេតុនេះហើយបានជាមានស្រះពីរនៅជិតនោះ ដែលមានវិស័យហាក់ដូចជាអណ្ដូងនៅជិតសាលាដូច្នោះដែរ ។

ក្រៅពីនេះទីតាំងនៃប្រាសាទបណ្ណាល័យនេះ ដែលស្ថិតនៅក្នុង

ផ្នែកប្រាសាទសម័យដើមនៃបង្គូរ៖ ជាការប្រសើរម្យ៉ាងដែលអាចឲ្យ
សាសនិកជនទាំងឡាយ ឈៀងចូលទៅមើលក្បួនច្បាប់ផ្សេងៗបាន
ដោយងាយផង ។ ប្រាសាទនេះមានសណ្ឋានទ្រង់ទ្រាយតាមបន្ទិច
ហើយមានសភាពប្រហែលគ្នានឹងក្លោងទ្វារទាំង ៤ នៃប្រាសាទអង្គរវត្ត
ដែរ ។ ក៏តាំងក្នុងផ្នែកមួយនៃអង្គរវត្ត និងសហមាត្រជំទាប លក្ខណៈ
ទាំងពីរនេះបើតាមការពិចារណា ជាភាពវិសេសរបស់ប្រាសាទ
បណ្ណាល័យនេះ ដែលប្លែកខុសស្រឡះពីភាពប្រក្រតីនៃប្រាសាទ
ទាំងឡាយ ។ យើងនឹងឃើញតទៅទៀត នៅក្នុងប្រាសាទអង្គរវត្ត
ក៏ដូចជានៅក្នុងអាគមសម័យថ្មីឥឡូវនេះដែរ ទូរសាលសម្រាប់ប្រជុំ
សាធារណជនឬសាសនិកជនទាំងឡាយ ។ នៅអមថ្នល់ដែលយើង
ចូលទៅកាន់ប្រាសាទមានស្រះពីរកង ៤ ជ្រុងស្មើ ស្រះទាំងពីរនេះ
មានតែស្រះមួយទេ ដែលមានមាត់ច្រាំងព្រោះថ្មហើយមានទឹកពេញ
ជានិច្ច ។ បើការណាយើងឈរគង់លើលពីមុខខាងជើងឈៀង
ខាងលិចស្រះនេះ នោះនៅគេប្រាសាទ នៃស្របក្នុងយើងនឹងបានជួប

ប្រទះឡូវស្រះមោលប្រាសាទតាំនមូលជំល្អក្រៅលែង ពោលទៅក្នុងទឹក

នឹងថ្កល់ដូចផ្គាំងកញ្ចក់ ទីនេះហើយដែលទេសចរមែនចូលចិត្តថតរូប

របស់គេទុកជាអនុស្សាវរីយ ។

ឯក្នុងប្រាសាទវិញ សាងទៀងខ្ពស់ពីដីលានពបស្មើនំទេងមួយ

ប្រកបទៅដោយកំពលតិណជាតិទៀវខ្ចី ហើយមានដើមត្នោតជាច្រើន

ដុះពន្រលាស់ទៅលើអាកាស ហាក់ដូចជាចង់ប្រកួតប្រជែងនឹងកំពស់

ប្រាសាទ ។ នៅជុំវិញប្រាសាទមានដើមស្វាយធំ ៗ ជាច្រើន

ពោលម្ចប់ត្រឈើងគ្រឹឈក្រាលមកលើ ទីលាន ធ្វើឲ្យមានសភាព

ត្រជាក់ល្ហឹមជានិច្ច ។

នៅមុខផ្លូវចូលទៅកាន់ព្រះវិហារ មានព្រះលានមួយខ្ពស់បែកជា

ពីរថ្នាក់ សណ្ឋានទ្រទ្រង់ព្រោយពង់កាកបាទ ដែលគេហៅថាព្រះលាន

កិត្តិយស នៅពេលបុណ្យទិងពេលហែក្បួនតាំងឡាយនាសម័យ

បុរាណ ព្រះលាននេះអាចក្លាយទៅជាវេទិកាមួយសម្រាប់ព្រះមហា-

ក្សត្រគង់ប្រថាប់ ហើយនៅវេលាយប់ផ្ញើឆាកសម្រាប់របាំព្រះកជទ្រព្យ

www.budinst.gov.kh www.elibraryofcambodia.org

ផង ។ ក្បាច់ក្បាលជញ្ជាំងប្រកបដោយក្បាច់រចនាល្អវិចិត្រ មាន
សសរជាច្រើនទ្រពីក្រោមប្រកាន់ដៃរូបនាគ ដែលមានលំអយ៉ាង
ស្រស់ស្អាត ។

✓ នៅខាងណោះ គេឃើញមានភាពផ្ដេកមួយនៃជាន់ទី ១ នៃ
ភាពីជ្រុងបីជាក់ ជាន់និមួយ ៗ មានកេងដែរព័ទ្ធជុំវិញ ដែលមាន
ប្រវែងទាំងអស់ ១២០០ ម៉ែត្រ ✓។ កេងដែរទាំងនេះបង្អៀតណាស់
ហើយមានសណ្ឋានទ្រង់ទ្រាយជាកំពែង យ៉ាងមាំព័ទ្ធជុំវិញតួព្រះវិហារ
កណ្ដាល ។ នៅក្នុងព្រះវិហារកណ្ដាលមានព្រះអាទិទេព អាសន
សាលាមួយ ដែលមានជ្រុងនិមួយ ៗ ប្រវែងមិនលើសពី ៥ ម៉ែត្រ 22
ឡើយ ។

ការខ្វះភាពធំទូលាយគ្រប់កន្លែងដែលមានសារៈប្រយោជន៍ ជា
ចារិតលក្ខណៈមួយក្នុងពពួកចារិតលក្ខណៈនានា នៃស្ថាបត្យកម្មរបស់
ប្រាសាទអង្គរវត្ត ម្យ៉ាងទៀតទស្សនវិស័យបែបនេះហាក់ដូចជាធ្វើឲ្យ
យើងយល់ឃើញច្បាស់ថា ជាស្នាដៃនៃមនុស្សស្ថាបនាឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ថែវខាងក្រោម ប្រកបដោយចម្លាក់យ៉ាងល្បីល្បាញជាងគេ ដែលអ្នកទេសចរចូលចិត្តមើលនោះ មានទទឹងប្រវែង ១៨៧ ម៉ែត្រ និងបណ្តោយប្រវែង ២១៥ ម៉ែត្រ ។ ក្លោងទ្វារឬគោបុរៈសឹងមាន គ្រប់ប្រាសាទទិស ហើយភ្ជាប់គ្នាត្រង់ត្រឡែងកែងនៃល្វែងមុខ នៅទិសកើតទិសមុខ ដែលមានជណ្តើរឡើងចុះ ដោយកូនប្រកតូចមួយពោង ក្លោងជាគ្របកផ្កាឈូក ទទឹង ២ ម៉ែត្រ ៤៥ ។ ផ្នែកដែលបែរឆ្ពោះទៅរកប្រាសាទ គ្មានបង្អួចទេ មានតែជញ្ជាំងជិតស្និទ្ធ ។ ឯចំណែកដែលឈមមកខាងក្រៅវិញនោះ គ្មានជញ្ជាំងទេ មានតែសសរជួរ ៗ ជាច្រើនតែប៉ុណ្ណោះ ។ នៅផ្នែកខាងក្រៅនេះ មាន
23 ល្វែងចំហៀងតាមខ្នង ក្លោងពាក់កណ្តាលបន្តើតតម្រួតពីលើសសរទាំងនេះ ។ ដំបូលរោងថែវទាំងអស់មានពណ៌ប្រផេះធ្វើពីថ្មសណ្ឋានជាក្បឿងប្រក់ពីលើគ្នា ។

មើលពីចម្ងាយគេឃើញកំពូលប្រាង្គទាំងឡាយនៅមុខនៃបរិវេណទី ២ ដែលបាក់កំពូលខ្លះ និងកំពូលទាំងឡាយនៃប្រាសាទកណ្តាល

www.budinst.gov.kh www.elibraryofcambodia.org

ពេទអាពហាក់ដូចជាផុសអណ្តែតលេចធ្លោឡើងលើអាកាសវេហាស៍ៗ កំពូលប្រាសាទមានសណ្ឋានរៀវមូលស្រួចទៅលើ ហាក់ដូចជាផ្កាឈូកក្រពុំទើបលេចចេញពីទឹក ហើយប្រកបដោយក្បាច់រចនាបោរាណគួរពិចិត្រ ៗ

✓ កំពូលប្រាសាទនិមួយ ៗ ចែកជា ៤ ជាន់ បន្ទប់ ទីតតម្រួតពីលើគ្នា ៗ នៅជាន់និមួយ ៗ មានរូបស្រីទេពអប្សរកើតទង់ក្នុងក្រុមព្រៃឈើខ្ទាំ វិស័យហាក់ដូចជាពេញជីវិតរស់រវើក ហើយមិនមានក្បាលនាគលើកតពារពើនកាចសាហាវ ឈមមុខទៅទិសទាំង ៤ ៗ នៅកំពូលប្រាសាទមានត្រួបផ្កាឈូក ៣ ស្រទាប់ទទួលក្រោមកំពូល ៗ តាមរូបចម្លាក់ក្នុងប្រាសាទបាយ័នបានបញ្ជាក់ថា នៅលើកំពូល 24 )
ទាំងនេះ មានកំពូលតូចបន្ថែមទៀតធ្វើពីសំរិទ្ធជារបៀបលំពែង ✓ ត្រីសូល៍ ៗ

✓ កំពែងថ្មនៃបរិវេណទី ២ មានបណ្តោយ ១១៥ ម៉ែត្រ ទទឹង ១០០ ម៉ែត្រ ភ្ជាប់គ្នានឹងកំពែងថ្មនៃបរិវេណទី ៣ ត្រង់ជ្រុងខាងលិច

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានសណ្ឋានជាកាកបាទ មានសភាពដូចគ្នានឹងប្រាសាទ « បឹងមាលា » ដែលជាប្រាសាទមួយប្រកបដោយបែបផែនមិនខុសគ្នាពីប្រាសាទអង្គរវត្តឡើយ ។ វិសាលភាពទាំងនេះផ្សំកើតឡើងពីប្រកសម្រាប់ដើរ ឬ រានហាលមានដំបូលមួយដែលភ្ជាប់ទៅនឹងគោបុរៈទាំងពីរ និងប្រកកាត់ទទឹងមួយទៀត ដូច្នេះសភាពវិសាលនេះមានរាងជាកាកបាទ ។ តាមការពិនិត្យ វិសាលភាពនេះស្ថិតនៅអមសងខាងថ្នាក់ទី ១ និងទី ២ នៃសាជីជ្រុង ។ បើគេដើរតាមវិសាលភាពនេះឆ្ពោះទៅហោជាងខាងលើបង្អស់ គេនឹងស្ងើចសរសើរដល់ស្នាដៃនៃស្ថាបត្យករជាមិនខាន ព្រោះថា មានតែកន្លែងត្រង់នេះហើយដែលប្លែកខុសពីកន្លែងឯទៀត ។ បើគេដើរពីខាងកើតឡើងមកប្រាសាទកណ្តាលវិញនោះ នៅកន្លែងត្រង់នោះគ្មានវត្ថុអ្វីជាបម្លែកឡើយ ។ តាមការវិនិច្ឆ័យគេសន្មតថា ប្រាសាទអង្គរវត្តមានលក្ខណៈល្អវិសេសជាងគេ ព្រោះជាប្រាសាទប្រកបដោយភាពហាក់ដូចជាស្រាលបំផុត អាចផ្តល់ឲ្យមានការស្ថាបនាបានខ្ពស់ទ្រៀបដូចជា

www.budinst.gov.kh www.elibraryofcambodia.org

អណ្តែតត្រសែតនៅលើអាកាសវេហាស៍ ។

✓ ឯចំណែករោងថែវតាំងពីរនៅចុងខាងជើងនិងខាងត្បូងវិញ មានទទឹងប្រវែង ២ ម៉ែត្រ ៩០ ✓ ។ ផ្នែកខាងក្រៅមានជញ្ជាំងជិត ប៉ុន្តែចំណែកដែលឈមទៅរកទីលានវិញ មានសសរពីរជួរ តែគ្មានជញ្ជាំងឡើយ ។

✓ ល្វែងតាំងពីរដែលខ្វែងគ្នាជារាងកាកបាទនោះ មានភាពធំទូលាយជាងគេ ល្វែងកណ្ដាលមានទទឹង ៣ ម៉ែត្រ ១៤ ។ រួមជាមួយនឹងល្វែងតាំងពីរផងមានប្រវែង ៧ ម៉ែត្រ ៧០ ✓។ នៅជ្រុងតាំងឡាយនៃត្រឡែងកែងមានផ្ទៃទំនេររាងជាអាងទឹកបួនលាន ដែលមានផ្នែកខាងក្រោមប្រកបដោយក្បាច់ចម្លាក់ជាច្រើន ហើយមានជណ្ដើរតែមួយសម្រាប់ចុះទៅក្នុងអាងទឹក ។ នៅជុំវិញអាងនោះសឹងពេញដោយទឹក ប៉ុន្តែផ្ទៃទឹកមានកំរិតមិនហួសពីកាំជណ្ដើរខាងលើគេនោះឡើយ ។ ជំពូលធំ ៗ ដែលខ្វែងគ្នាជាកាកបាទនោះ កាលពីសម័យបុរាណ មានពិតានឈើឆ្លាក់ក្បាច់ផ្កាបន្ទ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯពិតាននោះ សព្វថ្ងៃមាននៅសល់ខ្លះនៅឡើយ គឺពីនោះទៅ នៅក្តោងកណ្តាលនៃល្វែងចំហៀង គេឃើញមានពិតានថ្មសុទ្ធ ៗ ដែលខ្ចុកម្រក្សណ៍លាបទឹកមាសមានពន្លឺភ្លឺផ្លេកៗ ។ នៅតាមក្បាច់ក្លោងទ្វារគេឃើញរូបព្រះនារាយណ៍ ជាជំនួយដល់ការកូរសមុទ្រទឹកដោះ ទីឯព្រះអាទិទេពមួយអង្គផ្ទុំលើនាគរាជឈ្មោះ « អានន្ទ » ជាពិសេសនៅតាមជើងសសរ មានរូបមហាឥសីអង្គុយពត់ភ្នែន ភាវនាធម៌ ដៃតាំងពីរប្រណម្យសំពះទៅមុខ ៗ ចាប់បន្តពីកន្លែងនេះមក អ្នកទស្សនាទាំងឡាយនឹងមានមនោសញ្ចេតនា ស្ងើចសរ-សើរក្បាច់រចនា នៃស្រីទេពអប្សរដែលមានកក្រញញឹមប្រិមប្រិយ ហាក់ដូចជារីករាយនឹងទទួលទស្សនិកជន ព្រមទាំងស្ងើចសរសើរដល់ថ្វីដៃនៃស្ថាបត្យករ ដែលចេះក្រឡឹងជើងទៀនបន្ថែមឲ្យមានក្បាច់ក្បូរមូលក្រឡង់ មានវិស័យដូចជាក្រឡឹងឈើធម្មតា ។ ផ្ទាំងពេទថែវទាំងឡាយ សឹងប្រកបដោយក្បាច់រចនា ដែលឆ្លាក់បំផុសលើផ្ទាំងសិលាយ៉ាងល្អឆើតឆាយ ដែលស្ថិតនៅផុតពីការអន្តរាយ

www.budinst.gov.kh www.elibraryofcambodia.org

ដោយទឹកភ្លៀង ។ ម្យ៉ាងទៀតអ្នកត្រូវអញ្ជើញចូលទៅកំពែងទី២ អ្នកនឹងឃើញព្រះបដិមាករជាច្រើនអង្គ ដែលគេហៅថា "ព្រះពាន់" នៅពីស្តាំដៃនៃទ្វារចូល ។ ព្រះពុទ្ធរូបទាំងអស់នេះ គេបាននាំយកពីកន្លែងផ្សេង ៗ មកដំកល់ទុកនៅទីនេះ តាំងពីសម័យក្រោយអង្គរវត្តម្ល៉េះ ។ បើបានទស្សនាព្រះពុទ្ធរូបរួចហើយ សូមអញ្ជើញដើរតាមផ្លូវខាងជើងនៃកំពែងទីង អ្នកនឹងបានដល់កន្លែងមួយហៅថា "កន្លែងគក់ទ្រូង" ព្រោះនៅកន្លែងនេះកាលណាគេគក់ទ្រូងទៅ គេនឹងឮសំឡេងលាន់ខ្ទរមកវិញជាមិនខាន ។ ផុតពីកន្លែងនេះទៅមានធម្មទ្ទ័រមួយនៅខាងជើង ហើយនិងមានធម្មទ្ទ័រមួយទៀតនៅខាងត្បូងព្រះពាន់ ។ ឡើងផុតពីទីនេះមួយថ្នាក់ទៅ អ្នកនឹងបានឃើញប្រាសាទកំពូលប្រាំ ដែលគេធ្លាប់ហៅថាប្រាសាទ "បាកាន" ដែលនៅខ្ពស់ជាងគេ ហើយមានជណ្តើរ ៣៧ កាំ ។

ចំណែកឯទីធ្លា ដែលនៅអមបរិវេណទី ២ និងទី ៣ ពុំសូវមានវត្ថុអ្វីចំឡែកទេ មានតែរានហាលវែង ៗ តែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងទីធ្លានេះមានបណ្ណាល័យធំ ៗ ពីរ ប្រកបដោយក្លោងទ្វារពីរ ព្រមទាំងមានចម្រឹងបង្អួចជាច្រើន នៅល្វែងខាងមុខ ។

ក្រៅពីនេះ យើងត្រឡប់មកកាន់ពានថែវខាងជើងវិញនៅមុខព្រះពាន់ យើងនឹងបានជួបប្រទះផ្ទាំងសិលាចារឹកមួយផ្ទាំង ដែលសាងឡើងក្រោយសម័យអង្គរវត្ត រួចយើងត្រូវត្រឡប់បែរមកខាងត្បូង ឡើងតាមជណ្ដើរស៊ីម៉ងត៍ ដែលមិនរអិលដូចជណ្ដើរនៅអង្គរកណ្ដាល ហើយដើរតម្រង់ទៅថ្នាក់ទី ៣ ។

ពានថែវនៃបរិវេណទី ៣ មានទទឹង ២ ម៉ែត្រ ៤៥ ផ្នែកខាងក្រៅមានជញ្ជាំង ផ្នែកខាងទីធ្លាមានបង្អួចចម្រឹងជាច្រើន ។ ថែវនេះគ្មានពានហាលទេ មានតែរូបទេពកញ្ញាជាច្រើនដែលមានសក់តុបតែងលំអប្លែក ៗ គ្នាជាអនេក ។ ទិដ្ឋភាពពីជើងបន្ទប់មុខខាងជើង ធៀងខាងលិច នៅវេលាថ្ងៃទេរ និងពីមុខខាងជើងធៀងខាងកើត នៅវេលាយប់ខែភ្លឺស្រឡះចាំងផះលើវិមានកណ្ដាល អាចផ្ដល់ផល់ឲ្យយើងនូវការចាប់អារម្មណ៍មួយយ៉ាងអស្ចារ្យ ដែលមិនអាច

www.budinst.gov.kh www.elibraryofcambodia.org

បំភ្លេចបាន ។ នៅផ្នែកខាងក្រោមប្រាសាទវិញ មានកាពមាំ ខ្ពូលាយអស្ចារ្យបែកជាពីរជាន់ កំពស់ទាំងអស់១៣ម៉ែត្រ រាង ៤ ជ្រុង ស្មើដូចគ្នាទឹងបញ្ចូស្មូលដែលមានជ្រុងនិមួយ ៗ ប្រវែង ៦០ ម៉ែត្រ ។ ជណ្ដើរទាំងអស់ដែលសម្រាប់ឡើងទៅកាន់ប្រាសាទ សឹងប្រកបដោយការជាជាន់ជាថ្នាក់ សណ្ឋានទ្រេតលយទៅមុខនៅពីលើផ្លូវផ្នែកខាងក្រោមនេះបន្តិច ។ ជណ្ដើរទាំងនេះចោត ៗ ណាស់ ខ្លះមានជម្រាលដល់ទៅ ៧០ អង្សា ហើយមានបង្អួចតែមួយផង ។ នៅពីលើផ្នែកខាងក្រោមនេះ គេជួបប្រទះរោងថែវជាច្រើន ។ រោងថែវនិមួយ ៗ មានគោបុរៈជាអ័ក្ស ប្រកបដោយមុខក្លោងទ្វារមានសសរជាច្រើន ។ ក្នុងតួប្រាសាទទាំងមូលបានតែរោងថែវទាំងនេះទេ ដែលត្រូវការស្មើនៃព្រះអាទិត្យចាំងចូលទាំងសងខាង ទាំងព្រឹកទាំងល្ងាច ។ ពន្លឺអាចចូលទៅបំភ្លឺក្នុងរោងថែវទាំងនេះបាន អាស្រ័យដោយបង្អួចចម្រឹងនៅតាមជញ្ជាំង និងប្រទះឡោះសសរពីរជួរនៃល្វែងខាងដំណាប ៗ ។ √ នៅចំកណ្ដាល មានតួប្រាង្គជាស្តូបមួយធំជាងគេ

www.budinst.gov.kh www.elibraryofcambodia.org

កំពស់ ៤២ ម៉ែត្រ ផុសលេចចេញពីទ្រនុងតាំងពួននៃដំបូល ដែលខ្វែងគ្នាជាកាកបាទ ប្រកបដោយហោណាំងពីរជង ៗ ប្រាង្គនេះមានកំពស់ពីទ្រនាប់ថ្នាល់ខាងមុខចំនួន៦៥ ម៉ែត្រ ហេតុដូច្នេះប្រាង្គនេះខ្ពស់ផុតគេ ។ល។

ក្នុងខណៈដែលយើងដើរវង់តាមលានដែលព័ទ្ធជុំវិញជាន់ទី ២ យើងនឹងបានឃើញក្បាច់លំអ នៃក្លោងទ្វារចូលតាំងឡាយនៃពេងថែវបរិវេណប្រាសាទ ហើយជាពិសេសយើងនឹងបានឃើញក្បាច់ក្លោងទ្វារខាងកើតនៃពេងថែវខាងជើង និងក្បាច់ក្លោងទ្វារចូលកណ្ដាលនៃពេងថែវខាងត្បូង ។ ឆ្ងាយពីទីនេះបន្តិចមក យើងនឹងបានជួបប្រទះគេទៅទៀត នូវក្បាច់ក្លោងទ្វារនៃប្រាង្គមុមតាំងឡាយនៃក្រុមប្រាសាទកណ្ដាល ដែលនៅក្នុងចំណោមក្លោងទ្វារតាំងនេះ មានតែក្បាច់ក្លោងទ្វារខាងជើងឆៀងខាងកើតទេ ដែលមានលាកបំបាំងតាំងឡាយដ៏ច្រើន ហើយជាពិសេសនៅគង់វង់ល្អជាងគេ ៗ នៅមុខខាងលិច គមសង់ខាងអ័ក្សផងនោះ មានបណ្ណាល័យតូច ១ ពីរ

www.budinst.gov.kh www.elibraryofcambodia.org

ប្រកបដោយទ្វារពីរនឹងបង្អួចបញ្ឆោតជាច្រើន ។

បណ្ណាល័យនេះ មានទ្រូងថ្នល់មួយកងជាកាកបាទ ហើយមានសសរធ្វើ ៗ ជាច្រើនសម្រាប់ទល់ទ្រូងផង ។ ជណ្ដើរចុះមកជាន់ទី ៣ មិនសូវចោតដូចជណ្ដើរតាំង ១១ ឯទៀត ៗ ទេ ជម្រាលប្រហែល ៤០ អង្សាតែប៉ុណ្ណោះ ។ ប៉ុន្តែអ្នកទស្សនាចូលចិត្តចុះតាមជណ្ដើរអ័ក្សខាងត្បូងជាង ព្រោះជណ្ដើរមានការជួសជុលធ្វើដោយស៊ីម៉ងត៍ជាថ្មី ហើយមានបង្កាន់ដៃដែកមួយផង ដែលអាចឲ្យឡើងចុះបានយ៉ាងស្រួល គ្មានភ័យព្រួយនឹងរអិលធ្លាក់ឡើយ ។

រោងថែវជាបរិវេណខាងលើគេបង្អស់ មានទំហំតែ ២ ម៉ែត្រទេ ហើយត្រូវបែងចែកជាធ្លាតូច ៗ បួន ដោយរោងថែវដែលមានអ័ក្សទទឹង ២ ម៉ែត្រ ៤០ និងល្វែងពីរផង ។ អ្នកទស្សនាកាលបានមកដល់ទីនេះហើយ សូមកុំភ្លេច ត្រាច់ចរមើលរោងថែវខាងលើនេះឡើយ ហើយសូមកុំភ្លេចចោលភ្នែក មើលដំបូលនៃរោងថែវខាងក្រោមតាំង-ឡាយ និងទៅលើភូមិស្រុក ឬទេសភាពព័ទ្ធជុំវិញប្រាសាទ ក្នុងទិស

www.budinst.gov.kh www.elibraryofcambodia.org

បានឃើញផ្លូវបាញ់ត្រង់សំដៅទៅចំណតយន្តហោះ ហើយមិនខ្វង់ខ្វ៉ បារៃន ជាពិសេស សូមកុំភ្លេចពិនិត្យនូវទ្រុងថ្មលំនិត្យប្រាសាទកណ្តាលឲ្យសោះ ។

តាមការពិនិត្យគ្រប់បែបយ៉ាងទៅលើក្បាច់ចម្លាក់ លើស្លាមទឹកមាសដែលជិតនៅសល់ដោយកន្លែងខ្លះៗនោះ យើងអាចសន្មតបានថា ប្រាសាទអង្គរវត្តទាំងមូលសឹងលាបថ្នាំពណ៌ លាបទឹកមាសទាំងអស់ ។ តាមការសង្កេតទូទៅ នៅលើប្រាសាទកណ្តាល គេអាចដឹងថាក្នុងសម័យបុរាណបាន មានរូបទេវភាពជាដំណាងព្រះនារាយណ៍ នៅគ្រប់មុខប្រាង្គទាំងបួន ។ ដល់ក្រោយមក ពុទ្ធសាសនិកជនទាំងឡាយមានព្រះរាជាជាដើម បានយករូបទេវភាពទាំងនោះចេញហើយដាក់ថ្មបំពេញធកទាំង ៤ ជាទ្វារខ្វន ហើយឆ្លាក់ព្រះពុទ្ធរូបទ្រង់ឈរជាជំនួសវិញ ។ ក្នុងឆ្នាំ ១៩០៨ លោក គុម៉ុយ ក៏បានចំលុះបើកទ្វារខាងត្បូងធ្វើជាព្រះធម្មតាវិញ ហើយថែមទាំងបានរកឃើញអណ្តូងមួយផង ។ ក្រោយមក ក្នុងឆ្នាំ១៩៣៤លោកហ្សកទ្រូវ

www.budinst.gov.kh www.elibraryofcambodia.org

បានធ្វើប្រតិបត្តិការក្នុងអណ្តូងនោះ ។ អណ្តូងកណ្តាលបានជីកក្នុងដីរាបជម្រៅ ២៥ ម៉ែត្រ ស្មើនឹងផ្ទៃដីនៃបរិវេណខាងក្រៅធម្មតា ។ កាលដែលចុះទៅក្នុងអណ្តូងនោះ គេមិនបានប្រទះឃើញកំណប់អ្វីដ៏ធំ ៗ ចម្លែកឡើយ ព្រោះតាមការពិត កំណប់នោះត្រូវបានគេលួចយកទៅអស់តាំងពីបុរាណកាលទៅហើយ តែគេបានរកឃើញក្នុងជម្រៅ ២៣ ម៉ែត្រ នូវយ័ន្តពីរសន្លឹកនៃគ្រឹះពងមូល ធ្វើអំពីមាសដែលមានទំហំ ០,១៨ម. និងទម្ងន់ ៦៥ ក្រាម សិតបញ្ចូលទៅក្នុងផ្ទាំងថ្មបាយក្រៀម ។

យើងសូមទាញសតិអារម្មណ៍លោកអ្នកទស្សនាទាំងឡាយថាព្រះសង្ឃខ្មែរយើងកាលពីសម័យបុរាណ បានជួយប្រតិបត្តិការរៀបចំជួសជុលប្រាសាទឲ្យបានស្អាតល្អដែរ តែគួរឲ្យស្តាយទៅវិញព្រោះអង្គខ្លះ បានផ្លាស់ប្តូរជំនួសមេក្លោងទ្វារខ្លះ ដែលខូចខាតបាក់បែកដោយយកសសរ ពីផ្នែកផ្សេង ៗ ទៀតនៃប្រាសាទនោះ មកជំនួសនាំឲ្យខូចភាពដើម និងបាត់បង់ភាគផ្សេង ៗ ខ្លះនៃប្រាសាទទៅវិញ ។

www.budinst.gov.kh www.elibraryofcambodia.org

# រូបចម្លាក់

ផ្ទាំងសិលាជាជញ្ជាំងពេនវែងនៃបរិវេណទី ៣ សឹងប្រកបដោយរូបចម្លាក់ជាច្រើនអនេក ដែលមានកំពស់ ២ ម៉ែត្រ និងវែងក្រឡាទំហំពីរគីឡូម៉ែត្រទេគុណ ដោយឥតរួមបញ្ចូលមណ្ឌបពីរខាងក្នុងផង ។ រូបចម្លាក់ទាំងនេះ និទានអំពីរឿងព្រេងនិងភាគប្រវត្តិសាស្ត្រ ។ តាមការសង្កេតពិនិត្យយ៉ាងម៉ត់ចត់ ក្បាច់ចម្លាក់ទាំងឡាយមិនមែនឆ្លាក់ជ្រៅទៅក្នុងថ្មប៉ុន្មានទេ ហើយច្បាស់ជាថ្វីដៃបរិសុទ្ធរបស់វិចិត្រករដោយពិតប្រាកដ ព្រោះសម័យនោះអ្នកឆ្លាក់គ្រាន់តែធ្វើតាមលំនាំស្នាមគំនូសនៃអ្នកគូរតែប៉ុណ្ណោះ ។ លោកគ្រូដែលបានពោលបញ្ជាក់ថា ក្បាច់ក្បូរនិងរូបចម្លាក់ទាំងអស់មិនមែនជាស្នាដៃរបស់ជាងឆ្លាក់តែមួយរូបឡើយ គឺជាស្នាដៃរបស់វិចិត្រករច្រើនរូបរាប់មិនអស់ ។ ព្រោះគេបានសង្កេតឃើញថារូបចម្លាក់ខ្លះមានភាពយ៉ាងប្រណីតល្អជាងគេ ដែលជាស្នាដៃសិល្បករស្ទាត់ជំនាញ ហើយយល់ច្បាស់នូវទម្រង់រូបដែលត្រូវគូរ រូបខ្លះ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតមានភាពអន់ថយជាងគេ ដោយអ្នកផ្ទាល់មិនសូវយល់ច្បាស់លាស់ នូវទម្រង់រូប ហើយក៏បណ្ដាលឲ្យមានភាពមិនដូចគេឯង ដូចការរាងមូលក្រឡុបហួស ដូចការរាងស្គមស្ដើងហួសក៏សឹងមាន ៗ តាមធម្មតា អ្នកទស្សនាដែលមកមើលជាបន្ទាន់ ច្រើនតែចូលចិត្តទៅគន់ពិនិត្យរូបចម្លាក់ក្នុងពេនៈថែវ ដែលនៅខាងត្បូងអគ្នេយ៍នៃប្រាសាទ ទិសភាគបន្ថែមនៃពេនថែវដែលនៅខាងត្បូង ហេតុទៅទល់គ្នានឹងមណ្ឌបមុខខាងជើងឆៀងខាងលិច ។ ពេនថែវនេះប្រកបដោយរូបចម្លាក់ល្អបំព្រែក ៗ ម្យ៉ាងទៀត ក្រៅពីនេះនៅក្នុងផ្នែក ១/៤ នៃពេនថែវខាងជើងឆៀងខាងកើត រូបចម្លាក់មានភាពអន់ថយជាងគេ ព្រោះកន្លែងនេះ ហាក់ដូចជាធ្វើឡើងដោយប្រញាប់ប្រញាល់មិនសូវផ្ចិតផ្ចង់ឡើយ ។ លោក គោឡូប៊ែរ បានពិនិត្យយ៉ាងច្បាស់លាស់នូវលក្ខណៈនៃក្បាច់និងរូបចម្លាក់ ហើយបានធ្វើអត្ថាធិប្បាយថា ប្រាកដជាមានអន្តរាគមន៍នៃអ្នកប្រតិបត្តិការជាតិចិនមកជួយបង្ហើយជាបន្ទាន់ នូវកិច្ចការដែលបានគ្រោងទុកជាមុន

www.budinst.gov.kh www.elibraryofcambodia.org



## អង្គរវត្ត

មើលនៅលើថ្នាក់ទី ៣ កំពូលខាងលិចជ្រុងខាងជើង

www.budinst.gov.kh www.elibraryofcambodia.org

ហើយដែលមិនទាន់ហើយនៅឡើយ ។ ក្នុងការរៀបចំផ្ទាំងរូបចម្លាក់ គេបានជួបប្រទះឃើញភាពផ្សេងៗគ្នាពីរ ផ្ទាំងគំនូរទី១ ប្រកបដោយសមាសភាពតែ១ ដែលពោរពេញទៅដោយឆាកចំបាំងរាំងផល់មួយធំ ， ផ្ទាំងរូបឯទៀតៗ សឹងប្រកបដោយរូបជាជាន់ជាថ្នាក់តាមរបៀបជារូបចម្លាក់ដ៏ថ្លៃថ្នូរ នៃសម័យពាក់កណ្ដាលសតវត្សទី ១១ ។ បើតាមការពិនិត្យពិចារណារបស់លោក សេដែស សឹងតែទាំងអស់នោះ អ្នកទស្សនាត្រូវដើរមើលរូបចម្លាក់ ចាប់ពីក្លោងទ្វារចូលខាងលិចទៅខាងត្បូង តាមទិសហៃខ្វា មិនត្រូវដើរមើលពីកើត ទៅជើងតាមទ្រឹស្តីប្រមាណរបស់លោក បួស ដែលយកមូលដ្ឋានកាលសម័យនៃព្រឹត្តិការណ៍ដែលបញ្ជាក់ពីរជ្ជកាលនៃព្រះទេវរាជឡើយ ។

ក្រៅពីនេះ រឿងរ៉ាវនៅផ្ទៃផ្ទាំងនៃរោងទងសឹងទាក់ទងនឹងរឿងព្រះនារាយណ៍ស្ទើរតែទាំងអស់ ។

## រោងទងខាងលិច ផ្នែកខាងត្បូងអ័ក្ស

នៅតាមរោងទងខាងលិចផ្នែកខាងត្បូង មានរឿងចំបាំង

www.budinst.gov.kh www.elibraryofcambodia.org

នៃក្សេត្រ កុរុ  រវាងពួកខាងស្តាំកៅរវៈ  ខាងឆ្វេង បាណ្ឌវៈ ។ ក្នុងផ្ទៃរឿងព្រេងហិណ្ឌូនេះគេចែកជា ៤ សង្កាត់ដូចតទៅនេះ ។

ដំបូងបង្អស់ នៅខាងចុងទាំងពីរ មានក្បួនហែមួយ ដែលគេឃើញមានអ្នកក្សត្រី និងកងទ័ពថ្មើរជើងប្រកបដោយគ្រឿងអាវុធយុទ្ធភណ្ឌសម្រាប់ចូលប្រយុទ្ធ ។ គេឃើញមេទ័ពធំ ១ ជិះដំរីនិងរទេះសេះ នៅលើផ្ទៃកណ្ដាលមានការប្រយុទ្ធយ៉ាងឃោរឃៅដូចជាមានសេះត្រូវព្រួញនិងមនុស្សត្រូវស្លាប់ គួរឲ្យអាណោចអាធម្មជាងខ្លាំង ។ ក្នុងផ្ទៃចំពាំងគេឃើញមេទ័ពខាងកៅរវៈ ឈ្មោះ ភិស្មៈត្រូវព្រួញដួលដេកស្លាប់នៅកណ្ដាលចំណោមក្រុមគ្រួសារ ដោយបញ្ចេញទឹកមុខញញឹម ឥតតក់ស្លុតដល់សេចក្ដីស្លាប់ ហើយនិងទ្រោណៈដែលមានសក់បួងទៅក្រោយតាមរបៀបព្រាហ្មណ៍ ដោយគ្មានពាក់មកុដឡើយ ។ នៅខាងស្តាំ គេឃើញមេទ័ពឈ្មោះ អជ៌នៈជិះលើរថដែលមានសារថីដៃ៤ ជាអ្នកបររថ ។ អជ៌នៈនេះ ជាអវតារនៃព្រះនារាយណ៍ កាឡាខ្លួនផង ហើយជាមេទ័ពពួក បាណ្ឌវៈផង ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយការស្តាប់អដ្ឋបទនៃទស្សនិកជនច្រើនលើសពាន់នាក់ រូបចម្លាក់ខ្លះឡើងរលោងស្រិលរលើយដូចជាសំរិទ្ធ ហើយទាំងស្ទើរតែផុតលេចពីផ្ទាំងក្បាច់គួរឲ្យអស្ចារ្យក្រៃលែង ។

## មណ្ឌបមុមខាងត្បូង ឆៀងខាងលិច

ត្រង់ខ្លោងកែងនៃសាលាទាំង ៤ ជ្រុងខាងត្បូង ឆៀងខាងលិច មានក្បាច់ក្បូររូបចម្លាក់ជាច្រើន តែក្បាច់ខ្លះត្រូវខូចខាតអន្តរាយអស់ជាច្រើនអន្លើ ដោយហេតុមកពីត្រូវទឹកភ្លៀងដែលជ្រាបចូលតាមគ្រោងដំបូលដែលបិទមិនជិតល្អ ។

ទី ១.– នៅលើទ្វារខាងជើង : " រឿងរាមកេរ្តិ៍ ,, : ព្រះរាមទ្រង់ដេញបាញ់ពាយដប្រែសមាស ដែលយក្សឈ្មោះ មារីច មកនិម្មិតខ្លួនបញ្ឆោតព្រះរាមនិងព្រះនាង សីតា ជាឧបាយកលឲ្យក្រុងរាពណ៍លបលួចយកព្រះនាងសីតា ។

ទី ២.– នៅសាខាខាងជើង, ផ្នែកខាងកើត : " ក្រឹស្ណៈនិងព្រះនាង ផលាភមា ជាអគ្គមហេសី ,, : ក្រឹស្ណៈទ្រង់ទ្រគំ គោវទ្ធនៈ

ដែលមានរាងជាចតុរស្ស ឬ បួនជ្រុងស្មើ ដើម្បីជានិមិត្តរូបនៃការជួយការពារដល់ក្រុមគង្វាលគោទាំងឡាយ ឲ្យរួចផុតពីគ្រោះថ្នាក់អន្តរាយនៃព្យុះសង្ឃរា ដែលកើតឡើងដោយឥន្ទ្រាធិរាជ (កំហឹងនៃព្រះឥន្ទ្រ)។

ទី ៣.– សាខាខាងជើង ផ្ទាំងខាងលិច នៅលើបន្ទប់ : „ រឿងទាញនាគកូរទឹកសមុទ្រ ,, : ពួកទេវតាគ្នានឹងពួកអសុរម្នាង ខំទាញនាគដែលធ្វើជាព្រ័ត្រកូរទឹកសមុទ្រ ដើម្បីដណ្តើមយកទឹកអម្រឹត ។ ទីបំផុតជ័យជំនះត្រូវបានដល់ទេវតា ដែលត្រូវបានទឹកអម្រឹតគឺ “ ទឹកដែលផឹកទៅមិនចេះស្លាប់ ” ។ នៅខាងលើវង់ចក្រពីរ គឺជាឋានព្រះអាទិត្យនិងព្រះចន្ទ្រ ។

ទី ៤.– សាខាខាងលិច ផ្ទាំងខាងជើង នៅលើបន្ទប់ : ក្រុងពាណ៍ក្លាយខ្លួនជាសត្វតុកកែ ដើម្បីចូលទៅក្នុងក្រឡាបន្ទំព្រះជាយានៃព្រះឥន្ទ្រាធិរាជ ។

ទី ៥.– នៅលើទ្វារខាងលិច : ព្រះរាជកុមារក្រឹស្ណៈ ខំប្រឹងទាញត្បាល់ថ្មសិលា ដែលព្រះមាតាយកទៅចងភ្ជាប់នឹងដើមឈើ

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះអរជុន បណ្តាលឲ្យរលំរលើងដើមអរជុន អស់ពីរដើម ។

ទី ៦.– សាខាខាងលិច ជញ្ជាំងខាងត្បូង នៅលើបង្អួច : ក្រុងរាពណ៍សម្តែងឫទ្ធិនិមិត្តខ្លួនជាមុខ ១០ ដៃ ២០ ចាប់អង្រួនភ្នំកៃលាស់ ដើម្បីនាំវិនាសដល់ព្រះឥសូរ និងព្រះនាង ឧមាភគវតី ជាព្រះអគ្គមហេសីនៃព្រះអង្គ ។

ទី ៧.– សាខាខាងត្បូង ជញ្ជាំងខាងលិច នៅលើបង្អួច : ព្រះឥសូរគង់ធ្វើសមាធិលើភ្នំកៃលាស់ ព្រះនាងឧមាភគវតី និមិត្តខ្លួនជាក្សត្រមួយអង្គចូលទៅអង្គុយគាល់ ។ ព្រះកាមៈ " អាទិទេពនៃសេចក្តីស្នេហា " យិតកោទណ្ឌសរកក់កែវបាញ់ជម្រង់ព្រះឥសូរ ។ ដោយបាញ់ឫទ្ធិព្រះឥសូរ ព្រះកាមៈ ក៏ចូលទិវង្គតខ្លួនឯងក្នុងរង្វង់ព្រះហស្តទាំងទ្វេ នៃព្រះអគ្គមហេសីព្រះនាមរតិ ។

ទី ៨.– នៅលើមាត់ទ្វារខាងត្បូង : មានកម្មនៃព្រះលម្ព៍ និងការលត់អគ្គិភ័យដោយព្រះក្រឹស្ណៈ ។

ទី ៩.– សាខាខាងត្បូង ជញ្ជាំងខាងកើត នៅលើបង្អួច :

www.budinst.gov.kh www.elibraryofcambodia.org

រឿងរាមកេរ្តិ៍ត្រង់ក្រុង ពាលី និង សុគ្រីព ច្បាំងគ្នា ហើយព្រះរាមជួយ សុគ្រីព ដោយយកកោទណ្ឌបាញ់សម្លាប់ក្រុង ពាលី ។ នៅផ្នែកក្រោម គេឃើញស្ដេចស្វាឈ្មោះ ពាលី ពាក់មកុដត្រីសូល៍លើក្បាល ចូលទិវង្គតលើរទ្ធង់ព្រះហស្តនៃព្រះនាង តារា ជាអគ្គមហេសី ហើយ មានពួកពលស្វា កំពុងយាសយំសោកសៅអាណិតអាសូរដល់សព ក្រុងពាលីជាម្ចាស់នៃខ្លួន ដោយធ្វើទឹកមុខនិងអាកប្បកិរិយាប្លែកៗគ្នា ។

ទី ១០.– សាខាខាងកើត ផ្ទាំងខាងត្បូង នៅលើបង្អួច : ផ្ទាំងរូបចម្លាក់នៅកន្លែងនេះ ត្រូវវិនាសខូចខាតអស់ខ្លះទៅហើយ គេមិនអាចសន្និដ្ឋានបានថា ជារឿងអ្វីឡើយ ។ តែគេឃើញមាននៅកណ្តាល នូវរូបបុរសម្នាក់អង្គុយសន្ទនាជាមួយអ្នកឯទៀត ១ ជាច្រើន ។ នៅពីលើរូបនេះ មានរូបមហាឥសី ។

ទី ១១.– លើបង្អួចខាងកើត : ត្រង់ក្រស្ណៈ ប្រទំខ្លូលផ្កាយ ដែលគេយកមកថ្វាយ ។

ទី ១២.– សាខាខាងកើត ផ្ទាំងខាងកើត : " បុណ្យអុំទូក "

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាកវែត គេឃើញមានសំពៅពីរពោរពេញដោយមនុស្សកុះករ ។ នៅក្នុងទូកខាងលើ មានអ្នកលេងចត្រង្គ ទូកខាងក្រោម មានមនុស្សកំពុងប្រឡែងលេងជាមួយនឹងកូន ។ នៅខាងស្តាំ មានមនុស្សប្រជល់មាន់នៅលើទូក ។

## រោងទងខាងត្បូង ផ្នែកខាងលិច

នៅផ្ទាំងនៃរោងទងនេះ ថ្លែងបញ្ជាក់ពីប្រវត្តិសាស្ត្រ ដែលមានផ្ទាំងចម្លាក់តែមួយផ្ទាំងប្រវែង ៩០ ម៉ែត្រ ត្រង់ព្រះបាទ សូរិយា-វរ្ម័នទី ២ ដែលជារាជស្ថាបត្យករនៃប្រាសាទអង្គរវត្ត លុះដល់ក្រោយទិវង្គតគេថ្វាយព្រះនាមថា " ព្រះបរមវិស្ណុលោក " ។

ផ្នែកខាងចុងនៃផ្ទាំងរូបចម្លាក់ ថ្លែងត្រង់នាយកប្ដូបណ្ឌិតយកផ្កាយមកថ្វាយស្តេច ព្រះបាទសូរិយាវរ្ម័នទី ២ ដែលទ្រង់ជាអ្នកសាងប្រាសាទអង្គរវត្ត គង់ប្រថាប់ក្រោមស្វេតច្ឆត្រ ដែលលំអដោយរូបនាគរាជ នៅលើភ្នំគិរិបទ ហើយទ្រង់ប្រជុំនាម៉ឺនសព្វមុខមន្ត្រី ដែលគង់គាល់ជិតស្តេច មានព្រះរាជវង្សានុវង្សរាជបណ្ឌិត ព្រាហ្មណ៍

www.budinst.gov.kh www.elibraryofcambodia.org

បុរោហិត និងមន្ត្រីធំម្នាក់ឈ្មោះ ស្រីវធិនៈ អង្គុយប្រណម្យយកដៃម្ខាងដាក់លើដើមទ្រូង បែរមុខឆ្ពោះទៅរកព្រះរាជា ដោយសេចក្តីគោរពកោតក្រែង ៗ នៅខាងក្រោម ក្បួនហែនៃព្រះអង្គមហេសី គង់លើអង្រឹងស្នែង ដែលមានពលបរិវារកាន់ សែហែហមហោមរោម យ៉ាងអធឹកអធម ៗ តទៅទៀត ពួកពលសេនាពាក់មួកក្បាលសត្វយាត្រាទ័ពចុះពីលើភ្នំ ដែលមានពួកមេទ័ពជិះដំរីបាំងក្លស់ព្រោងព្រាត ឯកងទ័ពថ្មើរជើងវិញ ហែហមដោយកងទ័ពសេះ មានព្រាហ្មណ៍បួនសក់រាយឈ្មោះ នាយហោរាយជិះលើអង្រឹងស្នែង និងមានពួកទាហានសែងជើងក្រានភ្លើងសក្តិសិទ្ធ ដើម្បីបូជាទេព្តា ក្បួនទាហានចំបាំង មានពួកផ្លុំត្រែដើរជួរមុខដូចដែលយើងឃើញសព្វថ្ងៃនេះដែរ ៗ

បន្ទាប់ពីនេះមក គេឃើញព្រះបាទសុរិយាវរ្ម័នទី ២ ទ្រង់គ្រឿងក្រោះជាព្រះអង្គប្រមុខនៃកងទ័ព គង់លើដំរីក្បាលពាក់មកុដចមប្រាសាទ បាំងក្លស់ ១៩ ជាន់ ព្រះហស្តកាន់ផ្គាក់ ៗ នៅខាងមុខ ផ្នែកខាងស្តាំក្បួនហែនៃកងទ័ពសៀម ដែលជាចំណុះជាតិខ្មែរ

www.budinst.gov.kh www.elibraryofcambodia.org

សៀតពាក់ប្លែក ៗ ខុសគេ ដោយសំពត់សំឡាយរំសាយ ក្បាលពាក់ស្វាបសត្វ ដូចពាហានដើរទឹក សណ្ឋានជាពួកព្រៃដ៏កាចសាហាវ ។

## រោងទងខាងត្បូង ផ្នែកខាងកើត

ផ្ទាំងចម្លាក់នៅផ្នែកនេះ ចែកជា ៣ ថ្នាក់ស្របតាមទ្រឹស្តីនៃព្រះពុទ្ធសាសនាគឺ: ១ ស្ថានទេវលោក, ២ ស្ថានមនុស្សលោក, ៣ ស្ថាននរក ដែលផ្ទាំងនេះ គេហៅថាផ្ទាំងនរក មានប្រវែង ៦០ ម៉ែត្រ ។

សេចក្តីអធិប្បាយតាមផ្ទាំងចម្លាក់ : ព្រះយមរាជជាម្ចាស់នៃត្រៃ-លោកមានព្រះហស្ត ១៨ គង់លើគោឧសភរាជ ហើយមានលេខាធិការផ្ទាល់ព្រះអង្គម្នាក់ឈ្មោះ ចិត្រគុប្ត: អង្គុយពីខាងមុខកំពុងវិនិច្ឆ័យទោសចំពោះសត្វដែលធ្វើអំពើអាក្រក់ ៗ តាមសិលាចារឹកប្រាប់ថា „យេកធម៌ជាធំ„ ។ ចាប់ពីត្រង់មក នៅខាងលើ មានផ្លូវទៅកាន់ស្ថានសួគ៌ចំនួន ៣៧ ជាន់ ដែលមានជាវិមានអណ្តែត ហើយពួកទេវតាហោះលេងកំសាន្តសប្បាយខ្សៀវខ្សារ ៗ តែផ្ទុយទៅវិញ នៅខាងក្រោម មានផ្លូវទៅកាន់ស្ថាននរក ដែលគេឃើញពួកសត្វនរកកំពុង

www.budinst.gov.kh www.elibraryofcambodia.org

រងទុក្ខទោសស្រែកថ្ងូរហើះ ដោយអំពើអាក្រក់ដែលខ្លួនបានធ្វើ ។ ស្ថាននរកនេះមាន ៣២ ជាន់ ។

គេឃើញសត្វនរកខ្លះ ត្រូវពស់នាគកាចចាប់ស៊ី ខ្លះត្រូវរមាស ខ្លា ខ្លែង ចចក ហែកជញ្ញែងខាំស៊ី ខ្លះត្រូវខ្នោះឃ្នាងគាបកណ្ដាល ខ្លះត្រូវក្របីវ័ជ ដំរីព្រោបសម្លាប់ ខ្លះត្រូវក្អែកត្មាតចំពុះដែកចឹកចំហែកលលាដ៍ក្បាល ខ្លះឡើងដើមរកាដែកដោយអំពើលបលួចសាហាយស្មន់ប្រពន្ធ ប្ដី កូនគេ ខ្លះត្រូវនាយនិរយបាលបោះដែកគោលភ្ជាន់ដៃជើងភ្ជាប់នឹងជញ្ជាំង ខ្លះទៀត ត្រូវនាយនិរយបាលយកដែកចុំនដើមភ្លោកចុកទំលុះពីក្បាលដល់គូថ ពីឆ្វេងទៅស្ដាំ ចាក់ធ្លាត់ខ្លួនគ្នាយ៉ាំងទារុណ ។ នៅចន្លោះកណ្ដាលផ្នែកខាងកើតបន្តិច មានរបាំងដោយរូបគ្រុឌជាច្រើន ដែលជានិមិត្តរូបនៃស្ថានមនុស្សលោក នៅជាកណ្ដាលនៃស្ថាននរក និងស្ថានទេវតា គេឃើញស្រីទេពអប្សរ បវរកញ្ញាហោះអណ្ដែតត្រសែតយ៉ាំងសប្បាយរីករាយ ។

នៅស្ថាននរកវិញ គេឃើញសុទ្ធតែអំពើបាបនៃពួកសត្វនរក

www.budinst.gov.kh www.elibraryofcambodia.org

ដែលនឹងទុក្ខទោសយ៉ាងទារុណ ។ នៅជិតនុ៎ះ មានអក្សរសិលាចារឹកខ្លី ៗ ចំនួន ៣៦ កន្លែង សម្រាប់ពន្យល់នូវការកាត់ទោសចំពោះពួកសត្វដែលបានធ្វើអំពើល្អនិងអាក្រក់ ។ អ្នកធ្វើល្អព្រះធម៌ឲ្យទៅកើតស្ថានសួគ៌ឬស្ថានមនុស្ស អ្នកធ្វើអាក្រក់ស្តេចយមរាជឲ្យចាប់ជើងទម្លាក់ចុះក្រោម ធោះបញ្ចូលក្នុងស្ថាននរក ។

## រោងទងខាងកើត ផ្នែកខាងត្បូង

នៅផ្ទាំងនេះ ផ្នែកខាងត្បូង : កងទ័ពខាងពួកអសុរកំពុងត្រៀមខ្លួនចាំមេទ័ព , ផ្នែកខាងជើង : កងទ័ពខាងពួកទេវតាកំពុងត្រៀមខ្លួនចាំមេទ័ពខ្លួនដែរ ដើម្បីចូលប្រយុទ្ធនឹងគ្នាក្នុងការទាញព្រ័ត្រយកជ័យជំនះ ។

នៅចំពាក់កណ្តាលផ្ទាំង ឆ្លាក់អំពីរឿងកូរទឹកសមុទ្រដែលមានចែកជា៣ថ្នាក់ : ថ្នាក់លើគេឃើញពួកទេវតា និង ទេពអប្សរហោះហើរលើអាកាស ដែលមានព្រះនាង លក្ខ្មី ហោះចំពីលើពាក់កណ្តាលខ្លួននាគ , ថ្នាក់កណ្តាលគេឃើញពួកទេវតា និង ពួកអសុរកំពុងប្រឡង

www.budinst.gov.kh www.elibraryofcambodia.org

ផែនបូទ្ធិគ្នាដោយយកនាគរាជឈ្មោះវាសុកិ មកធ្វើជាព្រ័ត្រ ថ្នាក់ទី ៣ គេឃើញមានត្រី អណ្តើក និងសត្វសមុទ្រជាច្រើន នៅថ្នាក់ក្រោមបំផុត គេឃើញតួនាគរាជឈ្មោះវាសុកិ ។

តាមរឿងនេះ សេចក្តីបញ្ជាក់ថា : ទេវតានិងអសុរចង់បានទឹកអម្រឹត ដែលជាទឹកផឹកទៅមិនចេះស្លាប់ ទើបបណ្តាលជាហេតុឲ្យនាំគ្នាកូរទឹកសមុទ្រ ដោយយកនាគរាជឈ្មោះវាសុកិ មកធ្វើជាព្រ័ត្រ យកភ្នំមន្ទរជាស្នូល ។ ពួកអសុរ ទាញខាងក្បាល ពួកទេវតាខាងកន្ទុយឈរលើភ្នំមន្ទរ ស្ថិតលើខ្នងអណ្តើក ដែលជាអវតារនៃព្រះនារាយណ៍ ។ ការកូរទឹកសមុទ្រនេះ ជាភ័យមួយយ៉ាងធំដល់សត្វសមុទ្រទាំងឡាយ ដូចជាត្រី, អណ្តើក, ក្តាម, មករ ជាដើមដែលមានខ្លួនដាច់ខ្ទេចខ្ទីស្លាប់យ៉ាងកកកុញ ហើយបានទៅកើតជាស្រីទេព-អប្សរបរិវារគញ្ញា ហោះហើរត្រៀបត្រាលើអាកាស ។ គេឃើញនាងលក្ខ្មី ដែលជានាងបញ្ចតណៈកល្យាណី កកើតពីការកូរទឹកសមុទ្រនេះដែរ ។ ការកូរទឹកសមុទ្រអស់រយៈវេលាជាង ១.០០០ ឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

ហើយពួកទេវតាត្រូវបានជ័យជំនះលើពួកអសុរ ដោយបានទឹកអម្រឹត យកមកប្រើប្រាស់ដើម្បីការពារសេចក្ដីស្លាប់ ។

នៅត្រង់ផ្នែកកណ្ដាលនៃខ្លួននាគពជ ព្រះនារាយណ៍បែងភាគជាមនុស្ស ចុះមកជួយយកអាសាពួកទេវតា ។ ពួកអសុរមានភ្នែកធំក្រឡោត ៗ ហើយពាក់ក្បាំងកំពូល រីឯពួកទេវតាពាក់មកុដកំពូលស្រួច ធ្វើទឹកមុខបែបភិតភ័យ ហើយមានជនខ្លួនទ្រេតទៅមុខបន្តិច ចំណែកឯស្ដេចស្វាឈ្មោះ ហនុមាន ឈរកាន់កន្ទុយនាគជាជំនួយដល់ពួកទេវតា ។ នៅផ្នែកក្រោមគេឃើញនាគពជឈ្មោះវសុកិដែលជាព្រំត្រសម្រាប់ទាញក្រូវទឹកសមុទ្រ ។ 50

## រោងទងខាងកើត ផ្នែកខាងជើង

ក្នុងខណៈដែលគេដើរកាត់តាមក្លោងទ្វារខាងកើតនោះ គេឃើញតាមជញ្ជាំងនូវសិលាចារឹកមួយផ្ទាំង ដែលមានមកតាំងពីសតវត្សទី ១៨ សិលាចារឹកនោះមានសេចក្ដីថា មានពៅហ្វាយខែត្រខ្មែរម្នាក់

www.budinst.gov.kh www.elibraryofcambodia.org

បានធ្វើបុណ្យក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានកសាងចេតិយថ្ម មួយ បញ្ចុះអដ្ឋិធាតុបុត្រភរិយា ប៉ុន្តែសព្វថ្ងៃនេះ ត្រូវវិនាសខូចខាតស្ទើរតែអស់ទៅហើយ ។

គពីទីនោះបន្តិចទៅ គេឃើញរូបចម្លាក់នៃកងទ័ពអសុរយាត្រាចេញទៅច្បាំង ព្រះនារាយណ៍ជិះលើគ្រុឌ បែរព្រះកគ្គទៅរកទិសទក្សិណ ព្រះឥសូរទ្រង់ត្រីសូល៍ ព្រះគណេស និងក្រឹស្ណៈដៃប្រណម្យ ហើយមានពួកទ័ពជិះសត្វចំឡែកៗជាច្រើន ។ ការរចនានៅកន្លែងនេះមិនសូវចំណានទេ ព្រោះមានសណ្ឋានគគ្រោតគគ្រាតជាខ្លាំង ។

## រោងទងខាងជើង ផ្នែកខាងកើត

នៅកន្លែងនេះ ក្បាច់រចនាក៏មិនសូវចំណានដែរ ។ ក្បាច់ចម្លាក់ទាំងនោះនិទានពីរឿងព្រេង ត្រង់ចំបាំងទេពតា និងអសុរៗ ព្រះនារាយណ៍មានព្រះកគ្គច្រើន ព្រះហស្ត ៨ ជិះលើគ្រុឌ មានកងទ័ពក្មេងដើរមុខ ផ្នែកកណ្ដាលជាទីសមរភូមិ មានក្មេងមួយគំនរធំឃាំងកងទ័ពទាំងសងខាង ក្មេងនេះគ្រុឌសំដែងឫទ្ធិយកទឹកទន្លេ

LIBRARY BUDDHIST INSTITUTE
www.budinst.gov.kh www.elibraryofcambodia.org

ហើយពួកទេវតាត្រូវបានជ័យជំនះលើពួកអសុរ ដោយបានទឹកអម្រឹតយកមកប្រើប្រាស់ដើម្បីការពារសេចក្តីស្លាប់ ។

នៅត្រង់ផ្នែកកណ្តាលនៃខ្លួននាគរាជ ព្រះនារាយណ៍បែងភាគជាមនុស្ស ចុះមកជួយយកអាសាពួកទេវតា ។ ពួកអសុរមានផ្នែកធំក្រឡេត ៗ ហើយពាក់ក្បាំងកំពូល រីឯពួកទេវតាពាក់មកុដកំពូលស្រួច ធ្វើទឹកមុខបែបភិតភ័យ ហើយមានដងខ្លួនទ្រេតទៅមុខបន្តិច បំណែកឯស្តេចស្វាឈ្មោះ ហនុមាន ឈរកាន់កន្ទុយនាគជាជំនួយដល់ពួកទេវតា ។ នៅផ្នែកក្រោមគេឃើញនាគរាជឈ្មោះវាសុកិដែលជាព្រ័ត្រសម្រាប់ទាញកូរទឹកសមុទ្រ ។

## រោងទងខាងកើត ផ្នែកខាងជើង

កន្លែងណាដែលគេដើរកាត់តាមក្លោងទ្វារខាងកើតនោះ គេឃើញតាមជញ្ជាំងនូវសិលាចារឹកមួយផ្ទាំង ដែលមានមកតាំងពីសតវត្សទី ១៨ សិលាចារឹកនោះមានសេចក្តីថា មានចៅហ្វាយខែត្រខ្មែរម្នាក់

www.budinst.gov.kh www.elibraryofcambodia.org

បានធ្វើបុណ្យក្នុងព្រះពុទ្ធសាសនា ព្រមទាំងបានកសាងចេតិយឥដ្ឋមួយ បញ្ចុះអដ្ឋិធាតុបុត្រភរិយា ប៉ុន្តែសព្វថ្ងៃនេះ ត្រូវវិនាសខូចខាតស្ទើរតែអស់ទៅហើយ ។

គពីទីនោះបន្តិចទៅ គេឃើញរូបចម្លាក់នៃគង់ទ័ពអសុរយាត្រាចេញទៅច្បាំង ព្រះនារាយណ៍ជិះលើគ្រុឌ បែរព្រះភក្ត្រទៅរកទិសទក្សិណ ព្រះឥសូរទ្រង់ត្រីសូល៍ ព្រះគណេស និងក្រឹស្ណៈដៃប្រណម្យ ហើយមានពួកទ័ពជិះសត្វចំឡែកៗជាច្រើន ។ ការរចនានៅកន្លែងនេះមិនសូវចំណានទេ ព្រោះមានសណ្ឋានគគ្រោតគគ្រាតជាខ្លាំង ។

## រោងទងខាងជើង ផ្នែកខាងកើត

នៅកន្លែងនេះ ក្បាច់រចនាក៏មិនសូវចំណានដែរ ។ ក្បាច់ចម្លាក់ទាំងនោះនិទានពីរឿងព្រេង ត្រង់ចំបាំងទេវតា និងអសុរៗ ព្រះនារាយណ៍មានព្រះភក្ត្រច្រើន ព្រះហស្ត ៨ ជិះលើគ្រុឌ មានគង់ទ័ពក្មេងដើរមុខ ផ្នែកកណ្ដាលជាទីសមរភូមិ មានក្មេងមួយគំនរធំឃាំងគង់ទ័ពទាំងសងខាង ក្មេងនេះគ្រុឌសំដែងឫទ្ធិយកទឹកទ្វេ

LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

គង្គាមកលត់ ហើយជូនគំនរក្អែនទេះទៅ ។ គេឃើញយកក្បាល ៦ ជិះលើមោស ឈរពាំងពីមុខគ្រុឌ ប្រុងប្រៀបទិនច្បាំងគ្នា ។ កងទ័ពព្រះក្រឹស្ណៈវាយលុកកងទ័ពស្តេចអសុរឈ្មោះ ពាណៈ ដើម្បីដណ្តើមយកជ័យជំនះ ។ គេឃើញក្រឹស្ណៈដៃ ៤ ជិះលើគ្រុឌ ។ តទៅទៀត គេឃើញក្រឹស្ណៈ ជិះលើរថទឹមដោយសីហៈ មានស្នំពីរនាក់ចូលលុកវាយស្តេចអសុរ ពាណៈ តបន្តិចទៅទៀត គេឃើញព្រះឥសូរ, នាងបារវតី, ឥសីកិន្នរ គណេសជាបុត្រ គង់លើភ្នំកៃលាស ហើយឃើញក្រឹស្ណៈក្បាលច្រើន មានជ័យជំនះលើអសុរឈ្មោះពាណៈ ចូលទៅអង្គុយលើដៃប្រណម្យព្រះឥសូរ ។ ព្រះឥសូរមានបន្ទូលថា: « អើក្រឹស្ណៈ បាឯងមានមហិទ្ធិឫទ្ធិខ្លាំងណាស់ នៅក្នុងលោកសន្និវាសនេះ ឥតមានអ្នកណាមួយហ៊ានប្រឡងឫទ្ធីជាមួយបាឯងទេ ។ ធ្វើម្តេចឥឡូវនេះ យើងបានជួយអសុរឈ្មោះ ពាណៈ ទៅហើយ សំដីយើងមិនឥតប្រយោជន៍ទេ» ។ ក្រឹស្ណៈឆ្លើយតបវិញដោយឈ្លាសវៃថា: "សូមឲ្យអសុរៈ ពាណៈ មានជ័យជំនះចុះ ខ្ញុំព្រះអង្គ

www.budinst.gov.kh www.elibraryofcambodia.org

មិនបង់បានប្រសើរជាងគេទេ ទ្រង់សព្វព្រះទ័យជួបម្តេច ទូលបង្គំសូមធ្វើតាមព្រះអង្គទាំងអស់ ព្រោះព្រះអង្គទ្រង់បានជួយស្រោចស្រង់ដល់គេហើយ ,, ។

## រោងទងខាងជើង ផ្នែកខាងលិច

នៅពេលនេះ ចម្លាក់រស់រវើក និងមានអំពីចំបាំងរវាងទេវតា ២១ អង្គ និង ពួកអសុរ ២១ រូប ដែលគេឃើញមេទ័ពធំ ៗ បញ្ចេញឫទ្ធិដឹកនាំកងទ័ពខ្លួន ។

លោក សេដែស បានអធិប្បាយថា ផ្ទាំងចម្លាក់នេះ ជារឿងចំបាំងក្នុងសាសនាព្រាហ្មណ៍ ( ព្រហ្មញ្ញសាសនា ) ដែលមានទេវតាម្នាក់ច្បាំងនឹងអសុរម្នាក់ គេសំគាល់បានដោយទេវតាពាក់មកុដ និង ក្បាំង ច្បាំងតតាំងគ្នាគួរឲ្យរំភើបញាប់ញ័រក្រៃលែង ។ នៅមុខគឺទេវតាឈ្មោះ កុវេរៈ ជាទេវតាសម្បូណ៌សប្បាយដោយទ្រព្យសម្បត្តិ ជិះលើស្វាយក្ស , ទេវតាឈ្មោះ ស្កន្ទៈ ដៃ ១២ មុខច្រើនជិះលើក្ងោក , ព្រះឥន្ទ្រាធិរាជ ជិះលើដំរី ត្លកវណ្ណ ភ្លុក ៤

ដែលមានប្រមោយចាប់ព្រោបបច្ចាមិត្រនៅក្នុងសមរភូមិ , ក្រឹស្នះ ដៃ ៤ ជិះលើគ្រុឌ , តទៅទៀត គេឃើញក្រុងយក្សក្បាលច្រើនដៃច្រើន កាន់ដាវត្រីជាវង្វង់ចក្រ , ទេពតាឈ្មោះ យមៈ គង់លើគោ , ព្រះព្រហ្ម គង់លើហង្ស , ព្រះសូរ្យៈ មានរស្មីភ្លឺចិញ្ចាចគង់រាជរថ ដែលមានគ្រុឌពាជបក្សជានាយសារថី , ព្រះឥសូរ កំពុងយឹតកៅទណ្ឌ ធ្នូសរបាញ់សត្រូវ ។ នៅចុងភេងចង គេឃើញព្រះវរុណៈ ទេពតាខាងទឹកភ្លៀងជិះលើនាគក្បាល៥, ក្រៅពីនោះ គេឃើញទេពតា អគ្គធំ ៗ ខ្លះទៀត ជិះរាជរថទឹមសេះ ឬទឹមសីហៈ ចូលច្បាំងគ្នា ដោយឥតខ្លាចសេចក្តីស្លាប់ ។ គេឃើញពលអសុរត្រូវសរដាច់ ក្បាលដួលដេកពាសពេញលើប្រឹថពីគួរឲ្យអាណោចអាធម្មក្រៃលែង ។

## មណ្ឌបមុមខាងជើង ឆៀងខាងលិច

នៅមណ្ឌបនេះ ការតុបតែងលំអមិនខុសគ្នាពីមណ្ឌបមុមខាង ត្បូង ឆៀងខាងលិចឡើយ ព្រោះមានរឿងបុរាណដូច ៗ គ្នា ដែល បែកជាច្រើនសង្កាត់គឺ :

www.budinst.gov.kh www.elibraryofcambodia.org

១.– នៅលើច្រកទ្វារខាងកើត ផ្ទៃត្រង់ព្រះរាមនិងព្រះលក្ស្មណ៍ កំពុងចចារចងស្ពានមេត្រីនឹងសុគ្រីព ដើម្បីប្រមូលយកគងទ័ពទៅច្បាំងនឹងយក្សក្រុងលង្កា ។

២.– សាខាខាងកើត លើមាត់បង្អួចផ្ទាំងខាងជើង ព្រះនារាយណ៍ ផ្ទំលើនាគរាជ “ អានន្ទ ” ដែលមានផ្កាឈូកដុះចេញពីព្រះនាភី ( ផ្ចិត ) ព្រះអង្គជាយាទ្រង់កាន់ព្រះបាទ ។ ផ្នែកខាងលើពពួកស្រីទេពអប្សរ ហោះហើរលើអាកាសបាចសាចបុប្ផាទិព្វថ្វាយជោគជ័យចំពោះព្រះអង្គ ផ្នែកខាងក្រោមមានរូបចម្លាក់ជាច្រើន ដែលគេឃើញមានព្រះអាទិទេព ៩ អង្គ គឺ: សូរ្យៈ ជិះរាជរថ, កុវេរៈ ជិះស្វាយក្ស, ព្រះព្រហ្ម ជិះហង្ស, ស្កន្ទៈជិះក្ងោក, ទេពតាមួយអង្គដែលគេមិនស្គាល់ព្រះនាមជិះសេះ, ព្រះឥន្ទ្រ គង់លើដំរីឰរាវណ្ណក ៤, យមៈជិះគោ និងព្រះឥសូរ គង់លើគោណន្ទិន, ព្រះអាទិទេពមួយអង្គទៀតគង់លើសីហៈ ។

៣.– សាខាខាងកើត ផ្ទាំងខាងត្បូង ក្រឹស្ណៈទ្រង់សួយភ្នំ

www.budinst.gov.kh www.elibraryofcambodia.org

មណិបព៌ត: នៅផ្ទាំងនេះ គេឃើញក្រឹស្ណៈដៃ ៤ ជិះគ្រុឌជាមួយមហេសី សត្យភាមា ។ ព្រះអង្គមានជ័យជំនះលើពួកសត្រូវហើយទ្រង់នាំពួកពលសេនាដឹកជញ្ជូនគ្រឿងកស្តុការផ្សេងៗមានដាវ លំពែងជាដើម ដែលបានរឹបយកពីគូបំបាំងនាំចូលទៅកាន់ព្រះនគរវិញដោយសេចក្ដីសុខសាន្តត្រាណ ។

៤.— សាខាខាងជើង ជញ្ជាំងខាងកើត លើមាត់បង្អួច : ការសន្ទនាអំពីកិច្ចការផ្សេងៗ នៅក្នុងព្រះបរមរាជវាំង នៅខាងក្រោមមានមនុស្សពីរនាក់ដេកផ្កាប់មុខ ហើយមានស្រីស្នំជាច្រើននៅក្នុងវាំង ។

៥.— លើទ្វារខាងជើង : គ្រង់ព្រះរាមនិងព្រះលក្ស្មណ៍ ថ្វីនសរបាញ់តទល់នឹងយក្សឈ្មោះ ពិរាធ ជាបងរាពណ៍ដែលលបលួចយកនាង សីតា បញ្ជិះលើស្មាហោះចេញទៅ ។

៦.— សាខាខាងជើង មាត់បង្អួចខាងលិច : គ្រង់នាង សីតា យាងចូលគំនរភ្លើងកំពុងឆេះពេញក្រមុំ ដើម្បីសំដែងសេចក្ដីបរិសុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

ស្មោះត្រង់ចំពោះព្រះរាជស្វាមី ក្រោយពេលដែលត្រឡប់មកពីនគរលង្កាវិញ ។

នៅកន្លែងនេះមានការខូចខាតអស់ជាច្រើនអន្លើ ដោយត្រូវទឹកភ្លៀងហូរច្រោះ ប៉ុន្តែគេឃើញនៅគង់វង់ល្អខ្លះ ដូចជារូបព្រះរាមព្រះលក្ស្មណ៍ សុគ្រីព ហនុមាន ឯរូបក្រៅពីនោះ ដូចជារូបនាងសីតានិងគំនរភ្លើងជាដើម ត្រូវវិនាសខូចអស់ជាងពាក់កណ្ដាល ។

៧.- សាខាខាងលិច ផ្ទាំងខាងជើង លើមាត់បង្អួច : ថែងពីព្រះរាមច្បាំងឈ្នះក្រុងរាពណ៍ គង់លើរាជរថ បុស្បក ក្នុងក្រុងលង្កា រួចយាងត្រឡប់មកនគរ អយុធ្យាវិញ ដែលមានគងទ័ពស្វាយាំងកកកុញបញ្ចេញទឹកមុខរីករាយសប្បាយយ៉ាងក្រៃលែង ។

៨.- លើទ្វារខាងលិច : គ្រង់ព្រះរាមនិងព្រះលក្ស្មណ៍ចងសម្ពន្ធមិត្តជាមួយ វិភិសនៈ ( ពិភេក្សណ៍ ) ជាបងរាពណ៍នៅកណ្ដាលចំណោមពួកពលស្វា ដែលគេឃើញពិភេក្សណ៍អង្គុយប្រណម្យព្រះរាមនិងព្រះលក្ស្មណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

៩.- សាខាខាងលើ ជញ្ជាំងខាងត្បូង លើមាត់បង្អួច : ថ្ងៃងពីនាង សីតា នៅក្រុងលង្កា ព្រះរាមប្រើ ហនុមាន ទៅមើល នាង សីតា នៅនគរយក្ស ដែលឃើញសុទ្ធតែនាងយក្ខិនីមានមុខ ផ្សេង ៗ គ្នា នៅថែរក្សាគ្រប់គ្រងព្រះនាងក្នុងការសោកទុក្ខបាន រួចគេឃើញនាង សីតា ទ្រង់ប្រទានចិញ្ចៀនព្រះទម្រង់ដល់ហនុមាន ឲ្យយកទៅថ្វាយព្រះរាមជាព្រះរាជស្វាមី ដើម្បីជាសក្ខីភាពនៃសេចក្ដី ស្មោះត្រង់របស់ព្រះនាងចំពោះព្រះអង្គ ដែលទ្រង់បានប្រើរាជបំរើ ហនុមាន មកយកពត៌មាន ។

១០.- សាខាខាងត្បូង ជញ្ជាំងខាងលិច ពីលើមាត់បង្អួច : រឿងត្រង់នេះគេមិនដឹងថាជារឿងអ្វីឡើយ ប៉ុន្តែឃើញស្រីស្នំ ទ្រង់ទទួលដង្វាយពីនាងទេពធីតា ដែលនាំគ្នាដើរដង្ហែជម្រើ ចូលមក ។

១១.- លើមាត់ទ្វារខាងត្បូង : ព្រះរាមនិងព្រះលក្ស្មណ៍ចូល ប្រយុទ្ធជាមួយកុម្ភកណ្ណយក្ស គឺមហាយក្សដែលមានខ្លួនធំ ឥតក្បាល

www.budinst.gov.kh www.elibraryofcambodia.org

តែមានមុខនៅត្រង់ដើមទ្រូង ។

១២.- សាខាខាងត្បូង ផ្ចាំងខាងកើត : ត្រង់ព្រះរាមប្រឡងធ្នូសរដើម្បីឲ្យបានព្រះនាងសីតា ជាស្នំ ។ គេឃើញព្រះនាងសីតាទ្រង់មកុដកំពូល ៣ គង់នៅលើគ្រែ ហើយមានរាជបរិពារនៅហែហមផង ។ នៅខាងក្រោម មានពួកព្រះរាជបុត្រក្សត្រច្រើនកកកុញចូលទៅប្រឡងធ្នូជ័យ ប៉ុន្តែជ័យជំនះត្រូវបានទៅព្រះរាម ។

## រោងទងខាងលិច ផ្នែកខាងជើង

នៅរោងទងនេះ មានក្បាច់ចម្លាក់យ៉ាងល្អស្រស់បំព្រង ញឹកស្មើៗគ្នា ហើយឆ្លាក់ជ្រៅៗផង សម្បូរតែរូបយក្សនិងស្វាកំលេចក្រឡោតឡើងហើយគ្រវីលោងស្រិល បញ្ចេញទឹកមុខកញ្ចៀញដាក់គ្នាមានឫកពាជាអ្នកក្លាហានក្នុងសង្គ្រាម ។

ថែងត្រង់ព្រះរាមលើកកងទ័ពស្វាវាយលុកចូលក្រុងលង្កា ដែលគេឃើញកងទ័ពយក្សនៅបែកខាងជើងដើរជាក្បួន ។ មានមេទ័ពខ្លះកាន់ក្រឹះមុខពីរ ខ្លះកាន់ដុំមូល ឬដំបង និងខ្លះទៀតដែលខេ ។

www.budinst.gov.kh www.elibraryofcambodia.org

បំណែកកងពលស្វាវិញ មានខ្លះកាន់មែកឈើ ខ្លះកាន់ដាវលំពែងជាដើម ដើរចូលលុកក្រញីខាំសត្រូវ ។ នៅខាងមុខព្រះរាម មានកងទ័ពក្មេង ដែលក្នុងក្រុមនេះ មានពលស្វាយកស្មា, ជង្គង់, ច្រមុះ, ថ្ពាស, ក្បាល ឬ គូថទល់ទ្រូងទង់ជ័យដើរយ៉ាងសន្ធា ។

នៅផ្នែកខាងត្បូង មេទ័ពយក្សកំពុងបញ្ជាកងពលយក្សឲ្យចូលធ្វើសង្គ្រាមជាមួយកងពលស្វា ដែលមានមេទ័ពធំៗ ជិះរថទឹមសត្វផ្សេងៗ មានសេះជាដើម, ដៃកាន់លំពែង, ព្រះខាន់, ធ្នូសរ, ចំណែកឯពលយក្សប្រដាប់ដោយខែល, លំពែង, ដាវ, ដំបង, ធ្នូសរគ្រប់ដៃ ។

នៅកណ្ដាលផ្ទាំងចំឡាក់ គេឃើញព្រះរាមទ្រង់ធ្នូសរជិះលើស្វាហនុមាន ដែលកាន់ដុំមូលមួយនៅដៃហើយក្រញែញខ្លួន ច្បាំងតទល់នឹងក្រុងរាពណ៍ទសមុខដៃម្ភៃ ជិះលើរាជរថទឹមសីហៈ ។ ឈរនៅជិតពីក្រោយព្រះរាម គឺព្រះលក្ស្មណ៍ដែលទ្រង់ធ្នូសរ និងវិភិសនៈ (ពិភេក្សណ៍) ដៃកាន់ព្រះខាន់ ។ តទៅមុខទៀត មានមេទ័ពស្វាជំកាច

www.budinst.gov.kh www.elibraryofcambodia.org

សាហាវពីររូប គឺក្រុងទីលពាជ ដែលទំចំពោកជើងលើក្បាលសីហៈ ចាប់ត្រវែងសត្រូវពោកលើផែនដី និងអន្លក់ បុត្រក្រុងពាលី ដែល ចាប់ជកក្នុកដីរមានកំពូលត្រីសូល៍ ។ នៅផ្ដាំងរូបមួយទៀតគេ ឃើញមេទ័ពស្វាចាប់ឃ្នួរជើងក្រោយសត្វសីហៈពីរធំ ១ សម្រុកក្បាល ចុះក្រោម ។

ការពិពណ៌នាអំពីរូបចម្លាក់រឿងរាមកេរ្តិ៍នៅកន្លែងនេះ មិនបាន សព្វគ្រប់ទេ ព្រោះមានការញឹកញាប់ក្រៃស្មុគស្មាញខ្លាំងណាស់ ប៉ុន្តែការចតា រូបចម្លាក់តាំងនេះ ជាទីស្ញើចសរសើរដល់សិល្បករសម័យបច្ចុប្បន្ន នេះពន់ពេកណាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទតាព្រហ្មគិល

សាងនៅចុងសតវត្សទី ១២ ដោយស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧ បច្ចាមរណៈព្រះនាម មហាបរមសុគតបទៈ ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា ប្រាសាទនេះបានទទួលការថែរក្សាដោយក្រសួងអភិរក្សអង្គរ តាំងពី គ.ស. ១៩១៩ រហូតមកដល់សព្វថ្ងៃនេះ ។

នៅចម្ងាយ ៣០០ ម៉ែត្រ ពីខាងជើងអ័ក្ស ខាងលិចក្លោងទ្វារប្រាសាទអង្គរវត្ត គេប្រទះឃើញគុហាមួយតូចសាងពីថ្មកក់ ស្ថិតនៅខាងឆ្វេងដៃត្រង់បង្គោលគីឡូម៉ែត្រ ។ ប៉ុន្តែសព្វថ្ងៃនេះអន្តរាយអស់ជាច្រើនអន្លើ ។ ដោយសារការរុករកកាលពី គ.ស. ១៩២៨ គេបានរកឃើញសិលាចារឹកមួយ ដែលមានចុះព្រះរាជបញ្ញាផ្សេង ៗ នៃព្រះបាទ ជ័យវរ្ម័នទី ៧ ដែលធ្លាក់ជាប់នៅនឹងមន្ទីរព្យាបាលរោគ ។ តាមសិលាចារឹកនៅប្រាសាទតាព្រហ្មប្រាប់ថា ប្រាសាទនេះជាធម្មមន្ទីរសម្រាប់ស្វាធ្យាយន៍ធម៌ផ្នែកខាងព្រះពុទ្ធសាសនា ។

បើតាមរឿងព្រេងវិញ លោកសេដែស បាននិទានថា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទតាព្រហ្មកិលនេះ មានការទាក់ទងទៅនឹងរឿងពញាក្រែក ដែលជាជនពិការសរសៃ: ធ្វើដំណើរចេញទៅណាមកណាពុំបាន លុះគ្រាតែព្រះឥន្ទ្រប្រទានសេះមួយព្រមទាំងគ្រឿងអម្ពរណ៍, លុះដល់ក្រោយមក ទើបពញាក្រែកយកគ្រឿងអម្ពរណ៍មកស្លៀកពាក់ហើយ ឡើងជិះសេះហោះចេញបាត់ទៅ ។

នៅប្រាសាទនេះ គេប្រទះឃើញរូបព្រះពោធិសត្វ អវលោ-កេស្វរៈ ដែលជាអ្នកជួយព្យាបាលរោគសត្វលោក ។ ការធ្វើដំណើរចូលទៅ ត្រូវដើរតាមគោបុរៈមួយតូចសាងពីថ្មភក់ ទើបចូលដល់តួប្រាសាទ ដែលស្ថិតនៅជ្រុងប្រែកបដោយថ្នាក់តូចៗ ៣ ទៀតរួបជាប់គ្នាតាមកំពូលមុខខាងជើងនិងខាងកើត ។ តួគុហាបែរមុខទៅខាងកើត ប្រកបដោយទ្វារបញ្ឆោត ៣ និងបល្ល័ង្កមួយដែលមានក្បាច់ជាច្រើន ហើយនិងមានប្រឡាយបង្ហូរទឹកមួយ នៅតាមប្រហោងប្រាសាទទិសខាងជើង ។

ការរចនាប្រាសាទនេះ មិនសូវមានការផ្ចិតផ្ចង់ប៉ុន្មានទេ ប៉ុន្តែ

www.budinst.gov.kh www.elibraryofcambodia.org

មានទ្រង់ទ្រាយដូចប្រាសាទបាយ័នដែរ ព្រោះក្បាច់ចម្លាក់មានសភាព គោង ៗ និងមានឆ្លាក់ជារូបទេវតានៅតាមសសរជ្រុងប្រាសាទ ៗ នៅសសរមាត់ទ្វារចូល គេឃើញក្បាច់របនាយ៉ាងល្អផើត ហាក់ដូចជាកម្រាលព្រំបៀម ៗ ក្បាច់ចម្លាក់និមួយៗ មានឆ្លាក់ជារូបមនុស្សម្នាក់តាមទម្រង់ធម្មតា ហាក់ដូចជាមានជីវិតរស់រវើកនៅឡើយ ៗ

## ប្រាសាទបក្សីចាំក្រុង

សាងសង់ គ.ស. ៩៤៧ ដោយស្នាព្រះហស្តព្រះបាទរាជេន្ទ្រវរ្ម័ន បច្ឆាមរណៈ ព្រះនាមសិវលោក ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា (ថ្វាយព្រះនារាយណ៍) ប្រាសាទនេះបានទទួលការថែរក្សាអំពីក្រសួងអភិរក្សអង្គរ តាំងពី គ.ស. ១៩១៩ រហូតមកដល់សព្វថ្ងៃនេះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

នៅចម្ងាយ ១៥០ ម៉ែត្រ ពីជណ្ដើរបុរាណតាមអ័ក្សខាងកើត កំពែងខាង នៅឆ្វេងផ្លូវ គេនឹងប្រទះឃើញប្រាសាទតូចនេះលេចឡើងកណ្ដាលព្រៃឈើស្រោង មានថ្នាក់កាំជណ្ដើរស្ថាបនាដោយថ្មបាយក្រៀមនិងឥដ្ឋពណ៌ក្រហម ដែលជាសម្ភារៈម្យ៉ាងគេតែងប្រើប្រាស់ក្នុងជំនាន់សតវត្សទី ១០ ។

ប្រាសាទនេះ មានកំពែងឥដ្ឋព័ទ្ធជុំវិញដែលត្រូវវិនាសខូចខាតអស់ទៅហើយ នៅសល់តែស្នាកស្នាមគោបុរៈមួយសាងពីថ្មភក់ត្រង់ផ្នែកខាងកើតប៉ុណ្ណោះ ។ តួប្រាសាទបែកជាពីរថ្នាក់ : ថ្នាក់ក្រោមជារាង ៤ ជ្រុង ក្នុងមួយជ្រុង ១ ប្រវែង ២៣ ម៉ែត្រ ជ្រុងថ្នាក់លើប្រវែង ១៥ ម៉ែត្រ កំពស់ ១៣ ម៉ែត្រ ស្ថាបនាឡើងដោយថ្មបាយក្រៀម មានជណ្ដើរ ៤ នៅគ្រប់ទិសទាំង ៤ រចនាតាមសម័យនិយមនិងតាមប្រពៃណីខ្មែរ ។ ជណ្ដើរទាំងអស់នេះ មានតែជណ្ដើរ ៣ ទេ ដែលមានទម្រង់ល្អដាច់គេ ប៉ុន្តែគ្មានដំកល់រូបចម្លាក់អ្វីនៅលើក្បាលជណ្ដើរទេ ។ ឯជណ្ដើរមួយទៀត ដែល

www.budinst.gov.kh www.elibraryofcambodia.org

សាងភ្ជាប់ទីនគ្រឹះប្រាសាទនោះ មានផ្ទាក់ជាក្បាច់ត្របកឈូកគួរជាទីមនោរម្យក្រៃពេក ។

បើឡើងទស្សនាប្រាសាទនេះ សូមប្រុងប្រយ័ត្នបន្តិច ព្រោះកាំជណ្ដើរញឹកពេក ហើយរបិលរលស់ជាច្រើនអន្លើណាស់ទៅហើយ ។

គូហាសាងដោយថ្ម តែគ្មានប្រើកំបោរបូកបាយអដើម្បីភ្ជាប់មុខដែលគេមើលឃើញជាខ្សែធ្នារៗនោះទេ គេដាក់បន្ទុបលើផ្ទៃគ្រឹះទុកឲ្យឃើញតែតែបន្តិចៗ ។ គុហានេះមួយជ្រុងៗប្រវែង ៨ ម៉ែត្រ សាងបែរមុខទៅខាងកើត ហើយមានទ្វារបញ្ឆោត ៣ ដែលមានសសរទ្រនិងធ្នឹមសាងពីថ្មភក់ ព្រមទាំងមានផ្ទាក់ក្បាច់ជាកង់គោមៗដូចបណ្ដូលផ្កា ។ ជាពិសេសទៅទៀត ក្បាច់ដែលនៅលើធ្នឹមទទឹងទ្វារទិសខាងកើត មានផ្ទាក់ជារូបគណេសូរៈ មានប្រមោយវែង ដូចជារូបដែលគេឃើញនៅប្រាសាទមេបុណ្យទិសបូព៌ាដែរ ។ នៅចំកណ្ដាល

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបក្សីចាំក្រុង

មើលចំពីខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទឹមខទីងទ្វារនេះមានឆ្លាក់រូបព្រះឥន្ទ្រជិះលើដំរីក្បាល ៣ ព្រមទាំងរូបមនុស្សតូចៗនៅគមផង ។

នៅខាងក្រៅមានឆ្លាក់ជាក្បាច់ក្កីផ្កាផ្សេងៗ ព្រមទាំងរូបទេវតាដែលមានលាបថ្នាំខ្លះៗផង ដើម្បីកុំឲ្យបាត់សឹកក្បាច់ ។ នៅក្នុងប្រាសាទគេបានដាក់ដីបំពេញជំរៅ ១ ម៉ែត្រ ហើយមានព្រះពុទ្ធរូបបរិនិព្វានមួយអង្គធំនៅប្រែបទឹងជញ្ជាំង ព្រះពុទ្ធរូបបរិនិព្វានអង្គនេះ គេសាងនៅពេលក្រោយទេ ។

សិលោចារឹកនៅតាមជើងសសរក្លោងទ្វារ រៀបរាប់អំពីរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ព្រមទាំងអធិប្បាយបញ្ជាក់អំពីស្ថាន- 68
ភាពនៃប្រាសាទនេះក្នុង គ.ស. ៩៤៧ ទៀត ។ មានរូបសំណាកព្រះនារាយណ៍មួយ ដែលមានបិទមាសហើយសមរមតាមភាពប្រាសាទក្នុងជំនាន់នោះណាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទភ្នំបាខែង

សាងរាង គ.ស. ៨៩០ ដោយស្នាព្រះហស្តព្រះបាទយសោវរ្ម័ន ទី ១ បច្ចាមរណៈ " បរមសិវលោក " ឧទ្ទិសដល់ព្រហ្មញ្ញសាសនា ថ្វាយព្រះឥសូរ ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ចាប់តាំងពី គ.ស. ១៩១៩ រហូតមកដល់សព្វថ្ងៃនេះ ។

នៅចម្ងាយ ១៣០០ ម៉ែត្រ ពីខាងជើងក្លោងទ្វារអ័ក្សខាងលិចនៃប្រាសាទអង្គរវត្ត ហើយនៅពីខាងត្បូងក្លោងទ្វារប្រាសាទអង្គរធំចំនួន ៤០០ ម៉ែត្រ ។ នៅពីខាងឆ្វេងដៃ គេឃើញប្រឡាយទឹកមួយធំ និងភ្នំមួយតូចកំពស់ ៦០ ម៉ែត្រ មានព្រៃឈើដុះពាសពេញ នេះគឺជាភ្នំបាខែង ដែលជាទីតាំងនៃប្រាសាទដំបូងមួយ ។ ប្រាសាទនេះជាមជ្ឈមណ្ឌលនៃទីក្រុងមួយឈ្មោះថា " យសោធរបុរៈ " ដែលមានរាង ៤ ជ្រុងស្មើ គឺមួយជ្រុង ៗ ប្រវែង ៤ គីឡូម៉ែត្រ ។ បើធ្វើដំណើរតាមផ្លូវធំមក

www.budinst.gov.kh www.elibraryofcambodia.org

សៀមរាប គេនឹងប្រទះឃើញព្រំប្រទល់ទីក្រុងនេះ នៅត្រង់ដីទួល ដែលមានចម្ងាយ៦០០ម៉ែត្រ ពីស្រះបាកុរណីអង្គរវត្តខាងត្បូង ។

គេបានបោះបង់ចោលយសោធរបុរៈក្នុងរវាង គ.ស. ៨៨៩ ប៉ុន្តែទីក្រុងនេះនៅតែជាទីក្រុងដំបូងបង្អស់នៃអង្គរ ។ ដើម្បីនឹងរក្សាកេរ្តិ៍ដំណែលចាស់ឲ្យដូចជាទីក្រុង "ហរិហរាល័យ" ដែលកសាងដោយព្រះបិតាព្រះអង្គនៅលើទីវាលមួយ ក្នុងស្រុកសូទ្រនិគម "រលួស" នោះ ព្រះបាទយសោវរ្ម័ន ទី១ ទ្រង់សាងប្រាសាទក្នុងផ្ទៃដែនឲ្យមានឈ្មោះថា ប្រាសាទមហេន្ទ្របព៌ត ជានិមិត្តរូបក្នុងព្រះសុមេរុពជ ដើម្បីបូជាចំពោះទេវតាដែលមានសក្តិធំៗ ហើយ 70
យកស្ទឹងសៀមរាបធ្វើជាទន្លេ ។ ដោយការនៅជាប់ស្រយាលពីស្ទឹងសៀមរាបដូច្នេះហើយ ទើបទ្រង់សាងទីក្រុងថ្មីនៅពីខាងលិចស្ទឹងវិញ ។

ការសំខាន់នៃប្រាសាទបាគង ដែលស្ថិតនៅក្នុងស្រុកសូទ្រនិគម "រលួស" នោះក៏មានគំនិតគាតប្រហែលគ្នានឹងប្រាសាទ

www.budinst.gov.kh www.elibraryofcambodia.org

ភ្នំបាខែងដែរ ព្រោះមានទ្រង់ទ្រាយយ៉ាងល្អឯក បើមើលពីចំហៀង ទៅ គេនឹងឃើញគ្រប់ផ្នែកទាំងអស់សុទ្ធសឹងជាកន្លែងថ្លៃថ្នូរសម នឹងស្ថានភាពទាំងមូល ។ ព្រោះទីនេះជាអាសនៈរបស់ព្រះអាទិ- ទេពមួយព្រះអង្គព្រះនាម ទេវេសៈ ហើយនិងយោនព្រះអង្គម្ចាស់ ក្សត្រីនៅចំកណ្ដាលក្រុងយសោធរបុរៈ ។ តាមសិលាចារឹកប្រាប់ថា វត្ថុនេះជាព្រះរូបមួយ ដែលគេគោរពបូជាយ៉ាងក្រៃលែងនៅក្នុងព្រះ រាជាណាចក្រ ។ ការសាងរូបនេះទុកជាអនុស្សាវរីយ៍មួយសំដៅតាម លក្ខណៈប្រាសាទ ដំបូងគេបានដំកល់ទុកក្នុងគុហាដែលសាងពី ថ្មកក់មានក្បាច់របនារាងដូចជាមកុដគ្របពីលើតួប្រាសាទ ឲ្យបាន លំអឆើតឆាយស្រស់បំព្រងគួរឲ្យចាប់អារម្មណ៍យ៉ាងក្រៃលែង ។

ព្រឹកព្រហាម ឬ ល្ងាច ជាពេលដែលត្រូវឡើងមើលប្រាសាទ ភ្នំបាខែង ។ គេអាចឡើងតាមផ្លូវចំពីមុខ ឬតាមផ្លូវដំរីមួយនៅពី ឆ្វេងដៃដែលពួកទេសចរ តែងជួលដំរីជិះឡើងលេងកំសាន្ត ។ ពីលើខ្នងភ្នំទៅ គេអាចមើលឃើញកំពូលភ្នំពីរដូចគ្នាប្រកបដោយ

ប្រាសាទដែលព្រះបាទយសោវរ្ម័នទី១ បានកសាងគឺ: ប្រាសាទភ្នំក្រោមនាទិសទក្សិណក្បែរបឹងទន្លេសាប និងប្រាសាទភ្នំបូកនាទិសឧត្តរនៅឆ្ងាយពីភ្នំគូលែន ដែលមើលទៅឃើញខ្ពស់ៗ មិនតែប៉ុណ្ណោះនៅទិសបស្ចិម គេនឹងឃើញទឹកបារាយណ៍ល្ហល្ហប និងព្រៃឈើក្រាស់ ព្រមទាំងភាពធើតធាយពណ្ណរាយនៃប្រាសាទអង្គរវត្ត ដែលបញ្ចេញរស្មីភ្លឺផ្លេកៗ ហាក់ដូចជាទឹកមាស ឬជាដុំពេជ្រដែលគេដាក់ពាយលើផែនដី ក្នុងពេលដែលព្រះអាទិត្យជិតអស្តង្គតលិចចូលក្នុងភ្នំព្រះសុមេរុ ។

លោក ហ្គូល្លូបឺរ បានអធិប្បាយថា តាមការពិនិត្យ p. លក្ខណៈផ្សេងៗ គេអាចប្រៀបប្រដូចភ្នំនេះទៅនឹងភ្នំធំមួយ ។ តាមសិលាចារឹកពោលថា នេះជាទីក្រុងដំបូងបំផុតដែលកើតក្នុងសតវត្សទី ៩ ក្នុងបរិវេណអង្គរ ។ នៅជើងភ្នំបាខែងគេបានរកឃើញកំពែងមួយបណ្ដោយ ៦៥០ ម៉ែត្រ ពីកើតទៅលិច ទទឹងប្រវែង ៤៤០ ម៉ែត្រ ពីជើងទៅត្បូង ប្រកបដោយ

www.budinst.gov.kh www.elibraryofcambodia.org

គោបុរៈមួយនៅក្បែរជើងភ្នំខាងកើត ត្រង់ចន្លោះផ្លូវនិងជើងភ្នំ ។ ស្លាកស្នាមដ៏ច្បាស់ៗនេះ គេនៅតែងប្រទះឃើញនៅតាមអ័ក្សដែលជាទីតាំងនៃគុហាតូចៗ ដែលមានកាំជណ្ដើរដូចជានៅតាមជណ្ដើរធំទិសខាងកើតដែរ ។

វិចិត្រកម្មទាំងឡាយនៃព្រះបាទយសោវរ្ម័ន ទី ១ នេះ បានបង្ហាញឲ្យដឹងនូវសភាពខ្ពស់ខ្ពាយយ៉ាងខ្លាំងពុំមានល្ហែ តាមភាពនៃការរៀបចំប្រាសាទ ។ ដោយសារអ្នកបច្ចេកទេសយ៉ាងចំណានៗ ឥឡូវនេះ ភាពនៃប្រាសាទក៏បានស្រស់បំព្រោងខ្លះឡើងវិញ ។ ភ្នំនេះសម្បូណ៌ដោយប្រាសាទ ដែលមានគុហាតូចៗជាច្រើនលើកលែងតែកន្លែងខ្លះ ដែលមានភាពរឹងប៉ឹងមិនបាច់រៀបចំផ្ទុសផុលឡើងវិញដូចជាផ្ទៃគ្រឹះនឹងស៊ុម ដែលមានឆ្លាក់ជារូបទេវតានៅតាមសសរទ្រូងប្រាសាទហើយនិងមានសសរមួយតូចៗជាច្រើន ។ ប្រាសាទទាំងនោះពុំសូវមានល្វែងបន្ទប់ធំទូលាយ ហើយប្រកបដោយក្បាច់របនាក់ពុំកក់ពុកសមតាមភាពនៃប្រាសាទ ដែលជា

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនាំឲ្យផ្ទុយស្រឡះពីក្បួនខ្នាតនិងផ្ទាំងបញ្ឈរ ។ ក្នុងការគាស់កកាយរុះមើលនៅតាមផ្ទឹមទិងទ្វារ ដែលមានកិនភាគដូចជាផ្ទឹមទទឹងទ្វារទាំងឡាយនោះ គេបានឃើញសម្រស់យ៉ាងល្អសម ដូចក្នុំគូលែនដែរ ព្រោះមានក្បាច់ចេនាយ៉ាងត្រចះត្រចង់ប្រមាក់ចាក់ស្រេះគ្នាយ៉ាងរឹងប៉ឹង ដូចជាក្បាច់នៅប្រាសាទបាគងនិងប្រាសាទព្រះគោដែរ ។ ក្បាច់ទាំងឡាយមានការគោរពទៅកភាពល្អិតឆ្នារហើយស្តើងៗ ស្របទៅតាមសម័យនិយម ដូចជាក្បាច់លើបាយអដែលបូកៈលំវិមានស្តូបនាអំពីឥដ្ឋ និងក្បាច់ឈើឆ្លាក់ ដើម្បីជាព្រះកិត្តិយសដល់ព្រះពជា ។

## ពិពណ៌នា

រូបគោពីរ ដែលឆ្លាក់ដាក់នៅលើជម្រាលជើងភ្នំត្រង់ផ្លូវឡើងទៅខ្ទង់ពប មានសភាពហាក់ដូចជារស់រវើក នេះជាស្នាដៃសិល្បករខ្មែរយើងក្នុងសម័យនោះ ។ នៅលើកំពូលភ្នំមានកុដិព្រះសង្ឃត្រុឱត្រោម ដោយហេតុស្ថាបនាយូរណាស់មកហើយ ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទភ្នំបាខែង

( មើលពីខាងកើត )

www.budinst.gov.kh www.elibraryofcambodia.org

នៅខាងស្តាំដៃ មានផ្ទះតូចៗ សង់លើសសរថ្មកក់ តពីនោះទៅ មានព្រះវិហារតូចមួយ ដែលមានរូបសំណាកព្រះពុទ្ធបាទ ដែលគេបានសាងឡើងនៅជំនាន់ក្រោយ ហើយត្រូវធ្វើដំណើរចូលទៅកាន់ប្រាសាទ តាមគោបុរៈមួយក្បែរកំពែងថ្មបាយក្រៀម ។ នៅសងខាងអ័ក្សដែលចូលទៅ គេនឹងឃើញអគារពីរ ដែលមានកិនភាគជាបណ្ណាល័យ ប្រកបដោយប្រហោងចតុរង្គញាយ ជាប្រយោជន៍ដល់ពន្លឺនិងខ្យល់ចេញចូលបានស្រួល ។ អគារពីរនោះមានទ្វារតូចនៅទិសខាងកើត ។

តួប្រាសាទតាំងមូលនេះលេចឡើង ព្រមទាំងកាំជណ្ដើរទាំង ៥ ថ្នាក់ តម្រួតលើគ្នានៅគ្រប់មុខប្រាសាទទាំង ៤ ទិស តាំងពីក្រោមរហូតដល់ផ្ទៃលើមានកំពស់ពីដីទៅ ៤៧ ម៉ែត្រ ឯដំបូលប្រាសាទកណ្ដាលមានកំពស់ ១៣ ម៉ែត្រ ។ អមសងខាងមានឆ្លាក់ជារូបគោ ឈរចំអើតជើបជើយស្ទើតយ៉ាងសង្ហាគ្រប់ក្បាលជណ្ដើរ មានទាំងតួគុហាតូចៗ គ្រប់ៗថ្នាក់ នៃជ្រុង

ប្រាសាទទាំង ៤ ទិស ។ ផ្ទៃរាបស្មើខាងលើសាងភ្ជាប់ទៅតួគុហាតូច ៗ ដែលសព្វថ្ងៃខូចខាតអស់គ្មានសល់ ។ នៅខាងក្រោម តាមជុំវិញតួប្រាសាទធំគេឃើញមានប្រាង្គតូច ៗ សាងពីឥដ្ឋ ។ ប្រាង្គតូចៗ ទាំងនេះមានចំនួន ៣៦ តួ ស្ថិតនៅជាប់ពីគ្នា ។

ប្រាង្គតូច ៗ ដែលសាងដោយឥដ្ឋនោះ គេតែងប្រទះឃើញច្រើនពីខាងកើត តែជួនកាលមានប្រាង្គខ្លះនៅបន្ទាប់ពីខាងក្រោយទ្វារខាងលិច ។ លើកលែងតែគុហាតូច ៗ ដែលនៅតាមអ័ក្ស ដែលតែងមានមួយគូៗ ស្ថិតនៅលើផ្ទៃគ្រឹះជាប់គ្នា ។ គុហាតូចៗ ទាំងអស់មានចំនួន ៤៤ តួ ។ មានគុហាជាច្រើនទៀត ដែលត្រូវបាក់បែកអស់ដោយសារការសាងពុំទាន់បានរួចស្រួលបួល ។

នៅក្នុងដៃគេសង្កេតឃើញបល្ល័ង្កធំៗពីរ ដែលបានរកឃើញក្នុងពេលត្រួសត្រាយកាប់ឆ្ការ ។ គេបានដឹកលំទុកបល្ល័ង្កនេះនៅមុខគុហាតូចៗទាំងនោះ ព្រោះជាបល្ល័ង្កមានក្បាច់រចនាយ៉ាងល្អវិចិត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទភ្នំបាក់ខែង ជាប្រាសាទមួយដែលនៅក្នុងផ្ទៃគ្រឹះ គេពុំបានយកដីមកចាក់បំពេញដូចជាប្រាសាទទាំងឡាយទេ គឺគេបានកាត់យកពីភ្នំឲ្យរាបស្មើទើបគេរៀបក្រាលថ្មភក់ពីលើ ដោយហេតុនេះ ទើបគេឃើញកន្ទួនដែលថ្មរបៀលធ្លាក់នៅជ្រុងទិសឦសាន ហើយនិងជ្រុងទិសអគ្នេយ៍ ។ នៅតាមមុខប្រាសាទធំៗ មានកាំជណ្តើរសម្រាប់ចុះឡើង ជណ្តើរនេះមានទទឹង ៤ ម៉ែត្រ ហើយគុហាតូច ៗ នៅបាំងពីមុខ ។ គុហាតូច ៗ ទាំងឡាយដែលសាងពីថ្មភក់នៅលើមណ្ឌលប្រាសាទធំ មានចំនួន ៦០ តួ សុទ្ធតែជាគុហាដែលមានទ្វារបែរទៅទិសខាងកើត ឯមុខខាងលិចពុំមានសាងរូបៗ គុហាតូច ៗ ទាំងនេះសាងបណ្តើតតាមគែមគ្រប់ថ្នាក់មណ្ឌលគ្រឹះធំ ។ ប្រាង្គទាំងនេះមានថ្នាក់មួយធំរាងដូចមកុដ ហើយមានទ្រង់ទ្រាយដូចជាគុហាដែលមានថ្នាក់ ៤ ជាប់ ៗ គ្នានោះដែរ ។

នៅតាមស័ក្យប្រាសាទដែលលាតសន្ធឹងពីជើងទៅត្បូងមានភាពបែបបន្តិចទៅខាងលិច ព្រោះទីនេះជាទីតាំងនៃជណ្តើរថ្នាក់ទី ៥

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានផ្លូវនៅតាមគែមដែលមានទទឹងខុសគ្នា គឺប្រវែងពី ៤ ម៉ែត្រ ទៅ ១៦ ម៉ែត្រ ជាកន្លែងដែលសម្រាប់រៀបចំក្បួនហែឲ្យបានស្រួល ។

នៅតាមជញ្ជាំងទល់ច្រក មានឆ្លាក់ជាក្បាច់តាមផ្ទៃកំពស់ ១ ម៉ែត្រ ៦០ ជញ្ជាំងនេះស្ថិតនៅពីលើផ្ទៃគ្រឹះ ដែលមានប្រវែងមួយជ្រុង ៗ ៣១ ម៉ែត្រ ។

ដោយការទំលុះខ្លួនថែរក្សា នៅពេលនោះ ទើបនៅមូលដ្ឋានទាំងអស់ មានការទើសទែងដោយផ្ទាំងថ្មធំ ៗ ដែលព្រះសង្ឃបានយកទៅតម្រៀបជុំវិញតាមផ្នែកខាងក្រោម ដើម្បីជានិមិត្តរូបយ៉ាងសមរម្យដល់ព្រះពុទ្ធរូប ដែលមានព្រះកាយនៅផ្តេកក្នុងទីនោះ ។ គេតែងមានការជឿជាក់យ៉ាងខ្លាំងចំពោះការរីកចំរើននៃការកសាង ដែលគេបានប្រទះឃើញនៅក្រោមពើងថ្មតាមសំណង់តូច ៗ ដែលស្ថិតនៅជាផ្លូវគ្នាប្រហែះទីងទៀនប្រាសាទ ។ គូប្រាសាទកណ្តាលខាងលើ សាងនៅលើថ្នាក់ខ្ពស់បង្អស់ ប្រាសាទ

www.budinst.gov.kh www.elibraryofcambodia.org

នេះមួយជ្រុង ១ ប្រវែង ៨ ម៉ែត្រ ហើយនៅតាមជ្រុងថ្នាក់ខាងលើ ដែលមានគុហាតូច ៗ ៤ ទៀត មួយជ្រុង ១ ប្រវែង ៦ ម៉ែត្រ សាងប្របទីលបម្រាក់ជញ្ជាំងគ្រឹះ ។ ប្រាសាទភ្នំបាខែងទាំងមូល មានចំនួនគុហា ១០៨ តួ ប៉ុន្តែស្ថិតនៅជាប់ ៗ ពីគ្នា ។

តួប្រាសាទធំកណ្តាលមានសភាពប្លែកគេ តែសមតាមទំនង ដែលសាងថ្វាយព្រះអាទិទេព ហើយជាប្រាសាទមានមុខ ៤ បែរទៅគ្រប់ទិសទាំង ៤ ។ នៅតាមផ្ទៃកបខាងក្រោម ប្រាសាទនេះគេឃើញរូបគោឧសុភរាជ ៣ ។ គោឧសុភរាជនេះ ជាព្រះទីនាំងរបស់ព្រះឥសូរ ដែលកំពុងតែបញ្ចេញមហិទ្ធិឫទ្ធិ យ៉ាងអស្ចារ្យ ក្នុងពេលដែលយាងត្រួតមើលទិសទាំង ៤ ក្នុងទ្វីបលោក ។ នៅខាងក្នុងមានអណ្តូងមួយជំរៅ ២ ម៉ែត្រ អណ្តូងនេះសម្រាប់កំនទប់ថ្មកុំឲ្យរមៀលធ្លាក់ទៅក្រៅបាន ។ មានស្តូបមួយសាងពីថ្មភក់កង ៤ ជ្រុងទ្រវែង បណ្តោយ ១ ម៉ែត្រ ៤០ ទទឹង ០ ម៉ែត្រ ៨០ កំពស់ ០ ម៉ែត្រ ៧២ មានជាប់ចុះជា

www.budinst.gov.kh www.elibraryofcambodia.org

ប្រហែលដែលលោក សឺដែស បានយល់ឃើញថា ជាមូលដ្ឋានមានទ្រង់ទ្រាយដូចជាចេតិយ សម្រាប់បញ្ចុះព្រះអដ្ឋិធាតុព្រះរាជាដែលព្រះសុវណ្ណគតទៅ ដើម្បីទុកឲ្យគេធ្វើសក្ការបូជា ។ នៅពីខាងមុខ ទិសខាងកើត គេឃើញមានគុហាតូចៗសាងលើថ្មផ្លូវក្រាលថ្មកក់ ដែលមានស្នាកស្នាមសសរនៅសល់ខ្លះមានពន្លឺក្លឺរលើបរលោង ។ មានគុហាដំកល់លិង្គ ៤ ទៀត ប្រកបដោយបាទដ្ឋានរាងមូល ។ គុហានីមួយៗមានទ្វារ ២ នៅឈមមុខគ្នា ។

ឯវិចិត្រកម្មដែលគេបានឃើញនៅតាមគុហាទាំងនេះសរឲ្យដឹងថា សុទ្ធតែសាងឡើងប្រកបដោយគុណសម្បត្តិ ព្រមទាំងគុណវិបត្តិយ៉ាងច្បាស់តាមអធ្វើ គឺគេតែងប្រទះឃើញកិច្ចការអស់នេះនៅក្បែររូបចម្លាក់ទេវតាធំៗដ៏មានមហិទ្ធិឫទ្ធិយ៉ាងខ្លាំងក្លា ដែលឆ្លាក់ជាប់ ៗ គ្នាតាមសសរទ្រុងជិតទ្វារចេញចូល មិនតែប៉ុណ្ណោះ មានឆ្លាក់ជារូបស្រីទេពអប្សរជាលំអទៀតផង ។ តាមការវិនិច្ឆ័យនៅលើផ្ទាំងចម្លាក់ដែលមានរូបគំនូរតូច ៗ និងចំរឹងជើងទៀតខ្ពស់ ៗ ដែលមានរូបគំនូរតូច ៗ ដែរ នោះជាមណើយភាពមួយយ៉ាងគ្រប់

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់សមទៅតាមសេចក្ដីត្រូវការ ។ ឯចំណែកតាមប្រហោង វិញគេសង្កេតឃើញក្បាច់ក្បាំងសឹងមានពង ៤ ជ្រុងស្មើ ព្រមទាំង មានរូបចម្លាក់ផ្សេងៗមិនសូវល្អទៅលាយឡំគ្នា ។ រូបចម្លាក់ទាំងនេះ មានភាពរឹងប៉ឹងទៅបានគឺដោយសារមានរូប មករ នៅខប់ទ្រហូត ដល់កន្ទួងរាងកោងដូចផ្នួ ។ ខ្លប្រហោងទាំងនេះមានរាង ដូចជាពុងឡូតកាំភ្លើងធំដែលបង្ហាំដែក ហើយមានរូបចម្លាក់មនុស្ស ទឹងក្បាច់រចនាផ្សេង ៗ ទៀតដ៏មានរំយោល ដើម្បីជាគ្រឿងលំអ សម្រាប់បូជាចំពោះក្បាលមនុស្សដែលមានកតញ្ញុតាត ៗ ទ្រង់ព្រាយ ទាំងឡាយនេះ តែងមាននៅក្នុងក្បាច់រចនាខ្មែរក្នុងជំនាន់នោះ ។

សិលាចារឹកមួយផ្ទាំងដែលដំកល់នៅលើបល្ល័ង្កខាងកើតទ្វារ ទិសខាងជើងគ្រឹះមណ្ឌលប្រាសាទថ្នាក់ក្រោម មានចារឹករៀបរាប់ អំពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ ពី គ.ស. ៩៦៨ រហូតមកដល់ គ.ស. ១០០១ មិនតែប៉ុណ្ណោះមានចារឹកពីការកសាងនៃព្រះបាទ យសោវរ្ម័ន ទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

# អង្គរធំ

## បាយ័នអង្គរធំ

ប្រាសាទនេះ សាងនៅចុងសតវត្សទី ១២ ដោយព្រះបាទជ័យវរ្ម័នទី ៧ បញ្ចាមរណៈព្រះនាម មហាបរមសុគតបទៈ ឧទ្ទិសចំពោះព្រះពុទ្ធសាសនា "មហាយាន" បានទទួលការត្រួសត្រាយពី គ.ស. ១៩១១ ដល់ គ.ស. ១៩១៣ ហើយបានទទួលការសាងឡើងវិញនូវប្រាសាទកណ្តាលក្នុងឆ្នាំ ១៩៣៣ និងជួសជុលវង់ទានមុខតាំងពីឆ្នាំ ១៩៣៩ ។

នៅក្នុងចំណោមប្រាសាទទាំងអស់ មានតែប្រាសាទបាយ័នទេ ដែលមានការពិបាកយល់ច្រើនជាងគេខាងបុរាណវត្ថុវិទ្យា ។ ក្នុងប្រវត្តិរបស់ប្រាសាទ ការវិវាទគ្នាបានកើតមានឡើងមកដល់ឆ្នាំ១៩២៣ ចំពោះការដាក់កាលបរិច្ឆេទតាមសិលាចារឹកនៃស្រុកកោះធំ ចំពោះ "ប្រាសាទកណ្តាល" ។ ប្រាសាទនេះមានការតាក់តែងនៅទីន

www.budinst.gov.kh www.elibraryofcambodia.org

ក្បាខែង តែមិនមែនតាក់តែងទៅនឹងបាយ័នទេ ព្រោះបាយ័ននេះ មិនមែនជា "វិហារ-ភ្នំ" នៃ "យសោធរបុរៈ" ទេ គឺជាប្រាសាទមួយនៃរាជធានីនៃស្ដេច ជ័យវរ្ម័នទី៧ នៅចុងសតវត្សទី១២ ។ បាយ័នបានក្លាយទៅជាវិហារយ៉ាងពិតប្រាកដ នៅក្នុងក្រុងអង្គរធំ ដែលសាងឡើងដោយព្រះបាទ ជ័យវរ្ម័នទី៧ ក្រោយពេលដែលពួកចាមបានលុកលុយ ។

គេពុំសូវមានការងឿងឆ្ងល់ពីសភាពដែលជួយគ្នាក្នុងការរៀបចំវិហារដ៏សំខាន់នេះ ដែលត្រូវទុកៈព្រោមបណ្ឌលខាងក្រៅនឹងស្ពានគ្រោះជុំវិញទៀត នឹងប្រឡាយបង្ហូរទឹកតាមច្រាំដែលនាគនៅចាំ ។

## បណ្ឌលខាងក្រៅ

នៅតាមមុខមានប្រាសាទតូច ១ បួន ប្រាសាទនេះប្រគបទៅដោយរូបសំណាក ហើយមានសិលាចារឹកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧ នៃជយគិរី បានៈគូវលុបក្បាច់នៅខាងលើដោយនៃបារាំង ទីងផ្ទែករូ បានពួលដល់កុជ្ឈមាគ ។ លោកសឹដែស

www.budinst.gov.kh www.elibraryofcambodia.org

បានពន្យល់ថា យើងមិនអាចយល់បាននូវវត្ថុនិងគំនូសនោះបានទេ លុះត្រាតែមានសំដីវោហារខ្លះទៀតជាភាសាខ្មែរ ទើបយើងអាចពន្យល់បាន ។ ប្រាសាទនិងស្នាមភ្លោះនៅអង្គរធំហាក់ដូចជាភ្នំ និងមហាសាគរដែលព័ទ្ធជុំវិញដីយើង ៕

នៅប្រាសាទផ្សេងនិមួយ ៗ មានរបៀបធ្វើដូចជានៅអង្គរធំដែរ ហើយសន់ដូចជាទីក្រុងនៃពោធិសត្វលោកេស្វរៈ ដែលប្រកបដោយវិហារមួយធ្វើពីថ្មបាយក្រៀមមានកនជាជើងក្អែក ជម្រន់ទៅខាងលិចមានពីរជាន់ដោយសន្ធឹត ហើយឆ្លាក់លំអដោយក្បាច់ត្របកឈូក នៅលើខ្លួននាគទាំងបួន ។ ជញ្ជាំងខាងក្រៅលំអដោយទេវតាជិះលើយានជំនិះ និងនៅតាមបង្អួចបញ្ឆោតមានជើងទៀនចិចចាំងដោយរនាំង ។ ខាងលិចមានរូបសំណាកនៅលើបែបផែនជាពួនផ្សេងស្មើ និងមានមុខទាំងបួនបើកចំហដោយរន្ធន់គោលដូចជានៅខឿន ។ នៅជញ្ជាំងនិមួយ ៗ នៃមណ្ឌលមានទ្វារមួយផ្សេងខាងលិច ។

ការទស្សនាប្រាសាទផ្សេងនិងមុមខាងទិសនីរតី គេអាចធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ដំណើរដោយជើងឬដោយសេះទៅផ្លូវប្រាំង តាមផ្លូវជើងដោយ ដើរក្នុងព្រៃដែលមានចម្ងាយ ៣ គីឡូម៉ែត្រ ដែលគេឃើញមានក្ដី ស្រែរហូតដល់ទ្វារខាងត្បូង ។ គេអាចត្រឡប់មកវិញតាមទ្វារ ខាងកើត ក្រោយពេលដែលយើងបានដើរជុំវិញក្នុង ១/៤ នៃទីក្រុង ។ គេឃើញនៅកន្លែងខ្លះមានគ្រឿងដំណែលបុរាណធ្វើ ពីថ្មបាយក្រៀមដែលបានរកឃើញដោយលោក គ្លោឡូបឺវ ដែល នៅសព្វថ្ងៃនេះ ជាប់ដាក់ទុកនៅទីងមណ្ឌលស្នាមគ្រោះនៅអង្គរធំ ក្នុងសតវត្សទី ១១ ។

## ទ្វារនៅអង្គរធំ

នៅទីក្រុងប្រជាជនបានបង្កើតគ្រឿងសម្ភារៈ ពុំសូវមាន ប្រយោជន៍នឹងនៅតាមកន្លែងដែលបាំងជិត គេដាក់វត្ថុពុំសូវសំខាន់ ទេ នៅចំកណ្ដាលបាយ័នគេចែកទីក្រុងនេះជា ៤ សង្កាត់ ដោយ មានផ្លូវជើងបួននៅជិតមាត់ស្នាមគ្រោះ ។ ផ្លូវទី ៥ ដែលជាផ្លូវសំ-ខាន់ជាងគេបានកាត់ដំរង់ទៅក្នុងវាំង នៅផ្នែកខាងលិច ។

ទ្វារទី ៥ នៃប្រាសាទតាក់ទងទៅទីងក្រុងថ ។ មកពីខាង

www.budinst.gov.kh www.elibraryofcambodia.org



ខ្លោងទ្វារអង្គរធំ

មើលចំពីខាងក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ក្រៅត្រូវជួនកាត់ប្រឡាយទឹក ហើយត្រូវជួនផ្លូវមួយដែលយើងបាន
រៀបរាប់ពីមុខមកគឺផ្លូវដែលចាក់ដីបង្កើតបានជាស្ពាន ដែលសព្វ
ថ្ងៃនេះនៅជ្រុងខាងជើងនៅតាមកាត់នៃបណ្ដោយ បន្តមកទៀត
មានវិជ្ជាសាស្ត្រសិក្សាពីការហូរទឹកជាថ្មី ៗ នៅជ្រុងពីរទៀត
តាមអ្នកប្រវត្តិសាស្ត្រចិនម្នាក់ឈ្មោះចៅតាក្វាន់ បានប្រាប់យើងថា
មានបុ ៥៤ ប្រភេទដូចគ្នានឹងបុនោះ ដែលធំសម្បើមនឹងគួរឲ្យខ្លាច ៗ
បង្កាន់ដៃធ្វើសុទ្ធតែបុទ្ធាក់ជាកងពស់ក្បាលប្រាំពីរ ៗ បុ ៥៤
ប្រភេទនេះ មាននៅតាមដៃពស់និងបានការពារយ៉ាងហ្មត់ចត់
ប្រយោជន៍កុំឲ្យរលុប ៗ បើតាមគតិមានលោក ស៊ីដេស និង
លោក ប៉ូលមូស យើងឃើញថាបង្កាន់ដៃនាគនេះមានកងជានាគ
ជានិមិត្តរូបនៃឥន្ទធនូ ដែលមាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌា
គឺជាការរួបរួមគ្នារវាងមនុស្សនឹងទេវតា ដែលបង្កើតបានជារូបកង
ឡើងនៅក្នុងផ្ទាំង ៗ បើយើងក្រឡេកមើលទៅទៀត យើង
នឹងឃើញថាមានពីរផ្លូវ គឺមានពួកទេវតាមួយផ្លូវ និង ពួកអសុរា
"យក្ស" មួយផ្លូវទៀត អ្នកបង្កើតលោកបានឲ្យដំបូន្មានថា ឲ្យទាំ

www.budinst.gov.kh www.elibraryofcambodia.org

គ្នាកូរទឹកសមុទ្រ “ សមុទ្រទឹកដោះ ” ដែលធ្វើឡើងដោយសាមគ្គីភាពរវាងពួកទេវតានិងពួកអសុរា ដើម្បីបម្រាញ់យកទឹកអម្រឹតដែលជាទឹកពូកែសក្តិសិទ្ធិមិនចេះចាស់ស្លាប់ មានរូបភាពនៃការកូរទឹកសមុទ្រ ធ្វើនៅក្នុងស្នាមត្រោះជាជំនួសមណ្ឌលនៃសមុទ្រជាពិសេសទៅទៀត នៅតាមទ្វារមានជំបន់ចម្លាក់ ដើម្បីដំណាងនូវភ្នំគឺជាការប្រយុទ្ធប្រាំងនូវមន្តអាគមដែលសម្រាប់ការពារប្រទេសឲ្យបានសុខសប្បាយនិងឲ្យមានកិត្តិយសល្បីសុសសាយ ។

ហេតុមកដល់សព្វថ្ងៃនេះ គេឃើញនៅតែគ្រឿងឥស្សរិយយសរបស់ពួកអសុរានៅតាមទ្វារជ័យ “ ទ្វារដែលបែរមុខទៅខាងលិចចូលទៅកាន់ស្តូប ” ហើយគ្រឿងឥស្សរិយយសរបស់ពួកអសុរានៅទ្វារខាងជើង ដែលមុខម្យ៉ាងផ្ទុយពីមុខរបស់ពួកទេវតាដែលស្រស់ញញឹម ។

ទ្វារទាំង ៥ មានគំនូរភាគដូច ១ គ្នា និងមានភាពជាបន្ទុកក្នុងការរក្សាទុក ។ ក្នុងចំណោមទ្វារទាំងអស់ ទ្វារដែលមានភាពគ្រប់គ្រាន់ គឺទ្វារដែលនៅខាងមុខបែរទៅខាងលិចនៃទ្វារខ្មោច

www.budinst.gov.kh www.elibraryofcambodia.org

ផ្លូវដែលមានភាពល្អគន់វង់ គឺទ្វារខាងកើតដែលមានទំនងជាមុខខាងក្បៀសាននៃទ្វារជ័យ ។

វិសាលភាពនៃធក " ៣ ម៉ែត្រ និង ៧ ម៉ែត្រ កំពស់ " ឃើញមានភាពប្លែកដោយរំលេច ដោយផ្ទឹមទ្វារបន្ទួចនិងក្បាច់ក្បាំងជាដើម ក្បាច់ទាំងនេះបានធ្លាក់ជាប់ទៅនឹងទ្វារឈើ ដែលមានសន្ទឹកទ្វារពីរដាក់លើក្ដៅសម្រាប់វិលចុះឡើងបាន និងមានប្រហោងដែលអាចមើលឃើញនៅផ្ចាំងទ្វារនេះ ហាក់ដូចជាមានទុកសម្រាប់បិទបើក ។

នៅកំពស់ពី ២០ ម៉ែត្រមក ទ្វារទាំងអស់នេះធ្វើពីថ្មបាយក្រៀម បានបង្កើតជាសភាពមួយមាន ៣ ជុំយ៉ាងគ្រន់ ដែលសំខាន់ជាងគេ គឺទ្វារដែលមានមុខពីរផ្ទុយគ្នានៅអមទ្វារតូចពីរទៀត ដែលមានមុខតែមួយសម្រាប់ចូល ដែលតាក់តែងទៅខាងក្នុងដោយភាពខ្ជួន បង្កើតជាបន្ទប់ៗ តាក់តែងទៅនឹងទ្វារមួយ ៗ ដោយកំពែងខាងក្នុងពីរយ៉ាងដដែល ។ ទាំងអស់នេះមានភាពជាអន្ទូបនិយកម្ម

www.budinst.gov.kh www.elibraryofcambodia.org

ដែលព័ទ្ធជុំវិញមុខចាំងបួននៃបាយ័ន គឺជាឥទ្ធានុភាពនៃរាំងស្ដេច ដែលបង្ហាញនូវទិសទាំង ៤ ។

## បាយ័ន

១៨០០ ម៉ែត្រពីផ្លូវខាងស្ដាំបែកពីទ្វារខាងត្បូងនៃអង្គរធំ យើងដើរជុំវិញប្រាសាទនេះតាមផ្លូវស្ដាំ តាមផ្លូវចូលខាងកើតតាមមុំកំពែង ដែលលយជាជ្រុងចេញក្រៅ យើងនឹងឃើញសុទ្ធតែតោនឹងនាគមានជើងទ្រ ផ្លូវនេះតាក់ទងទៅនឹងផ្លូវចូលដែលសំខាន់ជាងគេ ហើយគេនឹងសង្កេតឃើញមានគម្រុបគ្រប់ស្នា ដែលមាននៅក្នុងរយៈកាលក្រោយសម័យ មានចំនួនជាគ្រុឌចាប់នាគជាចំណី នឹងនៅជ្រុងម្ខាងទៀតមានកេរ្តិ៍ដំណែលបុរាណចាស់ៗ នៅមាត់ស្រះ ។

នៅពេលព្រឹកប្រាសាទបាយ័នបញ្ចេញនូវរស្មីយ៉ាងស្រស់ គួរឲ្យចាប់អារម្មណ៍ ។ គេមិនអាចលះបង់បាយ័ននៅពេលយប់ដែលចាំងដោយពន្លឺព្រះចន្ទ្រ ផ្ទុះច្រេះហើយបានជារស្មីនៃម្លប់ឈើចាំង-ព្រាយបានផាត់ជាពណ៌នៅតាមថ្ម ឲ្យទៅជាពណ៌បែកគន់យ៉ាង

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបាយ័ន

មើលបំពីខាងជើង

www.budinst.gov.kh www.elibraryofcambodia.org

ស្រស់បំព្រង ។ មុខទីមួយ ៗ គួរឲ្យចាប់អារម្មណ៍យ៉ាងរំភើប ដូចជារបាំ ឬ តន្ត្រី បណ្តាលឲ្យមានគំនិតចូលទៅរកសន្តិភាពក្នុងលទ្ធិព្រះពុទ្ធសាសនា ។

នៅសម័យពីដើមលោក ពៀឡូទី បានប្រាប់យើងថា បាយ័នមានសុទ្ធតែដើមឈើមានបន្លានិងវល្លិ ដែលដុះច្រវាក់គ្នា បើចង់ធ្វើដំណើរទាល់តែរកផ្លូវដើរដោយដំបង ។ នៅក្នុងព្រៃដ៏ពោរ-ពេញទៅដោយដើមឈើ ដុះយ៉ាងបង្អៀតគ្នានៅគ្រប់កន្លែង មានដើមព្រៃធំ ៗ ជាច្រើន ដែលដុះបំផ្លាញរុក្ខជាតិឯទៀតរហូតដល់លើកំពូលប្រាសាទ ។

ដូចជាលោក កុំម៉ៃ ដែលបានត្រួសត្រាយ យើងទាំងអស់គ្នាជាអ្នកទីមួយ ដែលមានសេចក្តីសោយស្តាយធម្មជាតិដែលពេញទៅដោយបុប្ផានុភាពនិងប្រិយភាព ៗ មួយខែ ៗ ឬ មួយថ្ងៃ ៗ មានថ្មជាច្រើនដុំធ្លាក់បុះមក ។ ភាពខូចខ្ទេចខ្ទីនៃប្រាសាទនេះ នឹងកើតមានឡើងបើទុកឲ្យយូរទៅ ដូច្នេះត្រូវតែត្រួសត្រាយយ៉ាងឆាប់រហ័ស ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបាយ័ន

មើលទៅលើថ្នាក់ទី ៣ កំពូលខាងជើងជ្រុងខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

ប្រមាណប្រហែលជាមួយសតវត្សយ៉ាងតិច បាយ័នមានភាពផ្ទុយពីអង្គរវត្ត ។ ប្រាសាទអង្គរវត្តស្ថិតនៅក្នុងកំពែងច្រើនជាន់ បង្កើតឲ្យមានជាបែបផែនយ៉ាងទូលាយ មានខ្យល់ចេញចូលយ៉ាងស្រួល និងមានភាពស្រឡះខាងស្ថាបត្យកម្មដែលប្រកបដោយភាពឆើតឆាយនៅជុំវិញនិងនៅរោងទង ៗ ចំណែកឯបាយ័នវិញ ស្ថិតនៅក្នុងមណ្ឌលរាង ៤ ជ្រុងទ្រវែង មាន ១៤០ ម៉ែត្រ ទទឹង និងបណ្តោយ ១៦០ ម៉ែត្រ នៃកំពែងទី ៣ គឺ "រោងទងក្បាច់ចម្លាក់" ធ្វើឲ្យយើងចាប់អារម្មណ៍ថាស្ថិតនៅក្នុងមណ្ឌលមួយផងទៀត ។ មានវិសាលវិហារខ្លះទៀត សង់នៅកន្លែងខាងវិហារមណ្ឌលកណ្តាល បានកប់បញ្ចូលទៅខាងក្នុងនៃរោងទងទី ២ ដែលមាន ៧០ ម៉ែត្រ ទទឹងនិង ៨០ ម៉ែត្រ ។

នៅឆ្ងាយបន្តិចមក មានបន្ទាត់ជើងមេឃរុញច្រាននៅក្រោយមណ្ឌលខាងផ្នែកក្រោម មិនគ្រាន់តែមានគំនរថ្មប៉ុណ្ណោះទេ មានភាពច្របូកច្របល់ ម្យ៉ាងទៀតដែលមានបលនាគួរឲ្យក្តៅក្រហាយផល់លើមេឃនៅគ្រប់ទីកន្លែង គេឃើញជុំថ្មនៅតាមបន្ទាត់ពុះប្លុក

www.budinst.gov.kh www.elibraryofcambodia.org

នៅផ្នែកខាងមុខ  នៅវង់ ៥ ខាងមុខមានសភាពបែបផែនខុស ៗ គ្នា បានផ្តល់នូវការទាក់អារម្មណ៍ជាខ្លាំង ។

នៅលើដំបូលខាងលើ មានសភាពស្ងប់ស្ងាត់ គ្មានការរន្ធត់ ដោយដុំថ្មខាងមុខ គេមិនអាចមើលឃើញទៅទស្សនីយភាពយ៉ាងច្របូកច្របល់ទាំងអស់ទេ  បើសិនជាដើរកំសាន្តពីកន្លែងមួយទៅមួយនៃមុខទាំង ២០៨  ដែលនៅឆ្ងាយពីវិសាលភាពនិងកន្លែងនៃស្ថាបនិក  គេនឹងកោតស្ញប់ស្ញែងនូវរូបសំណាកដែលមិនអាចដឹងបានជាមុន ។ បន្តិចម្តង ៗ ភាពភ្ញាក់ផ្អើលក៏បានស្រួលឡើងវិញ ហើយគេបានឃើញវង់មណ្ឌល  មានភាពមែនទែនបែកជាសង្កាត់យ៉ាងសមរម្យជាក់ជាពួកជាក្រុមតាមកន្លែង ។ ចំណែកគ្រឹះស្ថានពីឥដ្ឋគេមិនរាប់បញ្ចូលផងទេ គេសង់គ្រាន់តែជានិមិត្តរូបតែប៉ុណ្ណោះ ។

បាយ័នជាស្នាដៃមួយនៃអ្នកកសាង  ដែលមានប្រពៃណីនៅក្នុងលោកយើងនេះ  ដែលគេនិយមពីគ្រឿងអាថ៌កំបាំង  និងចិត្តជាធំជួបជាស្តេចជ័យវរ្ម័នទី ៧  ដែលជាស្តេចនិយមនូវព្រះពុទ្ធសាសនា ។  ព្រះភក្ត្រទាំង ៤ នៃស្តេចបានក្រឡេកមើលទៅ

www.budinst.gov.kh  www.elibraryofcambodia.org

គ្រប់ទិសទាំង ៤ គឺជានិមិត្តរូបនៃព្រះពោធិសត្វ លោកេស្វរៈ ជាការសំគាល់នូវទិសទាំង ៤ ។ បើតាមជំនឿរបស់លោកសេដែស បានពោលថា ព្រះភក្ត្រទាំង ៤ គឺជារូបភាពនៃស្តេច ដែលដូចគ្នានឹងព្រះភាគទេវតា បើតាមលោក ប៉ូលមូស វិញបានពោលថា មណ្ឌលដែលទាក់ទងទៅនឹងកាណាទៃត្រុស ១ គ្នានេះ បានបង្កើតនូវការបំរើនលូតលាស់ ខាងឫទ្ធានុភាពនៃស្តេចភាគទេវតា ដែលនៅក្នុងស្រុកទាំងអស់ ។

មយ៉ាងទៀតប្រាង្គមានមុខបួននេះជាវិហារ ដោយមានអក្សរចារឹកខ្លះ ១ ទាក់ទៅតាមធម្មតារ ឬ បន្ទួររំលឹកគុណព្រះភាគទេវតា ដូចមានរូបព្រះពោធិសត្វ លោកេស្វរៈ ជាកស្តុតាងគ្រាប់, នៅវង់កណ្តាលឃើញមានរូបសំណាកនៃប្រទេសខ្មែរ គឺ "ស្តេចព្រះពុទ្ធ" ត្រូវនឹង លិង្គ ឬ ទេវរាជ នៃលទ្ធិព្រាហ្មណ៍: រូបនោះអង្គុយលើនាគ ហើយភាពបញ្ជាក់ឲ្យឃើញថាជារូបព្រះបាទជ័យវរ្ម័នទី៧ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងឆ្នាំ ១៩៣៣ លោកគ្រូវេ បានរកឃើញនូវរូបសំណាក មួយបាក់បែកអស់ នៅក្នុងអណ្តូងជំរៅ ១៤ ម៉ែត្រ នៅក្នុងវង់កណ្តាល ។ រូបចម្លាក់នេះមានកំពស់ ៣ ម៉ែត្រ ៦០ បានយកទៅរៀបផ្គុំឡើងវិញ ហើយបានថ្វាយចំពោះព្រះបាទ ស៊ីសុវត្ថិ-មុនីវង្ស យ៉ាងឧឡារិកនៅថ្ងៃទី ១៧ ខែឧសភា គ.ស. ១៩៣៥ ។ វិហារដែលដំកល់ព្រះបដិមាករនេះ ជាមណ្ឌបមានជំបូលប្រក់ក្បឿងស្អិតនៅចំពីមុខខាងត្បូងនៃផ្លូវទៅកាន់ទ្វារជ័យ មិនឆ្ងាយប៉ុន្មានពីព្រះពន្លាជំណាក់អង្គរធំ ។

## ការពិពណ៌នាអំពីប្រាសាទ

ការកែប្រែនៃបែបផែននៅបាយ័ន និងការចាត់ចែងខាងក្នុងនៃគ្រឹះស្ថាន មកពីការរៀបចំច្រើនដងពេកដែលនាំឲ្យប្រាសាទប្រែការផ្សេងៗទៀត ហើយគេបានឃើញស្នាមនៅសឹងតែគ្រប់ទីកន្លែងទាំងអស់ ។ ការប្រែការយ៉ាងដូច្នេះហើយការបានមានការសាងថែមៗគ្នា ដោយមានពេលសម័យខុសៗគ្នា សារុបសេច-

www.budinst.gov.kh www.elibraryofcambodia.org

គឺទៅ មិនមែននៅក្នុងវត្តកាលព្រះបាទជ័យវរ្ម័នទី៧ប៉ុណ្ណោះទេ ។

ក្នុងស្ថានភាពសព្វថ្ងៃ ប្រាសាទនេះបែកជាពេនខន នៅខាងក្រោមមួយ នៅមណ្ឌលទី៣ជាមួយនិងមណ្ឌបមុខបួនទិស ជាគបួននៅព័ទ្ធជុំវិញទីធ្លា ។ នៅខាងលិចមានបណ្ណាល័យពីរ នៅលើមណ្ឌលទី២នៃពេនខនមួយនិងរង់មុខបួនទិសរង់ទី៣ កណ្ដាល ។ នៅមុខនិមួយៗនៅរង់កណ្ដាល មានរូបនាគមាន របៀបដូចនៅពេនខន មានកំពែងលយចេញជាកន្លែង និងរង់ មុខហើយមានប៉មតូច ៤ កាត់កែង មានលានខ្ពស់មួយ មាន ច្រង់ព្រាយតាមបរិវេណនៃពេនខនកន្លែង ។ មានកំពូល កណ្ដាលកន្លែងមូល ដែលមានកំពស់ ៤៥ ម៉ែត្រ ពីផ្ទៃដីទៅក្រង កំពូល ប្រាសាទនេះបាននោះជាប្រហោងមួយនៅខាងលិចបន្ទប់ តូច ១ និងនៅយ៉ាងខាងមុខនៅជិតរង់ខ្ពស់ ។

១- នៅប្រាសាទកណ្ដាលមានតាក់ខនទៅទិសពេនខនខាង មណ្ឌលទី២ គឺជាផ្នែកខាងគ្រឿងបរិធាននៃពេនខនមានកំពែង ខ្ពង់ព័ទ្ធជុំវិញដោយទីហោរកណ្ដាលមួយដែលខ្ពស់ ដើម្បីធ្វើឱ្យទៅ

www.budinst.gov.kh www.elibraryofcambodia.org

ចាក់ជួនជ្រុងទ្រវែង ដោយមានការតភ្ជាប់ទៅនឹងថែបផែនខាងក្រោមនៃកេនទងដែលព័ទ្ធធ្លាតូចទាំងបួន ។

២- នៅលើលានខ្ពស់កន្លែងមានវិហារកណ្ដាល ដែលគសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧ នៅពេលក្រោយបំផុត គឺក្រោយដែលទ្រង់បានសម្រេច នឹងសាងបាយ័នជាវិហារនៅលើភ្នំនៃអង្គរធំ ដោយទ្រង់ជាព្រះឧបត្ថម្ភនៃព្រះពុទ្ធសាសនា ។

៣- ទីធ្លាព័ទ្ធជុំវិញបានចាក់ទងទៅនឹងការប្រតិបត្តិពីរយ៉ាង ដែលត្រូវបំពេញបន្តបន្ទាប់គ្នា ។ នៅផ្នែកខាងក្រោមធ្វើពីថ្មបាយក្រៀម មានកេនទងនៅមណ្ឌលទី៤បានតភ្ជាប់រហូតដល់ ២ ម៉ែត្រ ៥០ នៅខាងក្រោមហើយនិងការជីករកបានបង្ហាញនៅកន្លែងក្រាលថ្មបាយក្រៀម ផ្នែកទី១ និងនៅកណ្ដាលមានជម្រៅ១ ម៉ែត្រយ៉ាងខ្ពស់ ដោយមានឆ្លាក់ជារូបនៅលើថ្ម ។

៤- នៅកេនទងនៃមណ្ឌលទី៣ និងនៅតាមបណ្ណាល័យ បានចាក់ដីបំពេញរហូតដល់រួចស្រេច ។

៥- មានទីធ្លាព័ទ្ធជុំវិញបានចែកប្រហែងនេះទៅជាគ្រឹះស្ថាន

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបាយ័ន

www.budinst.gov.kh www.elibraryofcambodia.org

១៦ តែនៅសព្វថ្ងៃនេះ គេឃើញផុតអស់តែ ៤ នៅមុខម្ខាង ៗ និងមានកន្លែងសម្រាប់អង្គុយធ្វើដោយថ្មបាយក្រៀម ប៉ុន្តែអាចមើលឃើញជីដែលភ្ជាប់ពីរោងទងទី ២ និង ទី ៣ ខាងស្តាំ នៅវង់នីមួយ ៗ នៃមណ្ឌលទី ២ ។

ជណ្តើរមួយដែលនាំឲ្យយើងមកដល់លានខាងលើ មានតាំងពីដើមមកនៅតាមអ័ក្សនីមួយ ៗ នៅជណ្តើរខាងលិចមានជញ្ជាំងព័ទ្ធជុំវិញ នៅក្នុងសម័យមិនកំណត់ អាចប្រើជំនួសជណ្តើរពីរទៀត ដែលមានភាពជាអតិបរមាណ ជណ្តើរទាំងនេះមានភាពយ៉ាងមាំនិងរលោងស្រិល ៗ កាំជណ្តើរធ្វើពីស៊ីម៉ង់ត៍ មានប្រវែងនិងទទឹងពុំសូវធំល្មមក្នុងការធ្វើដំណើរយ៉ាងស្រួលឡើងទៅខាងជើង – ខាងត្បូងនិងខាងលិច ជណ្តើរខាងឆ្វេង ។

មកដល់ប្រាសាទដោយលានខាងកើត គេចូលដល់ពាក់កណ្តាលនៃមណ្ឌលទី ៣ មានសសរជារូបនាគខ្វែងនៅផ្នែកខាងក្រោម គេបានសង្កេតឃើញមានរូបចម្លាក់នៅជញ្ជាំងដែលធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យយើងយល់ឃើញច្បាស់នូវអត្ថន័យនៃការតុបតែងនេះ "ដោយធ្លាក់មកដើមផ្ទាំង" មានដំណើរហើងទន់ភ្លន់នៃស្រីទេពអប្សរពីរ ឬ បី នាក់រាំនៅលើផ្កាឈូក ៗ នៅទីនេះបើគេបត់ពីខាងឆ្វេងហើយចូលទៅក្នុងកោងទងនៃក្បាច់ចម្លាក់ ដែលគេឆ្លាក់តាមក្បួនប្រពៃណីពីបុរាណកាល ដោយទុកនូវប្រាសាទជាកេរ្តិ៍ដំណែលទៅខាងស្ដាំរហូតមកដល់ទាគខាងត្បូង ។

កោងទងនេះបានចែកជាល្វែងខណ្ឌ ដោយផ្ទាំងមាន ៤ ម៉ែត្រ ៥០ កំពស់ ដែលមាន ៣ ម៉ែត្រ ៥០ ធ្លាក់ នៅជ្រុងម្ខាងទៀត មានសសរតម្រៀបជាពីរជួរ មានបង្គោលតាចៗ ៗ នៅតាមបរិវេណប្រាសាទក្លោងទ្វារពោក់ចែកអស់ ដូចជាមេមណ្ឌបមុខ និង រូបនាគ នៅគ្រប់តែបែបផែនខ្វែង ៗ

អ្នកទស្សនាទាំងឡាយ ដែលមានពេលខ្លីពេកគួរពិនិត្យនូវក្បាច់ចម្លាក់នៅផ្នែក ១/៤ នៃទិសអគ្នេយ៍ ដែលមានខ្លឹមសារជាងគេ រួចឈប់នៅតាមទ្វារនីមួយ ៗ ដែលបើកចំហទៅទិសខាងក្នុង ដើម្បីបានឃើញទស្សនីយភាពទាំងអស់នៃប្រាសាទ

www.budinst.gov.kh www.elibraryofcambodia.org

ដែលប្លែកៗពីគ្នា ។

នាគខាងស្តាំមានរូបយ៉ាងសង្ហា រីឯទ្វារខាងជើងប្រកបដោយក្បាច់គ្រប់កល្បូកយ៉ាងល្អឆើតឆាយ នៃស្រីទេពអប្សរដែលឆ្លាក់យ៉ាងធំៗ ។ គេចូលមកដល់បរិវេណនេះ គេគាបជូនគាត់ចូលទៅដល់មណ្ឌល ដែលមានរូបនាគនៅក្នុងពេនខង ដែលមានទិសភាគមិនស្មើគ្នា ។ ផ្លូវបញ្ចប់ខាងជើងទិសខាងត្បូងនៃបាយ័នបានចុះមកក្រោមជំរង់ទៅខាងលិច ដោយទុកចន្លោះយ៉ាងទូលាយ នៅផ្នែកខាងកើតនៃបួនជ្រុងទ្រវែង នៅមណ្ឌលទី ២ ដែលមានផ្នែកខាងក្រៅនៃពេនខង នោះបីជាយ៉ាងណាក៏ហាក់ដូចជានៅផ្លូវខាងក្រៅ មានក្លោងទ្វារពាក់-កណ្ដាលទាក់ទងទៅខាងក្នុង នៃក្លោងទ្វារមួយប្រកបដោយក្បាច់ចម្លាក់ ដែលលយចេញជាប់ទៅខាងស្តាំនៃវង់និមួយៗ ។

ធ្វើដំណើរត្រឡប់មកពីខាងស្តាំ នៃព្រះហាខមានរូបនាគដែលតម្រង់ទៅខាងលិចនៃពេនខងខាងក្នុងដែលមានជ្រុងតាបៗ គេក្រឡេកឃើញតាមចុងៗនៅក្នុងមណ្ឌលមុខខាងអគ្នេយ៍ផ្នែក

www.budinst.gov.kh www.elibraryofcambodia.org

ខាងក្រោម មានព្រះពុទ្ធបដិមាករធំនៅក្រោមក្បាលនាគ ដែលធ្វើឲ្យមានការគោរពស្ញប់ស្ញែងយ៉ាងជ្រាលជ្រៅ ។

បែកផ្លូវទៅខាងជើងតាំងពីរនទី ១ គេបន្តដំណើរដោយពេនចងមានកំពែងវែងមានជ្រុងតាប ៗ នៅពាក់កណ្ដាលក្លោងទ្វារ ៗ តាំងពីក្លោងទ្វារនោះមកយើងឃើញកំទេចឥដ្ឋនៅពាសពេញយ៉ាងតិចណាស់ពី ១ ម៉ែត្រ ទៅផ្ញាំងឡើងទៅលើនៃលានខ្ពស់ ដែលយើងបានឃើញរួចមកហើយ បន្ទាប់មកចូលទៅក្នុងបរិវេណដែលប្រកបដោយរឿងព្រេង នៅជ្រុងក្បាច់និមួយ ៗ ៗ គេចុះពីទ្វាខាងទិសឧតរហើយចូលទៅក្នុងនៃមណ្ឌលទាំង ៣ ដោយសំគាល់ឃើញនៅកន្លែងខាងលិចនៃមណ្ឌលទី ២ មានជណ្ដើរមួយដែលនៅខាងត្បូងដែឡើងទៅលើលានខាងត្បូង ៗ ផ្លូវបត់នេះ បណ្ដាលឲ្យមានសេចក្ដីរន្ធត់ញាប់ញ័រយ៉ាងខ្លាំងនៃបាយ័ន ហើយមានភាពខ្ពស់តាបយ៉ាងច្រើនសគគណនា ទីធ្លាដែលត្រូវមាននៅជាន់ទី ១ នៃប្រាសាទ ដែលមានផ្លូវវែងហើយបង្អៀតគ្មានខ្យល់ចិន

www.budinst.gov.kh www.elibraryofcambodia.org

គ្មានពន្លឺព្រះអាទិត្យដែលគេឃើញហើយពិតនូវប្រិយភាព ដែលខុសគ្នាឆ្ងាយណាស់ពីអង្គរវត្ត ។

នៅតាមទីលានខាងលើ ដែលគេអាចដើរកំសាន្តជុំវិញបាន គេទើបឃើញនូវភាពកំបាំងហើយច្បាស់ នៅពេលដែលគេដើរកំសាន្ត ទើបបានឃើញព្រះភក្ត្រព្រះពោធិសត្វ ហោគេសួរ: ជាច្រើនដែលបាក់បែករលំគរលើគ្នានៅប្រាសាទកណ្តាល ។ បរិវេណទាំងនេះបានលេចចេញសឹងតែគ្រប់ទាំងអស់ តែមានភាពប្លែក ៗ គ្នា មិនមែនមកពីក្បាលដែលមានមុខ ៤ ដូចជាការបង្ហាញនៅក្នុងសាសនាព្រាហ្មណ៍នោះទេ គឺមានសភាពប្លែកពីគំរូនៅប្រាសាទបួនជ្រុងស្មើ មានបួនជាន់ដោយសន្ទូក ទើបមានជាក្បាច់ត្របកឈូក ដោយមានមុខនៃមនុស្សមានសភាពប្លែកៗគ្នាពី ១ ម៉ែត្រ ៧៥ ដល់ ២ ម៉ែត្រ ៥០ នៃកំពស់នៅលើអ័ក្សនិមួយ ចម្លាក់នៅតាមកំពស់នៃជាន់ទី ២ នៅផ្នែកទី ១ ។

នៅបរិវេណនេះ មានកំពង់ប្រាសាទកណ្តាលខាងបំពង់ខ្យល់ ដែលជាប់ទីងលយចេញមកក្រៅ ដោយគ្មានទាក់ទងទៅនឹងអ្វី

www.budinst.gov.kh www.elibraryofcambodia.org

នោះ ហើយមិនអាចទ្រាំបានទឹងឫសឈើទាំងឡាយ ហាក់ដូចជាប្រេះពីលើមកក្រោម តាមបន្ទាត់ត្រង់ជាប់គ្នាគ្មានដាច់ទងទៅទីងអ៊ី ហើយធ្វើឲ្យថ្មរលំដូចជាផ្លែឈើទុំ ៗ ការបាក់បែកដ៏សម្បើមនេះ បានរកឃើញដើមកំណើតហើយបានជួសជុលជាថ្មីឡើងវិញ ប្រហែលជាពាក់កណ្ដាលនៃប្រាសាទ នៅខាងមុខនៃទិសខាងកើតទិសខាងត្បូង បានបាកស្ទុតពីការខូចខាត ហើយការរៀបចំគំរេះតែបន្តទៅមុខទៀត ៗ

កំពូលកណ្ដាលមានបាតរាងមូល បន្ទាត់ពុះកណ្ដាលប្រវែង ២៥ ម៉ែត្រ នេះគឺជាវត្ថុមួយដែលពុំសូវមាននៅប្រទេសខ្មែរ ៗ នៅខាងលើនៃផ្នែកខាងក្រោមប្រកបដោយផ្លូវចូលទៅប្រាសាទ មានក្បាច់ចម្លាក់បង្កើតបានជាសសរ នៅក្បែរទ្វារមានរាងជាត្រីកោណ ឬ បួនជ្រុងទ្រវែង នៅលើថ្នាក់ ទី ១ នៅបន្ទប់ឯទៀត ខ្លះទៀតគ្មានផ្លូវចូលទេ តែក្លែងដោយបង្អួច រូបមកមាន ៨ ជុំ ខាងមុខដាក់នៅលើថ្មសម្រាប់សំគាល់ចំណុចទិសទឹងជ្រុងជាប់ ៗ គ្នា ហើយមានផ្នែកមុខមួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

គ្មានពន្លឺព្រះអាទិត្យដែលគេឃើញហើយពិតនូវប្រិយភាព ដែលខុសគ្នាឆ្ងាយណាស់ពីអង្គរវត្ត ។

នៅតាមទីលានខាងលើ ដែលគេគាប់ដើរកំសាន្តជុំវិញបានគេទើបឃើញនូវគាថកំបាំងហើយច្បាស់ នៅពេលដែលគេដើរកំសាន្ត ទើបបានឃើញព្រះភក្ត្រព្រះពោធិសត្វ លោកេស្វរៈជាច្រើនដែលឆ្លាក់ថែករលំគរលើគ្នានៅប្រាសាទកណ្តាល ។ បរិវេណទាំងនេះបានលេចចេញសឹងតែគ្រប់ទាំងអស់ តែមានភាពប្លែក ៗ គ្នា មិនមែនមកពីក្បាលដែលមានមុខ ៤ ដូចជាការបង្ហាញនៅក្នុងសាសនាព្រាហ្មណ៍នោះទេ គឺមានសភាពប្លែកពីគំរូនៅប្រាសាទបួនជ្រុងស្មើ មានបួនជាន់ដោយសន្ទុតទិឯមានជាក្បាច់គ្រប់គពូក ដោយមានមុខនៃមនុស្សមានសភាពប្លែកៗគ្នាពី ១ ម៉ែត្រ ៧៥ ដល់ ២ ម៉ែត្រ ៥០ នៃកំពស់នៅលើអ័ក្សនិមួយ ចម្លាក់នៅតាមកំពស់នៃជាន់ទី ២ នៅថ្នាក់ទី ១ ។

នៅបរិវេណនេះ មានកង់ប្រាសាទកណ្តាលខាងបំពង់ខ្យដែលជាប់ទឹងលយចេញមកក្រៅ ដោយគ្មានទាក់ទងទៅនឹងអ្វី

www.budinst.gov.kh www.elibraryofcambodia.org

ភោគះ ហើយមិនគាប់ព្រាំបានទីនឫសឈើទាំងឡាយ ហាក់ដូចជាប្រេះពីលើមកក្រោម តាមបន្ទាត់ត្រង់ជាប់គ្នាគ្មានពាក់ទងទៅទីនស៊ី ហើយធ្វើឲ្យថ្មរលំដូចជាផ្លែឈើទុំ ៗ ការបាក់បែកដីសម្បើមនេះ បានរកឃើញដើមកំណើតហើយបានជួសជុលជាថ្មីឡើងវិញ ប្រហែលជាពាក់កណ្ដាលនៃប្រាសាទ នៅខាងមុខនៃទិសខាងកើតទិសខាងត្បូង បានបាក់ស្រុតពីការខូចខាត ហើយ ការរៀបចំក៏ចេះតែបន្តទៅមុខទៀត ៗ

កំពូលកណ្ដាលមានបាតរាងមូល បន្ទាត់ពុះកណ្ដាលប្រវែង ២៥ ម៉ែត្រ នេះគឺជាវត្ថុមួយដែលពុំសូវមាននៅប្រទេសខ្មែរ ៗ នៅខាងលើនៃផ្នែកខាងក្រោមប្រកបដោយផ្លូវចូលទៅប្រាសាទ មានក្បាច់ចម្លាក់បង្កើតបានជាសសរ នៅក្បែរទ្វារមានរាងជាត្រីកោណ ឬ បួនជ្រុងទ្រវែង នៅលើថ្នាក់ ទី ១ នៅបន្ទប់ឯទៀត ខ្លះទៀតគ្មានផ្លូវចូលទេ តែក្តីដោយបង្អួច រួចមកមាន ៨ ជុំ ខាងមុខដាក់នៅលើថ្មសម្រាប់សំគាល់ចំណុចទិសទីនជ្រុងជាប់ ៗ គ្នា ហើយមានផ្នែកមុខមួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

ដែលនៅពុំទាន់មានសភាពស្រួលបួលនៅឡើយ ៗ នៅកំពូល ខ្ពស់បំផុតបានបញ្ចេញពន្លឺភ្លឺច្បាស់លាស់ ទ្រដោយសសរ នៅខាងក្រោមនៃក្លោងទ្វារក្រោយបង្អស់ ហើយប្រហែលជា មានក្បូរចិតបន្ទួចដែរ ក្រៅពីសសរនេះ កំពូលប្រាសាទលំអ ដោយក្បាច់នៅផ្នែកខាងក្នុង ដូចជានៅបរិវេណដែរ យ៉ាងហោច ណាស់ក៏មានស្នាមៗម្នាក់នេះ បន្ទាត់ដែលជាគ្រឿងលំអម្យ៉ាង ដែរ ៗ ពិតប្រាកដណាស់នៅបរិវេណដែលគេរក ពៀរ គ- គាន់ បានរៀបរាប់ថា ជាទីសម្រាប់សំគាល់មណ្ឌលនៃពិធីណា បក្រយើង ដែលបានការពារយ៉ាងមាំមួនដោយព័ទ្ធជុំវិញជា ២០ ជុំ និងមានជុំជាង ១០០ ធ្វើពីថ្មទាំងអស់ ៗ នៅគ្រប់ផ្នែក ខាងលើនេះ ត្រូវបាក់បែក ស្ទើរតែទាំងអស់ ក៏ប៉ុន្តែនៅ ឆ្នាំ ១៩៣៣ គេបានកសាងជាថ្មី និងមានការរៀបចំអង្គ ប្រាសាទយ៉ាងចាប់ហ័ស ៗ

នៅគណ្ឌប្រាសាទ ជុំសិលាទៀងពណ៌ស្រគាប់ មានប្រវែង ៥ ម៉ែត្រ ពីបុគ្គលក្ដោងកណ្ដាលព័ទ្ធជុំវិញដោយរបៀងយ៉ាងចង្អៀត

www.budinst.gov.kh www.elibraryofcambodia.org

នេះហើយជារូបសំណាក សម្រាប់ដំណាងនូវមណ្ឌលនៃព្រះរាជាចក្រកម្ពុជា មានរូបព្រះបដិមាករមួយអង្គធំសម្រាប់ជាទីសក្ការៈបូជា និងមានកំទេចថ្មជាច្រើនដែលគេបានរកឃើញនៅក្នុងអណ្តូងកណ្តាល ។ គេគាបឡើងទៅកាន់ប្រាសាទតាមជ្រុងខាងកើត ដោយប្រាសាទនៃខ្លួនមានកំពូល ៣ ទណ្ឌដោយយំតូច ១ ៗ នៅមួយផ្នែកទៀតមានគ្រឹស្ថានពីរវែង ១ ប្រកបដោយបរិវេណនៅកន្លែងបណ្ណាល័យ ៗ គេសង្កេតឃើញនៅជិតគ្រឹះស្ថានខាងផ្នែកនៃទិសខាងជើង មានមុមកែងជួបគ្នានៅទិសឦសាននៃទីលាន មានក្បាច់មួយដែលគួរឲ្យស្ញើចសរសើរ គឺជាក្បាច់តាំងពីបុរាណកាលមក ដែលគេលាក់ទុកនៅកន្លែងក្រាលថ្ម ហាក់ដូចជាមានរូប លោកេស្វរៈ មួយអង្គឈរនៅកណ្តាល នេះជាលក្ខណៈមួយដែលទាញការម្មណ៍យើងឲ្យផ្តោតទៅលើព្រះពុទ្ធសាសនានៅបាយ័ន ។

ការតុបតែងដោយក្បាច់តាក់ស្រែះ ដូចជានៅសម័យបុរាណគឺនៅពេលចាប់សាងសិល្បៈខ្មែរ ក្បាច់នេះមានសភាព

www.budinst.gov.kh www.elibraryofcambodia.org

ឆ្លាក់យ៉ាងផ្ចិតផ្ចង់ជាទីបំផុត ដូចជានៅខាងក្រោមមានឆ្លាក់លំអរដោយមែកឈើយ៉ាងត្រសុំត្រសាយ ដែលបង្ហាញនូវសោភ័ណភាពយ៉ាងអស្ចារ្យ ។ គេសង្កេតឃើញនៅតាមបង្អួចបញ្ឈោតមានរនាំងបាំងពាក់កណ្តាល នេះបង្ហាញពីការប៉ិនប្រសប់របស់អ្នកធ្វើ ហាក់ដូចជាសំពត់មានផ្កាព័ទ្ធជុំវិញដោយខ្សែក្រវាត់ ជាគ្រឿងសំយុងយ៉ាងស្រស់ប្រិមប្រិយនៃទេវតាដែលមានសក់បួងជាក្បួង ដោយធ្លាក់នៅលើត្រគាក ក្បាច់បម្លាក់នេះសម្រាប់បង្ហាញនូវការស្ទាត់ជំនាញ ដែលមាននៅគ្រប់ផ្នែកខាងមុខ ។ យើងសំគាល់ឃើញនៅកន្លែងឯទៀតមានស្រីទេពអប្សរយ៉ាងស្រស់ឆើតឆាយពីរនាក់ នៅបង្អួចប្រាសាទកណ្តាល និងមានផ្ទាំងបម្លាក់សំខាន់ៗច្រើនទៀតនៅលើជណ្តើរខាងត្បូងនៃផ្លូវចូលទៅទីលាន ដែលបានបង្ហាញពីរឿងព្រេងនៃ « ម៉ារីជ័យ » ដែលផ្សងរើសរកអ្នកមានបុណ្យម្នាក់មកគ្រងរាជ្យ ។

ចុះពីកៀនខាងនៃមណ្ឌលទី ២ មកដោយជណ្តើរដែលឡើង

www.budinst.gov.kh www.elibraryofcambodia.org

ទៅខាងត្បូងផ្នែកខាងកើត ពួកអ្នកទេសចរណ៍បានប្រញាប់ប្រញាល់ នឹងទៅទស្សនានៅពេងចង់ថ្មបាយក្រៀមទៀត គេនឹងឃើញមានរន្ធនៅចន្លោះមណ្ឌលខាងអ័ក្យ នឹងមណ្ឌលខាងជើង ដែលមានរឿងព្រេងមួយនិទានពីស្តេចកើតកុដ្ឋរោគ (រោគឃ្លង់) មួយអង្គ ។

បន្តដំណើរទៅទៀត នៅក្នុងពេងចង់ខ្វងទិសខាងលិច មានអណ្តូងមួយដែលមានជម្រៅប្រហែលជា ១០ ឬ ២០ ម៉ែត្រ នៅចំកណ្តាល ដែលហ៊ុំព័ទ្ធដោយរបងនៅពីខាងមុខ ។

## ក្បាច់ចម្លាក់

បាយ័នជាប្រាសាទមួយ ដែលមានពេងចង់ពីរនៅមណ្ឌលជាមួយគ្នា ប្រកបដោយក្បាច់ចម្លាក់, ពេងចង់ខាងក្នុង មានការតុបតែងយ៉ាងប្រណីត ដែលហាក់ដូចជាទេវតានិមិត្តថ្វាយ មានលើកយកសាសនាព្រាហ្មណ៍មកនិទាន នៅពេងចង់ខាងក្រៅមានការតុបតែងផ្ទុយគ្នាពីខាងក្នុង ដែលមានសុទ្ធតែពួកអ្នកកាន់សាសនាទៅគោរពបូជារំលឹកគុណ និងមានរឿងថ្លែង

www.budinst.gov.kh www.elibraryofcambodia.org

រៀបរាប់ពីការរស់នៅក្នុងសម័យប្រវត្តិសាស្ត្រ និងនៅពេលមានចំបាំង នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។ លោកប៉ូលមូស បានពោលថា ការរៀបរាប់និទានទាំងនេះគឺជាការឆ្លាក់ដោយពន្លាក ដែលមានភាពពិត ៗ នៃទេពកោសល្យក្នុងសម័យនោះ ដោយការឧបត្ថម្ភនៃលោកេស្វរៈ ស្តេចនៃអាទិទេពដែលបានជួយផ្សាយនៅពេលក្រោយនេះ ។

ទឹកដៃនៃចម្លាក់ពុំសូវប្រសើរទេ ព្រោះក្បាច់ចម្លាក់នៅបាយ័នពុំសូវល្អ តែមានជម្រៅជ្រៅជាងក្បាច់ចម្លាក់នៅអង្គរវត្ត នេះជាប្រភពមួយដែលមានឯកសារយ៉ាងសំខាន់ៗ ដោយក្បាច់យ៉ាងច្បាស់ៗ តែអន់ខាងរូបភាព ។ ឯកសារទាំងនោះបង្ហាញនូវបុរាណកាល និងជីវភាពនៃរាស្ត្រខ្មែរនៅសម័យដើម ។

ម្យ៉ាងទៀតគឺជាប្រាសាទគំរូ សម្រាប់កត់សំគាល់នូវហេតុការណ៍ផ្សេង ៗ ដូចជាបញ្ជីខាងក្នុងសម្រាប់បង្ហាញពីច្បាប់ទំ-ហប់ខាងសិល្បៈឲ្យបេះពិនិត្យគោលការណ៍ ម្យ៉ាងវិញទៀត

www.budinst.gov.kh www.elibraryofcambodia.org

ដូចជាជាន់ខាងលើនាជើងមេឃ ។ ចេញពីផ្លូវចូលខាងកើត យើងនឹងបន្តដំណើរទៅពាក់កណ្តាលខាងត្បូង នៃមុខខាងកើត យើងនឹងបានឃើញប្រាសាទខាងស្តាំផ្លូវ ជាគ្រឿងដំណាលពីបុរាណ ។

## រោងទងខាងក្រៅ មណ្ឌលទី ៣

### រោងទងខាងកើត ពាក់កណ្តាលខាងត្បូង

ក្នុងក្បាច់ចម្លាក់តាំងពីជាន់ផែលចង្អៀញចំណែកដ៏វិសេសនៃសិល្បករ មានក្បួនព្យុហយាត្រាមួយធ្វើដំណើរពីខាងត្បូងមកខាងជើង ។ ពួកពលទ័ពមានគ្រឿងការពារដូចជាស្នូ និងខែល ជាដើមនៅគ្រប់ដៃ ពួកទាហានទាំងនេះច្រើនតែមានសក់ខ្លីៗ និងក្បាលទទេ នៅពេលនោះមានទ័ពមួយពួកទៀតមកពីខាងក្រោយមានទុកពុកចង្កានិងសក់យ៉ាងចំឡែក ។ ក្រុមក្មេងដើរតាមពីក្រោយពួកទ័ពទាហាន និងមានមនុស្សម្នាក់វាយស្គរយ៉ាងធំដោយអន្ទូងពីរ ។ ពួកក្មេងទាំងនេះដើរដោយមានពួកអ្នកផ្សះសះគ្មានការនិងឈ្មោះផងអម បំណែកខាងមុខទ័ពវិញ

www.budinst.gov.kh www.elibraryofcambodia.org

មានធ្នូ លំពែងប្ដូស្ន ហើយបាំងដោយខ្ពស់ជាអ្នកនាំផ្លូវ អង្គុយនៅលើដំរីដែលដឹកនាំដោយហ្មដំរី ។

គេសំគាល់ឃើញនៅពេលចប់ក្បួនព្យុហយាត្រាម្តងៗ មានការស្រែកហ៊ោកញ្ជ្រៀវហ៊ោរីករាយសប្បាយ មានពួកអ្នកផ្គត់ផ្គង់ស្បៀងអាហារឲ្យគងទ័ព ដែលមានរទេះមានដំបូលសម្រាប់ដឹកដូចរទេះប្រើសព្វថ្ងៃដែរ ចំណែកឯដំរីម្តងនេះឥតមានហ្មទេ ។ ដើម្បីឲ្យមានសភាពដូចមែនទែន ហើយគេសង្កេតឃើញនៅចុងខាងជើងនៃជាន់ទី ២ មានគោមួយដែលគេបំរុងយកទៅបូជាយញ្ញចងនៅដើមឈើមួយ ។

នៅទីបញ្ចប់មានរឿងនៅក្នុងផ្ទះតាមជាន់ទាំង ៤ ។ ដំបូលផ្ទះអ្នកស្រុកបង្ហាញនូវប្រទុនផ្ទះ ដែលមានបក្សីទំលើ ។ លក្ខណៈពិសេសម្យ៉ាងទៀត មានការតុបតែងសក់និងសំលៀកបំពាក់របស់មនុស្ស និងវត្ថុដែលព្យួរនៅលើពិតាន អាចឲ្យយើងយល់បានយ៉ាងច្បាស់ថា អ្នកចម្លាក់នេះបន់បង្ហាញយើងពីរបៀបធ្វើជំនួញរបស់ជនជាតិចិន ។

www.budinst.gov.kh www.elibraryofcambodia.org

## មណ្ឌបមុម ខាងអគ្នេយ៍

ចម្លាក់នៅមណ្ឌបនេះ ឆ្លាក់មិនទាន់ហើយនៅឡើយទេ ផ្ទាំងចម្លាក់ទី ១ បង្ហាញយ៉ាងច្បាស់លាស់អំពីរបៀបធ្វើការតាមប្រពៃណីរបស់ខ្មែរ ។ គេសង់ជញ្ជាំងជាដំបូង ទើបគេដាប់តាមគំនូរឲ្យបានជាពង រួចលុងឲ្យក្បាច់លេចក្រឡោត ហើយសំអិតសំអាងជាក្រោយបំផុត ។ មានរូបស្រីទេពអប្សរពីររូបមានសោភ័ណភាពយ៉ាងស្រស់បញ្ចេញក្បាច់ខាងស្តាំ ចំណែកនៅខាងឆ្វេងវិញ មានប្រាងបីជុំទ្រទ្រង់នូវត្រកូលមួយទងនៅកណ្តាលមានលិង្គព្រះឥសូរមួយផង ។ នៅផ្ទាំងចម្លាក់
115 ឯទៀតៗ មានរឿងរ៉ាវតាក់តែងទៅតាមរឿងឆាវបរ ។

## រោងទងខាងត្បូង ពាក់កណ្តាលខាងកើត

នៅក្នុងផ្នែកនេះ មានតែកេងទងមួយទេ ដែលចំណានជាងគេ ហើយដាប់តាក់តែងទីងចំបាំងតាមឆាវ នៅចុងសតវត្សទី ១២ រវាងទ័ពខ្មែរ និង ចាម ។ ចម្បាំងនេះធ្វើឲ្យប្រជាជន

www.budinst.gov.kh www.elibraryofcambodia.org

រំជើបរំជួលយ៉ាងខ្លាំង ទំពៃខ្មោកាត់សក់ខ្ញី ៗ ឯទំពាម "មាន សក់ជោគផ្កាចំប៉ា" ។ មានការប្រជុំប្រជល់ជាខ្លាំង ក្បាលខ្មោចមួយ ៗ លំអយ៉ាងឆើតឆាយ មានទាវម្យ៉ាងទៀតដែល ប្លែកពីពេលនោះរៀបគ្នាជាជួរ ទិនពួកអ្នកចំបាំងដែលមានគ្រឿង សស្ត្រាវុធដូចជាធ្នូ ស្នា លំពែង ទិន ខែលជាដើម, មានខ្មោច ខ្លះស្រែក គរាត់បោលមកលើមាត់ច្រាំង ខ្លះទៀតទំលាក់ឲ្យ ក្រពើស៊ី ។

ព្រះរាជាមានមាឌខ្ពស់ គង់នៅក្នុងរាង នៅមុខខាងស្តាំ ពាក់ខែវគ្រឿងសំគាល់ ទិនបញ្ជាឲ្យអ្នកនៅក្រោមបង្គាប់គង្គុយ ទំពាក ដីទំ ហើយតាំងចាក់ក្តាក់ក្តែង ដូចជានៅក្នុងពេញក្នុងពេល បុណ្យអុំទូកអកអំបុក ការកំប្លែងនេះតែងមានជាធម្មតា ដើម្បី ធ្វើឲ្យអ្នកចាំមើលទូកមានកម្សាន្តផង មានការសប្បាយផង ៗ មាន ត្រលោះ ចីវប្រភេទ ខ្លះជ្រកតាមដើមឈើ ខ្លះទៀតនៅតាម ព្រៃដែលលិចទឹក នៅរដូវទឹកជំនន់បានបង្កើតជារូបភាពដ៏ជាក់ ស្តែង ដូចជាយើងបានជួបប្រទះនៅទន្លេសាបសព្វថ្ងៃនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅតាមជាន់ប្រាំង មានពិពណ៌នា ដោយប៉ិនប្រសប់អំពីព្រឹត្តិ-
ការណ៍ នៃជីវិតរស់នៅពលរដ្ឋគឺរឿងកំរើកនៅតាមផ្សារ នៅ
កន្លែងដាំបាយ នៅកន្លែងបរបាញ់សត្វ ឬ ប្រយុទ្ធជាមួយពាល
ច្រើន ៗ មានស្រីកកៃចៀវគេ ប្រឡែងលេងជាមួយកូនក្មេង
ខ្លះទៀតយំដោយជម្ងឺដែលឈឺចាប់ពោះវៃ ៗ នៅចុងខាងចុង
មានរូបបុរសញ្ញើម្នាក់ម៉ឺតស្អាតប្រដង់ដៃផ្ទាល់ក្របី ៗ ស្អាតនោះ
មានសភាពដូចជាស្នារបស់ខ្មែរសម័យសព្វថ្ងៃនេះ ៗ

នៅតាមជាន់ទី២ មានការពិពណ៌នាអំពីការនេសាទត្រី
ដោយសំណាញ់ ៗ ទូកចុកចាយមួយដែលពេញដោយពល
បង្ហាញពីការប៉ិនប្រសប់ខាងបោះយុថ្កា ដោយប្រើតែសន្ទ្រាប់រូត
ឡើង ៗ ចំណែកពួកអ្នកនៅលើទូកមួយទៀតសោត គឺកំពុង
យោធិនកាយ ដោយប្រព្រឹត្តល្បែងផ្សេងៗ ៗ នៅខាងក្រោយ
មានរឿងថ្មី ១ ចំនួនទៀត ដែលមានការប្រដល់មាន់ យោធិនកាប
គ្នាឱ្យចាប់ការម្ហូបជាវាំង ៗ

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាប់មកទៀតគ្មានការអ្វីប្លែកទេ មានតែរឿងនៅក្នុងវាំង ដែលមានព្រះអង្គម្ចាស់ក្សត្រីហែហម ដោយពួកកិលៀងវាំងបំពេរ និងមានលេងល្បែងចតុរង្គ "អុក" ។ នៅខាងក្រោមមានអ្នកចំបាប់និងអ្នកប្រដាល់ព្រមទាំងអ្នកប្រយុទ្ធជាមួយនឹងជ្រូកព្រៃ ។ ទាំងអស់នេះឆ្លាក់នៅក្រោមមនុស្សដេកមានរូបរាងមាំ ។ នេះប្រហែលជាស្តេចទ្រង់បញ្ជាឲ្យឆ្លាក់នៅក្នុងវាំង ក្នុងពេលដែលធ្វើបុណ្យតាមប្រពៃណី ឬ ក៏មានការអភិសេកម្តង ៗ ។

នៅផ្នែកខាងក្រោម ចំបាំងក៏ចាប់ផ្តើមឡើង ដោយពួកចាមលើកទ័ពមកលុកលុយ នៅខាងលើមានការប្រយុទ្ធជាមួយនឹងខ្មែរដែលមានសភាពហាក់ដូចជាយក្ស ដើមទ្រូងពន្ធ ដោយខ្សែ ។ នៅពេលសង្គ្រាមផុតរលត់ សន្តិភាពក៏ចាប់ 118
ផ្តើមកើតឡើង ព្រះរាជាទ្រង់ធ្វើបុណ្យរំលឹកពីជ័យជំនះ នៅគ្រប់មណ្ឌល ប្រជាជនតែងប្រកបការប្លែក ៗ គ្នា ដូចជាធ្វើជាងធ្នូ ជាងដែក និងអ្នករៀបចំម្ហូប ដើម្បីនឹងធ្វើការជប់លៀង ។

www.budinst.gov.kh www.elibraryofcambodia.org

នៅចុងខាងជើង ទ្វារក្រោយបន្ទប់មានផ្ទាំងថ្មឆ្លាក់មួយ យ៉ាងតូច ដែលរៀបរាប់ពីការជជែកគ្នាពីការប្រយុទ្ធ ។

## រោងទងខាងត្បូង ពាក់កណ្ដាលខាងលិច

នៅគ្រប់តែផ្នែកនេះ ដែលមានជាន់ខាងក្រោមបានឆ្លាក់ រូបស្រេប បំណែកនៅមណ្ឌលទី ២ ឆ្លាក់ពុំទាន់រួចនៅ តែមាន សារៈសំខាន់ជាមធ្យម ។ មានក្បួនព្យុហយាត្រាដោយកងទ័ព ដែលមានដំរីជាយានជំនិះ ជាពិសេសពាហនម្នាក់ៗ សុទ្ធតែ មានស្នាទៅលើខ្នងដំរី ហើយប្រយុទ្ធគ្នាដោយស្នាទៅវិញទៅ មក អ្នកខ្លះក៏ដង្ហក់ធ្លាក់ទៅលើកង់រទេះ ។ នៅចុងខាងកើត
(19 មានដំរីបោចកូស់ដង្ហែមកស៊ីនដើម្បីផ្តួចទឹក ។
ផ្ទាំងមួយមានឆ្លាក់រូបគ្រីជានិមិត្តរូបនៃស្មឹង ។

## រោងទងខាងលិច ពាក់កណ្ដាលខាងត្បូង

នៅទីនេះ មានសភាពប្លែកៗតែពុំទាន់បានឆ្លាក់ហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅជាន់ខាងក្រោម ពួកទ័ពចំបាំងនិងមេទ័ពជិះលើដំរី ដើម្បីធ្វើដំណើរចូលទៅក្នុងព្រៃនិងឡើងលើភ្នំ (ដែលមានសភាពជាត្រីកោណតូចៗជាប់ៗគ្នា) ។ ចំណែកនៅផ្នែកកណ្ដាលមានឥសីមួយអង្គរត់គេចពីខ្លាមួយដោយខំឡើងដើមឈើមួយដើម ។

នៅផ្នែកខាងលើ មានរឿងសំខាន់ៗដែលរៀបរាប់ពីការកសាងវិហារ ពួកកម្មករទំព្រឹងទាញថ្ម ដែលនៅទីនោះមានមេកងការទាំពាក់ផ្ដៅសម្រាប់បញ្ជា ខ្លះទៀតរៀបចំគ្រឿងបង្កាះ ខ្លះទៀតកំពុងខ្ចប់ថ្មដែលត្រូវដាក់លើវិហារ ។ ក្រោយបន្តិចមកមានការពណ៌នាពីការរស់នៅនៃពួកឥសី ។

នៅជិតទ្វារ មានផ្ទាំងចម្លាក់ហោងវ៉ែនដែលលោកសេដែស /20
បានដាក់ឈ្មោះថា " ចំបាំងគ្នាឯងក្នុងស្រុក " ចលនាយ៉ាងសស្រាក់ស្រាញនៃពួកក្បួនបដិវត្តន៍នៅតាមផ្លូវ តាមថ្នល់ មានមនុស្សប្រុសស្រីដែលត្រូវគេក្ដាន់ដៃហើយមិនត្រូវការគំរាមកំហែង អ្នកខ្លះទៀតរៀបចំខ្លួនប្រុងណាទៅច្បាំង ។ នៅភាគខាងលើមានមនុស្សម្នាក់អង្គុយក្រោមដំបូលហើយកាន់ក្បាលពីរ ដើម្បីបង្ហាញ

www.budinst.gov.kh www.elibraryofcambodia.org

ដល់ប្រជាជន ។ នៅខាងលើខ្ពស់មានអ្នកចរពាសចម្លាក់ជំរន់ឆ្ពោះទៅរកព្រះអង្គម្ចាស់ដែលទ្រង់គង់ចាំនៅក្នុងវាំង ។

បន្ទាប់មកទៀត មានសភាពលាយឡំគ្នាដោយការប្រយុទ្ធ ពួកទាហានមានខ្លួនទទេ និងមានការពាក់តែងជារបៀបខ្មែរដែលគេមិនអាចសំគាល់ម្នាក់ៗបានទេ មានទ័ពខាងជ័រចេញទៅជួយ ។

## រោងទងខាងលិច ពាក់កណ្ដាលខាងជើង

ពួកទ័ពចំបាំង មានតែជំបងសម្រាប់ការពារខ្លួន ខ្លះទៀតការពារខ្លួនដោយខែលតូចៗនិងជ័រ ពួកទាំងនោះនាំគ្នាដើរតាមមាត់ស្ទឹង ដែលនៅទីនោះគេឃើញមានត្រីមួយធំសំបើមត្របាក់
|2| សត្វចតុប្បាទតូចមួយ មានអក្សរចារឹកខ្មែរមួយបញ្ជាក់ថា៖ «ជ្រើសជាចំណីរបស់វា» ។

មានអង្គបទខ្លះទៀតវែងៗធ្លាក់នៅក្រោមសត្វធំៗ បង្ហាញពីស្ដេចដេញតាមពួកសត្រូវ ក្បាច់ចម្លាក់នេះនៅសល់ពីការយេតថ្មីដែលលៀនចេញមកក្រៅ នៅក្នុងផ្នែកខ្ពស់ៗ ដែលគេរកឃើញរូបសំណាកមនុស្សសំខាន់ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

មិនឆ្ងាយពីទ្វារប៉ុន្មានទេ មានអក្សរចារិកនៅពីក្រោយ សម្រាប់ទុករំលឹកដល់ស្ដេច ដែលចេញទៅធ្វើឈានក្នុងព្រៃ មុនពេលដែលទ្រង់នឹងធ្វើពិធីបុណ្យថ្វាយព្រះឥន្ទ្រ ដែលជាទំនៀមទំលាប់របស់ពួកព្រាហ្មណ៍ ។ នៅខាងក្រោយនៃក្បួនហែមានស្រី ៗ និងកូនក្មេង តែគេសង្កេតឃើញមានមន្ត្រីដែលតែងមានមាឌខ្ពស់ជាងអ្នកឯទៀត ឈរនៅលើដំរីមួយរូបហើយឱនក្បាលគោរពតោងទ្វារដែលត្រូវគោរព ។

## រោងទងខាងជើង ពាក់កណ្ដាលខាងលិច

នៅតាមផ្ទាំងដែលមានឆ្លាក់នៅផ្នែកក្រោម នៅចំណែកខ្លះទៀតមានគូររាសដូច ៗ គ្នា ។ នៅផ្ទាំងចម្លាក់ទី ១ មានរូបចម្លាក់ពួកអត្តពលករ អ្នកលេងប៉ាហ៊ី អ្នកលោតហក់ អ្នកប្រណាំងសេះ ។ នៅខាងលើរឿងនៅក្នុងព្រះពជាំងមានក្បួនសត្វគ្រប់បែប ដែលបង្ហាញនូវសត្វផ្សេងៗដែលរស់នៅប្រទេសខ្មែរក្នុងសម័យនោះ ។ នោះពុំម្នាំទៀតពានតសីអគ្គិយ ការនាឲមំនៅក្នុងព្រៃ ហើយនៅតាមភាគខ្លះដែល

www.budinst.gov.kh www.elibraryofcambodia.org

ចត់ថែន  មានពួកស្រីមួយក្រុមនិងមនុស្សម្នាក់មានមាឌខ្ពស់ ដែលធ្លាក់ពុំទាន់ហើយ ។

នៅមាត់ទ្វារ មានការប្រយុទ្ធជាថ្មីទៀត ជាមួយនឹងពួកចាមដែលជាសត្រូវរបស់ខ្មែរ តាំងពីបុរាណកាលមក ។

## រោងទង់ខាងជើង ពាក់កណ្ដាលខាងកើត

ផ្ទាំងប្រាសាទស្រួតសឹងតែទាំងអស់ លើកលែងតែផ្ទាំងពីរដែលនៅខាងចុង ដែលគេឃើញមានគូសត្រូវជាដែល ៗ ពួកចាមមកពីខាងកើតដោយកងទ័ពយ៉ាងច្រើន ប៉ុន្តែលើកមកម្ដងនេះ ឃើញថាទ័ពខ្មែរបរាជ័យដោយភៀសខ្លួន
123 ទៅនៅលើភ្នំពុំហ៊ានតស៊ូ ។ នៅគ្រប់ផ្នែកនេះ មានសភាព អ៊ូអរធ្លាក់ពីរៀនពិតជាក់ស្ដែង ។

## មណ្ឌបមុម ខាងទិសឦសាន

ក្បួនព្យុហយាត្រានៃពួកទ័ពចំប៉ាំងនឹងទ័ពជើរយ៉ាងច្រើន ប៉ុន្តែពុំសូវសំខាន់ឡើយ ។ នៅកណ្ដាលមណ្ឌបមានបាចផ្លន

www.budinst.gov.kh www.elibraryofcambodia.org

មួយយ៉ាងចេតឆាយ មានពានខ្ពង់សំរាប់ដាក់រូបព្រះព្រហ្ម ។ គេមិនអាចដឹងបាននូវដើមកំណើតនៃបាទស្ថាននេះ ដែលខុសពីរបៀបបាយ័ន គេចាត់ទុកថាប្រហែលជាសាងនៅក្នុងសតវត្សទី១០ ។

## រោងទងខាងកើត ពាក់កណ្ដាលខាងជើង

ការប្រយុទ្ធយ៉ាងធំរវាងកងទ័ពចាម នឹង កងទ័ពខ្មែរជាថ្មីម្ដងទៀត បង្កើតជាទីលានមួយគួរឲ្យខ្លាច ដែលមានទ័ពជំរឺជួយប្រយុទ្ធដែរ ជំរឺនីមួយ ៗ ប្រយុទ្ធទឹងប្រមោយ តែអាចធ្លុលគួរសត្រូវបាន ខ្លះទៀតប្រយុទ្ធតទល់គ្នា ។ ទង់បំបាំងនិងក្លស់មានចំនួនច្រើនឥតគណនា ហាក់ដូចជាផ្កាយពិត ៗ គេសំគាល់ឃើញៈឆាតាមជ្រុង កងទ័ពខ្មែរមានជ័យជំនះលើពួកកងទ័ពចាម ។

## រោងទងខាងក្នុង នៅអណ្ដាលទី ២

នៅទីនេះមានសភាពប្រហែលក្នុងការទស្សនា ក្នុងការធ្វើដំណើរចេញពីផ្លូវចូលខាងលិចមកដល់ប្រាសាទខាងត្បូង ។

www.budinst.gov.kh www.elibraryofcambodia.org

គេមិនមែនដើរព័ទ្ធជុំវិញរោងទងមួយជុំប៉ុណ្ណោះទេ គេគាបបន្ត ដំណើរទៅមុខទៀតដរាបដល់តួបនិងរោងទងជាកំណាត់ៗទៀតផង ។ នៅផ្ទាំងចម្លាក់ខ្លះទៀត មានឆ្លាក់ជាក្បាច់ចុកផ្ទួចជាផ្ទាំងមួយពីរូបភាព និងមានរោងទងខ្លះទៀតបានភ្ជាប់ទៅនឹងភាព ដែលលើកយកមកបង្ហាញយើងយ៉ាងច្បាស់លាស់ក្នុងការធ្វើដំណើរវែង ។

## រោងទងខាងកើត ពាក់កណ្ដាលខាងត្បូង

១– នៅចន្លោះរង់ពីរ នៅខាងស្ដាំ មានឥសីនៅក្នុងព្រៃ នៅស្រុក ក្នុំ ។ នៅខាងមុខ «ដែលមានស្នាមរលុបច្រើន» ពណ៌នាអំពីរឿងនៅក្នុងវាំង ព្រះរាជាដែលជាអធិបតីក្នុងពិធីនោះ ធ្លាក់ពុំទាន់ហើយ ។

២– នៅបន្ទប់តូច ១ នៅខាងស្ដាំ ស្ដេចគង់ក្នុងវាំង នៅក្នុងចំណោមពួកឥសីទាំងអស់ នៅពីលើរឿងនេះ មាននិទានពីរឿងខ្យល់ព្យុះនិងការបរបាញ់សត្វ នៅជុំវិញមុខព្រះព្រហ្មមានពន្លឺភ្លើងពីក្នុងប្រាសាទ ដែលមាននាងទេពកញ្ញាហោះ

www.budinst.gov.kh www.elibraryofcambodia.org

ហើរលើអាកាស ។

៣– ភេនទនៅខាងក្រោម នៅខាងស្តាំមានក្សត្រីគង់ក្នុងរាំងហែហមដោយពួកកីលៀង ។ មានផ្ទាំងចម្លាក់ហេងធំនៅខាងមុខផ្លូវបត់ខាងឆ្វេង មានក្បួនព្យុហយាត្រា ប៉ុន្តែនៅក្នុងក្បួននោះមានខ្មែរនិងចាមលាយឡំគ្នា មានមន្ត្រីឈរលើដំរីមួយ ។

## មុមខាងទិសអគ្នេយ៍

ពួកទាហានចេញដំណើរ ទិនមេទ័ពឈរលើដំរីមួយ ។

## រោងទងខាងត្បូង ពាក់កណ្ដាលខាងកើត

១– នៅភេនទនខាងក្រោម : មានផ្ទាំងចម្លាក់បាក់បែក ហើយមើលមិនច្បាស់ ។ ពួកទាហានចាមហែក្បួនទៅប្រយុទ្ធជាមួយមនុស្សព្រៃពួក ដែលសុទ្ធតែមានមាឌមាំ ៗ ពួកទាហានមកពីផ្លូវខុសគ្នា ក៏ប៉ុន្តែមានសាសន៍តែមួយ ។ រឿងនៅក្នុងរាំង : បន្ទាប់មកគេឃើញមនុស្សឡើងដើមដូង ហើយមានពស់មួយយ៉ាងធំទំត្រីមួយយ៉ាងសម្បើម នេះជានិមិត្តរូបនៃមហាសាគរ ម្យ៉ាងទៀតបង្ហាញពីការរស់នៅនៃពួកឥសីទិន

www.budinst.gov.kh www.elibraryofcambodia.org

សត្វដែលនៅលើគ្នី ។ មួននេះក្បួនព្យុហយាត្រានៃមនុស្ស ដែលមានបុណ្យសក្តិខ្ពស់ ៗ ហែនៅមុខព្រះមហាមេភពរាំង ដែលមានប្រាសាទយ៉ាងល្អចិញ្ចែងចញ្ចាច ។ បន្ទាប់មកទៀតមានក្សត្រីកំពុងថើបផ្កាទីងតាក់តែងកាយនៅមុខកញ្ចក់ ។

២- នៅបន្ទប់តូច ១ : មានមន្ត្រីមានមុខមាំប្រយុទ្ធនឹងគោ ហើយនៅខាងក្រោមប្រយុទ្ធជាមួយដំរី ដែលគាបផ្តួលដំរីបាន ព្រមទាំងចាប់កាន់ខាងមុខបានមួយ ។

៣- នៅចន្លោះវង់ពីរ : តាមនៅផ្ទាំងដែលបត់ពីផ្នែកខាងក្នុង មានពួកអ្នកជំនួញ នៅពីលើមានក្បួនព្យុហយាត្រា នៃពួកអ្នកចំបាំងនិងស្តេចមួយអង្គយាងចេញពីរាំង « ដោយឃើញមានដុំ, បំពង់សម្រាប់ដាក់ព្រួញ និងគំរោសសេះ » បំណែកខាងម្ចាស់ក្សត្រិវិញទ្រង់គង់នៅកណ្តាលពួកតិរច្ឆាន ។

នៅខាងមុខពីក្នុងទៅស្តាំ មានរឿងចំបាំងមួយ តែពុំសូវមានសកម្មភាពខ្លាំងណាស់ណាទេ និងឃើញមានការប្រយុទ្ធជាមួយព្រះអង្គម្ចាស់មួយអង្គទៀត ព្រមទាំងចំពោះរបស់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអគ្គិ ហើយមានភ្លើងមួយនៅមាត់ទឹក ដែលមានអពាវិង មនុស្សអង្គុយជុំវិញភ្លើង ។

បន្ទាប់មកមានហែក្បួនពួកអ្នកភ្លេង និងមនុស្សលើរូបគជបល្ល័ង្កនៅលើស្នាចេញពីភ្នំ ដែលមានតែពួកស្រី ៗ ពួកមន្ត្រីគង់ភ្នំ ។ នៅផ្ទាំងបម្លាក់ខាងក្រោម មានព្រះអគ្គមហេសីក្សត្រីមួយអង្គកំពុងរៀបរាប់ដាក់កូនក្មេង នេះហាក់ដូចជាធ្វើឲ្យយើងយល់ថា ក្មេងនេះនឹងត្រូវគេបណ្តែតបំបរបង់ចោលក្នុងត្រពាំងមួយ នៅក្បែរនោះដែលមានអ្នកនេសាទម្នាក់ជះទូកបង់សំណាញ់ ហើយនិងក្សត្រីមួយអង្គដែលមានគ្រឿងអលង្ការដោះច្រើន ហាក់ដូចជាស្រីទេពកញ្ញាចុះពីលើមេឃមក ។ បឹងនោះប្រកបដោយដើមឈូកសម្រាប់ទ្រទ្រង់នូវទេវរូប ឬមនុស្សដែលរលាយខ្លួនផុត និងពួកអ្នកធ្វើសក្ការបូជារំលឹកគុណ ។

រឿងនេះជាផ្នែកដើមនៃរឿងព្រេង ដែលធ្លាក់នៅលើផ្ទាំងបម្លាក់ខាងស្តាំនៃផ្លូវបត់ គឺរឿងប្រទុម្នៈ កូនរបស់ព្រះក្រឹស្ណៈ និងព្រះនាងរុក្មិនី ដែលបានយកទៅបណ្តែតចោលក្នុងសមុទ្រ

www.budinst.gov.kh www.elibraryofcambodia.org

ដោយពិសាចឈ្មោះ សម្បរៈ ។ កូនក្មេងនេះត្រូវជាចំណី
នៃត្រីមួយ ដែលត្រូវអ្នកនេសាទបង់បានហើយយកទៅជូន
សម្បរៈ ។ លុះដល់វះពោះត្រីបានឃើញប្រទ្យុម្នៈ (ដែលជា
កាមៈ គាថិទេពនៃស្នេហា) ។ ស្រីបំរើរបស់ សម្បរៈ គឺនាង
មាយាវតី (អវតារនៃ រតី ត្រូវជាប្រពន្ធរបស់ កាមៈ) បានយក
ប្រទ្យុម្នៈទៅចិញ្ចឹមដោយលាក់បំពួន ហើយក្រោយមកក៏យក
ធ្វើជាស្វាមី ហើយសម្លាប់ សម្បរៈចោល ។

គេឃើញក្មេងនោះមានជីវិតរស់នៅ ហើយអង្គុយលើពោះ
ត្រីដែល សម្បរៈ ធ្វើកាយវិការគាប់ជាកំណាត់ ហើយនាង
29 មាយាវតីលើកដៃទទួលកុមារប្រទ្យុម្នៈ ។

## រោងទង់ខាងត្បូង ពាក់កណ្ដាលខាងលិច

១ – នៅចន្លោះវង់ទាំងពីរ ៖ ផ្ទាំងចម្លាក់ខាងស្ដាំធូរបត់
មានស្នាមរលុបជាច្រើន គេសង្កេតឃើញមានមនុស្សដេកនៅ
ក្នុងបន្ទប់មួយ នៅក្នុងវាំង តែពេលមានប្រពន្ធអង្គុយយំនៅក្បាល
10 ជើងគេ ។ នៅផ្នែកខាងមុខ មានផ្ទាំងចម្លាក់ថ្លែងអំពីលទ្ធរបស់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះឥសូរ ដែលមានទឹកដៃពុំសូវល្អ : ព្រះឥសូរធ្លាក់ជាគាទិ-ទេពពីរបែប មួយនៅលើកដបល្អក មួយទៀតនៅលើផ្កាល្បូករីក កណ្ដាលពួកអ្នកធ្វើសក្ការបូជា ដែលម្នាក់ក្រាបផងរាំផង; មានប្រអប់ ឬ កោដ្ឋសម្រាប់ដំកល់អដ្ឋិធាតុដាក់លើកដរប ។

២– នៅតាមបន្ទប់តូច ៗ នៅខាងស្ដាំផ្លូវបត់ មានរូបព្រះឥសូរខុស ៗ គ្នា កាន់សត្រីស្ទូល៍ (ប៊្រុកថ្ងៃ) ខាងលើទិដ្ឋានពីព្រះនារាយណ៍បានដៃមួយចុះមកកសាងប្រាសាទ ហើយទ្រង់ហាក់ដូចជាជំរុំបូលមករកព្រះឥសូរ ដែលឈរកាន់សត្រីស្ទូល៍ ។ នៅភាគខាងមុខទិដ្ឋានពីរៀងដែលនេះតែគ្មានព្រះនារាយណ៍ទេ ។

៣– នៅតាមកេនទូងខាងក្រោម : មានស្រីទេពកញ្ញាហោះហើរលើអាកាស និងព្រះឥសូរកាន់គ្រឿងឥស្សរិយយសរបស់ព្រះព្រហ្ម ដោយធ្វើការរក្ដីចំពោះព្រះព្រហ្ម ។ ទេវតាពលើក្ដែលពោរពេញទៅដោយរត្នាកាឡុម្រឹក " មានខ្លាមួយស៊ីមនុស្សម្នាក់ " បានធ្លាក់តាមប្រាសាទដែលមានទ្វារបិទ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គម្ចាស់ក្សត្រីយានទៅក្រសាលក្នុងស្រះ ទៅម្ខាងទៀត មានពួកស្រីទេពកញ្ញាចីនាក់កំពុងរាំបាក់ក្បាច់លើផ្កាឈូក ខាងលើមានព្រះឥស្សរគង់លើភពបល្ល័ង្ក កណ្តាលចំណោមពួកបទ្រឹះទេវតា ។

ឆ្ងាយបន្តិចមក មានប្រាសាទព្រះឥស្សរ សាងនៅកណ្តាលស្រះ ។ តាមមាត់ស្រះមានឥសីមិនសក្តាសៅនៅ មានខ្លាមួយដេញចាប់ឥសីមួយរូប; ចំណែកពួកអ្នកកាន់ព្រះពុទ្ធសាសនា អង្គុយពាក់ផ្តាគ្នាទៅក្នុងរាំងធ្វើសក្ការបូជាចំពោះព្រះសម្ពុទ្ធ ។ នៅកណ្តាលផ្ទាំងចម្លាក់មានរូបព្រះនារាយណ៍ដៃ
/31 បួននៅមាត់ស្រះ ដែលព័ទ្ធជុំវិញដោយស្រីទេពកញ្ញាកំពុងហោះហើរ មានមនុស្សមួយក្រុមទៀតធ្វើសក្ការបូជាក្នុងចំណោមនោះមានមនុស្សម្នាក់ក្រាបសំពះដល់ដី ដោយគោរពចំពោះគោដ្ឋដែលដាក់នៅលើពានថេ ។ មានចំពះសះនៅក្នុងកូនហៃដែលធ្វើដំណើរមកក្នុងរាំង ។ ខាងជ្រុងមានដំណើរប៉ះដោយគោគមសមខាង មនុស្សម្នាក់អាឌុំផាមេបញ្ជាការ

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកពួកអ្នកបំរើម្ខាងរៀបចំដំណើរចេញ ។ នៅចុងផ្លូវបត់ មានព្រះអង្គម្ចាស់ក្សត្រីជាច្រើនអង្គកាច់ផ្កាឈូក ។ នេះប្រ-ហែលជាព្រះកេសរៀបចំ បូជនីយបេសចណ៍ត្រោះទៅវិហារព្រះ ភារិៈ១៣ ។

## រោងទងខាងលិច ពាក់កណ្ដាលខាងត្បូង

១– នៅពេលចូលខាងក្រោម : ខាងស្ដាំ មានពួកស្រី ៗ នៅក្នុងបន្ទប់ខាងមុខ មានព្រះមាកយណ៍ដៃជូនប្រគប ដោយកេតឧបកណ្ដាលលើគ្រុឌ ហើយបានបញ្ចេញបុប្ផានុភាព ដើម្បីបង្ហាញនូវប្ញូដៃដល់ប្រជាជននូវទៅ មានយក្សជាដើម ហើយមិនមានរឿងផ្សេង ៗ ជាច្រើនទៀតនៅក្នុងរាំង ។ 132

២– នៅបន្ទប់តូច : មានរឿងថ្មីទៀតនៅក្នុងរាំង ដោយមានស្រីទេពកញ្ញាកំពង់ផ្លោះដោយបទភ្លេងមួយក្រុម មានពួកស្រី ៗ កាំភ្លាបុផ្ចាំកហែលពេរ៉ែ ហេះផ្កាឈូកក្នុងស្រះ ។ តាមមាត់ស្រះមានសត្វសម្លេះគប្ពិ ហើយមានរបាំនៅខាងលើ មិនមានរឿងប្រហែលគ្នាពេលមនុស្សប្រុសពីរនាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

៣- នៅបន្ទោះវង់រាំងពីរ : ខាងស្តាំ មានការធ្វើសក្ការបូជាដល់ព្រះនារាយណ៍ដំបូង ដែលមានតាំងតែពីពេលកសាងប្រាសាទ ម្ល៉េះមកម្ល៉េះ ។ តាមក្បាច់ចម្លាក់នៃផ្នែកខាងខាងក្រៅ មានតួតុក្កតាទំហំប្រហែលតាញាប់ឲ្យធ្លាក់មើល ខ្លះទំពក់ថ្ពាល់យមតបត់ តាមរបៀបពិសេសម្យ៉ាង ដោយប្រើគស្លុត ហើយដាក់ទៅវិញ ខ្លះទៀតទំផ្លូនគ្រឿងសំភារ មិនប្រាប់វត្ថុ ទៀត ។

ខាងមុខមានគ្រឿងសក្ការបូជាចំពោះព្រះនារាយណ៍ ហើយមានស្រីទេពកញ្ញាជាអ្នកបំរើថ្វាយ ។ មានធ្វើពិធីសម្ពោធប្រាសាទ , រឿងទាវបរណ៍ ដោយមានលេងល្បែងចតុរង្គក្នុងទូក ដែលប្រកបដោយការតុបតែងយ៉ាងក្រអេតអាយ ហើយមានទូកតូចជុំវិញ និងការប្រយុទ្ធគ្នា ៖ ដូចគ្នានឹងបុណ្យនាគ-ចរណ៍នៅទ្វារពេកី មេរមណ្ឌបមុខខាងទិសខាងកើតនៃអគ្គិកេត្ត ។ ខាងក្រោមបន្ទប់ គេឃើញព្រះឥសូរនិងព្រះនារាយណ៍កំពុងកាត់ក្បាលយ៉ាងអស្ចារ្យ ។ ផ្ទាំងចម្លាក់ខ្លះទៀតរៀបរាប់ពីការ

www.budinst.gov.kh www.elibraryofcambodia.org

រស់នៅរបស់ឥសី ដែលគង់ខ្លះគង្គុយចង្ក្រមណ៍ការនាគម៉ែនៅ

ក្នុងគុហា ហើយមិនមានឥសីខ្លះទៅបេះផ្កាឈូកនោផិតសត្វ

ភក់មួយដែលចិកត្រីដោយចំពុះ ។

## រោងទី៤ខាងលិច ពាក់កណ្ដាលខាងជើង

១– នៅចន្លោះរង់កាំងពារ : ខាងស្ដាំផ្លូវបត់ មានរឿង

ទាក់ទងនឹងនៅក្នុងរាំងដែលត្រូវលុបអស់ជាច្រើន ខាងមុខមាន

ផ្ទាំងចម្លាក់ប៉ុផ្ទាំង ដែលពណ៌នាអំពីក្បួនព្យុហយាត្រាទ័ពដោយ

មានមេទ័ពជិះសេះ មិនមានពីរនាក់អង្គុយក្នុងរថកង់ពីរសម្រាប់

ប្រយុទ្ធក្នុងសង្គ្រាមសូម្បីដោយសេះ ។ ខាងឆ្វេងផ្លូវបត់

មានការហែត្រាទ័ពចូលដំណើរទៅមុខទៀត ។

២– នៅតាមបន្ទប់តូចៗ : ខាងស្ដាំផ្លូវបត់ មានការ

សន្ទនាគ្នារវាងមេទ័ពពីរនាក់នៅក្នុងរាំង ស្រីស្នំជួយតុបតែង

កាយឱ្យក្សត្រី ។ ខាងឆ្វេងមានប្រាសាទមួយ ដែលបិតបាំង

ដោយគំរបពីលើដែលមានកាន់ជាសាជីប្រហែលជា " មណ្ឌប

សំរាប់រក្សាយសពាទេវតា " ។ ខាងមុខមានកន្ទេលសម្រាប់

www.budinst.gov.kh www.elibraryofcambodia.org

ជាទីប្រជុំនៃពួកព្រាហ្មណ៍ ដែលមានខ្លះអង្គុយព័ទ្ធជុំវិញក្រោមមណ្ឌបមានដំបូលតែមួយ មានក្អានធ្នូមួយសំរាប់បាញ់ព្រួញ ចំណែកមនុស្សខ្លះទៀតរៀបចំគ្រឿងសាវុធយុទ្ធកណ្ឌ ។

៣– ផ្ទាំងនៅខាងក្រោម : ផ្ទាំងចម្លាក់ធ្លាក់ចុះមកអស់ភាគច្រើន ផ្ទាំងនេះបង្ហាញអំពីការកូរទឹកសមុទ្រ ។ ចម្លាក់ដែលនៅសល់ជាចំណែកដែលមានគុណសម្បត្តិពិសេស ។ ជាដំបូងមានមន្ទីរសន្និបាតនៃពួកព្រាហ្មណ៍ រួចមានស្រីទេពកញ្ញាហោះហើរលាយឡំនឹងបក្សី ។ នៅក្រោមនោះសត្វពស់មួយធំ ក្បាលទាញដោយពួកយក្ស កន្ទុយទាញដោយពួកទេវតា ហើយព្រមទាំងមានហនុមានមកជួយថែមទៀតផង ។ មានអណ្តើក « កុម្មាវតារៈ » វិស្ណុអវតារ នៅបាតសមុទ្រ ដើម្បីជាជំនួយដល់ការកូរទឹកអម្រឹតឲ្យពួកទេវតាផឹកកុំឲ្យចេះស្លាប់ ដូចនោះវត្តិវត្តដែរ ។

គេសង្កេតឃើញបានពីរ : បានព្រះអាទិត្យនិងព្រះចន្ទ ដូច្នេះហើយបានជាឃើញមានជបមួយ សម្រាប់ត្រងទឹកអម្រឹត

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានពួកទេវតានិងពួកអសុរ ( យក្ស ) ប្រាថ្នាចង់បាន ។ ទៅខាងជ្រុងមានព្រះភាទេពមួយអង្គ គង់លើសត្វស្វាបចេញបង្ក្រាបពួកអសុរក្នុងពេលមានចំបាំង ដោយមានមេទ័ពឈរលើរាជរថដែលទឹមសត្វគោពោងអស្ចារ្យ ។

# មុមនៅទិសពាយ័ព្យ

## ក្បួនយាត្រាទ័ព

## ជញ្ជាំងខាងជើង ពាក់កណ្ដាលខាងលិច

១- នៅពេលចុងខាងក្រោម : មានផ្ទាំងចម្លាក់បី និងមានអំពីរឿងនៅក្នុងកាំង ។ នៅតាមផ្ទាំងចម្លាក់ពីរទៀតមានក្បួនព្យុហយាត្រានៃកងទ័ព ដែលហាក់ដូចជាទៅចាំទទួលសំណោយ រៀងៗខ្លួន ហើយដើរដំរង់ឆ្ពោះទៅក្នុងមួយដែលមានសត្វច្រើនគ-ពាទ្យាហារ ដូចជាដំរី ខ្លា រមាស ជាដើម ។ បន្ទាប់មកមន្ត្រីម្នាក់ជាឧត្ដស់ ដើរកាត់តាមស្រះជំរំទៅវិហារដែលខ្ទារះរិចផត ។ បន្ទាប់មកគេឃើញវិហារមួយទៀត ដែលមានសភាពស្អាតជ្រៀបមានផ្ចុំបួលពីរ ។ 136

www.budinst.gov.kh www.elibraryofcambodia.org

ពួកឥសីលុតជង្គង់ទទួលក្បួនហែមួយ ដែលមកពីខាងត្បូង ដឹកនាំដោយមេទ័ពពីរនាក់ ដែលមានមាឌមាំកាន់ប្បូកផ្ចឹ ៗ ពួកនេះប្រហែលជាទេវតានិងទេព្ធីតានៅក្រោយម្ចាស់ ព្រោះរឿងនេះនិយាយអំពីសំពៅ ៣ ប្រភេទដោយការគុបផែនយ៉ាងស្រស់ ហើយមានទំហំធំ ៗ នៅលើសំពៅពីរមានមនុស្សកាត់សក់ខ្លី និងមេទ័ពកាន់ប្បូកផ្ចឹ ឯសំពៅមួយទៀតពេញដោយមនុស្សមានផ្កាគ្របលើក្បាល ៗ

២– នៅតាមបន្ទប់តូច ១ : នៅខាងមុខ ក្រោមការហោះហើរនៃស្រីទេពកញ្ញា នៅខាងត្បូងព្រះឥសូរមានដៃ ១០ កំពុងកាត់ក្បាច់តាមចង្វាក់ភ្លេង ព្រះនារាយណ៍នៅខាងស្តាំ ព្រះព្រហ្មមុខ ៤ នៅខាងត្បូង ជាមួយគណេស ចំណែកខាងក្រោមវិញមានពពួកគុម្ពលេបព្រះចន្ទ្រ ៗ នៅតាមបែបផែនផ្ទាំងផ្ទៃបត់ មានឥសីនៅលើភ្នំ ព្រះឥសូរគង្គុយលើជ្រូកមួយយ៉ាងធំ នៅក្នុងបន្ទោះព្រះនារាយណ៍និងព្រះព្រហ្ម ៗ

៣– នៅក្នុងបន្ទោះវង់ទាំងពីរ : ខាងស្តាំផ្ទៃបត់ មាន

www.budinst.gov.kh www.elibraryofcambodia.org

ព្រះឥស្សូរដែលព័ទ្ធជុំវិញដោយឥសីនិងពួកស្រី ។ ព្រមទាំងមហាឫសី បាពវតី ឯគោ ណាំឌិនឈរនៅក្បែរនោះ ។

នៅខាងមុខ មានពួកឥសីអង្គុយការនាធម៌នៅក្នុងព្រៃភ្នំ ហើយមានស្រីម្នាក់ បានរៀបចំតុបតែងកាយយ៉ាងស្រស់ឆើតឆាយ បង្ហាញនូវរូបភាពនៃខ្លួនតាមចន្លោះទ្វារនិងបង្អួច នៅចន្លោះព្រះអង្គប្រាសាទមួយអង្គ ឬ អាទិទេពមួយ និង ឥសីមួយអង្គ គេឃើញមានលិង្គនិងសត្វតុក្កែមួយ ។ នេះជារឿងព្រេងមួយដែលយើងបានឃើញនៅអង្គរវត្ត កាលដែលក្រុងរាពណ៍ កាឡាខ្លួនជាព្រះឥន្ទ្រ ចូលទៅរួមមេត្រីជាមួយនឹងមហេសីរបស់ព្រះឥន្ទ្រនៅក្នុងបន្ទប់ ។ នៅកន្លែងខ្លះទៀត ថ្លែងពីការហោះចុះនៃទេពធីតាឈ្មោះ គង្គា ថ្លែងកាលព្រះកាមៈ ទេវតានៃសេចក្តីស្នេហាបាញ់ព្រួញផ្ដោះទៅព្រះឥស្សូរ ដែលកំពុងធ្វើឈានលើកំពូលភ្នំមួយ ដោយមានកិរិយាព្រះនាងឧមានៅក្បែរផង ។ ព្រះឥស្សូរទ្រង់ក្រោធក៏តបទៅវិញ ។ ឯព្រះកាមៈត្រូវដួលដេកស្លាប់ ដោយចាញ់ឫទ្ធិបារមីរបស់ព្រះឥស្សូរ ហើយឃើញ

www.budinst.gov.kh www.elibraryofcambodia.org

មហេសីនៅខាងចុងជើង គោណន្ទិន នៅតាមចំពក់ភ្នំ ។ ផ្ទាំងថ្មម្ខាងនេះ បានបញ្ចប់ដោយរឿងមិនច្បាស់មួយ ដែលនិទានពីព្រះរាជាទ្រង់ប្រជុំនាម៉ឺនមុខមន្ត្រីក្នុងវាំង ។

នៅខាងចុងផ្ទាំងថ្ម ព្រះឥសូរជិះលើគោណន្ទិន ចេញទៅកាន់សាកលលោក ។

## រោងទងខាងជើង ពាក់កណ្ដាលខាងកើត

១– នៅចន្លោះវង់តាំងពីរ : ខាងស្ដាំផ្ទាំងថ្ម ព្រះឥសូរជិះលើគោ ណន្ទិន ជាមួយនិងមហេសីដែលនៅទីនោះ គេឃើញនាគពហុក្បាលច្រើន នៅខាងក្រោមមានស្រីទេពអប្សរឈររបាំតាក់ក្បាច់ ។

នៅខាងមុខ មានគ្រឿងប្រដាប់សម្រាប់បូជាសពមនុស្សម្នាក់ ដែលគេហែតាមផ្ទាំងថ្មម្ខាងក្រោម មានឈាបនស្ថាននិងមណ្ឌបសម្រាប់ធ្វើពិធីបញ្ចុះសព នៅលើក្បាលយក្សមួយ ។ មានរឿងប្រយុទ្ធគ្នារវាងកងទ័ពបាណ្ឌវៈ និង កៅរវៈ ក្នុងរឿងមហាភារតៈ ព្រះឥសូរក្នុងខ្លួនជា កិរាត ប្រយុទ្ធនឹងអជ៌ុន

www.budinst.gov.kh www.elibraryofcambodia.org

ដោយសារតែជ្រូកព្រៃមួយ ដែលម្នាក់ៗ ដណ្តើមថាខ្លួនបាន សម្លាប់ ៗ ក្រោយមកព្រះឥសូរបង្ហាញរូបព្រះអង្គពិត អជ្ជុន ទទួលទោសពីព្រះឥសូរ ហើយព្រះឥសូរក៏ឲ្យគ្រឿងសាស្ត្រាវុធ ដល់អជ្ជុន ដែលយកទៅប្រើការនៅថ្ងៃក្រោយទៀត ។

នៅខាងត្បូងក្លោង មានបន្ទប់តូចមួយជុំគ្នានៅក្នុងកង លើក ដែលមានស្រីទេពធីតា ៗ រូបមានរឿងព្រេងនិទានក្នុង ពិពណ៌នាដែលបន្ទប់ព្រះឥសូរស្ថិតក្នុងទីកណ្តាល និងការរៀបរៈ នៃគ្រឿងពិពណ៌ ដែលយើងយល់បានដោយសារក្បាច់ម្នាក់នៅ អង្គរវត្ត និងក្បាច់ខ្លះទៀតដែលធ្វើឲ្យយើងពុំអាចបំភ្លេចបាន បាន ដូចជាក្បាច់តារាងរងឹមដោយហត្ថ ។

នៅតាមផ្លូវពត់មានរឿងពីរដែលធ្លាក់ត្រួតលើគ្នា ។ 140

២ - នៅតំបន់ខាងកើត : មានតួស្រីបំរើការទំនួន ។ បន្ទាប់មកទៀតខាងលើមានឥសីស្រួចនៅលើថ្ម តាមាស់ទឹក ហើយមិនមានក្រុកដៃបីមុខនេះការបណ្តាប ខាងក្រោយមាន ដើមដូង ពពួកកុម្ភកណ្ណ ព្រាហ្មណ៍គ្នានព្រះពោធិសត្វនៅទេ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅតាមវិហារសន្ធាន មានរូបសំណាកព្រះនារាយណ៍និងព្រះនាងលក្សីជាមហេសី ។ ឆ្ងាយបន្តិចមកទៀត ព្រះឥសូរនិងពួកអ្នកធ្វើសក្ការបូជា នៅខាងក្រោមមានស្រីទេពកញ្ញា ហាក់ដូចជាក្បួនគ្រួមួយអង្គ មកបន់ស្រន់គាល់ទេពមុនពេលធ្វើដំណើរចេញទៅច្បាំង ។ មានក្បួនព្យុហយាត្រាខាងពលថ្មើរជើងនិងពួកក្មេង មានចំពង់រំ-សេះ ព្រមទាំងក្បែគ្រឿជាច្រើនអង្គគង់លើអង្រឹងស្នែង មានគោជ្ជដាក់ឆាតុមួយយ៉ាងធំដាក់លើរទេះទឹមដោយគោ ។ គេធ្វើដំណើរមកដល់ផ្ទះមួយគ្មានមនុស្សនៅបន្ទាប់មកគេឃើញស្ដេចយានចុះពីរាជរថ ដែលមានកង់ ៦ ហើយយានចូលប្រាសាទដែលមានរបាំរាំច្រៀង សម្រាកកំដរបរិយាកាសនៅពេលល្ងាចដ៏សែនរីករាយ ។

## មុមនៅទិសព្យាសាន

ក្បួនព្យុហយាត្រា ដោយសង្កាត់ ១: តៃតុំស្ងួរសំខាន់ ។

## រោងទងខាងកើត ពាក់កណ្ដាលខាងជើង

១— ភេនចងខាងក្រោម : មានក្បួនព្យុហយាត្រាយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ធំៗ ដែលគេសង្កេតឃើញមានរបៀបទុកសក់ពីរបែប : "សក់កាត់ខ្លីនិងសក់គ្របផ្កា" ។ នៅខាងក្រោមមានទ័ពថ្មើរជើងដែលព័ទ្ធជុំវិញដោយអ្នកជិះសេះ, ចំណែករាជរថក្សត្រវិញទឹមដោយសេះក៏មាន អូសដោយដៃក៏មាន ។ នៅខាងលើរទេះធំមួយកង់៦ មានហង្សា ព្រះអង្គម្ចាស់មួយអង្គគង់ ដោយមានអគ្គមហេសីពីរអង្គអមផង ។ ម្ចាស់ក្សត្រគង់លើអង្រឹងស្នែងដែលមានក្អែនព័ទ្ធជុំវិញ ចូលតាមក្លោងទ្វារពិសេសមួយ ដែលមានរាជបល្ល័ង្កនៅទំនេ និងស្ដេចប្រកបដោយឫគង់លើដំរីហែហមដោយមេទ័ពពីរនាក់ ។

ចូលតាមទ្វារ ដែលមានផ្ទាំងថ្មមួយតូចបង្ហាញពីស្ដេចមួយអង្គ ប្រហែលជាស្ដេចយាងទៅបួងសួងការទេពមុនពេលចេញទៅធ្វើចំបាំងនឹងនក្រាបថ្វាយបង្គំព្រះឥសូរនៅពីលើរាជបល្ល័ង្ក ។

២ - បន្ទប់តូចៗ : ក្នុងស្រះមួយមានទូកពីរដែលសោតមក ហើយនៅក្នុងទូកនោះគេឃើញមានក្បាលមនុស្សពីរ ។ អ្នកមុជទឹកចំមុជ ហាក់ដូចជាចាំការរករបស់មានតម្លៃប្រហែលជាជុំ

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាងដែលគ្មានរូបរាងច្បាស់លាស់ ដែលគេឃើញលើស្នា យកទៅដាក់លើកដបល្អក ៗ ស្រីទេពកញ្ញានិងបក្សីហោះ ហើរព្រោងព្រាតទៅខាងលើរឿងទាំងអស់នេះ ៗ

នៅខាងត្បូងផ្លូវបត់ : គេប្រទះឃើញរឿងនិទានអំពីការ បំផ្លាញរូបសំណាកដែលមានភេទជាស្រី ៗ គេបង់រូបនេះ ហើយអូសដោយមនុស្សនិងដំរី ៗ វេជបណ្ឌិត បុស បាន យល់ថាជារឿងជួយសង្គ្រោះស្ត្រីម្នាក់ឲ្យរួចពីការឃុំឃាំង ៗ នៅតាមថ្មដែលនៅលើក្បាលយើង គេបានគាស់ទីនបបគាស់ ដំរីបានខំវែកថ្ម នៅខាងក្រោមគេបានអនុវត្តន៍តាមរបៀប ចាស់ ដើម្បីនឹងកំរើកថ្ម : គេដុតថ្មដោយភ្លើងរួចហើយគេ បាចទឹកខ្លះ ៗ រឿងនេះ ហាក់ដូចជាឲ្យគតិមានដល់យើង ពីរឿងព្រេងជាគំរូ ដែលតំណាលពីព្រះរាជាមួយអង្គ ដែល បានយាងទៅក្រសាលព្រៃភ្នំ ហើយបានឮសំឡេងស្រីម្នាក់ ស្រែកច្រៀងគំសូញជាទីគាប់ព្រះទ័យ ទើបទ្រង់គាស់ថ្មចេញ ហើយទ្រង់ទតឃើញព្រះអង្គម្ចាស់ក្សត្រីមួយអង្គ នាមដើម នាគី

www.budinst.gov.kh www.elibraryofcambodia.org

ដែលទ្រង់នាំយកទៅអភិសេកជាមហេសី ។

រឿងខាងលើនេះ អាចជាប់ទាក់ទងទៅនឹងរឿងពីមុនមក ដែលបង្ហាញពីប្រភពដើមរហូតមក ដែលគេត្រូវការគោរពបូជាជាទីបំផុត ។ នៅប្រភពខ្លះទៀត គ្រាន់បញ្ជាក់ពីរឿងស្តេចគំលង់ មិនមានព្រះឥសូរនៅជិតទីនោះផង នៅផ្ទាំងចម្លាក់ខាងក្រោយបំផុតនៃរោងទងខាងក្រោម មានរូបឥសីកំពុងផ្សំថ្នាំកែរោគទៅ មុខរោងទងនេះ មានការគោរពចំពោះមន្ត្រីម្នាក់ដែលបានជួយសង្គ្រោះដល់ខ្លួន ។

៣– នៅបន្ទាះវង់ចាំងពីរ : រៀបរៀងដោយលោកគ្លូវបើរ ដែលត្រូវមើលពីឆ្វេងទៅស្តាំ ។ មានស្តេចមួយអង្គសោយរាជ្យនៅក្នុងវាំងដែលមានអគ្គមហេសី ហែហមដោយមន្ត្រីរាជការ និងពួកស្រីរបាំ ។ ស្តេចអង្គនេះទ្រង់បានប្រយុទ្ធជាមួយនឹងពស់មួយ ពស់នោះក៏ព្រួសពិសមកលើព្រះកាយរបស់ព្រះអង្គ ។ ដោយត្រូវនឹងពិសពស់នោះ ព្រះកាយនៃព្រះអង្គក៏ក្លាយទៅជាកើតរោគឃ្លង់មួយរំពេច ។ ព្រះអង្គទ្រង់ត្រាស់

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជាយ៉ាងប្រញាប់ ឲ្យពួកពលបុរសទៅនិមន្តឥសីពីក្នុងព្រៃមក ព្យាបាលរោគរបស់ព្រះអង្គ ។ ព្រះអគ្គមហេសីក៏បានទៅសាកសួរពីរោគនោះដែរ នៅទីបំផុត គេសង្កេតឃើញទ្រង់ជុំហើយ មានឥសីមួយដាក់ថ្នាំព្យាបាលរោគថ្វាយព្រះអង្គ ។ គេសង្កេតឃើញក្រោយពីរឿងនេះមក មានរឿងប្រយុទ្ធគ្នាជាមួយពស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបាពួន

សាងនៅរាជ្យ គ.ស. ១០៦០ ដោយស្ដេចព្រះបាទព្រះឧទ័យាទិត្យវរ្ម័នទី ២ ការជួសជុលដោយក្រុមសាលាបារាំងចុងបូព៌ា តាំងពីឆ្នាំ គ.ស. ១៩០៨ មកដល់សព្វថ្ងៃនេះ ។ ប្រាសាទនេះ សាងឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ប្រើជាព្រះវិហារព្រះឥសូរ ។

ប្រាសាទបាពួនស្ថិតនៅជាប់នឹងកំពែងនៃរាជធានីព្រះនគរធំ ហើយជាប្រាសាទដែលមានទំហំធំ [illegible] ស្របនឹងបណ្ដោយទិសត្បូងនៃព្រះលានជល់ [illegible] ប្រាសាទបាពួនដែលនៅខាងត្បូង ។ ប្រាសាទ [illegible] នេះសាងនៅជិតៗគ្នា ប៉ុន្តែជាប្រាសាទដែលសាងនៅពេលខុសគ្នា ហើយមិនមានលក្ខណៈដូចគ្នាទៀតផង [illegible] ដែលគេតុបតែងនឹងផែនរឿងរ៉ាវ [illegible] ជាច្រើនទៀតដែរ ។ នៅតាមមុខ [illegible]

ក្បែក ៗ នៃជញ្ជាំងសម្រាប់ទប់ទ្រដីទួលនៅផ្នែកខាងជើង ។ ផ្ទៃប្រាសាទនេះ មានរាងបួនជ្រុងទ្រវែង បណ្តោយ ៤២៥ ម៉ែត្រ ទទឹង ១២៥ ម៉ែត្រ ។

ឯអគារផ្ទានដែលខ្ពស់ ប្រវែងពីកើតទៅលិច ១២០ ម៉ែត្រ ពីជើងទៅត្បូង ១១០ ម៉ែត្រ ស្ថិតនៅជាប់នឹងកំពែងព្រះកាងកំង ហើយទីនឹងដីទួលតាមភាគស្នាមមុខខាងជើង គឺមានភាពស្រះជៀនគ្នានឹងដីទួល នៃស្រះខាងជើងរាជធានីព្រះបាទយសោ-វរ្ម័ន ដែលសាងនៅលើកំពូលភ្នំបាខែងក្នុងសតវត្សទី ៩ ។

បរិមាណនៃរូបភាពប្រាសាទនេះ គេចាត់ទុកបានថាជាប្រាសាទមួយយ៉ាងធំ ហើយក្បែរក្រៃលែងក្នុងចំណោមប្រាសាទផ្សេងៗ តាម ជីវតាគួន ប្រាសាទបាពួនគឺជា « ប្រាសាទស្ពាន់មានកំពស់ខ្ពស់ជាងប្រាសាទមាស ( បាយ័ន ) ដែលមើលទៅគួរឲ្យរំភើបចិត្តពន់ពេកក្រៃលែង » ( ចុងសតវត្សទី ១៣ ) ។

តាមសិលាចារឹកព្រះគោក ពិនលផ្នែកវាលគេគេឃើញ ទោះដឹងប្រាសាទបាពួនទេះនៃត្បូង លោក សឺដែស បានថ្លែង

www.budinst.gov.kh www.elibraryofcambodia.org

ប្រៀបប្រដូចថា ប្រាសាទបាពួននេះ មានគំនិតការសមជ៍ «ភ្នំមាស» ដែលជា «លំអនៃលោកទាំងបី» ហើយសាងឡើងដោយព្រះបាទឧទយាទិត្យវរ្ម័នទី ២ នៅកណ្តាលព្រះរាជធានីនគរធំ ។ គឺជាកន្លែងដំកល់សិវលិង្គនៃព្រះឥសូរ ពិត ហេតុនេះប្រាសាទ ក្រុមការក៏ សាងឡើងអនុលោមទៅតាម ទស្សនៈនោះ ហើយជាប្រាសាទមួយដែលគេចាត់ទុកជាជាទេវាល័យនៃរាជធានីមួយនោះ នៅចន្លោះកណ្តាលរាជធានីភ្នំបា-ខែង និង រាជធានីបាយ័ន ។

ទោះជាត្រូវស្រោបដោយកាប់ឆ្ការ ប្រាសាទបាពួននេះជាភ្នំមួយដែលមានទម្រង់ជាប្រាំជាន់គគុញ្ញពីលើ ហើយដែលមនុស្សបានរៀបរៀងខ្ទេចខាតអស់ជាច្រើន ។ សព្វថ្ងៃនេះប្រាសាទបាពួន បាក់ស្រុតជាលំបាកឡើងបង្ហាញឲ្យឃើញនូវស្នា-មេឃលោកបែលស្កាប់ទៅ រំលៃផ្សេងៗយ៉ាងរឹងប៉ុន កំពស់សើខឹងតាក់ ការការពារ ដែលប្រកបដោយបច្ចេកទេសមានតម្លៃបំផុត ទៅតាមគំនិតវិចិត្រ របស់ទ្រង់មួយយ៉ាងក្នុងគតាមស្ថានភាព

ប្រាសាទតូចដោយឡែកសាងពីថ្មភក់ ។ ប្រាសាទនេះ សាងនៅលើទួលខ្ពស់មួយកន្លែង ដោយផ្គុំនូវថ្មភក់ និងថ្មបាយ-ក្រៀមយ៉ាងធំៗ គួរឲ្យស្ងើចសរសើរទឹកមិនកើត ។

នៅប្រែបទឹងព្រះពលាបអន្ទ្រធំ មានផ្លូវមួយចូលទៅកាន់ប្រាសាទបាពួន ។ នៅក្បែរផ្លូវនោះគេបានសង់មណ្ឌប ៣ មានគោបុរៈកងគោងជាកាកបាទគ្របទៅទិសនៃ សំណង់ទាំង ៣ នេះសាងនៅលើគ្រឹះកោងកំពស់ ដែលបញ្ចេញឲ្យជីងជាមុខនៃគ្រឿងបរិក្ខារតាំងឡាយ ។ ថ្ងៃក្រោយមកគេបានយកប្រទង់ព្រះបដូបនេះ មកប្រើក្នុងសំណង់មុខខាងលិចនៃប្រាសាទអន្ទ្រវត្ត ។ គួរប្រាសាទធំស្ថិតនៅក្នុងកំពែងទី ៤ ដែលគេបានឃើញរូបឆ្លាក់ផ្តាំងហើយ និង សសរខ្ទះ នៅសាលក្រុម ។ គួរឲ្យខ្លាច ។ នៅតាមផ្លូវដែរនេះមានជំកាល់សិរីលិង្គពីលើយ៉ាទីឲ្យមាកខ្ញុំ ៣ ។

មានផ្លូវមួយសាងតពះគោបុរៈនេះទៅបណ្ដោយ ២០០ម៉ែត

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានទ្រង់ទ្រាយជាស្តូបមួយ ប្រកបដោយសសរ[illegible] ។

[illegible] ឲ្យមាន[illegible]ជាប់គ្នាជាចំណុចមួយ

ទទឹង ៥ ម៉ែត្រ [illegible] ។ គេបាន

គាស់លាយដីដែលលើក[illegible] ដើម្បីឲ្យមើលទៅឃើញនូវ

គ្រឿងបរិ[illegible]តំនូរឡាយនៃសសរទ្រ

នៅតាមបណ្តោយ [illegible] នៃមណ្ឌបមួយមានរានហាល

ម្ខាង មានការខូចខាតអស់ជាច្រើន ហើយមានផ្តាំផ្កាប់

ចម្លាក់លំអច្រើន [illegible] របស់ខាងត្បូង ។ មានទីលាន ២

លាន មួយលាតសន្ធឹងឆ្ពោះទៅខាងជើង មួយទៀតនៅខាងត្បូង

ឆ្ពោះទៅតាមបាត់ [illegible] ដែលមានបណ្តោយ ៣៧ ម៉ែត្រ ទទឹង

១៨ ម៉ែត្រ ។

តួប្រាសាទមានរាងជាស្រង់ខ្ពស់កក់តែត មានជណ្តើរ ៥

ថ្នាក់ឡើងទៅ ។ ជណ្តើរនេះសាងពីថ្មភក់ប្លុកពីជណ្តើរគាំង

ខ្លួយ [illegible] សតវត្សទី ៩ និងទី ១០ ព្រោះជះ[illegible]

តាំងនេះមានរបបផែន ៤ ជ្រុងស្មើ ហើយមានថ្នាក់ភ្ជាក់ខ្លួន

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបាពួន

មើលចំពីខាងជើង

www.budinst.gov.kh www.elibraryofcambodia.org

រហូតដល់ផ្នែកខាងលើ ៗ នៅខាងក្រោមវិញក៏មានកិនភាគ ប្រហែល ៗ គ្នាដែរ ៗ បើតាមទិសស្របនេះវិញ ប្រាសាទនេះ ពុំមែនសាងចំពោះនឹងផ្លូវដែរឡើយ ៗ ដែរចាំងនេះព័ទ្ធជុំវិញ ថ្នាក់ដំណើរទី ១ ថ្នាក់ទី ៣ និងថ្នាក់ទី ៤ ៗ ឯផ្នែកខាង លើមានកំពស់ពីដីទៅ ២៤ ម៉ែត្រ ៗ

នៅតាមជញ្ជាំងគ្រឹះ មានថ្នាក់ជាក្បាច់គ្របគល្បូកយ៉ាង ម៉ាំហើយល្អៗ តែពុំមានថ្នាក់លំអដោយរូបចម្លាក់អ្វីទេ ៗ ដែរខាងក្រៅកំផែងនេះ ទើបនឹងសាងឡើងនៅពេលបន្ទាប់ ក្រោយមកទេ ព្រោះគេឃើញមានស្នាកស្នាមដែលធ្វើព្រាង ដោយគំនូរថ្មជាច្រើនយកទៅរៀបបន្តុបលើគ្នា នៅផ្នែកខាង លិចមានថ្នាក់ព្រះពុទ្ធរូបចូលនិព្វានមួយអង្គ ដំកល់នៅលើដំបូល ដែរ គេអាចយល់បានថា លក្ខណៈយ៉ាងណាៗនៃគោបុរៈដែល មានផ្ចាំងចម្លាក់ មានកំពស់ជាងពាក់កណ្តាល ហើយមាន គាំទ្រតាំងនៅជាដុំធ្មុតាគ្មានការខូចខាតអ្វីឡើយ ៗ ឯប្រាង្គ នៅតាមជ្រុង បាក់បែកអស់ជាច្រើន ដូចគោបុរៈនៅខាង

ជើងទិសខាងលិចដែរ ។

គេចាប់ផ្ដើមដំណើរចូលទៅកាន់ប្រាសាទនេះតាមគោបុរៈខាងកើត ព្រោះគោបុរៈនេះមានទ្វារចូល ៣ ឆ្ពោះទៅកាន់ដំណើរដែលពុំសូវពោត ។ នៅតាមក្លោងទ្វារបន្ទោះថ្ងកណ្ដាលហើយនិងយ៉ទិសខាងជើង គេសង្កេតឃើញនូវលក្ខណៈតាំងឡាយនៃប្រាសាទនេះ សាងអនុលោមទៅតាមទំនៀមទម្លាប់នៃក្បាច់រចនាខ្មែរក្នុងសម័យបុរាណ ។ នៅកន្លែងនេះគេសង្កេតឃើញថ្មទទឹងទ្វារមួយសាងពីថ្មភក់ ដែលមានដុំឈើដាក់តម្រួតពីលើ ស្ថិតនៅនឹងកន្លែងដើម ដោយមានការរិចរិលអស់ជាច្រើន ។ គោបុរៈនេះមានលំអជាង
153 គោបុរៈ ៣ ទៀត ដែលមានក្លោងទ្វារតែមួយ ព្រោះជាគោបុរៈដែលមានកំពូល ហើយមានយ៉ដំបូលរាងកោងតម្រួតលើគ្នា ៗ មើលពីខាងក្រៅទៅ គេនឹងឃើញនូវចម្លាក់យ៉ាងល្អៗ ដែលឆ្លាក់ជារូបទេវតា និងរូបមនុស្សគួរ ៗ អនុលោមទៅតាមបេតនារម្មណ៍ដ៏ត្រចះត្រចង់ មិនតែប៉ុណ្ណោះមានឆ្លាក់ជាផ្កា

www.budinst.gov.kh www.elibraryofcambodia.org

ល្អគួរគាប់ពណ៌ថ្នាំទឹកពីរ ៤ ផ្ទៃស្មើ ដែលគេមើលទៅហាក់ដូច ជាផ្ទាំងកន្ទូរព្រំបៀម ដែលគេបានប្រទះឃើញនៅប្រាសាទ បន្ទាយស្រី ។

នៅតាមផ្ទៃពិដានខ្លះ គេបានប្រទះឃើញថ្នាំលាបជាច្រើន នៅត្រង់ផ្ទៃវិសាលក្បាច់ ដែលនៅពេលនោះក្រៅក្នុង ...នៅពេលថ្ងៃ [illegible] ។ [illegible] ... [illegible] [illegible] ដែល [illegible] ៣ ពណ៌ជាភាគច្រើន ហើយក្រែបជាលម្អ ... ៤ ដែលមានរូបរាងប្លែកជាច្រើនឈាក់ទៅ ... ជាបន្ទាត់ពណ៌ពីបុរាណមក ។ ម្យ៉ាងទៀតនៅតាមបាត់ទ្វារមាំង ឡាយ ដែលមានផ្ទៃសង់នៅលើសសរជន្ទល់ខ្ពស់ៗ ដូចជានៅ តាមប្រាក់ទី ២ នៃប្រាសាទឥន្ទ្រវត្តិដែរ ... ដែលគេបាន ឃើញនៅក្នុងនេះទាំងប៉ុន្មាន ... [illegible] ... ទាំងលើបន្ទាយ ។ ... នៅទៀត ... [illegible] ... នៅវាំងក្រុង នៅតាមព្រះវិហារ ... [illegible] ... យ៉ាងច្រើន ដែលជាហេតុបង្ហាញឲ្យឃើញនូវ [illegible] ។ [illegible]

www.budinst.gov.kh www.elibraryofcambodia.org

មានក្បាច់ចេតាភោគនាគ ៗ ដូចជាក្បាច់ ដែលគេធ្លាប់ជួបប្រទះ រួចមកហើយ ៗ ព្រមទាំងមានឆ្លាក់លំអជារូបទេវតា រូបសត្វ និងផ្កាភ្ញីជាច្រើនទៀត មិនតែប៉ុណ្ណោះមានឆ្លាក់ជារូបឥសី នៅកណ្ដាលគំនូរតូច ៗ នៃផ្ទាំងថ្មរាក់អន្ទុលោបទៅតាមចំនៀម មាត់យោធប្រាសាទ ។

នៅមុខទ្វារត្បូងមានជណ្ដើរស៊ីម៉ង់ត៍ដើម្បីឲ្យឡើងទៅព្រះ ស្រស ព្រោះកាំជណ្ដើរដើមទាំងដើមត្រូវសឹករិចរិលអស់ជាច្រើន ដូចជាជណ្ដើរនៅតាមមុខដទៃទៀត ដែលសុទ្ធតែជាជណ្ដើរ ខ្សាច់ហើយចោតពិបាកឡើងចុះ ហើយពុំមានប្រឹងសម្រាកនៅ សងខាងឡើង ។

នៅថ្នាក់ទី ២ មានថែវតូចចង្អៀតហើយមានបរិវេណដើរ ទៀតនៅអមខាងក្រៅ ឯចំណែកមុខទាំង ៤ មានធ្វើជាជណ្ដើរ ៗ ដំបូលថែវមានរាងជាក្បាំងឃុំគ្របពន្លបពីលើថ្ងៃពី ថែវទាំងឡាយនោះគ្រាសាទវិមានអាកាស ដែលសាងប្រឈម មុខគ្នាទៅតាមទិស ៗ នៅតាមចន្លោះចន្លោះថ្មដំបូលមួយ ៗ មានជា

www.budinst.gov.kh www.elibraryofcambodia.org

ចំរឹងជើងទៀនជាលំអផង ។

ឯប្រាង្គនៅតាមជ្រុងមានការខូចខាតអស់ជាច្រើន នៅសល់តែបន្ទាត់ជញ្ជាំងខ្លះ ដែលទល់ទ្រដោយសសរនៅជ្រុងទិសឦសាន ។ នៅគ្រប់តួកណ្ដាលនៃគោបុរៈទាំងអស់មានសង់ជាពីរថ្នាក់ ហើយមានបែលចេញ ៣ ផង ។ នៅតាមផ្នែកខ្នងនៃគោបុរៈនេះ បើមើលពីចម្ងាយទៅ គេឃើញមានក្បាច់ចម្លាក់យ៉ាងល្អ ៗ ។ គោបុរៈខាងត្បូង មានដំបូលកន្ទួលគ្លាក់លំអដោយក្បាច់ក្របកណ្ដូក ។ គោបុរៈយ៉ាងល្អិតនេះ ជាហេតុមួយនាំឲ្យដឹងនូវស្ថានការតាំងទុកដាក់នៃការរចនាខ្មែរតាមសម័យនិយម ។

នៅតាមជណ្ដើរដែលគេភ្ជាប់ពីផ្លូវមួយទៅកាន់ថ្នាក់ប្រាសាទទី២ មានផ្លូវមួយទៀតតូចចង្អៀតបត់បែនភ្ជាប់ តាមមុខប្រាសាទនីមួយ ៗ ដែលមានជាជណ្ដើរ ៣ នៅថ្នាក់ទី ៣ ដែលគេត្រឡប់ចូលទៅវិញតាមជណ្ដើរនោះ ដើម្បីនឹងចៀសកុំឲ្យជណ្ដើរដែលចោត ៗ ដោយគេត្រូវឡើងចុះតាមជណ្ដើរមួយចោតពីខា...

www.budinst.gov.kh www.elibraryofcambodia.org

លិចគោបុរៈខាងត្បូង ព្រោះជណ្ដើរនេះចុះឡើងស្រួលជាង ជណ្ដើរខាងឡាយ ដែលមានជុំចូរមៀលធ្លាក់ពីជ្រុងទិសនិរតី នៃគូប្រាសាទធំខ្ពស់ ។

ផ្លូវកថខាងលើមានបណ្ដោយប្រវែង ៤២ ម៉ែត្រ ទទឹង ៣៦ ម៉ែត្រ ហើយបានទទួលការវិនាសអន្តរាយអស់ជាច្រើន គឺនៅសល់តែគោបុរៈខ្លះនិងយ៉ខ្លះនៅជាប់នឹងគូប្រាសាទ ។ នៅតាមជន្ទុកខ្លួនជញ្ជាំង មានលំអដោយក្បាច់រចនាជារូបចម្លាក់តូចៗ យ៉ាងច្រើន ។ មានសំណង់មួយនៅជ្រុងទិសឦសាន ដែលគេឃើញនៅសល់តែជញ្ជាំង និងសសរនៅតាមផ្លូវដើរ ដែលបញ្ជាក់ឲ្យដឹងនូវការកសាងដោយគ្រឿងសម្ភារៈទាំងនេះ ។

ដើរទាំងនេះឲ្យឃើញទៀតនូវលក្ខណៈពិសេស គឺបែកជាពីរតាមបណ្ដោយស័ក្យ ដោយមានជញ្ជាំងទ័ណ្ឌរោះជាបន្ទប់ជាក់ប៉ីរនងជើងទៀនភ្ជាប់គ្នា បណ្ដាលឲ្យមានទម្រង់ហាក់ដូចជាសាងដោយប្រើសសរទ្រ លក្ខណៈថ្មីដែលគេពុំដែលប្រទះក្នុងការកសាងនៅជំនាន់នោះ ។

www.budinst.gov.kh www.elibraryofcambodia.org

បើនៅពេលក្រឡេកពីចម្ងាយទៅលើផ្លូវថ្នល់ចូលទៅខាងកើត, ទៅលើប្រាសាទកំពូលខាងនៅខាងត្បូង និងប្រាសាទវិមានអាកាសនៅខាងជើង ដែលស្ថិតនៅស្របតម្រង់គ្នាទាំងអស់ ព្រមទាំងទៅលើព្រៃឈើនៃអង្គរ គេអាចឃើញទស្សនីយភាពដ៏អស្ចារ្យក្រៃលែង ។ តែគេពុំអាចបំភ្លេចផងនូវវិចិត្រកម្មក្បាច់ចម្លាក់ ស្ថាបត្យកម្មនៃប្រាសាទកណ្តាលនេះ ដែលបានឆ្លាក់ឡើងដោយដៃនៅថ្មកល់ ហើយសុទ្ធសឹងរចនាលំអនិងបវរមាសតាមសម័យនិយម ។

ថ្មគ្រឹះនេះមានពីរប្លុក គឺថ្មគ្រឹះមួយជាក់ការ៉េ ៤ ជ្រុងស្មើព័ទ្ធជុំវិញ ថ្មគ្រឹះថ្មមួយទៀតកាត់ជាកាកបាទ ។ ថ្មគ្រឹះឆ្លាក់ទាំងពីរនេះសុទ្ធសឹងតែមានលំអគួរឲ្យស្ងើចសរសើរដល់ស្នាដៃនៃស្ថាបត្យករខានពុំបានឡើយ ។ ថ្មគ្រឹះនេះដែលស្ថិតនៅក្រោមដី តាមរបៀបនៃប្រាសាទនេះ និងប្រាសាទព្រះខ័ន ព្រោះគ្រប់ប្រាសាទជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដូច្នេះផ្នែកក្រោមដី ក៏មានកាត់ស្មើនឹងផ្នែកខាងលើដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

# ក្បាច់របាំ

ចំពោះប្រាសាទបាពួននេះ លោក សឺដែស បានមាន ប្រសាសន៍ថា : « រឿងរ៉ាវខ្លះៗ ជាលំអនៅតាមក្លោងទ្វារថែវ ទាំង ៤ ផ្នែកខាងក្នុងសុទ្ធតែមានទំនងជាពុទ្ធគន្ថ គឺយើងនឹង មើលតាមរឿងបង្កើតនៅតាមក្លោងទ្វារទាំង ៤ ព្រមទាំងរឿង រាមកេរ្តិ៍ នៅខាងលិច និងខាងកើត រឿងក្រឹស្នៈនៅក្លោងទ្វារ ខាងត្បូង ។ រឿងទាំងឡាយដែលមាននៅតាមផ្ទាំងចម្លាក់ ទាំងនេះ សុទ្ធសឹងតែមានគោលបំណងដើម្បីឲ្យយើងឆាប់យល់ ស្រួលប៉ុណ្ណោះ ។

ចំពោះក្បាច់ក្រឡាក់ទាំងនេះ គេឆ្លាក់តាមលំនាំក្បាច់នៅ ប្រាសាទបាគង ដែលសាងក្នុងសតវត្សទី ៩ ហើយមាន ក្បាច់ចម្លាក់ ដែលគេរចនាលំអនៅតាមរឿងផ្សេងៗដាច់ដោយ ឡែកៗពីគ្នា នៅតាមជញ្ជាំងទ្វារ និងនៅតាមក្បាច់ក្បាំង ដែលសុទ្ធតែមានសារៈសំខាន់ តាមស្លាកភាពនៃផ្ទាំងចម្លាក់ទាំង អស់ ដែលបានឆ្លាក់តាំងពីក្រោមរហូតដល់លើ ឲ្យមានច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ព្រោយដូចជាកម្រងក្បាច់ ៗ ក្បាច់ចម្លាក់ទាំងឡាយច្រើនតែ មានផ្កាំងតូច ៗ ជាលំអសមទៅតាមការនិយមរចនា ហើយ ដែលមានក្បាច់ខ្លះ បង្ហាញសោភ័ណភាពដ៏ត្រចះត្រចង់លាយ បំរុះនៅតាមផ្ទៃរឿងផ្សេង ៗ បែបជាក្ដួចបម្លាំងពិតប្រាកដ ៗ តួប្រាសាទទាំងមូលនេះមានលំអឥតខ្ចោះ ជាហេតុធ្វើឲ្យមនុស្ស បានយល់ឃើញជាក់ច្បាស់ នូវសាចរឿងទាំងឡាយ ។

## គោបុរៈខាងត្បូង មុខខាងឆ្វេង

នៅខាងលិច ខ្សែរជីវប្រវត្តិនៃរឿង មានសត្វខ្លា ដេញខាំឥសីម្នាក់ ដែលកំពុងតែគេចខ្លួនរត់ទៅឡើងដើមឈើ, រឿងព្រានព្រៃម្នាក់បាញ់សម្លាប់សត្វបក្សីមួយ, គ្រប់ផលគ្នា, ឥសីកំពុងការពារធម៌, ស្ត្រីម្នាក់កំពុងអង្គុយប្រឡែងជាមួយ កូន, រឿងទាំងនេះសុទ្ធតែមានការលាយឡំនឹងរឿងគ្រឹស្នៈ : ការប្ដូរកូនដើម្បីជៀសវាងអំពីសេចក្ដីស្លាប់ កុំឲ្យមកបៀត បៀនដល់គ្រឹស្ន, ការពិឃាតតារក, គ្រឹស្ន ប្រយុទ្ធឈ្នះ នាគរាជ ដោយហែកនាគរាជជាពីរផ្នែក ហើយកយុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះឆាតរាជទាំងពីរ ហើយបានទៅតយុទ្ធនឹងសត្វតោដែល
មានមុខដូចជាមនុស្សទៀត ។ នៅខាងកើតមានឥសីមួយអង្គ
កាន់ក្បាលមនុស្សត្រូវប្រួញ ក្បាលនេះប្រហែលជាក្បាល
មនុស្សកំពុងសូត្រធម៌ ដែលគេឃើញនៅចំពីខាងក្រោម ។

## គោបុរៈខាងត្បូង មុខខាងជើង

នៅខាងកើត ផ្ទាំងចម្លាក់ខាងក្រោមមានរឿងផ្សេងៗ
ដំណាលអំពីជីវិតឥសី គឺមានឥសីមួយកំពុងកូរទឹកដោះ មួយ
ទៀតកំពុងបុកពោះ ហើយនិងឥសីទី ៣ បង្ហាញឲ្យឃើញ
ទុរកាតព្យាធិនិងមរណៈ ។ នៅផ្នែកចម្លាក់ខាងលើមាន
/៦/ រឿងរាមកេរ្តិ៍ ត្រង់ចម្បាំងពួកស្វានិងយក្ស ។ ហនុមាន
និងនាងសីតាអង្គុយនៅក្នុងគុម្ពោតព្រៃឈើ ។ ផ្ទាំងចម្លាក់
មួយទៀតនៅខាងលើមានរូបព្រះនារាយណ៍ កាន់កេតនភណ្ឌ
តាមធម្មតា ។ នៅខាងលិច ត្រង់ផ្នែកផ្ទាំងដែលខូចខាត
មានឥសី មនុស្សនិងសត្វនៅក្នុងព្រៃ ព្រមទាំងការ
12 ប្រយុទ្ធគ្នាផ្សេងៗ ។

www.budinst.gov.kh www.elibraryofcambodia.org

## គោបុរៈខាងកើត មុខខាងកើត

នៅផ្នែកខាងត្បូងមានរឿងរាមកេរ្ដិ៍ ថ្លែងអំពីសេចក្ដីទុក្ខលំបាករបស់នាងសីតា ដែលទ្រង់ព្រះកន្សែងរៀបរាប់ថ្លែងសេចក្ដីស្មោះត្រង់របស់ព្រះនាងនៅលើភ្លៅព្រះរាម នាងលើកការប្រណម្យដាក់លើព្រះសិរ រំលឹកដល់គុណព្រះអគ្គីជាស្ដេចព្រះអគ្គីដែលនៅជិតព្រះនាង ហើយនិងព្រះមហោស្សូរជិះលើគោអសុភរាជជាពាហនៈ ។ នៅផ្ទាំងខាងលើព្រះរាមនិងព្រះនាងសីតា គង់លើបល្ល័ង្ករតន៍ ។ តមកគឺរឿងមហាភារតៈត្រង់បម្បាំងអជុន និង ព្រះនារាយណ៍ ដោយសាររឿងជ្រូកព្រៃដែលជាក្រុងយក្សមូកៈក្លែងខ្លួន ។

នៅផ្ទាំងបម្លាក់ខាងជើងមានរឿង មហាភារតៈ ដែលគេធ្លាប់បានជួបប្រទះរួចមកហើយ នៅខាងត្បូងនៃថែវអង្គរវត្តផ្នែកខាងលិច ប៉ុន្តែរឿងនៅប្រាសាទបាពួននេះ គេគ្រាន់តែលាតត្រដាងពីពលនាយសំខាន់ ៗ ខ្លះ ដែលនៅខាងលើមានក្រុមក្សត្រ្តី និង កងទ័ពបាណ្ឌវៈ លើកទៅច្បាំងនឹង

www.budinst.gov.kh www.elibraryofcambodia.org

កន្ទំពភិស្ម: ដែលមេទ័ពត្រូវព្រួញធ្លាក់ពីលើយានជំនិះ ដួលដេកស្លាប់ ៗ នៅខាងក្រោមគេឃើញរូបបម្នាក់មនុស្សធំ ៗ ជាយុទ្ធជនខ្លាំងពូកែ ហើយនិងកងទ័ពដែលបាញ់សង្គ្រាមយ៉ាងច្រើន នៅតាមបណ្តោយកំពង់ដែលមានស្តូបគង់ ៗ នៅជិតផ្ទាំងបម្ភាក់នេះ មានសេះជាច្រើនទៀតនៅលាយឡំគ្នា ហើយនិងមានសេះព្រានតូច ៗ ដែលមានសេះមួយបង្ហាញពីមនុស្សប្រុសម្នាក់ចង់ចាប់ស្ត្រីម្នាក់ ៗ

## គោបុរៈខាងកើត មុខខាងលិច

នៅខាងជើងមានរូបដំរីព្រៃមួយយ៉ាងល្អ និងរូបដំរីស្រុកមួយ ៗ មិនត្រឹមតែប៉ុណ្ណោះទេ គេឃើញមានក្រុមទេះមួយជួរផ្ទុកតួអ្នកបំរើ និងសេះមួយអង្គទៀតផង ៗ នៅខាងត្បូង ពលធ្នូស្នា កំពុងដំឡើងព្រួញបាញ់ស្រីម្នាក់ ៗ នៅក្បែរនេះ មានការប្រយុទ្ធរវាងមនុស្សនិងស្វា ហើយមិនដំរី ៗ នៅខាងត្បូង ពីលើមនុស្សម្នាក់ដែលកំពុងតែបាញ់សត្វទា មានរឿងប្រយុទ្ធនឹងស្ត្រីម្នាក់លើអាកាស នៅខាងស្តាំ

www.budinst.gov.kh www.elibraryofcambodia.org

មានមនុស្សកំពុងចាប់សត្វចតុប្បាទ , ផសីនៅក្នុងព្រៃ , ស្ត្រី ហើយនិងកងពលជើងសា ព្រមទាំងមានព្រះរាជាមួយព្រះអង្គ គង់លើបល្ល័ង្កកណ្ដាលរាជបរិពារ ។

## គោបុរៈខាងជើង មុខខាងជើង

នៅខាងកើត គឺសង្គ្រាមក្នុងរឿងរាមកេរ្តិ៍ ដែលគេឃើញព្រះរាមគង់លើរាជរថទឹមសេះ ២ , ព្រះបៅក្រុងរាពណ៍មានដៃនិងក្បាលច្រើន កំពុងតែយកក្បាលមនុស្សប្រមាញ [illegible] ។ ក្រុងរាពណ៍ច្បាំងនឹងហនុមាន ហើយនិង [illegible] ។ សុគ្រីពច្បាំងនឹងមេទ័ពយក្ស ឯក្រុងរាពណ៍ច្បាំង [illegible] ព្រះរាមជិះលើហនុមានជាសេនាដៃឯក ព្រះអង្គទ្រង់ [illegible] ដើម្បីជាគជ័យ ហើយពិស្ដារក្នុងការបំពេញ [illegible] ក្នុងរឿងនេះ ។ នៅតាមបណ្ដោយបន្ទប់ទី ១ នៃបរនេះ បានផ្ចាក់ជាក្បាច់មួលគ្រឿងៗយ៉ាងល្អស្រស់ក្រៃ ។

នៅខាងលិច គឺរឿងសង្គ្រាមនៅប្រទេសលង្កាដែល [illegible] ភាពក្បួ ១ មានរូបសត្វនិងរូបគំនូរផ្សេងៗ ។

www.budinst.gov.kh www.elibraryofcambodia.org

គេឃើញបុត្រក្រុងរាពណ៍ឈ្មោះ ឥន្ទ្រជិត ថែងសរកើតជាពស់ នាគពាជ រួបរឹតជុំវិញអង្គព្រះរាម និង ព្រះលក្ស្មណ៍ ចំណែកឯពលស្វា ភិតភ័យយំខ្សឹកខ្សួល ។ ក្រុឌ ហោះចុះពីលើអាកាសមកចាបចឹកពស់នាគពាជ ដោះក្សត្រទាំងពីរអង្គឲ្យរួចពីភ័យន្តរាយ ។ ព្រះរាមជិះលើរាជរថឈ្មោះកូសបក ទឹមដោយរាជហង្សបរសំដៅទៅក្រុងអយុធ្យាបុរី ក្រោយពេលដែលព្រះអង្គ ឲ្យពួកពលស្វាឈប់សម្រាករួចហើយ ។ នៅឆ្ងាយពីនេះបន្តិច ផ្នែកក្រោមមានដីមួយគូប និង ឥសីកូរទឹក ។ គេឃើញសុគ្រីពយំខ្សឹកខ្សួល កើតទុក្ខជាខ្លាំងដោយបងឈ្មោះ ពាលី បណ្តេញចេញពីក្ខិហិមាល័យ ។ ពាលីជាបងត្រូវសរព្រះរាមត្រង់កណ្តាលខ្លួន ដួលដេកស្លាប់កណ្តាលពួកពលស្វា ។

## គោបុរៈខាងជើង មុខខាងត្បូង

នៅខាងកើត មានគោឈមមុខទល់នឹងសេះ ហើយនិងព្រះរាម ព្រះលក្ស្មណ៍ព្រមទាំងពួកពលស្វារបស់សុគ្រីព

www.budinst.gov.kh www.elibraryofcambodia.org

ហើយខាងលិចមានការប្រយុទ្ធគ្នានឹងមនុស្សចិនសត្វ ។ ទៅ
ក្រុងផង ព្រះនាងសីតាស្ត្រីយកទៅគ្រងឧត្ដម អភិសេក ។

## គោបុរៈខាងលិច មុខខាងលិច

ហើយខាងជើងមានការប្រយុទ្ធគ្នានឹងសត្វចិនសត្វ ។
... ព្រះឥន្ទ្រ ... ទ្រង់ ម្នាក់ជិះលើរាហូបាត់
ពេញដែលបាញ់ចំព្រះមុខ ។ ខាងត្បូងពីលើក្របខ្ចូ
ផ្ទាំងនេះ មានសត្វហង្សកំពុងត្រូវអាចមួយនៅលើអាកាស
ដែលជាវិមានព្រះគោចរតមួយព្រះឥន្ទ្រ មានក្បាលពាងនៃដៃ៤ ៗ
មិនតែប៉ុណ្ណោះ មានតួអាក់ជារឿងចម្លាំងជាច្រើនទៀត ហើយ
គឺមិនជិះលើយានទៅមុខព្រះពស់ថ្ម ចំណែកឯអសុរ
កំពុងចម្បាំងនៅក្រោមព្រះហស្តព្រះនារាយណ៍ ។

## គោបុរៈខាងលិច មុខខាងកើត

ខាងជើង មានរឿងចម្លាំងទំនើមការប្រយុទ្ធជាច្រើន
ទៀត ដែលគេ...ខ្លាំងពេក ៗ ...
... ម្នាក់ម្នាក់ត្រូវស្លាប់ ហើយណាល

www.budinst.gov.kh www.elibraryofcambodia.org

ផ្ដាំផចម្លាក់ដោយមានជើងតូចមួយទ្រពីក្រោម ។ ឆ្ងាយពីរូបនេះបន្តិច មានការប្រយុទ្ធគ្នារវាងជ្រូកព្រៃនឹងជ្រូកព្រៃ ក្បែរនោះខ្មាន់ជ្ឈម្នាក់ ឃើតផ្ទូបាញ់គប្រើងយក្សមួយក្បាលជាមនុស្ស មិនតែប៉ុណ្ណោះមានឆ្លាក់ជារូបសេះពីរឈមមុខទល់គ្នា ។

# បរិវេណវាំងស្ដេច

## វិមានអាកាស

ប្រាសាទវិមានអាកាស ជាវត្តមួយពោរពេញទៅដោយ ទេវកថាអាកាសស្រុកខ្មែរកំពែងសម្បូរ ។ ប្រាសាទនេះសាង ឡើង នៅដើមសតវត្សរ៍ ទី១០ ដោយព្រះបាទរាជេន្ទ្រវរ្ម័ន បព្វាបរណៈព្រះនាម សិវលោក ក្រោយមកដោយព្រះបាទ ជ័យវរ្ម័នទី ៥ បព្វាបរណៈព្រះនាម បរមវីរលោក និងព្រះបាទ សូរ្យវរ្ម័នទី១ បព្វាបរណៈព្រះនាម បរមនិព្វានបទ ដែលមាន ... កំណើត ។ ... ដោយក្រុម ... ចាប់តាំងពី គ.ស. ១៩០៨ ហើយមកដល់សព្វថ្ងៃនេះ ... បញ្ចប់ ... តាមប្រពៃណី ... ក្នុងបរិវេណ ... គេត្រូវធ្វើ ... ២០០ ម៉ែត្រប៉ុណ្ណោះ គេឃើញមាន ... ព្រំប្រទល់ ... តាមផ្លូវ ...

www.budinst.gov.kh www.elibraryofcambodia.org

ដែលគក្លាប់មកពីជញ្ជាំងខាងក្រៅនៃកំពែងវាំង ប្រហែលជា ១០០ ម៉ែត្រ គេនឹងបានឃើញនូវគ្រើដំណែលចុកណាក្នុងស្រះមួយដែលបានរក្សាទុកនូវសភាពដូចដើម ដូចនៅលើទួលស្ដេចគំលង់ដែរ ៖ នៅជញ្ជាំងខណ្ឌខាងលិចមានចម្លាក់រឿងនាគបរណ៍នៅផ្នែកខាងកើត ។

បើចង់វិលមកវិញ ត្រូវដើរតាមនាគខាងលិចមុខខាងជើងនៅក្នុងបរិវេណវាំង ដែលនៅក្នុងមណ្ឌលនេះ ជញ្ជាំងធ្វើពីថ្មបាយក្រៀម មានកំពស់ ៥ ម៉ែត្រ ហើយសង់យ៉ាងមាំ មានកំពស់ពីរដងនៃជញ្ជាំងទី២ ដែលសាងឡើងនៅពេលក្រោយ ៗ នេះ ទីងខណ្ឌពីជញ្ជាំងទី ១ ដោយស្នាមភ្លោះមួយទទឹង ២៥ ម. ។ ជញ្ជាំងនេះព័ទ្ធណាខមួយ ទទឹង ២៥០ ម៉ែត្រ បណ្ដោយ ៦០០ ម៉ែត្រ ។

នៅផ្នែកខាងជើង និង ខាងត្បូងនៃមណ្ឌលនេះដែលមានក្រឡាផ្ទៃ ១៥ ហិកតា មានភាគពីរនៅផ្នែកនីមួយ ៗ សាងអំពីថ្មបាយក្រៀមទាំងអស់ ហើយភាគដែលមានភាគនៅគង់វង់

www.budinst.gov.kh www.elibraryofcambodia.org

ជាន់គេ គឺខាងត្រង់ផ្លូវដែលដើរកាត់មក ៗ នៅលើផ្លូវដែកថ ស្មើពន់ខ្នង ត្រង់ផ្លូវតាំងពីខាងលើ មានបរិវេណផ្លូវមួយ ពង ៤ ជ្រុងស្មើប្រកបដោយជាន់ - ថ្នាក់ ៗ បញ្ចូត ព្រមទាំង ស្នាបគោនពីរជួបជាអង្រឹង រំលេចជាក្បាច់ចាយោងល្អពេក ឆាយ ប្រកបដោយគ្រឿងតុបតែងលំអពីសម័យបុរាណ ដូច នៅក្នុងមុមមាត់រូបសំពប់ធ្វើជាយានជំនិះ ៗ

ដីដែលបានជីករកខាង ជាប់ពាក់ចនទៅខាងក្រោម ប្រាសាទវិមានអាកាស ដែលនៅកណ្ដាលមណ្ឌលនេះគឺហួស ពី ១ ម៉ែត្រ ២០ ទៅខាងលើដី មានភាពខុសគ្នា តែភាព ក្បាច់ទៅនឹងជ្រុងនេះបាន ៗ គេភាពធ្វើដំណើរជំរន់ទៅ ខាងស្ដាំបាន បើសិនជាផ្លូវនោះបានរៀបចំស្រួល ពោលគឺផ្លូវ ទៅខាងកើត ដែលនៅទីនោះមានស្រះធាស់មួយ ប្រវែង ៩០ ម៉ែត្រ ទទឹង ២៥ ម៉ែត្រ មានទៀននិងថ្នាក់សំរាប់ឡើង ចុះធ្វើពីថ្មបាយក្រៀម ដែលភាពឡើងដល់ដីទួលមួយតូច ប្រកបដោយជញ្ជាំងធាត់ក្បាច់ផ្សេង ១ បង្ហាញក្បូនត្បូងហយាត្រា

www.budinst.gov.kh www.elibraryofcambodia.org

មនុស្ស, ប៉ី មិន សេះ នៅក្រោមក្បាច់ត្របកជាសត្វហង្ស ។

វិលមកវិញតាមផ្លូវជើង ដោយបន្តដំណើរជុំវិញទៅខាងកើត គេត្រូវបត់ទៅខាងត្បូងចេញតាមទ្វារ មិនបានដល់មុខពិសាលផ្ទៃនៃស្រះធំមួយ ដែលមានប្រវែង ១២៥ ម៉ែត្រ ទទឹង ៤៥ ម៉ែត្រ តែសព្វថ្ងៃនេះត្រូវកប់បាត់ដោយដីដុះឡើង ហើយមានជម្រៅតាមការស្ទង់មើលប្រហែលជា ៧ ម៉ែត្រ ៥០ ។ ស្រះនេះ មានជាថ្នាក់ៗ ចុះជាប់ពីចំពុមក្រាលថ្មនៃមណ្ឌលខាងជើង មិនមានស្រះមួយទៀតនៅខាងកើត ប្រវែងប្រហែល ៥០ ម៉ែត្រ ទទឹង ២០ ម៉ែត្រ ជម្រៅ ៤ ម៉ែត្រ ៥០ ។

ផ្នែកមុខខាងលិច ខាងត្បូងមិនកាត់ខ្វះខាងកើតស្រះនេះ លំអដោយក្បាច់ចម្លាក់ជាសត្វនៅក្នុងទឹក ដូចជាត្រី, ក្ដាម, មករ, អណ្ដើក, កន្លាយ, ពស់ជាដើម ដែលមានសភាពហាក់រស់រវើកហែលត្រៀតត្រាត់នៅក្នុងទឹក ។ ផ្នែកបាតជាថ្នាក់នាគ ដែលមានរូបជាសត្វឬជាមនុស្ស ព័ទ្ធជុំវិញដោយ

www.budinst.gov.kh www.elibraryofcambodia.org

នាគីទាំងឡាយយ៉ាងគគកុញ និងមានមនុស្សផុះស្វាបប្រហែលជាពួក "គន្ធ" ។ សភាពទាំងអស់នេះ ប្រហែលគ្នានឹងប្រាសាទបាយ័នដែលមានមកុដកជ្យ . ទ្រះជាយមានគសម្រាប់ចាត់ចែងវេទិកា ចំពោះព្រះមហាក្សត្រ និងចំពោះអ្នកមានបណ្តាសក្តិធំៗ នៅក្នុងព្រះពន្លាសម្រាប់ធ្វើពិធីបុណ្យផ្សេងៗ យ៉ាងអឹកធឹក ។

អ្នកទស្សនាអាចចុះមកខាងក្រោមដើរពិនិត្យមើលនូវក្បាច់ចម្លាក់ តាំងពីជ្រុងខាងលិចរហូតដល់ជ្រុងខាងត្បូង ដែលនៅទីនេះ មានសុទ្ធតែដុំថ្មតំរៀបគ្នាជាជណ្តើរអាចឲ្យឡើងទៅខាងលើវិញបាន ។

នៅទីនេះ មានបញ្ហាមួយជាអាថ៌កំបាំងជាងគេ ក្នុងចំណោមបញ្ហាទាំងអស់ដែលពោលឡើង ចំពោះប្រវត្តិសាស្ត្រនៃព្រះពលាំងនេះ ៖ ថ្នាក់ទាំងនេះព័ទ្ធជុំវិញស្រះដែលប្រកបដោយការតុបតែងយ៉ាងចំណានៗ សុទ្ធសឹងតែមានប្រយោជន៍ទាំងអស់ គឺសម្រាប់ការពារយ៉ាងមាំនូវដីដែលលើក មានសភាពខ្ពស់តាម

www.budinst.gov.kh www.elibraryofcambodia.org

មិនស្មើគ្នា ជាពិសេសផ្នែកកណ្ដាល ដែលត្រូវស្ថាបនាប្រាសាទវិមានអាកាស ។

ប្រាសាទនេះ បានរៀបចំឡើងវិញ ដោយលោក ហ. ម៉ាកសាល់ ។ ការជីកកកាយខ្លះទៀតនៅពេលថ្មីៗនេះ បង្ហាញឲ្យឃើញកម្ពស់ដីមួយទៀត ដែលខ្ពស់ជាងដីបាតក្រោម ០ម៉ែត្រ ៨០ ។ ដូច្នេះការបំពេញដីត្រូវបំពេញយ៉ាងតិចពីរដង ហើយកម្ពស់ដីមួយជាន់ៗ ពាក់ទងទៅនឹងវត្ថុបុរាណជាច្រើន នៅតាមជញ្ជាំងនិងតាមផ្លូវក្រាលថ្ម ។ ការនេះផ្ដល់ពត៌មានយ៉ាងជាក់ច្បាស់ថា ប្រាសាទនេះ សាងឡើងដោយសម្ភារៈស្រាលៗត្រង់ផ្នែកខាងកើតនៃវិហារ ហើយវិហារនេះស្ថិតនៅក្នុងចំណោមសំណង់យ៉ាងស្កុកស្កាញ ហេតុនេះហើយបានជាការជីកដី បង្ហាញឲ្យឃើញកំទេចឥដ្ឋនិងក្បឿង ព្រមទាំងស្លាកស្នាមជាច្រើនកន្លែង ដែលមកពីឈើចាក់ឫសបំផ្លាញ ឬក៏មកពីត្រូវភ្លើងឆេះ ។

យើងគ្មានឃើញសញ្ញាអ្វី ដែលបញ្ជាក់ពីការបំពេញដីបន្ត

www.budinst.gov.kh www.elibraryofcambodia.org

បន្ទាប់គ្នានោះទៀត លើកលែងតែជាន់កណ្ដាលដែលមាន សិលាចារឹកតាមព្រះបាទជ័យវរ្ម័នទី ៧ ដែលបញ្ជាក់ឲ្យឃើញថា ជាន់នេះបានលើកដល់ទៅចុងសតវត្សទី ១២ ។

សិលាចារឹកទី ១ និយាយរៀបរាប់ពី " ដើមជ្រៃ " មានប្រយោជន៍សំខាន់ ដោយបង្ហាញនូវភស្តុតាងនៃការបញ្ចូលលាយគ្នា ពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ដែលគេនិយមកាន់កាន់នៅសម័យនោះ គឺដើមពោធិព្រឹក្សក្នុងពុទ្ធសាសនាមានសភាពដូចគ្នានឹងព្រះព្រហ្ម ដែលទុកជាឫសគល់ ព្រះឥសូរជាដើម ព្រះនារាយណ៍ជាមែកធាង ។

សិលាចារឹកទី ២ និយាយសរសើរក្សត្រមួយអង្គដែលមានប្រាជ្ញាឈ្លៀវឆ្លាតលើសពួកស្រីនានា ដែលបានផ្សប់ផ្សាយនូវគុណប្រយោជន៍ដល់មហាជនជុំវិញព្រះអង្គ ហើយកាន់ខ្ជាប់នូវសីលធម៌ដូចឥសី ។ សភាពសព្វថ្ងៃចំពោះបញ្ហានេះ មិនអាចធ្វើឲ្យគេដឹងបានថា នៅផ្ទៃក្នុងព្រះបរមរាជវាំង មានការបែងចែកជាច្រើនខ្ទះ ។ ប្លង់ទាំងនេះ សុទ្ធតែធ្វើពីគ្រឿង 174

www.budinst.gov.kh www.elibraryofcambodia.org

សម្ភារៈផ្សេង ៗ ដែលពុករលួយ ជាពិសេស ទីកន្លែងសម្រាប់ព្រះពជា ៗ គេមិនអាចយល់បាននូវការរៀបចំអគារតាំងឡាយ ឲ្យមានសភាពសមរម្យ ៗ អ្នកខ្លះបានទៅពិនិត្យមើលសភាពតាំងអស់ មុនពេលរៀបចំនៅឆ្នាំ ១៩២៤ ហើយពោលថា មានសភាពដូចគ្នានឹងព្រះបរមរាជវាំង ភ្នំពេញ ៗ ប៉ុន្តែច្រើនសតវត្សមក ព្រះមហាក្សត្រមានខ្សែស្រឡាយជាមួយគ្នាបានគង់នៅទីនេះ ហើយបានរុះរើ ឬ សាងអាគារតាមព្រះទ័យរៀង ៗ មក ៗ

លោក ហ. ម៉ាកសាល់ ដោយសំអាងទៅលើភាពនៃរបងខ្លះ ដែលមើលឃើញពីចំហៀង ចែកបរិវេណវាំងជា ៥ មណ្ឌល គឺ: ១/ ពីខាងកើតទៅខាងលិច : ទីធ្លាមួយជម្រៅចូល ៧០ ម៉ែត្រ មានគោបុរៈបីសម្រាប់ចូល; ២/ ព្រះលានប្រវែង ២៨០ ម៉ែត្រ ក្នុងលាននេះមានវិហារវិមានអាកាស និង ស្រះធំមួយ ដែលអាចចូលទៅបានដោយគោបុរៈពីរ ; ៣/ ផ្នែកសម្រាប់ស្រី ៗ ប្រវែង ១៥០ ម៉ែត្រ គឺមានទីធ្លាជាសាធារណៈ

www.budinst.gov.kh www.elibraryofcambodia.org

ពីខាងត្បូង ចាំងអស់នេះគ្មានទាក់ទងអ្វីទៅនឹងមណ្ឌលខាងក្រៅទេ ; ៤/ មណ្ឌលទី ៤ ដែលបើកចំហទៅមណ្ឌលទី ៣ សម្រាប់ពួកក្មេងស្រីៗ ស្អកបំរើ ៥/ ទីធ្លាក្រោយបំផុតបិទជិតទឹងពុំដឹងជាសម្រាប់ប្រើការអ្វីជាពិតប្រាកដឡើយ ។

គេយល់លក្ខណៈនៃបរិវេណទីមួយៗដោយសំអាងទៅលើវត្ថុផ្សេងៗ ដែលបានរកឃើញដូចជា វត្ថុធ្វើអំពីសំរិទ្ធិ និង ក្អមឆ្នាំង ហើយនិងទៅលើការតាក់តែងលំអស្របទៅតាមវប្បធម៌ ។

## ការពិពណ៌នាអំពីប្រាសាទវិមានអាកាស

បើយើងក្រឡេកភ្នែកមួយភ្លែតទៅ យើងនឹងអាចប្រៀបធៀបប្រាសាទនេះ ទៅនឹងប្រាសាទភ្នំបាខែង ដែលទុកដូចជាភ្នំនៅកណ្ដាលមណ្ឌលនៃរាជធានីរបស់ព្រះបាទ យសោវរ័ន្ម ដែលបានសាងឡើងក្នុងសតវត្សទី ៩ ។ ក្នុងចំណោមវិហារតូចៗ នៅតាមប្រាសាទវិមានអាកាស វិហារទី ២ បានទាញអារម្មណ៍យើងយ៉ាងខ្លាំង ដែលមានរបៀបរៀបចំយ៉ាងសមរម្យ

www.budinst.gov.kh www.elibraryofcambodia.org

ផតខ្លះ ដោយសារដើកន ៤ ជ្រុងទ្រវែង ហើយមិនប្រាសាទមួយគត់ ដែលធ្វើឲ្យយើងវិនិច្ឆ័យបានថាជាវិហារនៃមួយក្នុងព្រះរាជវាំង ។

នេះគឺជា "ប្រាង្គមាស" ដែលអ្នកទេសចរចិនម្នាក់ ឈ្មោះ ជីវ តា ក្វាន់ បានពណ៌នារៀបរាប់ ។ តាមអ្នកដំណើរនេះគេឃើញមានប្រាសាទសម្រាប់ស្តេចផ្ទំ ទាំងនេះបញ្ជាក់យ៉ាងច្បាស់លាស់ពីស្ថានភាពនៃប្រាសាទ ទិនបង្ហាញពីវត្ថុបុរាណដែលមានចំនួនយ៉ាងច្រើនឥតគណនា ។ នៅក្នុងប្រាង្គនេះ មានព្រលឹងនាគមួយ ដែលមានក្បាល ៩ ហើយជាម្ចាស់ផែនដីនៃព្រះរាជាណាចក្រ ។ ពស់នេះចេញមករាល់រាត្រីហើយមានភេទជាស្ត្រី ។ ស្តេចត្រូវតែផ្ទំជាមួយពស់នេះជាមុនលុះដល់វេនទី ២ ទើបព្រះអង្គស្តេចទ្រង់ផ្ទំជាមួយមហេសី ។ ប្រសិនបើរាត្រីណាមួយព្រលឹងពស់នោះមិនបានមកទេ នៅពេលនោះហើយ ដែលមរណភាពនៃស្តេចជិតមកដល់ហើយ ឬ បើស្តេចទ្រង់ខានផ្ទំមួយយប់ជាមួយពស់នោះ ស្តេចនឹងត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ទទួលគ្រោះកាចជាមិនខាន ។

ប្រាសាទវិមានអាកាសមានរាងជាសាជី ប្រកបដោយជាន់ថ្នាក់ធ្វើពីថ្មបាយក្រៀម មានកំពស់ ១២ ម៉ែត្រ ដែលមានជើងរាង ៤ ជ្រុងទ្រវែង បណ្ដោយ ២៨ ម៉ែត្រ ពីខាងទិសពាយ័ព្យ ទៅខាងក្រោមមាន ២៨ ម៉ែត្រ ពីជើងទៅត្បូង ទីង ៣០ ម៉ែត្រ × ២៣ ម៉ែត្រ និងព័ទ្ធជុំវិញដោយជញ្ជាំងរឹងមាំដែលមានបង្អួច ៦ បង្អួច ២ នៅតាមថ្នាក់ៗ ដែលមានគោ ចំណោតដ៏តូចៗ ឈរលើគ្រឿងទ្រសម្រាប់សំគាល់ជាមុខ ។

ជាន់ថ្នាក់ដែលតូចៗ មិនអាចឲ្យយើងធ្វើដំណើរបាន ហើយប្រកបដោយក្បាច់រចនាលំអទៀនក្រឡោតៗ ហាក់ដូចជាមកុដមួយដ៏តូច ធ្វើពីថ្មបាយក្រៀម ក្បាច់មកុដនេះ មានក្បាច់ផ្កាៗ នៅជុំវិញនិងនៅបាតកេងទង ដែលមានបង្អួចដាក់ចំនេទីងមុខកែងសម្រាប់សំគាល់នូវមណ្ឌបតូចៗ ចំណោតបរិណាសម្រាប់ធ្វើដំណើរតាមមាគ៌ មានរាងខ្ពង់ណាស្រាប

www.budinst.gov.kh www.elibraryofcambodia.org

តាំងពីរ ៗ នៅទីនោះ មានសភាពស្រៀមស្ងាត់ពុំមានជាសកម្មភាពអ្វីសោះឡើយ នៅតាមពេងទងកងកោង ធ្វើពីថ្មបាយក្រៀមហុំព័ទ្ធដោយដីខ្ទួលមួយ ធ្វើនេះហាក់ដូចជាស្របទៅនឹងការគាក់តែង ដែលបានចារឹកនៅជំណាច់នៃសតវត្សទី ១០ និងនៅដើមសតវត្សទី ១១ ។

អ្នកទស្សនាដែលបានឈប់សំរាកនៅលើជណ្តើរនៃវិមានពងសាជីនៅខាងលិច នឹងឃើញប្រាសាទមួយនេះទេ ដែលបានផ្តល់នូវការកត់សំគាល់របស់ពិសេស ៗ នៅតាមពេងទងតូច ៗ ដែលមានប្រវែងតែមួយម៉ែត្រ ដូនកាលមានជារន្ធ
(៧) កោង ២ ភ្ជាប់គ្នា ហើយមានរចនាជាក្បាច់នៅតាមថ្មឲ្យកើតទៅជាពងមូកដែលមាននៅក្នុងកន្យាមតាត ។

នៅលើដីខ្ទួលខ្ពស់ បង្កើតបានជាទីធ្លាមួយសម្រាប់សំរាកកាយ ហើយមានទស្សនីយភាពថ្លុក ៗ យ៉ាងល្អ ៗ នៅលើវិហារជិតខាងនៃប្រាសាទបាពួន គេសង្កេតឃើញខ្លះទៀតមានស្នាកស្នាមចាស់ ៗ នៅពេងទងក្រោមវិហារពង ៤ ជ្រុងទ្រវែង

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទ វិហារអាកាស

មើលពីជ្រុងខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

ដែលលេចត្រដែតឡើងនៅខាងក្រោមពីថ្ពាយក្រៀម ដែលមាន ប្រវែង ២ ម៉ែត្រ ៥០ ។ វត្ថុកណ្ឌជាច្រើនបានត្រូវខូចខ្ទេចខ្ទីអស់ នៅវិហារកន្លែងផ្តើពីថ្ពាយក្រៀម មានប្រាសាទ សម្រាប់បន្តុលបង្ហាញទិសទាំង៤ ត្រង់ផ្នែកខ្ពស់បានខូចខ្ទេចខ្ទីអស់ ។ ការកសាងនេះប្រហែលជាមានសភាពដូចដើម ប៉ុន្តែត្រូវរៀបចំផ្លាស់ប្តូរចរិកនៃផ្នែកក្នុងសម័យណាមួយមិនខាន បើតាមមតិលោក ជ័រ-គា-ក្លាន់ ថា សំណង់ខ្ពស់ជាងគេផ្តើឡើងដោយគ្រឿងសម្ភារៈស្រាល ៗ ។

ថ្នាក់ទី ១ នៃវិមានអាកាស ហាក់ដូចជាមាននៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ពីព្រោះមានអក្សរសិលាចារឹកក្នុងឆ្នាំ ៩១០ ធ្លាក់ភ្ជាប់នៅតាមធ្នឹមទ្វារបង្អួចនៃធកខាងកើតនៃវិហារសព្វថ្ងៃនេះ តាក់តែងទៅនឹងរូបសំណាកព្រះនារាយណ៍-ក្រឹស្ណៈ ទុកសម្រាប់បួងសួងដែលមាននាមថា "ត្រៃលោក-នាថ" ។ សភាពដែលប្រឌិតឡើងឲ្យស្របទៅតាមសភាពនៃធម្មជាតិ ដែលសមតាមភាពនៃប្រាសាទវិមានអាកាស ហើយ

www.budinst.gov.kh www.elibraryofcambodia.org

បញ្ចាក់នូវស្នាព្រះហស្ថនៃព្រះបាទ យសោវរ្ម័ន ។ ផ្លូវចូលទៅ
កាត់បណ្ដាលកំពែងទាំងមូល ត្រង់ផ្លូវខាងកើតបានចិតចូលទៅ
ដល់វិហារ នេះមិនមែនជាមតិរបស់លោក ល្វី រិណូ ដែលបាន
លើកឡើងនូវធម្មតាប្រដិច បានសិលាចារឹកតាមថ្នៃវិមានអាកាស
ពោលពេលដែលផ្លាស់ប្ដូរវិហារមួយនៅក្នុងបាខែង ។

ចេញពីវិហារខាងត្បូងមក គេកាច់ចូលតាមប្រហោងជញ្ជាំង
នៃកាច្នុះ នោះបណ្ដាលនេះ ត្រង់ផ្លូវចូលខាងកើតនៃបាពួន
នៅជិតប្រាសាទនេះ បានផ្លូវដើរមួយទៀតខាងទិសត្បូងសាន
សម្រាប់ចាត់ចែងការៈកិច្ចផ្សេង ៗ ។

ផ្លូវនេះយើងអាចធ្វើដំណើរបានស្រួលដែរ ដោយចេញពី
បណ្ដាលកំពែងមកតាមទ្វារខាងកើត ហើយដើរបន្តមកទៀតតាម
ផ្លូវខាងស្ពាននៃទួលខ្ពស់កងខ្មែរដែលធ្វើពីថ្មបាយក្រៀម ប្រកប
ដោយដំបូកដែលទ្រទ្រង់ដោយសសរយ៉ាងត្រង់ ពីជញ្ជាំងខាង
ក្នុងទិសខាងត្បូង ដែលទំណាងជាប់ពីបណ្ដាលកំពែង ជិតទីលានសម្រាប់
ការ គ្រឿងសំណល់ពីបុរាណនៅបណ្ដាប់ទាំងបួន ធ្វើពីថ្មបាយ

www.budinst.gov.kh www.elibraryofcambodia.org

ក្រៀម ត្រូវបើកចំហរតាំងពីខាងលិច ដែលត្រូវខូចខ្ទេចខ្ទីអស់ ។

នៅតាមមុមខាងទិសអគ្នេយ៍នៃមណ្ឌល មានសង់គ្រឹះស្ថានពីរធ្វើពីថ្មបាយក្រៀមនៅសម័យក្រោយបំផុត គ្រឹះស្ថានដែលសំខាន់ជាងគេ គឺគ្រឹះស្ថានដែលមានផ្លូវមុខពីរ មានបង្អួចបែរទៅទិសខាងត្បូងនិងមានវង្វង់កោងហើយធំដែលមើលពីចំហៀងហាក់ដូចជាផ្តត់អង្កាញ់ៗ គ្រឹះស្ថាននេះ គេហៅថា “បណ្ណាល័យ”

មានរូបនាគមួយ នៅខាងកើតផ្លូវចូលទៅក្នុងរាំងខាងក្រោយខឿនជណ្ដើរនៃជម្លូលលានដីរ ហើយជាកន្លែងសំខាន់ជាងគេនៅខាងជើងនិងខាងត្បូង ព្រោះនាគនេះមានផ្លូវពីរចាក់ថ្មបាយក្រៀម ។ លើកលែងតែផ្នែកកណ្ដាលដែលមានជាទីធ្លាមួយ រូបនាគកោងដោយឥទ្ធនោះជាសញ្ញាឲ្យប្រយ័ត្នដោយមានសភាពគុំស្ងូវមាំទាំល្អ ។ នៅតាមធ្នឹមទ្វារបង្អួចមានរូបបម្ងាក់ក្បាលយក្ស ។ មានសិលាចារិកផ្ទាក់ក្នុងឆ្នាំ ១០១១ គ.ស. ក្នុងរជ្ជកាលនៃព្រះបាទ សុរិយាវរ្ម័នទី ១ ជាអគ្គបទនៃសម្បថអ្នកការពារនៃព្រះរាជាណាចក្រ ។

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះទេពប្រណម្យ

កសាងក្នុងបុរាណសម័យ ថែរក្សាដោយក្រសួងអភិរក្សអង្គរ ពី គ.ស. ១៩១៨ រហូតមកដល់សព្វថ្ងៃនេះ ។

នៅឆ្ងាយប្រហែលជា ១០០ ម៉ែត្រ ពីទិសខាងជើងនៃព្រះលានស្តេចគម្លង់ គេនឹងឃើញផ្លូវកាត់តាមដងព្រៃព្រោះ តម្រង់ទៅព្រះពុទ្ធរូបអង្គធំ គឺព្រះទេពប្រណម្យដែលកំពុងគង់ពត់ព្រះភក្ត្រទៅទិសបាចិ ។ គេត្រូវធ្វើដំណើរកាត់តាមផ្លូវលំមួយក្រាលថ្មបាយក្រៀមប្រវែង ៧៥ ម៉ែត្រ ទទឹង ៨ ម៉ែត្រ តាមលំដាប់ទីលានដែលមានសន្ទឹកសីមាដាក់នៅតាមជ្រុង ៗ និងតាមទិស ៗ ។ 184

ទីលាននេះ បណ្តោយ ៥០ ម៉ែត្រ ទទឹង ១៤ ម៉ែត្រ នៅខាងលិចមានទីលានមួយទៀតក៏ជាកាកបាទ ជ្រុងមួយ ៗ មានប្រវែង ៣០ ម៉ែត្រ ។ ជញ្ជាំងផែនខាងក្រោមធ្វើពីថ្មភក់ និងផ្នែកខាងលើធ្វើពីថ្មភក់ ប្រកបដោយក្បាច់ឆ្លាក់ផ្កាឈូក ។ នៅតាមជណ្តើរដាក់ឈមមុខទៅខាងកើតនិងក្បាច់ដៃនាគ ដែល

www.budinst.gov.kh www.elibraryofcambodia.org

សាងក្នុងបុរាណសម័យ ។ មានសីមាមួយសន្លឹកចារជាអក្សរ
នៅគ្រប់ជ្រុងបញ្ជាក់សេចក្តីថា ព្រះអាស្រមជំនាន់ដើម ដែល
ព្រះបាទ យសោវរ្ម័ន បានកសាងក្នុងសតវត្សទី ៩ ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទព្រះប៉ាលីល័យ

មើលបំពីមុខ ខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះបាលិល័យ

គូព្រះវិហារសាងនៅដើមសតវត្សទី ១២ គោបុរៈខាងក្នុងសាងក្នុងចុងសតវត្សទី ១២ ដល់ដើមសតវត្សទី ១៣ ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ក្រសួងអភិរក្សអង្គរ ចាប់ផ្ដើមថែរក្សាតាំងពី គ.ស. ១៩១៨ រហូតមកដល់សព្វថ្ងៃនេះ ។

ធ្វើដំណើរតាមផ្លូវចោតមួយ ឆ្ពោះទៅទិសខាងជើងឈៀងខាងត្បូងបន្តិច ក្រោយទេពប្រណម្យតាមផ្លូវប្រវែង ១៥០ ម៉ែត្រតាមព្រះកដណានដែលមានកំពស់ពីរថ្នាក់ គេនឹងបានឃើញព្រះពុទ្ធរូបអង្គធំមួយនៅតាមគោបុរៈ ហើយនឹងបានដល់ព្រះវិហារព្រះបាលិល័យ ដែលព័ទ្ធព័ទ្ធដោយដើមស្នួននឹងដើមឈើតាលមើលពីចម្ងាយទៅមានសម្រស់យ៉ាងល្អថ្កុំថ្កើង ។

# ប្រាសាទព្រះពិធូ

វត្ថុសំខាន់ៗ សាងនៅចុងសតវត្សទី ១២ ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា លើកលែងតែគូព្រះវិហារមួយ ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។

www.budinst.gov.kh www.elibraryofcambodia.org

ការតុបតែងថែរក្សាដោយក្រសួង អភិរក្សអង្គរ ពី គ.ស. ១៩១៨ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទព្រះពិថ្នូ គឺជាទីប្រជុំដែលមានប្រាសាទ ៥ ខ្នង ទីលានស្ថិតនៅខាងជើងព្រះរាជលានជ្រុងខាងកើត នៅចំពីមុខទេពប្រណម្យ ដែលលេចឡើងឆ្ពោះតាមកន្លែងក្រោមដើមរុក្ខជាតិធំៗ ។ ប្រាសាទនេះសាងឡើងក្នុងជំនាន់ដែលប្រកបទៅដោយការសំអិតសំអាងយ៉ាងពិចិត្រ តាមការរចនាអង្គរវត្ត ក្នុងដើមសតវត្សទី ១២ ។

www.budinst.gov.kh www.elibraryofcambodia.org



ព្រះលានជំរី

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះរាជវាំងអង្គធំ

នៅមុខខាងជើងប្រាសាទបាយ័ន ផ្លូវស្រឡះគ្នាពីរតម្រង់ពីជើងទៅត្បូងបង្កើតជាទីលានមួយបណ្ដោយ ៧២០ម. ទទឹង ៨០ម. ដោយមានផ្លូវមួយកាត់ចំកណ្ដាលឆ្ពោះទៅ " ទ្វារជ័យ " នៅខាងកើត ។ ផ្លូវស្រឡះទាំងពីរនេះធ្វើឲ្យមានការទាក់ទងរវាងប្រាសាទនានា ។ គឺផ្នែកខាងកើត : ប្រាសាទសួព្រ័ត្រ , ប្រាសាទឃ្លាំងខាងត្បូងនិងខាងជើង, ព្រះពិធូ; ខាងលិចប្រាសាទបាពួន, ព្រះលានដំរី, ព្រះរាជវាំង, និងប្រាសាទវិមានអាកាស, ព្រះលាន " ស្ដេចគំលង់ ", ទេពប្រណម្យ និងព្រះបាលិល័យ ។

ទំហំព្រះលានពិតនោះមាន ២០០ម. X ៥៥០ម. អាចឲ្យក្បួនហែនានា និងក្បួនព្យុហយាត្រា ប្រព្រឹត្តទៅបានយ៉ាងងាយៗ គឺព្រះបាទជ័យវរ្ម័នទី ៧ ( ចុងសតវត្សទី ១២ ) ដែលបានសាងព្រះលាននេះ ។ លើព្រះលានមានសង់វេទិកា

www.budinst.gov.kh www.elibraryofcambodia.org

អំពីសម្ភារៈស្រាល    សម្រាប់ព្រះរាជាព្រមទាំងព្រះរាជបរិពា

ទ្រង់ទតទស្សនីយភាពផ្សេង ៗ ។

ព្រះលាន " ស្តេចគំលង់ " ស្ថិតនៅខាងជើងព្រះលាន

ជ័យ ដោយប្រកម្មួយចំណោចាច់ពីគ្នា ៗ បដិមាករដែលគេនិយម

ហៅថា " ស្តេចគំលង់ " នោះ គឺដោយហេតុតែមានស្នេហ៍

លើស្នើឲ្យពពាលដូចជាកើតឃ្លង់ ។ តាមការស្រាវជ្រាវនិង

ដោយសំអាងទៅលើសេចក្ដីចារឹកមួយឃ្លាក្រោមព្រះថែន បដិ-

មាករនេះគឺ " ស្តេចយោមរាជ " ហើយលានជ័យនេះគេអាច

បាត់ទុកជា "វាលព្រះមេរុ" សម្រាប់រំលាយព្រះសពព្រះរាជា ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទធម្មានន្ទ

មើលចំពីខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទធម្មនន្ទ

សាងនៅចុងសតវត្សទី ១១ ដល់ពាក់កណ្ដាលសតវត្សទី១២ ដោយស្នាព្រះហស្ដព្រះបាទឧត្យាទិត្យាវរ្ម័នទី ២ ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ។ ក្រសួងអភិរក្សអង្គរ ចាប់ផ្ដើមថែរក្សាពី គ.ស. ១៩១៩ រហូតមកដល់សព្វថ្ងៃនេះ ។

ធ្វើដំណើរពីអង្គរធំតាមទ្វារជ័យ ដែលស្ថិតនៅតាមអ័ក្សនៃគោបុរៈខាងកើត ចម្ងាយប្រហែល ៥០០ ម៉ែត្រ ពីគោបុរៈនេះទៅ គេនឹងឃើញប្រាសាទធម្មនន្ទស្ថិតនៅពីខាងជើងប្រាសាទចៅសាយ ។ ប្រាសាទនេះមាននិម្មាបនកម្មនិងការរចនាផ្សេង ៗ មានលក្ខណៈដូចប្រាសាទបាពួននិងប្រាសាទអង្គរវត្ត ប៉ុន្តែមានការខូចខាតអស់ជាច្រើន សព្វថ្ងៃក្រសួងអភិរក្សអង្គរបានស្ថាបនាឡើងវិញរួចស្រេច ។ បើតាមអក្សរសិលាចារឹក នៅតួកណ្ដាលនៃប្រាសាទបេងមាលាប្រាប់ថា ប្រាសាទធម្មនន្ទ សាងឡើងក្នុងពេលជាមួយគ្នានឹងប្រាសាទបេងមាលា ហើយនិងប្រាសាទបន្ទាយសំរែ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទជម្ពូនទួមានគោលសំខាន់មួយគឺតួវិហារ ដែលលាតសន្ធឹងពីលើខ្ពប់ពង់ ៤ ជ្រុងទ្រវែងមួយនៅទិសខាងកើត ដែលជាប្រាសាទប្រកបទៅដោយគោបុរៈពីរយ៉ាងសំខាន់ៗ គឺគោបុរៈមួយស្ថិតនៅខាងកើត មួយទៀតស្ថិតនៅត្រង់ជ្រុងខាងត្បូង ។ គេត្រូវដើរឆ្លងកាត់ស្រះបោក្ខរណីមួយ ដែលព័ទ្ធជុំវិញប្រាសាទ ហើយគេចូលទៅក្នុងបរិវេណប្រាសាទ ដែលមានគ្រឹះកំពែងធ្វើពីថ្មបាយក្រៀមព័ទ្ធជុំវិញ មានបណ្តោយ ៦០ ម៉ែត្រ ទទឹង ៤៥ ម៉ែត្រ ។



www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទចៅសាយទេវតា

មើលពីជ្រុងខាងកើតឈៀងខាងជើង

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទចៅសាយទេវតា

សាងនៅចុងសតវត្សទី ១១ ដល់ពាក់កណ្តាលសតវត្សទី ១២ ដោយស្នាព្រះហស្តព្រះបាទឧត្យាទិត្យាវរ្ម័នទី ២ ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ។ ក្រសួងអភិរក្សអង្គរ ចាប់ផ្តើមថែរក្សាតាំងពី គ.ស. ១៩១៩ រហូតមកដល់សព្វថ្ងៃនេះ ។

ធ្វើដំណើរចេញពីអង្គរធំតាមទ្វារជ័យ ដែលស្ថិតនៅតាមអ័ក្សនៃគោបុរៈខាងកើត គេនឹងប្រទះឃើញប្រាសាទចៅសាយទេវតា ដែលស្ថិតនៅឆ្ងាយពីគោបុរៈអង្គរធំប្រហែល ៥០០ ម៉ែត្រ ។ ប្រាសាទចៅសាយទេវតានេះមានសភាពស្រដៀងគ្នានឹងប្រាសាទធម្មនន្ទដែរ ហើយស្ថិតនៅខាងត្បូងប្រាសាទធម្មនន្ទ ទុកណាជាគេពុំបានដឹងពិតប្រាកដនូវការខូចខាតរបស់ប្រាសាទនេះក៏ដោយ ក៏គេអាចយល់ស្ថាបត្យកម្មនិងការរចនាផ្សេង ៗ ដែលមានលំនាំលក្ខណៈដូចប្រាសាទអង្គរវត្តដែរ ព្រោះជាប្រាសាទមានការរចនាតាមលំនាំខ្មែរនៅចុងសតវត្សទី ១១ ដល់ពាក់កណ្តាលដើមសតវត្ស

www.budinst.gov.kh www.elibraryofcambodia.org

ទី ១២ បើតាមសិលាចារឹកនៅនឹងត្លូកណ្តាលនៃប្រាសាទបេង
មាលាប្រាប់ថា ប្រាសាទនេះកសាងក្នុងពេលជាមួយគ្នានឹងប្រា
សាទបេងមាលា ហើយនឹងប្រាសាទបន្ទាយសំរៃ ។

ប្រាសាទចៅសាយទេវតា មានការបាក់បែកគស់ជាច្រើន
មកជាយូរអង្វែងហើយ ប្រាសាទនេះប្រកបដោយគោបុរៈ ៤
និងបណ្ណាល័យ ២ ដែលបង្ហាញឲ្យឃើញនូវសំណល់នៃផ្ទាំង
ចម្លាក់ជាច្រើនគរនៅជុំវិញប្រាសាទ ។

## ប្រាសាទតាកែវ

សាងនៅចុងសតវត្សទី ១០ និងដើមសតវត្សទី ១១
រវាងឆ្នាំ ១០០០ ដោយព្រះបាទជ័យវរ្ម័នទី ៥ បច្ឆាមរណៈ
(៩៧) ព្រះនាមបរមវីរៈ លោក និង ព្រះបាទសុរិយាវរ្ម័នទី ១
បច្ឆាមរណៈ ព្រះនាមបរមនិព្វានបទៈ ឧទ្ទិសចំពោះព្រះនា-
រាយណ៍ ព្រហ្មញ្ញសាសនា ។ ក្រសួងអភិរក្សអង្គរ
បានចាប់ផ្តើមថែរក្សាតាំងពីឆ្នាំ១៩២០រហូតមកដល់សព្វថ្ងៃនេះ ។
ប្រាសាទតាកែវ ស្ថិតនៅពីខាងកើតស្ទឹង ហើយស្ថិត

www.budinst.gov.kh www.elibraryofcambodia.org

[illegible]ខាងកើតថ្នល់ ការធ្វើដំណើរទៅកាន់ប្រាសាទនេះ ដោយ
[illegible]តាមផ្លូវខាងលិចនិងខាងត្បូង ។ ប្រាសាទនេះធ្វើ
[illegible]ក្រៅពីលើ ។ ដែលមានសភាពតាមក្បាច់រចនា
[illegible]ខាងនិរតី [illegible]ប្រាសាទខ្លះទំនៀមទំលាប់ប្រហែលណា
ពីព្រះ[illegible]ក្រុម[illegible]តាមគ្រឿង
[illegible]ថ្មី ។ ប៉ុន្តែមាន[illegible]ជា[illegible] បើការពីតីមុខគេឃើញ
មុខជាប្រជុំយកូប ។ ស្ថិតនៅតម្រៀបគ្នាជាជួរ ៤ ជ្រុងទ្រវែង
[illegible]តាយកូប ។ ទាំងនេះលេចជាកន្លែងមានទំនងជាផ្លូវ ដែលលយ
[illegible]ញ ហើយមានជួបជាធំតា ។

មិនដឹងជាហេតុអ្វី បានជាការកសាងប្រាសាទនេះពុំរួច
[illegible]ទាជាលំអ ប្រហែលជាកំពុងកសាងពុំទាន់រួចហើយ
[illegible]តែព្រះករុណាត្រូវចូលទីវង្គតទៅ ព្រះករុណាដែលសោយរាជ្យ
[illegible]យកទៀតពុំបានកសាងបន្ត ឲ្យមានគ្រប់រប[illegible]
[illegible]នៅតាមសភាពធានៀយ នោះបីជាព្រះករុណាកសាង
[illegible]ព្រះហស្ថ[illegible]ណាក៏ដោយ ក៏តានទៃណាមួយជា

www.budinst.gov.kh www.elibraryofcambodia.org

ស្នួកជានាគៈគានបន្ថែមលើការកសាងឡើយ ព្រោះហេតុនោះ
បានជាប្រាសាទនេះពុំមានសម្រស់ដូចប្រាសាទដទៃឯទៀត ។

ទោះបីយ៉ាងណាក៏ដោយ ក៏ប្រាសាទនេះនៅតែមានចំនួន
និងគុណភាពយ៉ាងប្រសើរនៅផ្នែក ខ្លះដែលមានការសំអិតសំ-
អាងគួរជាទីពេញចិត្តដែរ ។ ដោយសារការសិក្សាយ៉ាង
ល្អិតល្អន់ ពីសំណាក់លោកស្រី គូក៏ល់ដឺរេមុយសាត់ ,
លោក ហ្វេខ្សែវ៉ែរ និង លោក សឺដែស ដែលពិនិត្យប្រាសាទ
នេះក្នុងសម្ព័នៈផ្សេងៗគ្នា គេអាចសន្និដ្ឋានបានថាប្រាសាទនេះ
សាងនៅចន្លោះពេលដែលសាងផ្នែកមួយ នៃប្រាសាទបន្ទាយ
/៩៧ ស្រី និង គោបុរៈ នៃព្រះលានអង្គរធំ គឺកសាងឡើងនៅក្នុង
ចន្លោះចុងសតវត្សទី ១០ និងដើមសតវត្សទី ១១ ។
អក្សរសិលាចារឹក ដែលនៅនឹងជើងសសរគោបុរៈខាងកើត
មានចំនួន ១០០៧ តួ ដែលសំណាលពីសំណាយនៃការ
កសាងប្រាសាទនេះ តែពុំបានប្រាប់ពីគ្រឹះដែលជាមូល
ដ្ឋានទេ គេបានចារភ្ជាប់នឹងផ្ទាំងសន្លឹកសីមាមួយ ដែលគេបាន

www.budinst.gov.kh www.elibraryofcambodia.org

គេឃើញនៅក្នុងបណ្ណាល័យខាងត្បូង ផ្ទាំងសិលានេះមាន គតិប្បាយពីការចាត់តែងទូទៅ ក្នុងរជ្ជកាលនៃព្រះបាទសុរិ-យាវរ្ម័នទី ១ ប៉ុន្តែគ្រាន់តែបានធ្វើនិទ្ទេសពីការកសាង ក្នុង គ.ស ៩៩៣ ដោយព្រះបាទយសោវរ្ម័នយ៉ាងណាក៏ដោយ ក៏ លោក សឺដែស បានយល់ឃើញថាប្រាសាទតាកែវនេះ ចាប់ផ្តើមកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី ៥ ហើយកសាងបន្ថែមដោយព្រះបាទសុរិយាវរ្ម័នទី ១ គឺជាភ្នំមាសឈ្មោះ " ហេមគិរី " តំណាងភ្នំព្រះសុមេរុ ជាប្រាសាទសំណាក់ការមួយរបស់ព្រះយុវរាជ ជាគុហាការជាន់ខ្ពស់ ៗ

ប្រាសាទនេះមានរាងជាសាជីហើយមានថ្នាក់ ៥ ដែល មានកំពស់រួមទាំងអស់ ២២ ម៉ែត្រ ក្នុងប្រាសាទដែលមានថ្នាក់ពីរនៅពីក្រោម មានផ្លូវព័ទ្ធជុំវិញ ដែលថ្នាក់ក្រោមបំផុតមានធ្វើជាកំពែងជញ្ជាំងព័ទ្ធជុំវិញ ថ្នាក់បន្ទាប់មួយទៀតមានថែវព័ទ្ធជុំវិញ ដែលមានគ្រឿងតាំង កើតឡើងដោយស្នាដៃមនុស្សពិត ៗ ដែលសាងឡើងស្ថិតនៅក្នុងផ្លូវនៃប្រជុំតែមួយ

www.budinst.gov.kh www.elibraryofcambodia.org

ស្របនឹងកិច្ចការនៃប្រាសាទ ជាកន្លែងមានសភាពចង្អៀត ចង្អល់ ហើយមិនជាកន្លែងដែលធ្វើឡើងដើម្បីព្យាបាលជម្ងឺ ជាបណ្ដោះអាសន្ន នេះជាហេតុនាំឲ្យមានការចាប់អារម្មណ៍ យ៉ាងក្រៃលែង ។

ប្រាសាទនេះសាងពីថ្មភក់ដូចប្រាសាទនានាដែរ តាមសភាពធម្មតា ការកសាងឡើងដើម្បីឧទ្ទិសផលមនុស្សណា ដែលមានបុណ្យបារមីដូចព្រះអាទិទេព ។ បើតាមការពិចារណា សព្វគ្រប់ទៅ ឃើញថាការកសាងនោះមានការសំអិតសំអាង ល្អិតល្អន់ជាទីបំផុត ថ្វីត្បិតតែពុំមានការរចនាជាក្បាច់យ៉ាង ណាក៏ដោយ ការតុបតែងនៅតែមានសភាពល្អជាធម្មតា ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទតាកែវ

មើលពីមុខខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទតាព្រហ្ម

សាងពីពាក់កណ្តាលសតវត្សទី១២ ដល់ចុងសតវត្សទី១៣ "១១៨៦" ដោយព្រះបាទជ័យវរ្ម័នទី ៧ បញ្ចាមរណៈព្រះនាមមហាសំគត បត: ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ក្រសួងអភិរក្សអង្គរ ចាប់ផ្តើមថែរក្សាពី គ.ស. ១៩២០ រហូតមកដល់សព្វថ្ងៃនេះ ។

ការធ្វើដំណើរចូលទៅទស្សនាប្រាសាទនេះ ត្រូវចូលបានតាមផ្លូវពីរគឺ បើចូលពីទ្វារទិសខាងលិចត្រូវឲ្យយានជំនិះរ៉ឺម៉ក ឬ រថយន្តទៅឈប់ចាំនៅទ្វារទិសខាងកើត បើចូលពីទ្វារទិសខាងកើត ត្រូវឲ្យយានជំនិះទៅឈប់ចាំនៅទ្វារទិសខាងលិចវិញ ។ ពីទ្វារខាងកើតទៅទ្វារខាងលិចនៃប្រាសាទតាព្រហ្មមានចម្ងាយផ្លូវ ១ គីឡូម៉ែត្រ ។

តាមធម្មតាទូទៅ លោក គាល់ឌូហ៊ុចខ្យ បានមានប្រសាសន៍ថា : លោកអ្នកត្រូវតែថែរក្សាធម្មជាតិទាំងនេះឲ្យស្ថិតនៅក្នុងសភាពថ្មីថ្មាជានិច្ច ព្រោះធម្មជាតិទាំងនេះត្រូវប្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ព្រំដោយទឹកភ្លៀងនិងកំដៅព្រះអាទិត្យ ។

ទោះបីធម្មជាតិទាំងនេះ ពុំមានការហត់នឿយយ៉ាងណាក៏ដោយ ប៉ុន្តែមានការវិនាសខូចខាតអស់ជាច្រើន ដោយហេតុនេះហើយ បានជាសាលាបារាំងសែសផ្នែកចុងបូព៌ាបានប្រៀបធៀបនូវការលូតលាស់ចំរើនយ៉ាងសំខាន់ ក្នុងករណីយដែលគេបានជួសជុលឡើងវិញខ្លះ ដើម្បីនឹងរក្សានូវសភាពបុរាណឲ្យបានគង់វង្សដដែល ហើយជាប្រាសាទប្រកបដោយព្រៃឈើធំច្រើនដុះស្រោងស្រង ។ បើនិយាយឲ្យស្របទៅតាមភស្តុតាងដែលគេបានសំគាល់ ឃើញនូវក្បាច់រចនាខ្មែរហាក់រស់រវើក ។

គួឲ្យមានសេចក្តីសោកស្តាយយ៉ាងខ្លាំង ចំពោះបដិមរូបដែលគួឲ្យអត់សរសើរមិនបាន ព្រោះវត្ថុនិមួយ ៗ មានបច្ច័យទាក់ទងទៅនឹងចិត្តជាស្ថាពរ ហាក់ដូចជាទីនេះធ្វើឲ្យនឹកឃើញនូវគុណជាតិដែលជាហេតុនាំឲ្យដឹងខុសត្រូវ ។

ការត្រួសត្រាយឲ្យបានស្រឡះ ដើម្បីឲ្យស្រួលដល់ការ

www.budinst.gov.kh www.elibraryofcambodia.org

ទស្សនានូវបុរាណវត្ថុដែលបាក់ទ្រុឌទ្រោម ហើយមានលតាវល្លិ តូចធំដុះគ្របពីលើ ព្រមទាំងឫសឈើធំ ៗ ដែលរុំព័ទ្ធពីទ្រន់ ព្រាយនៃនិម្មាបនកម្ម នាំឲ្យបាត់លំអនៃប្រាសាទ ៗ យើង សូមឲ្យមានការត្រេះរិះពីអ្នកទេសចរ នូវការពិនិត្យពិច័យយ៉ាង យូរចំពោះថ្ងុះនៃប្រាសាទនេះឲ្យបានសព្វគ្រប់ លោកអ្នកនឹង មានការរញ្ជួលចិត្តយ៉ាងខ្លាំងចំពោះការទ្រុឌទ្រោមចុះនៃប្រាសាទ ទាំងស្រុង ៗ

ការទស្សនាប្រាសាទតាព្រហ្មត្រូវចូលតាមទ្វារពីរគឺ ទ្វារ ខាងកើតនិងទ្វារខាងលិច ព្រោះទ្វារទាំងពីរនេះមានការទាក់ទង គ្នាជួបបង្ហាញទៅផែនទីស្រាប់ ការធ្វើដំណើរត្រូវប្រុងប្រយ័ត្ន បន្តិច ព្រោះច្រើនវង្វេងផ្លូវ ៗ បើតាមការពិតទ្វារទាំងពីរ នេះស្ថិតនៅម្ខាងម្នាក់ទាក់ទងគ្នាដោយសារបន្ទប់តូច ៗ ដែល នៅហែរគ្នា ពុំចេះអស់ពុំចេះហើយពាសពេញរកយល់មិនបាន ព្រោះបន្ទាយទាំងនេះ ប្រទាក់ប្រទិសគ្នាដោយផែនសិលាធំ ៗ ដែលរលំធ្លាក់ ប៉ុន្តែនៅតែមានគុណភាពយ៉ាងប្រសើរតាមការ

www.budinst.gov.kh www.elibraryofcambodia.org

ប្រមូលផ្ដុំនៃវត្ថុធាតុពិត ៗ ។

ប្រាសាទតាព្រហ្ម គឺជាព្រះវិហារសម្រាប់ព្រះពុទ្ធសាសនា ដែលមានទម្រង់ជាជាន់ ៗ ក្នុងចំណោមប្រាសាទទាំងឡាយ ដែលកសាងឡើងជាថ្នាក់ ៗ ព្រោះមានផ្នែកខ្ពប់កប ៗ ឯរបៀបកសាងមានទម្រង់ផ្ដេកផ្ដួល ទៅតាមការតាំងបេញនៃថែវជាយ៉ ៗ និងគូវិហារធំ ដែលស្ថិតនៅលើការប្រជុំនៃគោលសំខាន់ ៗ ដែលទាក់ទងគ្នាមានទម្រង់ស្របទៅនឹងថែវ ដែលមានជាស្នូល "ប្រក" នៅត ៗ គ្នាដោយបន្ទាយនិងជួរ ៗ ឯចំណែកស័ក្យខាងកើតនិងខាងលិច មានផ្លូវចូលរហូតទៅដល់ក្នុងប្រាសាទ ៗ យើងមានមនោសញ្ចេតនារន្ធត់ញាប់ញ័រ ចំពោះផ្ទាំងសិលាដែលបាក់បែកនៅក្នុងប្រាសាទទាំងនេះ ដែលសាងបន្ដុប ៗ លើគ្នាលយចេញក្រៅ បើតាមការពិនិត្យឲ្យច្បាស់ទៅគេច្រើនឃើញមាននៅក្នុងប្រាសាទបែកខាងកើត ។

កំពែងបរិវេណពីរដែលនៅត ៗ គ្នា មានសភាពជាផ្ញាំងឈមគ្នា កំពែងខាងក្រៅមានបណ្ដោយ ១.០០០ ម៉ែត្រ ទទឹង

www.budinst.gov.kh www.elibraryofcambodia.org

៦០០ ម៉ែត្រ ព័ទ្ធជុំវិញគូប្រាសាទទាំងមូល គេពុំមានការងឿងឆ្ងល់ពីជញ្ជាំងទាំងនេះទេ ព្រោះជាជញ្ជាំងដែលសង់ឡើងប្រកបដោយថែវ ៣ យ៉ាងសំខាន់ៗ ហើយដែលស្ថិតនៅជិតៗគ្នា ក្នុងផ្ទៃដីកង ៤ ជ្រុងស្មើ ដែលមានប្រវែងមួយជ្រុង ១ ចំនួន ១០០ ម៉ែត្រ គប់បាក់នៅក្នុងប្រកតនៃប្រាសាទដែលមានផ្ទៃដី ៦០ ហិកតា ។ សិលាចារឹកនៅប្រាសាទនេះបានបញ្ជាក់ប្រាប់ថា មានមនុស្សចំនួន ១២.៦៤០ នាក់ ស្ថិតនៅក្នុងនាទីប្រាសាទ គឺមានព្រះសង្ឃធំៗ ចំនួន ១៨ អង្គ មានមន្ត្រីជាន់ខ្ពស់ ២.៧៤០ នាក់ ទាហាន ២ ២៣២ នាក់ ហើយនៅក្នុងចំណោមពួកទាំងនេះមានស្រីរបាំចំនួន ៦១៥ នាក់ ។ល។

ទុកជាគេបានដឹងនូវកំណត់ពេលកសាងចំនួន ២០ ឆ្នាំ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ យ៉ាងណាក៏ដោយ ក៏ការកសាងប្រាសាទទាំងឡាយនេះ នៅតែមានទ្រង់ទ្រាយប្រហែលគ្នានឹងប្រាសាទបាយ័នដែរ តែសព្វថ្ងៃនេះគេរកឃើញគ្រឿងសម្ភារៈដែលនៅសល់ក្នុងបណ្ដោះពេលយ៉ាងខ្លី ដោយបានសាងបន្ថែម

www.budinst.gov.kh www.elibraryofcambodia.org

និងពង្រីកឲ្យមានសភាពប្លែក ៗ ព្រមទាំងបំពេញសព្វគ្រប់ពុំឲ្យមានខ្វះត្រង់កន្លែងដែលត្រូវទាក់ទងដល់លទ្ធិសាសនា ដែលគេបានសាងបញ្ជាក់ នូវគ្រឿងអាភរណៈនៃអង្គណាមួយឲ្យកើតមានឡើង ៗ ប្រាសាទតាព្រហ្មនេះមានសភាពស្មុគស្មាញយ៉ាងខ្លាំងតាមការពិនិត្យរបស់លោក ក្រូលីយេ ព្រោះជាប្រាសាទ ដែលសាងដោយមានសំណង់លយពេញជាយ៉ ៗ ហើយដែលមានជាស្នាមរើរៀបចំគ ៗ គ្នា ដែលនៅតាមកន្លែងខ្លះមាន ទ្រង់ទ្រាយប្រហាក់ប្រហែលគ្នានឹងប្រាសាទអង្គរវត្ត ឬ បាយ័ន ៗ ដោយសារការបង់ជីងនូវជុំរៅនៃការត្រួសត្រាយ ដែលបានតាក់តែងបញ្ចូលគ្រឿងសម្ភារៈខ្លះ ដើម្បីឲ្យមានការពិតប្រាកដឡើង គេបានទុកប្រាសាទតាព្រហ្មនេះឲ្យនៅមានភាពដដែល ដើម្បីជាភស្តុតាង ៗ

សន្លឹកសីមានៅប្រាសាទតាព្រហ្មនេះ មានចារឹកនៅគ្រប់ជ្រុងទាំង ៤ ដែលគេបានរកឃើញនៅក្នុងវែរជិតគោបុរៈកំពែងទី ២ ដែលមានចុះពីកំណត់កាលពី គ.ស. ១១៨៦ គឺក្រោយ

www.budinst.gov.kh www.elibraryofcambodia.org

ពេលដែលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ឡើងសោយរាជ្យ ។ ដោយមានការតាក់តែង និងការសាងរូបព្រះមាតារបស់ព្រះអង្គ ដែលសាងឡើងជា "ព្រះប្រាជ្ញាបារមីតា" ជាតួ "សុក្រឹតភាពនៃគតិបណ្ឌិត" ដែលចូលចិត្តខាងការដោះប្រស្នាសមតាមកិរិយានៃអ្នកប្រាជ្ញ ហើយដែលទុកដូចព្រះមាតានៃព្រះពុទ្ធទាំងឡាយ គេគាបតាត់ដាក់ប្រាសាទនេះទៅក្នុងចំណោមប្រាសាទជាទីគោរពទាំងឡាយ ឧទ្ទិសចំពោះបុព្វានុភាពនៃព្រះញាតិវង្ស ដែលទុកដូចជាទេវៈ ។ ក្រោយពីបានរៀបរាប់នូវព្រះនាមនៃព្រះអយ្យកោ ព្រះអយ្យកា ព្រមទាំងជោគជ័យ ក្នុងចម្បាំងជាមួយប្រទេសចំប៉ា សិលាចារឹកនេះបានកត់សម្គាល់ថា ព្រះបាទជ័យវរ្ម័នទី ៧ បានតាក់តែងឲ្យសាងរូបទេវៈចំនួន ២៦០ ព្រមទាំងរូបព្រះគ្រូនៃព្រះអង្គ , ប្រាសាទមានស្តូបខ្ពស់ ៣៩ ធ្វើពីថ្មកក់ខ្ពស់ៗ , លំនៅ ៥៦៦ ធ្វើពីថ្ម និង ២៨៦ ធ្វើអំពីឥដ្ឋ ព្រមទាំងមានជញ្ជាំងកំពែងប្រវែង ២៧០២ ព្យាមធ្វើពីថ្មបាយក្រៀម ។

www.budinst.gov.kh www.elibraryofcambodia.org

មានឃុំ ៣១៤០ ហើយមានប្រជាជន ៧៩.៣៦៥ នាក់ ជាអ្នកកៃវគ្យាប្រាសាទ តាមសេចក្ដីយ៉ាងពិស្ដារនៃអត្ថបទនេះ ដែលអធិប្បាយបញ្ជាក់យ៉ាងក្បោះក្បាយ នូវបែបបទផ្សេងៗ ។ គេបានរៀបរាប់ ជាពិសេសនូវនានាភោជភ័ណ្ឌធ្វើអំពីមាស ទម្ងន់ ៥ តោន ព្រះវិហារធ្វើពីស្បូត្រ ៥១៦ និងកំពស់ ៥២៣ ហើយក្រោយពីជបញ្ញត្តិ ដែលតែងតាំងឡើងសម្រាប់ពិធីបុណ្យផ្សេងៗ ទ្រង់បានបញ្ជាឲ្យសាងមន្ទីរព្យាបាលរោគ ចំនួន ១០២ ទៀត ។



21

ប្រាសាទតាព្រហ្ម

មើលបំពីខាងកើតនៃខ្លោងទ្វារទី ២

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបន្ទាយក្ដី

សាងក្នុងពាក់កណ្ដាលសតវត្សទី ១២ ដល់ចុងសតវត្សទី ១៣ ដោយព្រះបាទជ័យវរ្ម័នទី ៧ បច្ឆាមរណៈព្រះនាម មហាបរមសុគតបទៈ ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ក្រសួងអភិរក្សអង្គរ បានថែរក្សាពី គ.ស. ១៩២០ រហូតដល់សព្វថ្ងៃនេះ ។

លក្ខណៈសំខាន់ :

ប្រាសាទនេះមានលក្ខណៈដូចប្រាសាទតាព្រហ្មដែរ ការធ្វើដំណើរកាត់ប្រាសាទនេះពុំងាយទៅងាយបាន ដោយសារបាក់បែកខ្ទេចខ្ទីនិងរលំគគាំងច្រើន ។

បើចេញពីប្រាសាទតាព្រហ្មហើយ ធ្វើដំណើរទៅកាន់ប្រាសាទបន្ទាយក្ដី ដោយដើរកាត់តាមផ្លូវរទេះតូចដែលមានចម្ងាយ ៥០០ ម៉ែត្រ គេនឹងបានទៅដល់ខ្លោងទ្វារខាងកើតនៃប្រាសាទ ។

ប្រាសាទនេះជាឧទាហរណ៍មួយច្បាស់ នៃគំនិតប្រឌិតប្រាសាទ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងការរៀបចំ ។ ប្រាសាទបន្ទាយក្ដីមានទំហំតូចជាងប្រាសាទតាព្រហ្មនិងប្រាសាទព្រះខាន់ ដែលសាងបំពេញដោយស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី ៧ ។ ប្រាសាទបន្ទាយក្ដីនេះ សាងនៅជិតគ្នា នៅក្នុងកំពែងពិសេសដែលមានបណ្ដោយ ៦៣ ម៉ែត្រ ទទឹង ៥០ ម៉ែត្រ ហើយដែលមានកំពែងខាងក្រៅបណ្ដោយ ៧០០ ម៉ែត្រ និង ៥០០ ម៉ែត្រទទឹង ។

តាមស្លាកស្នាមខ្លះ ដែលគេបានឃើញនៅប្រាសាទនេះប្រហែលជាសាងពីរដងខុសគ្នា ហើយមានលំនាំដូចប្រាសាទអង្គរវត្តនិងប្រាសាទបាយ័ន ដែលមានក្បាច់ចម្លាក់ខ្លះស្ថិតនៅកំប៉ាំងនឹងក្បាច់ក្បាំងយ៉ាងច្រើន តាមកន្លែងខ្លះនៃការកសាងបន្ថែម ដើម្បីឲ្យដឹងច្បាស់ឡើងទៀត ហើយមានខ្ទង់ព្រាយដូចជាខូចខាតវត្ថុមួយក្រោយពេលដែលកសាង ដោយមានគោលសំខាន់ៗនៃថែវនិងរបៀងមុខ ដែលបង្កើតបានជារូបមន្តនៃសាកលោទ្យាន ។

វិចិត្ររូបដែលមានសភាពប្លែកពីសភាពដើមនោះ គឺមកពីរង្វាស់ចុកណាដែលមានសភាពស្មើ ហើយជាតួព្រះវិហារសម្រាប់ព្រះពុទ្ធសាសនា ដោយមានដៃពីរទាក់ទងគ្នាតាមស្បូលតែមួយ "ប្រក" ដែលបញ្ជាក់ឲ្យដឹងនូវសភាពសម្បូណ៌ ដោយបន្ទាយយ៉ាងពិត ៗ បន្ទាយទាំងនេះ ស្ថិតនៅទាក់ទងនឹងទីធ្លាមួយដែលមានដំបូលជាកាកបាទ នៅខាងកើតមានកំពែងពីរសង់នៅត ៗ គ្នា ៗ

ឯសភាពដែលខូចខាតនោះ មានមកជាយូរអង្វែងណាស់ហើយ គឺច្រើនមានផ្ទាំងថ្មធំ ៗ រមៀលធ្លាក់ ដោយមកពីការរៀបចំពុំបានល្អ ហើយជាហេតុនាំឲ្យបាក់ខូចខាត ព្រោះថ្មភក់ដែលយកមកកសាងនោះ ច្រើនតែថ្មស្រួយ បណ្ដាលឲ្យមានការរបើករបាញអស់ជាច្រើន ៗ ប្រាសាទបន្ទាយក្តី ដែលហាក់ដូចជាដុះគ្នារឡើងប្រកបដោយសម្រស់យ៉ាងល្អពេក មិនទាញសម្រស់នៃប្រាសាទឯទៀតឡើយ ព្រោះប្រាសាទនេះបង្ហាញឲ្យឃើញនូវផ្ទុកធំ ៗ ដែលរលំធ្លាក់ មិន

www.budinst.gov.kh www.elibraryofcambodia.org

អាចនឹងរៀបចំឲ្យបានស្រួលបួលវិញឡើយ គេពុំអាចរកការពិតនូវការប្រើប្រាស់ដែលបានបំរុងទុកជាមុន ក្នុងការកសាងប្រាសាទនេះទេ ។ សិលាចារឹកដែលគេរកឃើញនៅគោបុរៈខាងលិចនៃកំពែងទីពីរ បានបង្ហាញនូវថាសដែលគេយកមកប្រើម្តងទៀត ថានេះមានចំណាស់តាំងពីរជ្ជកាលព្រះបាទរាជិន្ទ្រាវរ្ម័ន ក្នុងសតវត្សទី ១០ ។ សិលាចារឹកនេះបានបង្ហាញឲ្យដឹងទៀតថា ប្រាសាទបន្ទាយក្តីនេះសាងនៅជិតប្រាសាទកុដិស្វរៈ ហើយព្រមតាំងសំបូងសង្រួងដល់ព្រះឥសូរ ម្យ៉ាងទៀតសិលាចារឹកនេះ បានរៀបរាប់អំពីការកសាងរូបសំណាកពីរ គឺរូបព្រះព្រហ្មមួយ រូបព្រះនារាយណ៍មួយ ។

ឯក្បាច់ក្បាំង ហើយនិងក្បាច់នៅធ្នឹមទ្វីងទ្វារនៃព្រះវិហារពុទ្ធសាសនាបែកខាងមហាយាននេះ សុទ្ធតែគួរជាទីជាប់ចិត្តហើយសំខាន់ៗទៀតផង ។ ក្បាច់ខ្លះត្រូវខូចខាតដោយសារការបង្កិនបំផ្លាញនៃសាសនាព្រាហ្មណ៍ ក្នុងសតវត្សទី ១៣ ព្រោះគេឃើញនៅសល់កុដិមួយធ្វើពីឈើ ដែលក្រសួងកសិកម្ម

www.budinst.gov.kh www.elibraryofcambodia.org

អគ្គិរបាទក្រុងស្រោយពេញ ។

## ស្រះស្រង់

សាងនៅចុងសតវត្សទី ១២ ដោយព្រះបាទជ័យវរ្ម័នទី ៧ "បុរាណៈ ព្រះនាម "មហាបរមសុគតបទ" ។ ក្រសួងអេកូលរក្សា គោចរៃក្សាតាំងពី គ.ស. ១៩២០ រហូតមកដល់សព្វថ្ងៃនេះ ។

ការធ្វើដំណើរចេញពីប្រាសាទបន្ទាយក្តីតាមទ្វារខាងកើត កាត់តាមថ្នល់ឆ្ពោះត្រង់គីឡូម៉ែត្រលេខ ១១ គេមិនបានទៅដល់ កាំជណ្តើរយ៉ាងសង្ហានៃនាគបាល ដែលស្ថិតនៅចំពីមុខ ប្រាសាទបន្ទាយក្តី គេមិនឃើញផ្ទៃទឹកល្ហល្ហបនៃស្រះស្រង់ ដែលមានបណ្តោយ ៧០០ ម៉ែត្រ ទទឹង ៣០០ ម៉ែត្រ បើតាម ការស្មានមើលទៅ ប្រហែលជាស្រះនេះជីកក្នុងរជ្ជព្រះ បាទជ័យវរ្ម័នទី ៧ ព្រោះស្រះនេះស្ថិតនៅឃ្លាតពីកំពែងប្រាសាទ បន្ទាយក្តី ។ ស្រះនេះមានកាំជណ្តើរធ្វើពីថ្មបាយក្រៀម ហើយនៅមានធ្វើពីថ្មភក់, នៅកណ្តាលស្រះមានកោះមួយធ្វើពី

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទាំងថ្មដែលមានរាងទៅជាប្រាសាទមួយតូច ៗ

ស្រះនេះមិនដែលរីងទឹកទេ ហើយមានដើមរុក្ខជាតិធំ ៗ ដុះនៅជុំវិញ ដែលធ្វើឲ្យមានទិដ្ឋភាពយ៉ាងត្រចះត្រចង់នៅក្នុងចំណោមប្រាសាទនានានៃអង្គរ ៗ មានទីលានភ្ជាប់ទៅនឹងសំណង់តូច ៗ ខ្លះនៃរានហាល ដែលមានជាបន្ទប់មួយរាង ៤ ជ្រុងទ្រវែង ព្រមទាំងមានជាថែវព័ទ្ធជុំវិញផង ផ្នែកក្រោលធ្វើពីថ្មភក់ បើតាមការពិតនៃផែនទី "រានកៅ" នឹងមានធ្វើជាផ្លូវតូច ៗ ពីរទៀត ហើយមានកាំជណ្តើរមួយស្ថិតនៅជាប់នឹងស័ក្ស ដែលមានជាសន្ទាត់ ៗ ថែកបានជាជណ្តើរ ៣ នៅកណ្តាលស័ក្ស ដែលនៅតាមជណ្តើរនេះមានឆ្លាក់ជារូបតោពីរ មានភាពយ៉ាងអង់កាច មានសាងជាផ្នែករានហាល ដែលលៀនលយចេញ ហើយជាលំអដោយភ្ជាក់ដៃនាគយ៉ាងសង្ហាផង ៗ ការរចនាសិនប្រកបដោយថ្វីដៃយ៉ាងប្រណីតបង្ហាញពីភាពសម្បូណ៌កក្កុញ ដោយក្បាច់ប្រសើរផ្សេង ៗ នៅពីខាងមុខរានហាលមានរូបគ្រុឌមួយយ៉ាងធំប្រគង

www.budinst.gov.kh www.elibraryofcambodia.org

ប្រទាក់លើរូបនាគដែលមានក្បាល ៣ ឯក្បាលឯទៀតសម្រាប់ រុំព័ទ្ធ ៗ នៅពីខាងក្រោយ មាននាគក្បាល ៣ មួយទៀត ដែលមានកន្ទុយផ្ទាក់ភ្ជាប់លំអដោយក្បាលនាគតូច ៗ ដាក់ពី លើក្តោគ្រុឌយ៉ាងច្បាស់ ៗ ៗ ឯកន្ទុយនាគផ្ទាក់ដាក់លើជើង សសរដែលមានផ្ទាក់ជាលំអប្លែក ៗ ហើយដែលដាក់ភ្ជាប់ទៅ នឹងគ្រឹះយ៉ាងធំ ៗ រូបទាំងនេះមានសភាពល្អឥតខ្ចោះ មានទ្រង់ទ្រាយនៅសល់ខ្លះ ដែលមានសភាពដូចនៅប្រាសាទ បាយ័នដែរ ៗ

## ប្រាសាទក្រវ៉ាន់

សាងនៅដើមសតវត្សទី ១០ "គ.ស. ៩២១" ដោយ ព្រះបាទ ហសវរ្ម័នទី ១ បញ្ចាមរណៈព្រះនាម "រុទ្រលោក" ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ៗ ក្រសួងអភិរក្សអង្គរ បាន ថែរក្សាតាំងពី គ.ស. ១៩២៩ រហូតមកដល់សព្វថ្ងៃនេះ ៗ

ប្រាសាទក្រវ៉ាន់នៅចំពីខាងកើតអង្គរវត្ត តាមផ្លូវរង់តូច ត្រង់គីឡូម៉ែត្រលេខ ១២ និងលេខ ១៣ ដែលមានតួប្រាសាទ

www.budinst.gov.kh www.elibraryofcambodia.org

៥ សន់អំពីថ្ម តែសព្វថ្ងៃនេះត្រូវវិនាសខូចខាតអស់ជាច្រើន ។ ប្រាសាទនេះមានលំអគ្រប់កន្លែងទាំងអស់ ដែលមានលក្ខណៈពិសេសម្យ៉ាងតាមការរចនានៅអង្គរ ដូចជាក្បាច់រចនាខ្លះឆ្លាក់នៅលើថ្មខាងក្នុងតួវិហារទាំងនោះ ។

មានស្រះបោក្ខរណីព័ទ្ធជុំវិញ ហើយមានចំនប់មួយនៅទិសពាយ័ព្យ សម្រាប់ជាផ្លូវចូលកាន់ប្រាសាទ ។ ប្រាសាទទាំងនេះស្ថិតនៅជិត ៗ គ្នាលើទីលានថ្មមួយ ដែលបែរមុខទៅទិសខាងកើត ។ ការខូចខាតនេះមានមកអស់កាលជាយូរមកហើយ ព្រោះមានរុក្ខជាតិធំ ៗ មានឫសចាក់រូតរឹតពីលើថ្ម ឯការដែលវិនាសនៃផ្ដើរនៅធរណីទ្វារ គួរឲ្យស្ដាយណាស់ ។

## ប្រាសាទប្រែរូប

សាងនៅចុងសតវត្សទី ១០ "គ.ស. ៩៦១" ដោយព្រះបាទរាជេន្ទ្រវរ្ម័ន បច្ឆាមរណៈព្រះនាម "សិវៈលោកា" ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា ថ្វាយចំពោះព្រះនាកយណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្រសួងអភិរក្សអង្គរ បានចាប់ផ្តើមថែរក្សាតាំងពី គ.ស. ១៩៣០ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទនេះ ស្ថិតនៅចម្ងាយ ២៣០០ ម៉ែត្រ ពីផ្លូវខ្វែងវង់ធំនិងវង់តូចត្រង់ជ្រុងស្រះស្រង់ ដែលស្ថិតនៅត្រង់ផ្លូវកែងកាច់ទៅទិសខាងជើង ហើយដែលស្ថិតនៅចម្ងាយ ៨០០ ម៉ែត្រ ពីខាងត្បូងទំនប់ទិសទក្សិណនៃបារាយណ៍ទិសបូព៌ គឺស្ថិតនៅត្រង់បង្គោលគីឡូម៉ែត្រលេខ ១៦ ។

ប្រាសាទប្រែរូប លាតត្រដាងឲ្យឃើញនូវទ្រង់ទ្រាយនិងវិសាលភាពយ៉ាងប្រណីត ដែលសាងឡើងដោយវត្ថុធាតុពណ៌ក្រហម គឺសាងអំពីឥដ្ឋបាយក្រៀមនិងឥដ្ឋ ។ គេបានប្រឹងប្រែងរៀបចំឡើងវិញ ដោយយកដីនិងឫសឈើឲ្យអស់ចេញ ដើម្បីកុំឲ្យរមៀលធ្លាក់ ហើយយកកំបោរនិងបាយអមកភ្ជាប់ឥដ្ឋ ដើម្បីឲ្យមានសភាពរឹងប៉ឹងដូចធម្មតា ។

ប្រាសាទនេះ សាងក្រោយប្រាសាទមេបុណ្យ ប៉ុន្តែមានសភាពដូចគ្នាបេះបិទ គឺប្រាសាទដែលសាងឡើងជា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទក្តី ព្រមទាំងមានថែវលេចលយចេញតាំងពីពេល
គេសាងមកនោះ ហើយមានទាំងបន្ទប់វែងៗ សំយុងបន្តមក
ក្រោមទៀតៗ ពួកប្រាសាទក្តីទាំងនេះ ជាកន្លែងសម្រាប់
ព្រះអាទិទេព មានកន់ជាសាជី ដូចជាមកុដកង៤ ជ្រុងញាយ
ហើយមានជាបន្ទប់ វែងសាងទុកបចពោះវែរៈផខ ព្រមទាំង
ភាពយាត្តហារ.. ចំនួន ១២ នៅតាមក្បាលដំណើរ
ដើម្បីជាកន្លែងសម្រាប់ដំកល់ សិវៈលិង្គ ដូចជានៅប្រាសាទ
បាគងដែរ ។ ឯសិលាចារឹកបានអធិប្បាយប្រាប់ពីកំណត់
កាលសាងសាងពី គ.ស. ៩៦១ មិនប្រាប់ពីឈ្មោះប្រាសាទព្រម
ទាំង..ទបញ្ជាក់ពី ព្រះកដវង្សនៃព្រះបាទរាជេន្ទ្រវរ្ម័ន ដែល
ព្រះអង្គបានសាងការិក្តិឈ្មោះ កវីន្ទ្រាម្រគ្រស្វរៈ ដាក់នៅ
ទីងគុ ប្រាសាទកណ្តាល ហើយមានរូបសំណាកព្រះអង្គ
ដំកល់នៅ ទីប្រាសាទតាមជ្រុង គឺជាព្រះរូបដែលទាក់ទងទៅ
មិនសាសនាព្រាហ្មណ៍ ព្រោះព្រះអង្គជាអ្នកទ្រទ្រង់និងគោរព
ព្រះឥស្សូរ ឯព្រះមាតុបាទិនព្រះអង្គរបស់ព្រះអង្គទ្រង់គោរព

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនាងកុមារកគវតី ដែលជាមហេសីនៃព្រះឥស្សរ ព្រះបាទហសិវវ័ទ្ធនទ្រង់គោរពព្រះនាកយណ៍ ។

សិលាចារឹកនេះ បានបញ្ជាក់ឲ្យដឹងពីការនៅរួបរួមសាមគ្គីរវាងព្រះពុទ្ធវង្សព្រាហ្មណវង្ស ក្នុងពេលដែលព្រះអង្គទ្រង់មានព្រះជន្មនៅឡើយ ។

នៅស្រុកបទឹងអ័ក្សនៃប្រាសាទមេបុណ្យខាងកើត មានទីវាលមួយប្រកបដោយផលិតផលយ៉ាងប្រសើរ ដោយការបង្ហូរទឹកពីបារាយណ៍ទិសខាងកើតមកប្រើប្រាស់ ។ បើតាមយោបល់លោក ហ្វីលិតស្តូន ថាទំនេះ ជាកន្លែងដែលលូតលាស់ក្រោយពេលដែលលើកទីក្រុងពីកោះកេរ្តិ៍មក ព្រោះទីក្រុងនេះបានត្រូវបោះបង់ចោល ក្រោយពីពេលដែលបានរីកចម្រើនពី គ.ស. ៩២១ រហូតមកដល់ គ.ស.៩៤៤ ។ ព្រះបាទរាជេន្ទ្រវរ្ម័ន បានបោះបង់រាជធានីនេះដើម្បីមកកាន់អង្គរវិញ ដែលក្នុងសម័យនោះហៅថា យសោធរបុរៈ ។

www.budinst.gov.kh www.elibraryofcambodia.org

គេពុំបានដឹងថាតើមកពីហេតុអ្វីទេ បានជាជនជាតិកម្ពុជា ហាក់តែងសាងប្រាសាទនេះឡើង ឲ្យមានទ្រង់ទ្រាយដូចជាកន្លែងបញ្ចុះសព ដែលមានឈ្មោះថា ប្រែរូប ដែលជាកន្លែងធ្វើឡើងតាមប្រពៃណីនៃឈាបនកិច្ច ដូចមានការគួសរាសព្រាងជាដំបូង នូវកង់តំនូររូបឥសុរយ៉ាងច្បូរហែរគ្នាតាមការផ្គត់ផ្គង់យ៉ាងវែង ៗ ពីគ្នា ដូច្នេះ ៗ គេឃើញមានជើងមួយស្ថិតនៅក្រោមជើងជណ្តើរខាងកើត នៃតួប្រាសាទពងសាជី ដែលគួរឲ្យក្រឡេកភ្នែកមើលនូវពិធីបុណ្យ តាមចំណងជើងរូបតំនូរដែលរមៀលធ្លាក់មកពីក្រប ដែលសាងសម្រាប់ពិធីថ្វាយព្រះភ្លើងស្ដេចតំលង់ដែលទ្រង់សុគតនៅលើភ្នំគូលែន ៗ

បើតាមផ្ទៃនៃនិម្មាបនកម្ម ប្រាសាទនេះមានកំពែងពីរជាន់ប្រកបដោយគោបុរៈ ៤ ហើយនិងមានជាតួប្រាសាទពងសាជីដែលមានជណ្តើរតូច ៗ សម្រាប់ទល់ទៅតួប្រាសាទបន្ទាយទាំង ៤ នោះ ៗ ផ្នែកខាងកើតនៃកំពែងខាងក្រៅមាន

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទប្រែរូប

មើលពីខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ទ្រាយសមតាមការនិយម ដោយមានសាងជាប្រាង្គ ប្រាសាទពីរក្រុមស្ថិតនៅ ៣ ខ្នង តាមរបៀបយ៉ាងសមទៅតាមអ័ក្ស នៅលើខឿនគ្រឹះធំតែមួយ ៗ តួប្រាង្គទីមួយដែលនៅខាងដើមផ្លូវចូល ពុំបានសាងនៅលើមូលដ្ឋាននៃខឿនដែលបានប្រុងប្រៀបជាស្រេចនោះទេ ឬមួយក៏គេយកតួប្រាង្គនេះទៅប្រើជួសជុលកន្លែងដទៃទៀត ដោយប្រាង្គនោះទ្រុឌទ្រោមពេក ៗ នៅលើខឿនគ្រឹះកណ្តាល មានប្រាង្គមួយធំជាងគេដែលមានសភាពគ្រប់សង្កត់ ទៅលើប្រាសាទឯទៀត ៗ ប្រាសាទនិមួយ ៗ មានប្រវែង ៥ ម៉ែត្រ ក្នុងមួយជ្រុង ៗ ព្រមទាំងមានសាងជាថ្នាក់ៗ តូចៗ នៅផ្នែកដំបូល ៗ នៅតាមជ្រុង មានការខូចខាតអស់ជាច្រើនតាមកន្លែងខ្លះ ដែលខ្ពស់ ហើយមានផ្ទាំងថ្មរមៀលធ្លាក់ ហើយនិងនៅតាមកងប្រាសាទដែលលៀនលយចេញក្រៅ ដែលមានស្នាមក្រហែងឥដ្ឋ ៗ ឥដ្ឋនិមួយៗ មានទំហំ ៣០×១៦×៨,៥ ដែលរៀបផ្គុំភ្ជាប់គ្នា

46 បានដោយមិនចាំបាច់ប្រើបាយអ គឺយកជ័រឈើមកភ្ជាប់ផ្គុំសវិញៗ

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទមេបុណ្យទិសបូព៌

សាងនៅពាក់កណ្ដាលសតវត្សទី ១០ "គ.ស. ៩៥២" ដោយព្រះបាទរាជេន្ទ្រវរ្ម័ន "បច្ចាមរណៈព្រះនាមសិវលោក" ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ពី គ.ស. ១៩៣៥ រហូតដល់សព្វថ្ងៃនេះ ។

នៅខាងជើងប្រាសាទប្រែរូបចម្ងាយ ៥០០ម៉ែត្រ គេនឹងទៅដល់បារាយណ៍ទិសបូព៌ ដែលស្ថិតនៅត្រង់បង្គោលគីឡូម៉ែត្រលេខ ១៦ បារាយណ៍នេះមានទទឹង ២ គីឡូម៉ែត្រ បណ្ដោយ ៧ គីឡូម៉ែត្រ ហើយមានដីទួលខ្ពស់ព័ទ្ធជុំវិញប្រកបដោយសទ្ទឹកសីមាដាក់នៅតាមមុមធំ ។ ទីនេះលោក ជីវ. តា ក្វាន់ បានឲ្យឈ្មោះថាបឹងធំ ដែលឈ្មោះដើមហៅថា យសោធរតតាកៈ ដែលបានជីកក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ក្នុងចុងសតវត្សទី ១០ ។

ក្នុងទីកយ៉ាងធំនេះ ជាកន្លែងសម្រាប់បញ្ចូលបញ្ចេញទឹក

www.budinst.gov.kh www.elibraryofcambodia.org

ស៊ីនសៀមរាប ហើយព្រមទាំងជាកន្លែងសម្រាប់បន្ទោរទឹកទៅ
ដាក់តាមទីវាលទំនាប ដែលសព្វថ្ងៃនេះបានក្លាយទៅជាវាល
ស្រែអស់ទៅហើយ ។ កាលជំនាន់ដើមបារាយណ៍នេះមាន
ជម្រៅ ៣ ម៉ែត្រ ដោយមានកស្តុតានជាសំអាងគឺកាំជណ្ដើរ
ធ្វើពីថ្មបាយក្រៀម ដាក់ទៅនឹងទីទួលនៃប្រាសាទមេបុណ្យ
បំណុះទឹកដែលមាននៅក្នុងបឹងនេះមាន ៤០ លានម៉ែត្រគូប ។
ដោយហេតុមកពីមានដីខ្សាច់ និងដីល្បប់ហូរមកចាក់បំពេញ
ដូច្នេះហើយបានជាមានកន្លែងខ្លះ ត្រូវគោកអស់គ្មានសល់
ទឹកឡើយ ។

០៦ 7 ហេតុនេះហើយ បានជានៅកណ្ដាលនេះឃើញមានជា
កោះតូចមួយរាងបួនជ្រុងស្មើ ក្នុងមួយជ្រុង ៗ ប្រវែង ១២០
ម៉ែត្រ ។ នៅលើកោះនេះ គេបានសាងប្រាសាទ
មេបុណ្យទិសបូព៌ា ស្របទិសស័ក្យនៃគុហារជាទ្វារចូលទៅ
ព្រះរាជវាំងអង្គរធំនឹងក្បាលទ្វារជ័យ ។ ប្រាសាទនេះ
មានស្ថានភាពជាប្រាសាទភ្នំ ដែលជានិមិត្តរូបនៃភ្នំព្រះសុមេរុ

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទមេបុណ្យទិសបូព៌

សាងនៅពាក់កណ្ដាលសតវត្សទី ១០ "គ.ស. ៩៥២" ដោយព្រះបាទរាជេន្ទ្រវរ្ម័ន "បច្ឆាមរណៈ ព្រះនាមសិវលោក" ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ពី គ.ស. ១៩៣៥ រហូតដល់សព្វថ្ងៃនេះ ។

នៅខាងជើងប្រាសាទប្រែរូបចម្ងាយ ៥០០ ម៉ែត្រ គេនឹងទៅដល់បារាយណ៍ទិសបូព៌ ដែលស្ថិតនៅត្រង់បង្គោលគីឡូម៉ែត្រលេខ ១៦ បារាយណ៍នេះមានទទឹង ២ គីឡូម៉ែត្រ បណ្ដោយ ៧ គីឡូម៉ែត្រ ហើយមានដីទួលខ្ពស់ព័ទ្ធជុំវិញប្រកបដោយសន្ទឹកសីមាដាក់នៅតាមមុមជង ។ ទីនេះលោក ជីវ-តា ក្វាន់ បានឲ្យឈ្មោះថាបឹងធំ ដែលឈ្មោះដើមហៅថា យសោធរតតាកៈ ដែលបានជីកក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ក្នុងចុងសតវត្សទី ១០ ។

ត្រួតគហើងនេះ ជាកន្លែងសម្រាប់បញ្ចូលបញ្ចេញទឹក

www.budinst.gov.kh www.elibraryofcambodia.org

ស៊ីនសៀមរាប ហើយព្រមទាំងជាកន្លែងសម្រាប់បង្ហូរទឹកទៅ ដាក់តាមទីវាលទំនាប ដែលសព្វថ្ងៃនេះបានក្លាយទៅជាវាល ស្រែអស់ទៅហើយ ។ កាលជំនាន់ដើមបារាយណ៍នេះមាន ជម្រៅ ៣ ម៉ែត្រ ដោយមានភស្តុតាងជាសំគាល់គឺកាំជណ្ដើរ ធ្វើពីថ្មបាយក្រៀម ដាក់នៅនឹងទីទួលនៃប្រាសាទមេបុណ្យ បំណុះទឹកដែលមាននៅក្នុងបឹងនេះមាន ៤០ លានម៉ែត្រគូប ។ ដោយហេតុមកពីមានដីខ្សាច់ និងដីល្បប់ហូរមកចាក់បំពេញ ដូច្នេះហើយបានជាមានកន្លែងខ្លះ ត្រូវទះគោកអស់គ្មានសល់ ទឹកទៀត ។

ហេតុនេះហើយ បានជានៅកណ្ដាលនេះឃើញមានជា កោះតូចមួយរាង ៤ ជ្រុងស្មើ ក្នុងមួយជ្រុង ១ ប្រវែង ១២០ ម៉ែត្រ ។ នៅលើកោះនេះ គេបានសាងប្រាសាទ មេបុណ្យទិសបូព៌ ស្របនឹងស័ក្យនៃគុហារជាទ្វារចូលទៅ ព្រះរាជវាំងអង្គរធំនឹងក្លោងទ្វារជ័យ ។ ប្រាសាទនេះ មានស្ថានភាពជាប្រាសាទភ្នំ ដែលជានិមិត្តរូបនៃភ្នំព្រះសុមេរុ

www.budinst.gov.kh www.elibraryofcambodia.org

ឯគូប្រាសាទកងជាសេះដែលមានស្ពានឆ្លងទៅជាប់ៗ ហើយនៅក្នុងបរិវេណកំពែងទាំង ៤ ជាន់ ។ គូប្រាសាទនេះមានប្រាង្គឆ្ងាយធម្មតា គឺមានកំពស់ពីកន្លះ ៣ ម៉ែត្រ ព្រមទាំងមានគុហាតូចៗ សាងតម្រៀបគ្នាជាជួរ ៗ ផ្នែកខាងក្រៅវែង ប្រហែលជាគេខ្លាចក្រែងកំទេចនេះ ដែលពាក់កណ្ដាលជុំវិញនោះត្រូវខូចខាតអស់ ។ គេត្រូវធ្វើដំណើរឆ្លងទៅកាន់ប្រាសាទនេះតាមស្ពាន ដែលជាហេតុនាំឱ្យយើងមានការសង្ស័យចំពោះការចេះធ្វើនេះណាស់ ព្រោះជាហេតុនាំឱ្យមនុស្សទៅគោរពសក្ការបូជាបានចំនួនតិចណាស់ តែមានសភាពត្រជាក់ស្រួលជាទីបំផុត ។

មានសិលាចារឹកយ៉ាងច្រើន ដែលគេបានរកឃើញនៅក្បែរប្រាសាទ ព្រមទាំងបានរកឃើញរូបសំណាកជាច្រើនទៀត ។ ឯសិលាចារឹកនោះ មានចុះថ្ងៃ កំណត់ពេលនៃការកសាងក្នុង គ.ស. ៩៥២ គឺសាងមុនប្រាសាទប្រែរូប ៩ ឆ្នាំ ដែលនាំឱ្យយើងសំគាល់ឃើញនៅគ្រប់ប្រាង្គទាំងឡាយ ដែលមាន

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទមេបុណ្យទិសបូព៌

មើលចំពីខាងកើត

www.budinst.gov.kh www.elibraryofcambodia.org

ចំកល់លិង្គ ស្រូកជំគ្រាស្វៈ ឯរូបសំណាកដែលគួរ
គោរពបូជា គឺរូបព្រះឥសូរ និង រូបព្រះបកវតី ដែលទុកដូច
ជាព្រះវរមាតា – បិតា នៃព្រះបាទពជ្រ្កាវរ័ន ៗ មានរូប
លិង្គ ៨ ទៀត ដែលជារូបលិង្គរបស់ព្រះគាទំទេព ៨ រូបដែល
ចំកល់នៅក្នុងគុហារូប ១ ទាំង ៨ នៅជុំវិញ គឺមានលិង្គព្រះ
ទកយេណ៍ និង លិង្គព្រះព្រហ្មជា ដើម ៗ ប្រាសាទមេបុណ្យ
គាបចាក់បញ្ចូលទៅក្នុងពពួកប្រាសាទ ដែលគួរជាទីគោរពបូជា
តាមអារម្មណ៍ដែលជាកិត្តិគុណដល់ព្រះកាទំទេព គឺមានរូប
សំណាកស្រីទេពអប្សរមួយយ៉ាងល្អ ដែលបានរកឃើញនៅ
ក្នុងពេលគ្រួសគ្រាយរៀបចំ រូបនេះមានក្បាច់យ៉ាងល្អ
អាចផ្ទឹមបានទឹងក្បាច់ នៃរូបព្រះនាងបកវតីតាមការអធិប្បាយ
នៃសិលាចារឹក ៗ

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទនាគព័ន្ធ

សាងនៅពាក់កណ្ដាលសតវត្សទី ១២ ដោយព្រះបាទជ័យវរ្ម័នទី ៧ បច្ឆាមរណៈ ព្រះនាមមហាបរមសុគតបទ: ថ្វាយចំពោះព្រះពុទ្ធសាសនា ។ ក្រសួងអភិរក្សអង្គរ បានថែរក្សាតាំងពី គ.ស. ១៩២២ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទនាគព័ន្ធ ស្ថិតនៅពីខាងមុខប្រាសាទក្រោលគោ តាមផ្លូវតូចមួយមានចម្ងាយ ៣០០ ម៉ែត្រ ដែលកាត់តម្រង់ទៅកាន់កោះដ៏តូចមួយនៃប្រាសាទ ដែលមានសណ្ឋានមិនប្លែកពីប្រាសាទមេបុណ្យដែលស្ថិតនៅក្នុងបារាយណ៍ ។ ប្រាសាទនេះស្ថិតនៅតាមអ័ក្សជាមួយគ្នានឹងប្រាសាទព្រះខ័ន ដែលមានឈ្មោះថា ជយតតក: មានបណ្ដោយ ៣៥០០ ម៉ែត្រ ទទឹង ៩០០ ម៉ែត្រ ។ កោះដ៏តូចនេះ មួយជ្រុងៗប្រវែង ៣៥០ ម៉ែត្រ សាងភ្ជាប់នឹងកាំជណ្ដើរដែលឆ្ពោះទៅអ័ក្ស ព្រមទាំងមានឆ្លាក់ជារូបដំរីតូចៗ ដាក់នៅតាមមុខប្រាសាទ ដែលសព្វថ្ងៃនេះ គេឃើញរូបមួយនៅសល់នឹងកន្លែងត្រង់ទិសឦសាន ។

www.budinst.gov.kh www.elibraryofcambodia.org

តាមសិលាចារឹកនៅប្រាសាទព្រះខ័ន បានបញ្ជាក់ឲ្យដឹង ថាជយតដាកនេះ គឺជាឈ្មោះបឹងនៅខាងជើង ។ លោក ជ័រតាក្រាន់ បានពណ៌នាថាស្រះនេះមានទឹកហូរមកពីស្ទឹងនៃ ប្រាសាទ ដែលមានពន្លឺដូចមាសចាំងឆ្លុះកាយឲ្យនឹងផ្កាឈូក ដែលនាំមកនូវពណ៌សម្បុរដូចទឹក "បឹងឈាម" នៃព្រះភគវន្ត ។ នៅកណ្តាលមានកោះមួយប្រកបដោយប្រាសាទ ដែលគួរឲ្យ រីករាយនៅតាមផ្ទៃទឹកដែលព័ទ្ធជុំវិញប្រាសាទនេះ ហើយជា ទីត្ថ "ទឹកមន្ត" សម្រាប់លាងបាបដែលប៉ះពាល់ ការ ឆ្លងកាត់តាមបឹងនេះទៅកាន់ប្រាសាទ គេត្រូវជិះទូក ។

លក្ខណៈជាគ្រឿងសំគាល់នៃប្រាសាទនាគព័ន្ធនេះ គេ បានដឹងហើយច្បាស់លាស់ ។ កាលពីឆ្នាំ ១៨៧៣ លោក ដឺឡាប៉ត បានយល់ថាជាវិហារឧទ្ទិសចំពោះព្រះពុទ្ធដែលចូល និព្វាន និងជាកន្លែងទឹកសម្រាប់ជម្រះមន្ទិលចាំងឆ្ងាយ ដើម្បី ឲ្យបានបរិសុទ្ធស្អាត ។

តាំងពីពេលដែលគេរកឃើញថ្មីឡើងវិញ ដោយលោក

www.budinst.gov.kh www.elibraryofcambodia.org

សីផែស លោក ហ្វីណូត៍ និងលោក គោឡូប៊ែវមក គេបាន សំគាល់បាននៅនឹងផ្ទៃស្រះធំ ដែលមានទ្រង់ទ្រាយដូចជាស្រះ អនោតត្តៈ ដែលជាស្រះស្ថិតនៅកណ្ដាលភូមិភាគភ្នំហិមពាន្ត គឺជាភ្នំកំពូលពិភពលោក ។ ស្រះនេះជាទីគោរពបូជាតាម ទំនៀមទម្លាប់នៃប្រទេសឥណ្ឌា ព្រោះស្រះនេះភ្ជាប់ទៅស្រះ តូច ៗ ៤ ទៀត ទំហំប៉ុន ៗ គ្នាតាមទរ ៤ ដែលជានិមិត្តរូប នៃទន្លេធំ ៗ ទាំង ៤ នៃពិភពលោក ។

ផ្ទៃទឹកហើយនិងផ្កាឈូករីកមួយទ្រព្រះអាទិទេពជានិមិត្តរូប នៃផែនដីដ៏បរិសុទ្ធ ហើយមានគំនូសភាគដូចរូបព្រះនារាយណ៍ គង់នៅលើទឹក បញ្ចេញ "ផ្កាឈូកព្រះព្រហ្ម" ។ រូប ប្រដូចដ៏ល្អ ៗ នេះ របស់លោក ប៉ូល មូស ជាអត្ថន័យ នៃផ្ទៃ ទឹកដែលមានភាពបរិសុទ្ធនេះព្រមទាំងតួប្រាសាទផង ។

www.budinst.gov.kh www.elibraryofcambodia.org

តាមសិលាចារឹកនៅប្រាសាទព្រះខ័ន បានបញ្ជាក់ឲ្យដឹងថាជយតដាកនេះ គឺជាឈ្មោះបឹងនៅខាងជើង ។ លោកដឺវេតាក្កាន់ បានពណ៌នាថាស្រះនេះមានទឹកថ្លាមកពីរស្មីនៃប្រាសាទ ដែលមានពន្លឺភ្លឺពាសចាំងនោះ ណាយខ្យល់និងផ្កាឈូក ដែលនាំមកនូវពណ៌សម្បុរដូចទឹក «បឹងឈាម» នៃព្រះភគវន្ត ។ នៅកណ្ដាលមានកោះមួយប្រកបដោយប្រាសាទ ដែលគួរឲ្យរីករាយទៅតាមផ្លូវទឹកដែលព័ទ្ធជុំវិញប្រាសាទនេះ ហើយជាទីត្ថ "ទឹកមន្ត" សម្រាប់លាងបាបដែលប៉ះពាល់ ការឆ្លងកាត់តាមបឹងនេះទៅកាន់ប្រាសាទ គេត្រូវជិះទូក ។

លក្ខណៈជាគ្រឿងសំគាល់នៃប្រាសាទនាគព័ន្ធនេះ គេបានដឹងហើងច្បាស់លាស់ ។ កាលពីឆ្នាំ ១៨៧៧ លោកដឺឡាពែត បានយល់ថាជាវិហារឧទ្ទិសចំពោះព្រះពុទ្ធដែលចូលនិព្វាន និងជាអាងទឹកសម្រាប់ជម្រះមន្ទិលទាំងឡាយ ដើម្បីឲ្យបានបរិសុទ្ធស្អាត ។

តាំងពីពេលដែលរុករកជាថ្មីឡើងវិញ ដោយលោក

www.budinst.gov.kh www.elibraryofcambodia.org

សីផែស លោក ហ៊ីណូត៍ និងលោក គោឡូប៊ែមក គេគាប់សំគាល់បានទៅនឹងផ្ទៃស្រះធំ ដែលមានទ្រង់ទ្រាយដូចជាស្រះអនោតត្តៈ ដែលជាស្រះស្ថិតនៅកណ្ដាលកូម៉ាគន្ធហិមពាន្តគឺជាភ្នំកំពូលពិភពលោក ។ ស្រះនេះជាទីគោរពបូជាតាមទំនៀមទម្លាប់នៃប្រទេសឥណ្ឌា ព្រោះស្រះនេះភ្ជាប់ទៅស្រះតូច ៗ ៤ ទៀត ទំហំប៉ុន ៗ គ្នាតាមទរ ៤ ដែលជានិមិត្តរូបនៃទន្លេធំ ១ ទាំង ៤ នៃពិភពលោក ។

ផ្ទៃទឹកហើយនិងផ្កាឈូករីកមួយទ្រព្រះគណទេពជានិមិត្តរូបនៃផែនដីដ៏បរិសុទ្ធ ហើយមានគំនូរគាគដូចរូបព្រះនាគយណ៍គង់នៅលើទឹក បញ្ចេញ "ផ្កាឈូកព្រះព្រហ្ម" ។ រូបប្រដូចដ៏ល្អ ១ នេះ របស់លោក ប៉ូល មូស ជាអត្ថន័យ នៃផ្ទៃទឹកដែលមានភាពបរិសុទ្ធនេះត្រូវតាំងក្នុងប្រាសាទជន ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទនាគព័ន្ធ

មើលពីជ្រុងខាងកើតខាងត្បូង

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទព្រះខ័ន

សាងនៅពាក់កណ្ដាលសតវត្សទី ១២ "គ.ស. ១១៩១" ដោយព្រះបាទជ័យវរ្ម័នទី ៧ បច្ចាមរណៈ ព្រះនាម "មហាបរមសំគតបទៈ" ឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ក្រសួងអភិរក្សអង្គរ បានចាប់ផ្ដើមថែរក្សាពី គ.ស. ១៩២៧ រហូតមកដល់សព្វថ្ងៃនេះ ។

លក្ខណៈសំខាន់ :

ការធ្វើដំណើរទៅកាន់ប្រាសាទនេះ ត្រូវចូលពីខាងកើតចេញទៅទិសខាងលិច ឬ បញ្ច្រាសមកវិញ ។ មុនចូលលោកអ្នកត្រូវមានការប្រុងប្រៀបជាមុនបន្តិច គឺត្រូវទុកយានជំនិះនៅទីធ្លាវាលនៅឈមមុខ លោកអ្នក ឬ ក៏យកទៅទុកនៅទ្វារកណ្ដាលនាទិសខាងជើងក៏បាន ។ ផ្លូវចូលទាំង ៣ នៃប្រាសាទនេះជាប់ទាក់ទងនឹងផ្លូវធំ គឺផ្លូវឆ្ពោះទៅកាន់ទ្វារខាងកើត ដែលស្ថិតនៅជិតគីឡូម៉ែត្រលេខ ៩ ផ្លូវចូលទៅកាន់ទ្វារខាងជើងនៅជិតគីឡូម៉ែត្រលេខ ៨ ឯផ្លូវ

www.budinst.gov.kh www.elibraryofcambodia.org

ដើរដែលតម្រង់ទៅកាន់ទ្វារខាងលិច ស្ថិតនៅត្រង់គីឡូម៉ែត្រលេខ ៧ ។

ប្រាសាទព្រះខ័នមានរាង ៤ ជ្រុងទ្រវែង បណ្តោយ ៨០០ ម៉ែត្រ ទទឹង ៧០០ ម៉ែត្រ ដែលមានស្រះពោក្ខរណីព័ទ្ធជុំវិញ ហើយជាប្រាសាទមានផ្ទៃដីចំនួន ៥៦ ហិកតា ។ ប្រាសាទនេះមានតិនភាគ ទីងល់ទាំជាច្រើន ដូចប្រាសាទតាព្រហ្ម ហើយមានសំណង់ជាច្រើនសាងតជាប់ ៗ គ្នាពីមួយទៅមួយ នៅសល់តែបន្ទោះតូច ១ ។ កំពែងទី ៣ មានបណ្តោយ ២០០ ម៉ែត្រ ទទឹង ១៧៥ ម៉ែត្រ ហ៊ុំព័ទ្ធប្រាសាទតាំងមូល ដែលមានភាពទូលំទូលាយល្អសមទៅតាមវិលាស-ភាពជំនាន់ដើម ថ្វីត្បិតតែមានភាពប្រឡូកប្រឡល់នៃទិម្ចាបនកម្មដូចនេះក៏ដោយ ។ ប្រាសាទនេះច្រើនស្ថិតនៅជុំគ្នាទៅតាមភាពហាក់រុងរឿងបំផុត ព្រោះសំណង់តាំងនេះស្ថិតនៅជុំគ្នា លើមណ្ឌលតែមួយហាក់ទូលាយ ដោយមានសំណង់ខ្លះសាងដោយឈើប្រក់ក្បឿង ។

www.budinst.gov.kh www.elibraryofcambodia.org

នៅប្រាសាទព្រះខ័ននេះ វត្ថុធាតុទាំងឡាយនាំឲ្យស្រួលយល់ណាស់ ដោយហេតុនេះហើយបានជានៅតាមទ្វារប្រាសាទមាន សិលាចារឹករៀបរាប់ពីសមាណចិត្តដែលពោរពេញដោយការរីកចំរើនខាងករុណាធម៌ ហើយនិងមានរៀបរាប់បង្ហាញពីឈ្មោះវត្ថុដែលជាទីគោរពបូជា ដើម្បីជាតំណាងមនុស្សដែលមានកិត្តិគុណទុកដូចជាព្រះអាទិទេព ។ វត្ថុតាំងនេះតាក់តែងសាងឡើង សមជាប្រាសាទដែលមានលក្ខណៈជាប្រាសាទអនុស្សាវរីយ៍ ។ ម្យ៉ាងវិញទៀត បើតាមសិលាចារឹក ដែលគេរកឃើញកាលពី គ.ស. ១៩៣៩ មានបរិយាយថាកន្លែងនេះ ទុកដូចជាកន្លែងនាំមកនូវជ័យជំនះគឺជាទីក្រុង "ជ័យស្រី" ។

តាមយោបល់របស់លោក សឺដែស ថា : ប្រាសាទនេះសមជាមានឈ្មោះថា ព្រះខ័នពិតមែន ប៉ុន្តែតែមានឈ្មោះដើមថា ទីក្រុងជ័យស្រី និងឈ្មោះថ្មីថាព្រះខ័នដូច្នេះ ក៏ឈ្មោះតាំងពីនេះសមតាមការនិយាយរបស់ខ្មែរពិតប្រាកដ គឺមានន័យ

www.budinst.gov.kh www.elibraryofcambodia.org

ជាព្រះច័នរាជ្យ ៗ ឯឈ្មោះថា នរៈសៀមស្រី នេះមានន័យថា ទីក្រុងដែលពោរពេញទៅដោយសេចក្ដីសម្បូណ៌សប្បាយដែលប្រជាជនតែងហៅថា ព្រះច័នរាជ្យ ពោលគឺព្រះច័ននោះឯង ។

ផ្ទុយទៅវិញ ចំពោះលោកអ្នកណាដែលបានទស្សនាប្រាសាទតាព្រហ្ម ឬ បន្ទាយក្ដី ដែលស្ថាបនាដោយព្រះបាទជ័យវរ្ម័នទី ៧ នោះដែរ រមែងមានផ្លូវចូល ៤ ចូលកាត់ស្រះបោក្ខរណីដែលគេតែងឃើញរហូតមកដល់សព្វថ្ងៃនេះ ព្រោះតាមផ្លូវចូលកាត់ស្រះ តែងមានឆ្លាក់ជារូបយក្ស "អសុ" ទាញនាគ ដូចជានៅតាមមាត់ច្រកនៃក្លោងទ្វារគន្លងធំដែរ ហើយជាទីក្រុងមួយដែលជានិមិត្តរូបនៃនិម្មាបនកម្ម ដែលនៅដាច់ស្រយាលពីប្រាសាទឧបក្សាយន្ទា ៗ ទីក្រុងទាំងពីរនេះមានលក្ខណៈដូចគ្នាបេះបិទ វត្តទាំងនេះជាជំណាន់កដជានី ដែលត្រូវទទួលការកែះកាន់បន្ថែមតាមសេចក្ដីសំរេចចិត្ត ឬ តាមគុណប្រយោជន៍យ៉ាងប្រសើរនៃទ្វារចូល ព្រោះជាផ្លូវដើរខុស

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃកពីសភាពធម្មតា ធ្វើឡើងសម្រាប់រទេះឬដំរីចេញចូល ។ ព្រះខ័នពុំមានទំរង់មុខនុហារដូចជាប្រាសាទបាយ័ន កំពែងខាងក្រៅនៃប្រាសាទតាព្រហ្ម, បន្ទាយក្តី, ប្រាសាទតាសោមនឹងប្រាសាទអង្គរធំនោះទេ ព្រោះជាប្រាសាទសាងមុនគេ ហើយជាព្រះរាជនិវេសនបណ្តោះអាសន្នសម្រាប់ព្រះបាទជ័យវរ្ម័នទី ៧ ក្នុងពេលដែលកំពុងស្ថាបនាជាថ្មីឡើងវិញនៅទីក្រុងនេះ ដែលត្រូវខូចខាតដោយពួកចាមចូលមកលុកលុយក្នុង គ.ស. ១១៧៧ ។

នៅប្រាសាទនេះមានសិលាចារឹកមួយ ចារឹកនូវអក្សរយ៉ាងច្បាស់លាស់កាលពី គ.ស. ១១៩១ ថា: ព្រះពោធិសត្វលោកេស្វរៈព្រះនាមជ័យវរមេស្វរៈនោះ ព្រះអង្គទ្រង់គោរពបូជាទុកដូចព្រះបិតារបស់ព្រះអង្គ ដូចជានៅប្រាសាទតាព្រហ្មដែលព្រះបាទជ័យវរ្ម័នទី ៧ បានសាងរូបមួយជាដំណាងព្រះមាតានៃព្រះអង្គ ដែលមានព្រះនាមថា ប្រជ្ញាបារមិតា ។

សិលាចារឹកនេះបានបង្ហាញឲ្យដឹងថា មានរូបសំណាក

www.budinst.gov.kh www.elibraryofcambodia.org

៥១៥ រូប   មានមន្ទីរពេទ្យបាលរោគ ១០២ ក្នុងព្រះរាជាណាចក្រ តែពុំបានបញ្ជាក់ថាសាងនៅត្រង់ណា ៗ នោះឡើយ   ព្រមទាំងមានគេហស្ថានមួយជាកន្លែងឈប់សំរាក ។  ឯចំណែកកម្មករ ហើយនិងអ្នកបំរើក្នុងការកសាងប្រាសាទ  មានចំនួន៩៧,៨៤០ នាក់   ដែលក្នុងចំណោមនេះមានស្ត្រីរបាំចំនួន ១.០០០ នាក់ ផង ។ ក្នុងមួយឆ្នាំមានបុណ្យធំ ៗ ចំនួន ១០ ដង  ហើយ ក្នុងមួយខែមានថ្ងៃបុណ្យ ១០ ថ្ងៃ   ដែលជាថ្ងៃសំដែងនូវទឹកចិត្ត របស់ខ្មែរ   ក្នុងថ្ងៃបុណ្យតាមប្រពៃណីសាសនា និង តាមពេល សំរាកលំហែ ។

www.budinst.gov.kh   www.elibraryofcambodia.org



ប្រាសាទព្រះខ័ន

មើលចំពីខាងលិចនៃគ្លោងទ្វារទី ១

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទលលៃ

សាងនៅចុងសតវត្សទី ៩ "គ.ស ៨៩៣" ដោយ
ព្រះបាទ យសោវរ្ម័ន បញ្ចាមរណៈព្រះនាម "បរមសិវលោក"
ឧទ្ទិសចំពោះសាសនាព្រាហ្មណ៍ ថ្វាយចំពោះព្រះឥស្វរ
ក្រសួងអភិរក្សអង្គរ បានថែរក្សាតាំងពី គ.ស. ១៩៣២ រហូត
មកដល់សព្វថ្ងៃនេះ ។

ប្រាសាទលលៃស្ថិតនៅ តាមផ្លូវចូលទៅកាន់ប្រាសាទ
បាគង ពីចម្ងាយ ៥០០ ម៉ែត្រពីផ្លូវជាតិលេខ ១ តាមផ្លូវលំ
ដែលចូលទៅកាន់ប្រាសាទនេះ ហើយស្ថិតនៅខាងជើងផ្លូវ
សៀមរាប ភ្នំពេញ ត្រង់បង្គោលគីឡូម៉ែត្រលេខ ១៣ ហើយ
មានចម្ងាយជាង ៤០០ ម៉ែត្រ ពីផ្លូវទៅប្រាសាទបាគង ។
នៅត្រង់ផ្លូវខ្វែងគ្នានេះ មានផ្លាកតាភ្ជិសំគាល់ ហើយមាន
ចម្ងាយ ៦០០ ម៉ែត្រ ទៅតាមផ្លូវលំកាត់វាលស្រែដោយ
ត្រូវបើករថយន្តតាមស្ពានឈើមួយ ។

គេអាចមើលឃើញថាតើប្រាសាទហេតុឈ្មោះបាកយណាំ

ទិសខាងកើត ដែលហាក់ដូចជាកោះមួយស្ថិតនៅកណ្ដាល ឥន្ទ្រតដាក: ដែលជាបឹងមួយយ៉ាងធំបណ្ដោយ ៣៨០០ ម៉ែត្រ ទទឹង ៨០០ ម៉ែត្រ ។ គេបានដឹងច្បាស់ថាបឹងនេះបានចាប់ផ្ដើមស្ថាបនា ៥ ថ្ងៃ ក្រោយពេលដែលព្រះបាទឥន្ទ្រវរ្ម័នទី ១ ទ្រង់បានទទួលអភិសេក តាមសិលាចារឹកនៃទីក្រុងហរិហរ-ល័យ ដែលបានបញ្ជាក់ទៀតថា សម្រាប់ផ្ដល់ទឹកដល់ទីវាល នៅក្បែរបឹងនោះ ។

តាមសិលាចារឹក បកស្រាយដោយលោក សឺដែស មានសេចក្ដីថា ប្រាសាទនេះសាងថ្វាយ ឥន្ទ្រវម្មេស្វរៈ ដើម្បីជាគុណូបការីយ៍ដល់ព្រះបិតានៃព្រះបាទ យសោវរ្ម័ន ហើយមានរៀបរាប់អំពីការកសាងរមណីយដ្ឋានមួយជួរ មានឈ្មោះថាយសោធរាស្រម ហើយសាងឡើងអនុលោមទៅតាមពាក្យរបស់ព្រះអង្គផង ។

ស្ថានភាពនៃប្រាសាទនេះ ត្រូវវិចរិលអស់ជាច្រើនណាស់ទៅហើយ គួប្រាសាទគេប្រទះឃើញមានជណ្ដើរតារ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

មានទៀនផញ្ចាំងសាច់ពីថ្ងៃយក្រៀម  មិនមានធ្វើជណ្ដើរ ៤ ទៀតតូច ៗ នៅតាមសក្យ  តាក់តែងលំអដោយរូបតោមៅ មាត់ជណ្ដើរ  ហើយមានធ្វើជាចង្អូរទឹកបញ្ចេញពីទីលានថ្នាក់ខាងលើផង ៗ  ថ្នាក់ទី ១ មានប្រវែងទទឹង ៩ ម៉ែត្រ ហើយវែងជុំវិញទទឹង ២ ម៉ែត្រ  តភ្ជាប់ទៅនឹងសណ្ឋានកន្សូលនៃរូបនាគពស ៗ  ថ្នាក់ទី ២ ពីកើតទៅលិចប្រវែង ៩០ ម៉ែត្រ ពីជើងទៅត្បូងប្រវែង ៨០ ម៉ែត្រ  មានកំពស់ ២ ម៉ែត្រ ៤០ " វែង "  ឯវែងជុំវិញទទឹង ២ ម៉ែត្រ ៤០  តភ្ជាប់ទៅនឹងកំពែង  ដែលជាជញ្ជាំងទល់ទ្រនៃថ្នាក់ខាងលើ  ដែលមានបាក់ដីបំពេញ ៗ

ប្រាសាទនេះមានប្រាង្គ ៤  សងពីឥដ្ឋស្អិតទៅជាប់ ៗ គ្នាលើផ្ទៃគ្រឹះជាមួយគ្នា ៗ  សព្វថ្ងៃនេះដាច់ជុះហើយមានទម្រង់ពីរជួរ គឺជួរខាងក្រោមមានលំអជាងគេ  ដោយមានសាងជាថ្នាក់ ៗ  ទៅជាន់ខាងលើមានលក្ខណៈដោយទឹកកំពោរ  តែសព្វថ្ងៃនេះរលំបាត់អស់ហើយ  ពុំសំគាល់ជាន់គេទៀត

www.budinst.gov.kh www.elibraryofcambodia.org

ជ្រុងខាងជើងឆៀងខាងកើត ចំណែកប្រាង្គនៅជ្រុងខាងត្បូងឆៀងខាងកើត ក្រៀងខាងលើត្រូវវិនាសខូចខាតអស់ហើយ ។ ឯការស្ដាបនាប្រាង្គទាំងពីរប៉ែកខាងជើង ដែលស្ថិតនៅស្របនឹងផណ្ដើរពីកើតទៅលិចនោះ គឺជាឧទាហរណ៍មួយគាប់នាំឲ្យយល់នូវទម្រង់ដើមដែលមានប្រាង្គពីរជួរ ដូចនៅប្រាសាទព្រះគោដែរ ឯប្រាង្គពីរទៀតនោះ ស្ថិតនៅក្នុងសភាពដូចទើបនឹងព្រោង ៗ មួយក៏ ត្រូវវិនាសខូចខាតអស់ ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទព្រះគោ

( មើលពីខាងកើត )

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទព្រះគោ

សាងនៅចុងសតវត្សទី ៩ "គ.ស. ៨៧៩" ដោយព្រះបាទ "ឥន្ទ្រាវរ្ម័នទី ១" បច្ឆាមរណៈ ព្រះនាម "សិវ-លោក" ថ្វាយចំពោះព្រះឥសូរ ក្នុងសាសនាព្រាហ្មណ៍ ។ ក្រសួងអភិរក្សអង្គរ បានថែរក្សាតាំងពី គ.ស. ១៩៣២ រហូតមកដល់សព្វថ្ងៃនេះ ។

ព្រះគោសាងឧទ្ទិសចំពោះដល់វិញ្ញាណក្ខន្ធព្រះបាទជ័យវរ្ម័នទី ២ ព្រមទាំងបុព្វបុរសនៃព្រះបាទឥន្ទ្រាវរ្ម័នទី ១ ។ ប្រាសាទនេះ សង់នៅខាងលិចផ្លូវចូលទៅកាន់ប្រាសាទបាគង ហើយស្ថិតនៅខាងត្បូងផ្លូវជាតិលេខ ៦ សៀមរាប ភ្នំពេញ ចម្ងាយ ៥០០ ម៉ែត្រ ។ ប្រាង្គទាំងឡាយនៃប្រាសាទនេះ បើកមាត់ទៅផ្នែកខាងកើត ហើយសាងឡើងនៅលើផ្ទៃដី ប្រវែងពីកើតទៅលិច ៥០០ ម៉ែត្រ ពីជើងទៅត្បូង ៤០០ ម៉ែត្រ ដោយមិនរួមទាំងស្រះជុំវិញផង ហើយជាប្រាសាទសាងដោយឥដ្ឋមិនបូកបាយក្រៀម ។ មានផ្ទាំងសិលាចារឹកមួយ មាន

www.budinst.gov.kh www.elibraryofcambodia.org

ទាំងបួនយ៉ាងក្នុងស្ដេចនៅទីនេះតាមព្រះកំពែងទី ១ សិលាចារឹកនេះ ថ្លែងសក្ការបូជាចំពោះព្រះឥសូរ ហើយបន្ទាប់មកថ្លែងអំពីបុត្រា ឧត្តមភាពនៃព្រះបាទឥន្ទ្រាវរ្ម័ន ការផ្សាយក្បួនសំរុកយ៉ាងវែង ព្រមទាំងពិធីការគោរពបូជាព្រះទេវរាជ ដែលស្ថិតនៅលើ មហេន្ទ្រា គឺ ភ្នំគូលែន ព្រមទាំងបញ្ជាក់អំពីការកសាងបដិមា-ករ ក្នុង គ.ស. ៨៧៩ គឺ ព្រះឥសូរ និង ទេវី ។ នៅមុខសិលាចារឹកម្ខាងទៀត មានចុះជាភាសាខ្មែរ រៀបរាប់បញ្ជាក់កាលពី គ.ស. ៨៩៣ ក្នុងរជ្ជព្រះបាទ យសោវរ្ម័ន ដែលទ្រង់បញ្ជាក់ឲ្យគេសាងរូប ឋានេសូរៈ ដាក់នៅខឿនប្រាង្គផ្នែកខាងកើត ហើយនិងរូប ត្រិភុវនេស្វរៈ ដាក់នៅប្រាង្គខាងត្បូង ។ មានសិលាចារឹកមួយទៀតចុះកំណត់កាលសតវត្សទី ១១ " គ.ស. ១០០៥ " ដែលបញ្ជាក់ឲ្យដឹងពីរជ្ជកាលព្រះបាទ ជ័យវីរវរ្ម័ន ដែលគ្រងរាជ្យពី គ.ស. ១០០២ ដល់ គ.ស ១០១០ ព្រមទាំងបង្ហាញឲ្យដឹងនូវការដណ្ដើមរាជសម្បត្តិព្រះអង្គ ដោយព្រះបាទសូរ្យវរ្ម័នទី ១ ។

www.budinst.gov.kh www.elibraryofcambodia.org



ប្រាសាទបាគង

មើលពីជ្រុងខាងជើង ខាងលិច

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបាគង

សាងនៅចុងសតវត្សទី ៩ គ.ស. ៨៨១ ដោយព្រះបាទឥន្ទ្រវរ្ម័នទី ១ បច្ឆាមរណៈ ព្រះនាម " ឥសូរលោក " ថ្វាយចំពោះព្រះនាភយណ៍ ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ចាប់តាំងពី គ.ស. ១៩៣៦ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទបាគង ស្ថិតនៅតាមផ្លូវដើរមួយប្រហកដោយដីខ្សាច់ចម្ងាយ ១៥០០ ម៉ែត្រ ពីផ្លូវលេខ ១ នៅត្រង់ផ្លូវខ្វែង ដែលមានសញ្ញាចម្ងាយ ១៣ គីឡូម៉ែត្រពីសៀមរាបក្រុង តាមផ្លូវ " សៀមរាបភ្នំពេញ " ។ ផ្លូវដើរនេះតម្រង់ទៅជ្រុងប្រាសាទធំទិសឧត្តរមើលពីចំហៀង ។ នៅទិសឦសានមានជញ្ជាំងកំពែងទី ២ អមជុំវិញរហូតដល់ចុងទិសខាងកើតនៅមុខគោបុរៈទី ២ ។

បាគងជាប្រាសាទមានរាងជាសាជី ស្ថិតនៅក្នុងកំពែងទី ៣ គឺជាប្រាសាទភ្នំ មានទ្រង់ទ្រាយប្រហែលគ្នានឹង

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសាទអកយំ ដែលស្ថិតនៅទិសនិរតីក្រុងសៀមរាបហើយ និងប្រាសាទរោងចិន នៅលើភ្នំគូលែន ។ ប្រាសាទនេះជាប្រាសាទកណ្ដាលនៃក្រុងមួយឈ្មោះ «ហរិហរាល័យ» សាងឡើងថ្វាយចំពោះព្រះអាទិទេព ។ នៅប្រាសាទនេះ គេឃើញមានគាររូបមួយ ជាជំណាន់ដំបូងខ្មែរសាបដែលនៅ ដិតកជជាតិខ្មែរ ។ ប្រាសាទនេះប្រហែលចាប់ផ្ដើមបាន ឡើងក្នុងរជ្ជកាលព្រះបាទ «ជ័យវរ្ម័នទី ២» ក្រោយពេល ដែលព្រះអង្គទ្រង់យាងចាកចេញពីភ្នំគូលែន ។

ប្រាសាទទាំងឡាយនៅអង្គរ សុទ្ធតែមានទីលានសាង ឡើងជាថ្នាក់ ៗ បន្តបន្ទប់លើគ្នា ។ ប្រាសាទនេះគេគាប់ប្រៀប ទៅនឹងភ្នំព្រះសុមេរុដែលជាភ្នំនៅកណ្ដាលទ្វីប ព្រោះសាងឡើង មាន ៥ ថ្នាក់ ព្រមទាំងមានតាំងរូបនាគ គ្រុឌ ឆ្មាំទ្វារ និង យក្ស នៅគ្រប់មុខប្រាសាទទាំង ៤ ទិស តាំងពីថ្នាក់ក្រោម រហូតដល់ថ្នាក់លើ ។

ប្រាសាទនេះស្អាតល្អសមណាស់. មានទីលានយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ល្អ ៗ ព្រមទាំងមានលំអដោយរូបតារ័ក្បូរគា និងជារូបស្រីជាដើម សុទ្ធតែជារូបដែលគេឆ្លើសក្ការបូជាកល់ថ្ងៃ ដើម្បីសេចក្តីសុខចំរើនព្រមទាំងមានរូបសង្ឃ្យកជមួយអង្គ ដែលគេតែងគោរពបូជាមួយឆ្នាំម្តងរៀងកល់ឆ្នាំ គឺសុទ្ធតែជាខិចសប្រខៈមួយថ្ងៃថ្ង ដែលបង្ហាញឲ្យឃើញនូវភាពស្រឡះហើយនិងមានលំអដោយរូបមនុស្សដាក់ហូរហែតាមដំណើរ ប្រៀបបាននឹងដំណើរមួយទៅស្ថានសួគ៌ ជាកសិណសាក្សីមួយបង្ហាញនូវក្រឹត្យវិន័យទៅបូពាំទិស ៗ

បាគងជាប្រាសាទមួយមុនគេ សាងអំពីថ្មភក់ប្រកបដោយនិម្មាបនកម្មយ៉ាងប្រសើរ ដោយព្រះបាទ "ឥន្ទ្រាវរ័ន" ដែលទ្រង់បានឲ្យឈ្មោះថាជា " ប្រាសាទថ្មនៃឥសៈ " ៗ

សិលាចារឹកមួយរកឃើញដោយលោក ទ្រូវេ កាលពី គ.ស. ១៩៣៥ មានឆ្លាក់ជាអក្សរយ៉ាងល្អ ៗ ហើយរៀបរាប់អំពីការបួងសួង និងការរំលឹកអំពីកត្តិសព្ទនៃព្រះបាទ " ឥន្ទ្រាវរ័ន " ដែលទ្រង់បានកសាងកាលពី គ.ស. ៨៨១

www.budinst.gov.kh www.elibraryofcambodia.org

នូវរូបសិវលិង្គ "ស្រីឥន្ទ្រាសូរ" ហើយនិងអំពីការកសាងរូបព្រះ នារាយណ៍ ៨ យ៉ាង សមរម្យទៅតាមទ្រង់ទ្រាយនៃប្រាសាទទាំង៨ ដែលនៅជុំវិញផ្នែកខាងក្រោម, នៅខាងលើបាទដ្ឋានមានជណ្ដើរនៅគ្រប់អ័ក្ស ។ ប្រាសាទនេះមានរូបសំណាកជាច្រើនទៀតសាងនៅក្នុងប្រាង្គថ្ម ព្រមទាំងមានគារវៈរូបជាច្រើនទៀត និងរូបសំណាកខ្លះមានភាពទាក់ទងទៅនឹងរូបមនុស្សស្លាប់ មិនតែប៉ុណ្ណោះ មានរៀបរាប់អំពីការកសាងបឹងមួយនៅប្រាសាទលលៃ មានឈ្មោះថា "ឥន្ទ្រតដាកៈ" ។

ល្អ ៗ ព្រមទាំងមានលំអដោយរូបអារក្សអ្នកតា និងជារូបស្រីជាដើម សុទ្ធតែជារូបដែលគេធ្វើសក្ការបូជារាល់ថ្ងៃ ដើម្បីសេចក្តីសុខចំរើនព្រមទាំងមានរូបសង្រ្គាមជាមួយគ្នា ដែលគេតែងគោរពបូជាមួយឆ្នាំម្តងរៀងរាល់ឆ្នាំ គឺសុទ្ធតែជានិទស្សនៈមួយថ្ងៃថា ដែលបង្ហាញឲ្យឃើញនូវភាពស្រឡះហើយនិងមានលំអដោយរូបមនុស្សដាក់ហូរហែតាមជណ្តើរ ប្រៀបបាននឹងជណ្តើរមួយនៅស្ថានសួគ៌ ជាកសិណសាក្សីមួយបង្ហាញនូវក្រឹត្យវិន័យនៅបូព៌ាទិស ។

បាគងជាប្រាសាទមួយមុនគេ សាងអំពីថ្មភក់ប្រកបដោយនិម្មាបនកម្មយ៉ាងប្រសើរ ដោយព្រះបាទ "ឥន្ទ្រាវរ្ម័ន" ដែលទ្រង់បានឲ្យឈ្មោះថាជា " ប្រាសាទថ្មនៃឥសៈ " ។

សិលាចារឹកមួយរកឃើញដោយលោក ទ្រូវេ កាលពី គ.ស. ១៩៣៥ មានឆ្លាក់ជាអក្សរយ៉ាងល្អ ៗ ហើយរៀបរាប់អំពីការបួងសួង និងការរំលឹកអំពីកិត្តិសព្ទនៃព្រះបាទ " ឥន្ទ្រាវរ្ម័ន " ដែលទ្រង់បានកសាងកាលពី គ.ស. ៨៨១

www.budinst.gov.kh www.elibraryofcambodia.org

នូវរូបសិរីលិង្គ "ស្រីឥន្ទ្រាស្វរ" ហើយនិងអំពីការកសាង រូបព្រះ នាគយណ៍ ៨ យ៉ាង សមរម្យទៅតាមទ្រង់ទ្រាយនៃ ប្រាសាទទាំង ៨ ដែលនៅជុំវិញថ្នាក់ខាងក្រោម, នៅខាង លើបានដាំនមានជណ្តើរនៅគ្រប់ទិស ។ ប្រាសាទនេះ មានរូបសំណាកជាច្រើនទៀតសាងនៅក្នុងប្រាង្គថ្ម ព្រមទាំង មានគារវៈរូបជាច្រើនទៀត និងរូបសំណាកខ្លះមានភាពទាក់ទង ទៅនិងរូបមនុស្សស្លាប់ មិនតែប៉ុណ្ណោះ មានរៀបរាប់អំពី ការកសាងបឹងមួយនៅប្រាសាទលលៃ មានឈ្មោះថា "ឥន្ទ្រតដ្គកៈ" ។

53

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបន្ទាយសំរែ

បន្ទាយសំរែ សាងក្នុងសតវត្សទី ១២ ក្រោមឥទ្ធិពលនៃ " វិស្ណុនិយម " ។ គេបានកាប់ឆ្កាព្រៃបញ្ចេញនៅក្នុងឆ្នាំ ១៩៣០ ហើយបានជួសជុលរៀបចំឡើយដោយក្រសួងអភិរក្សអង្គរ ក្នុងឆ្នាំ ១៩៣៦ រហូតមកដល់សព្វថ្ងៃនេះ ។

ការធ្វើដំណើរទស្សនាបន្ទាយសំរែនេះ អាចធ្វើស្របគ្នានឹងការទស្សនាបន្ទាយស្រីតែក្នុងរយៈមួយព្រឹកប៉ុណ្ណោះ ដោយត្រឡប់ពីបន្ទាយស្រី បត់មកខាងត្បូងតាមភូមិប្រដាក ជិតដល់ផ្លូវបត់ខាងស្តាំនៃវង់ធំ យើងត្រូវធ្វើដំណើរអស់ ១៧០០ ម៉ែត្រ តាមទំនប់ខ្ពស់នៃបារាយណ៍ខាងកើត ដែលឆ្ងាយជាង ៥០០ ម៉ែត្រពីផ្លូវទី ១ នាំចូលតាមទ្វារខាងកើតនៃប្រាសាទ ហើយបត់មកខាងស្តាំចម្ងាយ ៣០០ ម៉ែត្រ មានស្លាកបង្ហាញពីផ្លូវខ្វែង យើងតម្រង់ឆ្ពោះទៅដល់មុខទ្វារក្បូលខាងកើតដែរ ។

បើសិនជាយើងធ្វើដំណើរទស្សនាតែម្តងតាមផ្លូវវង់ធំដែលមានផ្លូវដើរប្រកបដោយដីខ្សាច់ ហើយពីបាកធ្វើដំណើរតាម

www.budinst.gov.kh www.elibraryofcambodia.org

រ៉ឺម៉ក ឬ កង់ បាញ់ត្រង់ទៅចំណុចដែលមានចម្ងាយ ១៤ គីឡូម៉ែត្រពីសៀមរាប ហើយនៅចន្លោះប្រែរូបនិងមេបុណ្យខាងកើតរហូតដល់ច្រកចូលមកផ្លូវខាងកើត នៃប្រាសាទដែលមានចម្ងាយ ៥ គីឡូម៉ែត្រ ហើយត្រូវត្រៀមដំណើរចូលមើលក្នុងពេលព្រឹក ។

255



ប្រាសាទបន្ទាយស្រី

មើលចំពីមុខ ខាងកើតនៃខ្លោងទ្វារទី ៣

www.budinst.gov.kh www.elibraryofcambodia.org



18

ប្រាសាទបន្ទាយស្រី

បណ្ណាល័យខាងត្បូង

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបន្ទាយស្រី

បន្ទាយស្រីសាងនៅក្នុងសតវត្សទី ១០ គឺពីឆ្នាំ ៩៦៧ ដោយព្រះគ្រូជាតិព្រះអង្គគឺ ព្រះបាទរាជេន្ទ្រវរ្ម័ន បច្ឆាមរណៈព្រះនាម «សិវលោក» ក្រោយមកព្រះបាទជ័យវរ្ម័នទី ៥ បច្ឆាមរណៈព្រះនាម «បរមវីរលោក» ឧទ្ទិសចំពោះព្រហ្មញ្ញសាសនាថ្វាយដល់ព្រះឥសូរ ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ពី គ.ស. ១៩២៤ រហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទបន្ទាយស្រី ស្ថិតនៅចម្ងាយជាង ២០ គីឡូម៉ែត្រ ពីទិសឦសាននៃប្រាសាទបាយ័ន នៅត្រើយស្តាំស្ទឹងសៀមរាប ដែលហូរចុះពីភ្នំគូលែន ឆ្ពោះទៅបឹងទន្លេសាប ។ ប្រាសាទនេះគ្របដណ្ដប់ដោយដើមព្រឹក្សធំ ៗ យ៉ាងប្រណិតគ្រប់បែប ក្នុងដងព្រៃស្រោងស្រិងគួរឲ្យស្រងេះស្រងោចក្រៃពេក ។ ក្រសួងអភិរក្សអង្គរបានរៀបចំជួសជុលឡើងវិញ ក្នុងឆ្នាំ ១៩៣១ ដល់ឆ្នាំ ១៩៣៦ ដើម្បីឲ្យបានគង់វង្សនៅតាមសភាពដើម នៃប្រាសាទ ។ ឥឡូវ

www.budinst.gov.kh www.elibraryofcambodia.org

នេះផ្លូវចូលទៅកាន់ប្រាសាទ មានប្រវែង ២៤ គីឡូម៉ែត្រ ក្រាលដោយគ្រួសបាយក្រៀម ផ្លូវនេះរថយន្តអាចចេញចូល បានគ្រប់រដូវ ។

លុះចេញពីវង់ធំគម្រង់ទៅទិសខាងជើង ត្រង់ចន្លោះ ប្រាសាទប្រែរូបនិងប្រាសាទមេបុណ្យទិសបូព៌ ដែលមាន ចម្ងាយ ១៥ គីឡូម៉ែត្រពីសៀមរាប តាមផ្លូវចូលឆ្លងកាត់ភូមិ ប្រដាក ដើម្បីនឹងបែកចំទៅប្រាសាទនេះដែលមានចម្ងាយ ៦ គីឡូម៉ែត្រយ៉ាងឆ្ងាយ ហើយផ្លូវនេះត្រូវបែកឆ្ពោះទៅទិស ឦសាន រួចបែកទៅទិសពាយ័ព្យភ្ជាប់ទៅដល់ភ្នំគូលែន ដែល មានចម្ងាយ ៩ គីឡូម៉ែត្រ ។

នៅតាមផ្នែកខ្លះប្រកបដោយសម្រស់យ៉ាងឆើតឆាយ ដែល ហូរចេញពីបន្ទាយស្រីនូវការកត់សំគាល់នៃភាពគង់វង់ និងភាព យ៉ាងត្រចះត្រចង់ខាងបច្ចេកទេស ក្នុងការតុបតែងលំអដោយ ក្បាច់ចម្លាក់យ៉ាងរស់រវើកដូចប្រាសាទអង្គរ ហើយអាចវិនិច្ឆ័យ បានថា សោភណភាពទាំងនេះ ជាសិល្បៈយ៉ាងចំណាននៃ

www.budinst.gov.kh www.elibraryofcambodia.org

# ប្រាសាទបន្ទាយស្រី

បន្ទាយស្រីសាងនៅក្នុងសតវត្សទី ១០ គឺពីឆ្នាំ ៩៦៧ ដោយព្រះរាជាពីរព្រះអង្គគឺ ព្រះបាទរាជេន្ទ្រវរ្ម័ន បច្ចាមរណៈព្រះនាម "សិវលោក" ក្រោយមកព្រះបាទជ័យវរ្ម័នទី ៥ បច្ចាមរណៈព្រះនាម "បរមវីរលោក" ឧទ្ទិសចំពោះព្រហ្មញ្ញសាសនាថ្វាយដល់ព្រះឥសូរ ។ ការថែរក្សាដោយក្រសួងអភិរក្សអង្គរ ពី គ.ស. ១៩២៤ ហូតមកដល់សព្វថ្ងៃនេះ ។

ប្រាសាទបន្ទាយស្រី ស្ថិតនៅចម្ងាយជាង ២០ គីឡូម៉ែត្រ ពីទិសឦសាននៃប្រាសាទបាយ័ន នៅត្រើយស្ទឹងសៀមរាប ដែលហូរចុះពីភ្នំគូលែន ឆ្ពោះទៅបឹងទន្លេសាប ។ ប្រាសាទនេះគ្របដណ្ដប់ដោយដើមព្រឹក្សធំ ៗ យ៉ាងប្រណីតគ្រប់បែប ក្នុងដងព្រៃស្រោងស្រឹងគួរឲ្យស្រណោះស្រណោចក្រៃពេក ។ ក្រសួងអភិរក្សអង្គរបានរៀបចំជួសជុលឡើងវិញ ក្នុងឆ្នាំ ១៩៣១ ដល់ឆ្នាំ ១៩៣៦ ដើម្បីឲ្យបានគង់វង្សមរតកតាមសភាពដើម នៃប្រាសាទ ។ តឡូវ

www.budinst.gov.kh www.elibraryofcambodia.org

នេះផ្លូវចូលទៅកាន់ប្រាសាទ មានប្រវែង ២៤ គីឡូម៉ែត្រ ក្រាលដោយគ្រួសបាយក្រៀម ដូច្នេះរថយន្តអាចចេញចូលបានគ្រប់រដូវ ។

លុះចេញពីវង់ធំតម្រង់ទៅទិសខាងជើង ត្រង់ចន្លោះប្រាសាទប្រែរូបនិងប្រាសាទមេបុណ្យទិសបូព៌ ដែលមានចម្ងាយ ១៥ គីឡូម៉ែត្រពីសៀមរាប តាមផ្លូវចូលខ្ទង់កាត់ភូមិប្រដាក ដើម្បីនឹងបែកចំទៅប្រាសាទនេះដែលមានចម្ងាយ ៦ គីឡូម៉ែត្រយ៉ាងឆ្ងាយ ហើយផ្លូវនេះត្រូវបែកឆ្ពោះទៅទិសឦសាន រួចបែកទៅទិសពាយ័ព្យភ្ជាប់ទៅដល់ភ្នំគូលែន ដែលមានចម្ងាយ ៩ គីឡូម៉ែត្រ ។

នៅតាមផ្លូវខ្លះប្រកបដោយសម្រស់យ៉ាងឆើតឆាយ ដែលហូរចេញពីបន្ទាយស្រីនូវការកត់សំគាល់នៃភាពគង់វង់ និងភាពយ៉ាងត្រចះត្រចង់ខាងបច្ចេកទេស ក្នុងការតុបតែងលំអដោយក្បាច់ចម្លាក់យ៉ាងរស់រវើកជួបប្រាសាទអង្គរ យើងអាចវិនិច្ឆ័យបានថា សោភណភាពទាំងនេះ ជាសិល្បៈយ៉ាងចំណាននៃ

www.budinst.gov.kh www.elibraryofcambodia.org

- ស្នាដៃដ៏ល្អប្លែក ហើយចំនែកក្បាច់មានភាពជ្រៅៗ ខុសប្លែកពីប្រាសាទនានានៅអង្គរ ។ ប្រាសាទបន្ទាយស្រីជាគ្រឿងអលង្ការនៃសិល្បៈខ្មែរ ដែលបានទទួលការស្ងើចសរសើរពីគ្រប់មជ្ឈដ្ឋាន នៃអ្នកចំឡងសិល្បៈ និង ក្បាច់ចម្លាក់លើឈើឬថ្ម ។ គ្រឿងសម្ភារៈដែលយកមកប្រើប្រាស់ក្នុងការកសាងនេះ គឺមានថ្មភក់ពណ៌ផ្កាឈូកដ៏រឹងមាំ ដែលគេពុំដែលឃើញនៅប្រាសាទដទៃ ។ សំណង់ទាំងឡាយមានភាពតូចបង្អៀត តែប្រិននៅគង់វង់ល្អ មានប្រាសាទខ្លះទៀតត្រូវខូចខាតសម្រស់ខាងវិជ្ជានិម្មាបនកម្ម គឺនៅសល់តែដំណែលគ្រឹះតែប៉ុណ្ណោះ ។

វិសាលភាពដ៏តូចនៃបន្ទាយស្រី ធ្វើឲ្យមានការតឿនតួលហើយមិនអាចនឹងពន្យល់បាន ។

សិល្បករខ្មែរក្នុងសម័យនោះ មានការចាប់អារម្មណ៍ទៅលើការតុបតែងលម្អដោយក្បូរក្បាច់របនាដ៏ល្អិតល្អន់ ជាងទៅលើទិដ្ឋភាពធំធេងទូលំទូលាយ ។ សត្វប្លែកក្បាច់ដែលសិល្បករ

www.budinst.gov.kh www.elibraryofcambodia.org

យើងតែងហៅថាក្បាច់អង្គរនោះ គឺច្រើនតែក្បាច់ចម្លងចេញពីប្រាសាទបន្ទាយស្រីនេះឯង ។ ឈ្មោះបន្ទាយស្រីដែលអ្នកស្រុកហៅប្រាសាទនេះ ប្រហែលជាហៅតាមភាពតូចប្រឡូង សោភណភាពល្អិតល្អន់ មិនតុបតែងដោយក្បាច់រចនាវិចិត្រទៀងដូចជាគ្រឿងអលង្ការ ។ បន្ទាយស្រីជាប្រាសាទមួយដោយឡែក ក្នុងចំណោមប្រាសាទនានានៃអង្គរ ហេតុដូច្នេះបានជាអ្នកប្រាជ្ញបានបង្កើត ជារចនាបថមួយហៅថា « រចនាបថបន្ទាយស្រី » ក្នុងសិល្បៈខ្មែរ ។

ចប់

www.budinst.gov.kh www.elibraryofcambodia.org

# សៀវភៅសិក្សាដែលបោះពុម្ពផ្សាយចេញពីបណ្ណាគារ ភ្នំពេញ លេខ ១៥៩ វិថីប៉ាស្ទ័រភ្នំពេញ មានដូចតទៅនេះ៖

១ វចនានុក្រមបារាំង-ខ្មែរ និពន្ធដោយ ឌិច យក់, ជាវ គង់ តម្លៃ ៤០០រ

២ វចនានុក្រមបារាំង-ខ្មែរសង្ខេប និពន្ធដោយ ឌិច យក់, ជាវ គង់, លីវគុង ៣០០រ

៣ សព្ទានុក្រមបារាំង-ខ្មែរ ព្រះឃោសធម្ម ប.ស. ធម្មាភម . ២០០រ

៤ អនុវចនានុក្រមបារាំង-ខ្មែរ ឃិន ឌៃ . . . . ១៥០រ

៥ អនុវចនានុក្រមបារាំង-ខ្មែរ តូច ឃិន ឌៃ . . . ១០០រ

៦ កូនអនុវចនានុក្រមបារាំង-ខ្មែរ ស៊ឹម-ហុង . . . ៥០រ

៧ វចនានុក្រមខ្មែរសង្ខេប ប្រជុំសាស្ត្រាចារ្យ . . . ១២០រ

៨ អនុវចនានុក្រមខ្មែរ គួ ជាន . . . . . ៥០រ

៩ វចនានុក្រម អង់គ្លេស-ខ្មែរ ឆាយ ហុក ហ៊ី . . . ៧៥រ

១០ យើងរៀនអានថ្នាក់ទី ១២ ល្បាក ឡុង មៅ, ហួរ ហេង . ១៥រ

១១ យើងអានថ្នាក់ទី ១១ ហួរ ហេង . . . . . ២៥រ

១២ យើងអានថ្នាក់ទី ១០ . . . . . . . ២៦រ

១៣ យើងអានថ្នាក់ទី ៩ . . . . . . . ៣០រ

១៤ យើងអានថ្នាក់ទី ៧ . . . . . . . ៣០រ

១៥ កុមារដ្ឋាន ស-បិត្ត . . . . . . . ១៥រ

១៦ វិជ្ជាខេមរៈភាសា កុមារដ្ឋាន . . . . . ១៥រ

១៧ — បរិពណ្ណដ្ឋាន . . . . . ១៥រ

១៨ — អាទិកដ្ឋាន . . . . . ១៥រ

www.budinst.gov.kh www.elibraryofcambodia.org

១៩ វិទ្យាសាស្ត្រអនុវត្តថ្នាក់ទី ៨ - ៧ . . . . . ៣៥រ

២០ — ៤ . . . . . . . ១៨រ

២១ សុភាវធម៌ ឈួក ប៊ុង មៅ . . . . . ៣០រ

២២ សគ្គមវិជ្ជា . . . . . . . ៣៥រ

២៣ ផ្កាស្រពោន . . . . . . . . ២៣រ

២៤ កុលាបប៉ៃលិន . . . . . . . . ២០រ

២៥ រៀនភាសាបារាំងដោយខ្លួនឯង . . . . . ៤០រ

២៦ កិត្តិយស ឬ ស្នេហា (Le cid) . . . . . . ២៣រ

២៧ លិខិតពីរោងត្បាល់បក់ខ្ញុំ (លុក ផៃ) . . . . ២០រ

២៨ គ្រូពេទ្យភិសតាល្អ (បាន់ ឌុំ ផារី) . . . . . ២០រ

២៩ អ្នកមានឃ្លានយស (ហ៊ី ស៊ី សាផន) . . . . ៣៥រ

៣០ ក្បួននព្វត្ត ឈឹម សុខ . . . . . . ៧៥រ

៣១ អនុពាក្យថ្មី ឧត្តមញ្ញាន . . . . . . ២៥រ

៣២ សរសេរតាមសូត្រ លី ធាម តេង . . . . ១៨រ

៣៣ ប្រមូលសរសេរតាមសូត្រ ឧត្តមញ្ញាន . . . . ១៧រ

៣៤ សរសេរតាមសូត្រឧត្ដម ជិន ពៅ . . . . . ២០រ

៣៥ តែងសេចក្ដីឧត្ដម សែម សួរ . . . . . ២២រ

៣៦ មូលដ្ឋានអក្សរសាស្ត្រ ហ៊ុន គីម សៀ . . . . ២០រ

៣៧ តែងសេចក្ដី អ៊ុង ហុង សាត . . . . . ២០រ

៣៨ វិជ្ជាគិតគូរខ្មែរបំរុះ សែម សួរ . . . . . ៣៥រ

៣៩ តែសេចក្ដីខ្មែរបំរុះ សែម សួរ . . . . . ៣៥រ

៤០ សិក្សារឿងកាកី សែម សួរ . . . . . ២៥រ


www.budinst.gov.kh www.elibraryofcambodia.org

264




៤១ សិក្សាកថារឿងទុំទាវ អ៊ុក សាម៉ិន . . . . . ៣៨រ

៤២ បរមាធិប្បាយពិសេស ថ្នាក់ទី ១ សែម សូរ . . . . ៤០រ

៤៣ សិក្សាមហាវេស្សន្តរជាតក សែម សូរ . . . . ៤០រ

៤៤ អធិប្បាយសុភាសិតស្រីហិតោបទេស សែម សូរ . . . ៣០រ

៤៥ វិញ្ញាសាមធ្យមសិក្សាប័ត្រ សែម សូរ . . . . ៤០រ

៤៦ ប្រជុំវិញ្ញាសាពិសេស ថ្នាក់ទី ៦ សែម សូរ . . . ៤០រ

៤៧ វិញ្ញាសាពួកយើង ថ្នាក់ទី ៦ សេង ឆយ . . . . ៤០រ

៤៨ ភាសិតសំរាយ តៅ ហ៊ុង . . . . . . ២៥រ

៤៩ រឿងចៅស្រទបចេក . . . . . . . ៣៥រ

៥០ ចរណមាតា . . . . . . . . ៣៥រ

៥១ ស័ង្ខសិល្បជ័យ . . . . . . . . ៣៥រ

៥២ លិខិតឆ្លើយឆ្លងបារាំង, អង់គ្លេស, ខ្មែរ . . . . ១០រ

៥៣ រឿងធនញ្ជ័យ . . . . . . . . ១២រ

៥៤ តស់កេងកង . . . . . . . . ៥រ

៥៥ សុបិនកុមារ . . . . . . . . ៧រ

៥៦ មាយាស្រី . . . . . . . . ៥ះ

៥៧ មាយើង . . . . . . . . ៥រ

៥៨ ច្បាប់ប្រុស . . . . . . . . ៥រ

៥៩ ច្បាប់ស្រី . . . . . . . . ៥រ

៦០ ច្បាប់ប្រុស - ស្រី . . . . . . . ៧រ

៦១ រឿងរួមថ្នាក់ទី ៦ . . . . . . . ១៧រ

៦២ ច្បាប់រួមថ្នាក់ទី ៥ . . . . . . . ១០រ


www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

264




៤១ សិក្សាកថារឿងទុំទាវ អ៊ុក សាមិន . . . . . ៣៨រ

៤២ បរមាធិប្បាយពិសេស ថ្នាក់ទី ១ សែម សួរ . . . . ៤០រ

៤៣ សិក្សាមហាវេស្សន្តរជាតក សែម សួរ . . . . . ៤០រ

៤៤ អធិប្បាយសុភាសិតស្រីហិតោបទេស សែម សួរ . . . ៣០រ

៤៥ វិញ្ញាសាមធ្យមសិក្សាប័ត្រ សែម សួរ . . . . . ៤០រ

៤៦ ប្រជុំវិញ្ញាសាពិសេស ថ្នាក់ទី ៦ សែម សួរ . . . . ៤០រ

៤៧ វិញ្ញាសាពួកយើង ថ្នាក់ទី ៦ សេង ផយ . . . . ៤០រ

៤៨ ភាសិតសំរាយ តៅ ហ៊ុង . . . . . . . ២៥រ

៤៩ រឿងចៅស្រទបចេក . . . . . . . . ៣៥រ

៥០ ឧរណមាតា . . . . . . . . . ៣៥រ

៥១ ស័ង្ខសិល្បជ័យ . . . . . . . . . ៣៥រ

៥២ លិខិតឆ្លើយឆ្លងបារាំង, អង់គ្លេស, ខ្មែរ . . . . . ១០រ

៥៣ រឿងធនញ្ជ័យ . . . . . . . . . ១២រ

៥៤ តស់កេងកង . . . . . . . . . ៥រ

៥៥ សុបិនកុមារ . . . . . . . . . ៧រ

៥៦ មាយាស្រី . . . . . . . . . ៥រ

៥៧ មាយើង . . . . . . . . . ៥រ

៥៨ ច្បាប់ប្រុស . . . . . . . . . ៥រ

៥៩ ច្បាប់ស្រី . . . . . . . . . ៥រ

៦០ ច្បាប់ប្រុស - ស្រី . . . . . . . ៧រ

៦១ រឿងរូបថ្នាក់ទី ៦ . . . . . . . ១៧រ

៦២ ច្បាប់រូបថ្នាក់ទី ៥ . . . . . . . ១០រ


www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org